ព្រះ
ត្រៃបិដកបាលី
និង
សេចក្តីប្រៀបភាសាខ្មែរ
១ឆយបិដក
មហាវគ្គ ចតុត្ថភាគ
៤

បាចិត្តិយកណ្ឌ បាដិទេសនីយកណ្ឌ

សេខិយកណ្ឌ និង អធិករណសមថកណ្ឌ

ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុកន្ធាមហាសង្ឆរាជាធិបតី ហ្ស ត្រ៊ី

សម្តេចព្រះមហាសង្ឆរាជនៃគណៈធម្មយុត្តិកនិកាយ

នៃព្រះរាជាណាចក្រកម្ពុជា

ព. ស. ២៥៥៣

Vinayapiṭaka

Mahāvibhaṅga Catutthabhāga

4

Pācittiyakaṇḍa Pāṭidesanīyakaṇḍa

Sekhiyakaṇḍa

&

Adhikaraṇasamathakaṇḍa

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឆរាជាធិបតី ហ ស ម្រ៉ី
សម្តេចព្រះមហាសង្ឆរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំក្រោយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឆបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យាកាពតរៀងទៅ ។

វត្តបឋុមធ. ថ្ងៃ៨ ០៨ ខែមិថុនា ឆ្នាំ ២០០៩

ហ ស ម្រ៉ី

Printed and donated for free distribution by
The Corporate Body of the Buddha Educational Foundation
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
This book is strictly for free distribution, it is not for sale.
សំរាប់ចាកចូនទានតែប៉ុណ្ណោះ

សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឆរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្ធឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

វិនយបិដក មហាវិភង្គ

ចតុត្ថភាគ

៤

ចាចិត្តិយកណ្ឌ ចាជិនេសនីយកណ្ឌ

សេខិយកណ្ឌ និង អធិការណសមថកណ្ឌ

ឆដ្ឋសិក្ខាបទំ

[១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ រាសេយ្យាយោ
បលិពុទ្ធន្តិ ថេរេ ភិក្ខូ ឧដ្ឋាបេន្តិ ។ អថខោ ឆព្ភក្ខិ-
យានំ ភិក្ខូនំ ឯតទហោសិ គោន ឧ ខោ មយំ
ឧចាយេន ឥធេវ រស្មុ រាសេយ្យាមាតិ ។ អថខោ
ឆព្ភក្ខិយា ភិក្ខូ ថេរេ ភិក្ខូ អនុប្បទ្ធ សេយ្យំ
ការ្ប្ពន្តិ យស្ស សម្ពាធោ ភវិស្ស្ពតិ សោ បក្ក-
មិស្ស្ពតីតិ ។ យេ តេ ភិក្ខូ អប្ប្ជិច្ឆា ។ ២ ។ តេ
ឧជ្ឈាយន្តិ ១ីយន្តិ ១ិចាចេន្តិ ១ាកំ ១ិ ១ាម ១ព្ភ-
ក្ខិយា ភិក្ខូ ថេរេ ភិក្ខូ អនុប្ប្ទ្ធ សេយ្យំ ១ាកប្ប្ស្ស-
ន្តីតិ ។ អថខោ តេ ភិក្ខូ ១ាតវ្ពោ ឯតមត្ថំ
អារ្ពេ្ចសុ ។ ២ ។ សច្ចំ ១ិ ១ ១ ១

សិក្ខាបទទី ៦

[១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ បៀតបៀនយកទីដេកល្អ ។ ញុំងភិក្ខុចាស់ទាំងឡាយ ឲ្យក្រោកចេញទៅ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា យើងទាំងឡាយនៅចាំវស្សាក្នុងទីនេះ ដោយឧបាយដូចម្តេចហ្ន៎ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅដេកជ្រៀតបៀតភិក្ខុចាស់ទាំងឡាយ ដោយគិតថា ភិក្ខុណាមានសេចក្តីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបីនឹងចូលទៅដេកជ្រៀតបៀតពួកភិក្ខុចាស់សោះ ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកវាល់គ្នាចូលទៅដេកជ្រៀតបៀតភិក្ខុចាស់ទាំងឡាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចូលទៅដេក

មោឃបុរិសា ថេរេ ភិក្ខូ អនុប្បទ្ធ សេយ្យំ ការ្ប-
ស្ស្ថ ឌេតំ មោឃបុរិសា អប្ប្ស្ស្ថ ១ ១ ១

ជ្រៀតជ្រៀតពួកភិក្ខុចាស់សោះឡើយ នៃមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងហើយ ចូលទៅជ្រៀតជ្រៀតនូវភិក្ខុដែលចូលទៅនៅមុនហើយសំរេចនូវទីដេក ក្នុងវិហាររបស់សង្ឆ ដោយគិតថា ភិក្ខុណាមានសេចក្តីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវសេចក្តីជ្រៀតជ្រៀតនោះឯង ឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ ។

[២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ វិហារដែលគេលះប្រគេនដល់សង្ឆ ហៅថា វិហាររបស់សង្ឆ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងថា ភិក្ខុនេះចាស់ ដឹងថា ភិក្ខុនេះឈឺ ដឹងថា វិហារនេះសង្ឆបានឲ្យហើយ ។ ពាក្យថា ចូលទៅជ្រៀតជ្រៀតគឺចូលទៅជ្រៀតជ្រែក ។ ពាក្យថា សម្រេចនូវទីដេក សេចក្តីថា ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តីនូវទីដេកក្នុងឧបចារ[1] នៃគ្រែក្តី នៃតាំងក្តី នៃភិក្ខុចូលទៅក្តី ចេញមកក្តី ត្រូវអាបត្តិទុក្កដ ភិក្ខុអង្គុយសង្កត់ក្តី

---

១ ឧបចារ:គ្រែនិងតាំង តាមអដ្ឋកថា ថាកំណត់ពីរហត្ថមួយចំអាម ។

ចាចិត្តិយស្ស ។ ឯតេវ បចូយំ ការិត្វា អនញ្ញត្តិ ន អញ្ញោ ការោ ចិ បចូយោ ហោតិ អនុប្ប១ជ្ជ សេយ្យ៑ ការ១ត្ថ ។

[៣] សជ្ជ៑ិ១ ១ សជ្ជ៑ិ១ សញ្ញ៑ អនុប្ប១ជ្ជ សេយ្យ៑ ១ ១ ១ អាបត្តិ ១ ១ ១

ដេកសង្កត់ក្តី (លើទីដេកនោះ) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើនូវសេចក្តីជ្រៀតជ្រៀតនេះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ សេចក្តីថា គ្មានហេតុដទៃនីមួយដែលក្រៅពីការចូលទៅដេកជ្រៀតជ្រៀតនោះឡើយ ។

[៣] វិហាររបស់សង្ឆ ភិក្ខុសំគាល់ថា វិហាររបស់សង្ឆមែន ហើយចូលទៅដេកជ្រៀតជ្រៀត ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឆ ភិក្ខុមានសេចក្តីសង្ស័យ ហើយចូលទៅដេកជ្រៀតជ្រៀត ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឆ ភិក្ខុសំគាល់ថា របស់បុគ្គលវិញ ហើយចូលទៅដេកជ្រៀតជ្រៀត ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក រៀរលែងតែឧបចារនៃគ្រែក្តី នៃតាំងក្តី នៃភិក្ខុចូលទៅក្តី ចេញមកក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអង្គុយសង្កត់ក្តី ដេកសង្កត់ក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក ក្នុងឧបចារនៃវិហារក្តី ក្នុងឧបដ្ឋានសាលាក្តី[១] ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងទីវាលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអង្គុយសង្កត់ក្តី ដេកសង្កត់ក្តី ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថា របស់សង្ឆ

---

១ ប្រែថា សាលាសម្រាប់បម្រើ តែអដ្ឋកថា ថាបានដល់សាលាសំរាប់ឆាន់ ឬរោងឆាន់ ។

អាបត្តិ ទុក្ការ ។ បុគ្គលិកេ ឯមតិកោ អាបត្តិ ទុក្ការ ។ បុគ្គលិកេ បុគ្គលិកសញ្ញី អញ្ញស្ស បុគ្គលិកេ អាបត្តិ ទុក្ការ ។ អត្តនោ បុគ្គលិកេ អនាបត្តិ ។

[៤] អនាបត្តិ តិណានោ ឋបេតិ ។ ១ ១ ១

ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថា របស់បុគ្គលដទៃ ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គល គឺវិហារ នៃភិក្ខុដទៃ ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារ ជារបស់បុគ្គល គឺវិហារ របស់ខ្លួនឯង ។

[៤] អាបត្តិមិនមាន ដល់ភិក្ខុដែលមានជំងឺចូលទៅក្តី ដល់ភិក្ខុដែលត្រូវត្រជាក់ ឬក្តៅបៀតបៀនហើយចូលទៅក្តី ដល់ភិក្ខុមានសេចក្តីអន្តរាយក្តី ដល់ភិក្ខុឆ្កួតក្តី ដល់ភិក្ខុដើមបញ្ញត្តិក្តី ។

សិក្ខាបទទី ៦ ចប់ ។

សត្តមសិក្ខាបទំ

[៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិ-
យំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ
អញ្ញតរំ បច្ចន្តិមំ មហាវិហារំ បដិសង្ខរោន្តិ ឥធ
មយំ វស្សំ វស្សិស្សាមាតិ ។ អទ្ធសំសុ ខោ
ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយេ ភិក្ខូ វិហារំ ប-
ដិសង្ខរោន្តេ ឌិស្វាន ឯវមាហំសុ ឥមេ អាវុសោ
សត្តរសវគ្គិយា ភិក្ខូ វិហារំ បដិសង្ខរោន្តិ ហន្ទ-
នេ[1] រុជ្ជាបេស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ អា-
គមេថាវុសោ យាវ បដិសង្ខរោន្តិ បដិសង្ខតេ រុជ្ជា-
បេស្សាមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ សត្ត-
រសវគ្គិយេ ភិក្ខូ ឯតទវោចុំ ឧជ្ជេថាវុសោ អម្ហាកំ
វិហារោ ចាបុណាតីតិ ។ ជនុ អាវុសោ បដិកច្ចេ

---

១ តេតិបិ ១ ។

សិក្ខាបទទី ៧

[៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេត-
វន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកសត្ត-
រសវគ្គិយភិក្ខុ (ភិក្ខុមានពួក ១៧ រូប) នាំគ្នាជួសជុលវិហារធំ ១ មាននៅ
ក្នុងបច្ចន្តប្រទេសដោយគិតគ្នាថា យើងទាំងឡាយនឹងនៅចាំវស្សាក្នុងទី
នេះ ។ ពួកឆព្វគ្គិយភិក្ខុ (ភិក្ខុមានពួក ៦ រូប) បានឃើញពួកសត្តរស-
វគ្គិយភិក្ខុនាំគ្នាជួសជុលវិហារ លុះឃើញហើយបាននិយាយគ្នាយ៉ាងនេះថា
ម្នាលអាវុសោ ពួកសត្តរសវគ្គិយភិក្ខុនេះនាំគ្នាជួសជុលវិហារ បើដូច្នោះ
យើងទាំងឡាយនឹងធ្វើឲ្យភិក្ខុទាំងនោះចៀសចេញទៅ ។ ឆព្វគ្គិយភិក្ខុពួក
ខ្លះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ សូមលោកទាំងឡាយបង្ហ្គង់ចាំ
ឲ្យសត្តរសវគ្គិយភិក្ខុទាំងឡាយជួសជុលវិហាររួចសិន លុះជួសជុលស្រេច
ហើយ យើងទាំងឡាយនឹងធ្វើភិក្ខុទាំងនោះឲ្យចៀសចេញទៅ ។ គ្រានោះ
ពួកឆព្វគ្គិយភិក្ខុបាននិយាយពាក្យនេះនឹងពួកសត្តរសវគ្គិយភិក្ខុថា ម្នាល
អាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើង
ទេ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ ហេតុដូចម្តេច

អាចិក្ខិតព្ពំ មយញ្ហ អញ្ញ្ហ បដិសន្ធ្ហយ្យាមាតិ ។ ឧនុ អាវុសោ សជ្ជ្ហិកោ ១ៃហ្ការ ១ៃ ។ អាមាវុសោ សជ្ជ្ហិកោ ១ៃហ្ការ ១ៃ ។ ១ដ្ឋ១ាវុសោ អ១ាកំ ១ៃហ្ការ ១ៃ ១ាបុណ្ណ១ីតិ ។ ១ហាលូ១ោ អាវុសោ ១ៃហ្ការ ១ៃ ១ុ១ៃ្ហ១ិ ១ៃ១ ១ យ១ំ១ិ ១ៃ១ិ១ៃ្ហ១ាតិ ។ ១ដ្ឋ១ាវុសោ អ១ាកំ ១ៃហ្ការ ១ៃ ១ាបុណ្ណ១ីតិ ១ុ១ិ១ា អ១ត្ត១ា ១ីវ១ំ ១ហ១ា ១ិ១ៃ្ហ១ៃ្ហ ។ ១ៃ ១ិ១ៃ្ហ១ៃ្ហ១ិ១ា ១ៃ១ ។ ១ិ១ៃ្ហ ១ៃ១ា១ាំ១ុ ១ិ១ៃ្ហ ១ុ១ៃ្ហ អាវុសោ ១ៃ១ ១ាតិ ។ ១ម អាវុសោ ១ព្ធ១ិ១ា ១ិ១ៃ្ហ ១ុ១ិ១ា អ១ត្ត១ា អ១ៃ្ហ ១ជ្ជ្ហិ១ា ១ៃ១ ១ិ១ៃ្ហ១ៃ្ហ១ីតិ ។ ១ យ ១ ១ ១

ក៏ពួកលោកមិនប្រាប់យើងជាមុនសិន យើងទាំងឡាយនឹងបានជួសជុលវិហារឯទៀតវិញ ។ ពួកធម្មគ្គិយភិក្ខុសួរថា ម្នាលអាវុសោ ក្រែងវិហារនោះជារបស់សង្ឆទេដឹង ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយតបថា អើអាវុសោ វិហារជារបស់សង្ឆ ។ ពួកធម្មគ្គិយភិក្ខុផ្ញើយថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារជាវិហារធំ ពួកលោកក៏នៅបាន ពួកយើងក៏នៅបាន ។ ពួកធម្មគ្គិយ-ភិក្ខុនិយាយដដែលទៀតថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ហើយមានចិត្តកម្រើកខឹងឡើងនាំគ្នាចាប់ককន្ត្រាក់ទាញចេញទៅ ។ ពួកសត្តរសវគ្គិយភិក្ខុនោះ កាលត្រូវពួកធម្មគ្គិយភិក្ខុ ককន្ត្រាក់ককទាញចេញ ក៏នាំគ្នាយំ ។ ទើបភិក្ខុទាំងឡាយ (ភិក្ខុដទៃចាកភិក្ខុពីរពួកនោះ) បាននាំគ្នាសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វី បានជាពួកលោកយំ ។ ពួកសត្តរស-វគ្គិយភិក្ខុនិយាយតបថា ម្នាលអាវុសោ ធម្មគ្គិយភិក្ខុទាំងនេះ មានចិត្តកម្រើកខឹងនាំគ្នាបណ្តេញពួកយើងចេញចាកវិហាររបស់សង្ឆ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកធម្មគ្គិយភិក្ខុមិនសមបី

ឆព្វគ្គិយា ភិក្ខូ ឝុបិតា អនត្តមនា ភិក្ខូ សង្ឆ្យិ-
ឝា វិហារ និក្ខ្ឌ្ឍិស្សន្តីតិ ។ អថខោ តេ ភិក្ខូ
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា
ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ ឝិរ តុម្ហេ ភិក្ខវេ
ឝុបិតា អនត្តមនា ភិក្ខូ សង្ឆ្យិឝា វិហារ និក្ខ-
ឌ្ឍថាតិ ។ សច្ចំ ភគវាតិ ។ វិតរហិ ពុទ្ធោ
ភគវា ឝមំ ហិ ឝាម តុម្ហេ មោឃបុរិសា
ឝុបិតា អនត្តមនា ភិក្ខូ សង្ឆ្យិឝា វិហារ
និក្ខ្ឌ្ឍិស្សថ នេតំ មោឃបុរិសា អប្ឋសន្ថ្ឌ
ឝ បសាឝាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ
សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ឝុបិតោ
អនត្តមោ សង្ឆ្យិឝា វិហារ និក្ខ្ឌ្ឍេយ្យ ឝ និក្ខ-
ឌ្ឍាបេយ្យ ឝ ឝាចិត្តិយន្តិ ។

នឹងមានចិត្តក្រោធខឹងទង់ទាញ ភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឆ សោះ ។ ទើបភិក្ខុទាំងនោះ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មាន ព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់សួរពួកឆព្វគ្គិយ-ភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយមានចិត្តក្រោធ ខឹងទង់ទាញភិក្ខុទាំងឡាយចេញចាកវិហារជារបស់សង្ឆ មែនឬទេ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំង ឡាយ អ្នកទាំងឡាយមិនសមបីនឹងមានចិត្តក្រោធខឹងទង់ទាញភិក្ខុទាំង ឡាយចេញចាកវិហាររបស់សង្ឆសោះ ម្នាលមោឃបុរសទាំងឡាយ អំពើ ដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់បុគ្គលទាំងឡាយដែល មិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមានចិត្តក្រោធខឹង នឹងភិក្ខុផងគ្នា ហើយទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ចេញចាក វិហាររបស់សង្ឆ ត្រូវអាបត្តិបាចិត្តិយ ។

[៦] យោ បនាតិ យោ យាវិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញ ភិក្ខុំ ។ កុបិតោ អនត្តមនោតិ អនភិរញ្ជោ អាហតចិត្តោ ខិលជាតោ ។

[៧] សជ្ជិកោ នាម វិហារេ សជ្ជ្សស្ស ឌិណ្ណោ ហោតិ បរិចូតោ ។ ឌិក្ខ្ណេ្ឌយ្យាតិ ឥមេ ឥហេ ត្វា បមុ១ ឌិក្ខ្ណ្ឌតិ អាបត្តិ ចាចិត្តិយស្ស ។ បមុ១ ឥហេ ត្វា ពហិ ឌិក្ខ្ណ្ឌតិ អាបត្តិ ចាចិត្តិយស្ស ។ ឯកេ១ បយោ១ ពហុ១ ឥមេ ត្ថ ត្ថ ត្ថ

[៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខា-បទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា នឹងភិក្ខុ គឺនឹងភិក្ខុដទៃ ។ ពាក្យថា មានចិត្តក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តដែលទោសកំចាត់បង់ មានចិត្តរឹងរូស ។

[៧] វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឆ ឈ្មោះថា វិហាររបស់សង្ឆ ។ ពាក្យថា ទង់ទាញឯង គឺភិក្ខុចាប់យកពីក្នុងបន្ទប់ ហើយទង់ទាញទៅឯរបៀងវិហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុចាប់យកពីក្នុងរបៀងហើយ ទង់ទាញទៅខាងក្រៅ ក៏ត្រូវអាបត្តិបាចិត្តិយ ។ ទុកជាភិក្ខុទង់ទាញភិក្ខុឲ្យកន្ធងទ្វារទាំងឡាយជាច្រើន តែដោយប្រ-យោគមួយ ក៏ត្រូវអាបត្តិបាចិត្តិយ តែមួយ ។ ពាក្យថា ប្រើគេឲ្យទង់ទាញនោះ គឺបង្គាប់អ្នកដទៃ (ភិក្ខុអ្នកបង្គាប់នោះ) ក៏ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែវារៈម្តង អ្នកទទួលបង្គាប់ទៅទង់ទាញភិក្ខុដទៃឲ្យកន្ធងទ្វារសូម្បីច្រើន ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ ។

[៨] វិហាររបស់សង្ឆ ភិក្ខុសំគាល់ថា ជារបស់សង្ឆដដែល ហើយមានចិត្តក្រោធខឹងទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឆ ភិក្ខុមានសេចក្តីសង្ស័យ ហើយមានចិត្តក្រោធខឹងទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។

សជ្ជិកោ បុក្ខលិកសញ្ញី ឥមិនា អនត្តមនោ ជិក្ខ្ឌតិ វ ជិក្ខ្ឌាបេតិ វ អាបត្តិ ចាចិត្តិយស្ស ។ ឥស្ស បរិក្ខារំ ជិក្ខ្ឌតិ វ ជិក្ខ្ឌាបេតិ វ អាបត្តិ ទុក្ខ្ឌស្ស ។ វិហារស្ស ឧបចារ វ ឧបដ្ឋានសាលាយ វ មណ្ឌ្ឌ វ រុក្ខ្ខមូលា វ អជ្ឌ្ឌោកាសា វ ជិក្ខ្ឌតិ វ ជិក្ខ្ឌាបេតិ វ អាបត្តិ ទុក្ខ្ឌស្ស ។ ឥស្ស បរិក្ខារំ ជិក្ខ្ឌតិ វ ជិក្ខ្ឌាបេតិ វ អាបត្តិ ទុក្ខ្ឌស្ស ។ អនុបសម្ជ្ជ្ជ

វិហាររបស់សង្ឆ កិក្ខុសំគាល់ថា ជារបស់បុគ្គលទៅវិញ ហើយមានចិត្ត ក្រោធខឹងទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវបរិក្ខាររបស់កិក្ខុនោះ ត្រូវ អាបត្តិទុក្កដ ។ កិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវកិក្ខុឲ្យចាក ឧបចារនៃវិហារក្តី ចាកឧបដ្ឋានសាលាក្តី ចាកមណ្ឌបក្តី ចាកម្ទប់ឈើក្តី ចាកទីវាលក្តី ត្រូវអាបត្តិទុក្កដ ។ កិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវបរិក្ខារនៃកិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ កិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យ ទង់ទាញក្តី នូវអនុបសម្បន្នឲ្យចាកវិហារក្តី ចាកឧបចារនៃវិហារក្តី ចាក ឧបដ្ឋានសាលាក្តី ចាកមណ្ឌបក្តី ចាកម្ទប់ឈើក្តី ចាកទីវាលក្តី ត្រូវអា-បត្តិទុក្កដ ។ កិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវបរិក្ខាររបស់ អនុបសម្បន្ននោះ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល កិក្ខុសំគាល់ថា ជា របស់សង្ឆ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល កិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល កិក្ខុសំគាល់ថា ជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ ព្រោះវិហារជារបស់បុគ្គលនៃកិក្ខុដទៃ គឺវិហាររបស់គេ កិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់បុគ្គលនៃខ្លួន គឺវិហាររបស់ខ្លួនឯង ។

[៩] អជាបត្តិ អលជ្ជី ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា តស្ស បរិក្ខារំ ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា ឧម្មត្តកំ ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា តស្ស បរិក្ខារំ ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា ភណ្ឌនការកំ វា កលហការកំ វា វិវាទការកំ វា ភស្សការកំ វា សង្ឆេ អធិការណការកំ វា ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍ-បេតិ វា តស្ស បរិក្ខារំ ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា អន្តេវាសិកំ វា សទ្ធិវិហារិកំ វា ន សម្មាវត្តន្តំ ជិញ្ចឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា តស្ស បរិក្ខារំ ជិញ្ច-ឆ្ឍតិ វា ជិញ្ចឆ្ឍាបេតិ វា ឧម្មត្តកស្ស អាធិកម្មិ-កស្សាតិ ។

[៥] អាបត្តិមិនមាន ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុអលជ្ជី ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុអលជ្ជីនោះ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុឆ្គត ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញ នូវបរិក្ខាររបស់ភិក្ខុឆ្គតនោះ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុជាអ្នកធ្វើនូវសេចក្តីបង្ករហេតុក្តី អ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ក្តី អ្នកធ្វើនូវសេចក្តីទាស់ទែងក្តី អ្នកធ្វើនូវពាក្យឡេះឡោះតាមតែរួចពីមាត់ក្តី[១] អ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆក្តី ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុនោះចេញ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវអន្តេវាសិក ឬសទ្ធិវិហារិក ដែលប្រព្រឹត្តមិនត្រឹមត្រូវ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់អន្តេវាសិក ឬសទ្ធិវិហារិកដែលប្រព្រឹត្តមិនត្រឹមត្រូវនោះ ដល់ភិក្ខុឆ្គត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

---

១ ពោលពាក្យជាតិរច្ឆានកថា ឬនិយាយសរសើរពីស្ត្រីនិងប្រុសជាដើម ។ ន័យអដ្ឋកថា ។

អដ្ឋមសិក្ខាបទំ

[១០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ទ្វេ ភិក្ខូ សជ្ជៃកេ វិហារេ
ឧបរិវេហាសកុដិយា ឯកោ ហេដ្ឋា វិហរតិ ឯកោ
ឧបរិ ។ ឧបរិមោ ភិក្ខុ អាហច្ចចាឧកំ មញ្ញំ សហសា
អភិនិសីទិ ។ មញ្ចចាឧោ បតិត្វា ហេដ្ឋិមស្ស ភិក្ខុនោ
មត្ថកេ អវត្ថាសិ ។ សោ ភិក្ខុ វិស្សរមការិ ។
ភិក្ខូ ឧបជាវិត្វា តំ ភិក្ខុំ ឯតទវោចុំ កិស្ស ត្វំ
អាវុសោ វិស្សរមការីតិ ។ អថខោ សោ ភិក្ខុ
ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ
អប្ឌិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ
 កថំ ហិ នាម ភិក្ខុ សជ្ជៃកេ វិហារេ ឧបរិវេហា-
សកុដិយា អាហច្ចចាឧកំ មញ្ញំ សហសា អភិនិ-
សីទិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ អថខោ ភគវា តំ ភិក្ខុំ បដិបុច្ឆិ

សិក្ខាបទទី ៨

[១០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុ ២ រូប ១ រូបនៅថ្នាក់ខាងក្រោម ១ រូបនៅថ្នាក់ខាងលើ ក្នុងវិហាររបស់សង្ឆ ។ ភិក្ខុដែលនៅខាងលើអង្គុយចុះ ដោយរហ័សសង្កត់ត្រែដែលមានជើងគ្រាន់ តែស៊ីកទុក (ដោយបណ្ណាះអាសន្ន) ។ ជើងត្រែ (នោះ) ក៏របូតធ្លាក់ចុះ មកទង្គិចក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុនោះបានស្រែកសំឡេង ឮប្ញែក ។ ភិក្ខុទាំងឡាយបានសួរទៅសួរភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វី ក៏លោកស្រែក ។ ភិក្ខុនោះ បានប្រាប់សេចក្តីនោះ ដល់ភិក្ខុទាំង ឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុមិនសម បីនឹងមកអង្គុយចុះ ដោយរហ័សសង្កត់ត្រែដែលមានជើងគ្រាន់ស៊ីកទុក (ដោយបណ្ណាះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឆសោះ ។ ទើប ភិក្ខុទាំងឡាយនោះនាំគ្នាក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ឮថាអ្នកឯង

សចេ្ចំ ការ ត្ងំ ភិក្ខុ សជ្ជិកេ វិហារេ ឧបរិវេហា-
សកុដិយា អាហចេ្ចចាឧកំ មញ្ចំ សហសា អកិនិ-
សីឧសីតិ ។ សចេ្ចំ ភគវាតិ ។ វិតរហិ ពុទ្ធោ ភគវា
ភេចំ ហិ ជាម ត្ងំ មោឃបុរិស សជ្ជិកេ វិហារេ
ឧបរិវេហាសកុដិយា អាហចេ្ចចាឧកំ មញ្ចំ សហសា
អកិនិសីឧិស្ស្ស សិ ឧេតំ មោឃបុរិស អប្ប្ស្ឧ្ធានំ ភ
បសាឧាយ ។ បេ ។ ឯវញ្ច បន ភិក្ខូវ ឥមំ សិក្ខាបទំ
ឧទ្ទិ្ទសេយ្យាថ យោ បន ភិក្ខុ សជ្ជិកេ វិហារេ
ឧបរិវេហាសកុដិយា អាហចេ្ចចាឧកំ មញ្ចំ ភ ឬ ឬ
ភ អកិនិសីឧេយ្ យ ភ អកិនិបជ្ជេយ្ យ ភ ចាចិត្តិយន្តិ ។

[១១] យោ បឧាតិ យោ យាឧិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឺ អត្ថ អធិប្ប្ឧោ ភិក្ខូតិ ។
សជ្ជិកោ ជាម វិហារេ សជ្ជ្ស្ស ឧិ ហ្ន្ ហោតិ
ឧ្ឧ ។

[១២] ឧេហាសកុដិ ជាម ឧ្ឧ្ឧ ឧ្ឧ ឧ
ឧ ។ ។ ។

អង្គុយចុះ ដោយរហ័សសង្កត់ត្រែដែលមានជើងគ្រាន់តែស៊ីកទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឆ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងមកអង្គុយចុះ ដោយរហ័សសង្កត់ត្រែដែលមានជើងគ្រាន់តែស៊ីកទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឆទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលអ្នកមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយអង្គុយចុះ ដោយរហ័សសង្កត់ ឬដេកសង្កត់នូវត្រែក្តី នូវតាំងក្តី ដែលមានជើងគ្រាន់តែស៊ីកទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឆ ត្រូវអាបត្តិបាចិត្តិយ ។

[១១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា នឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឆ ហៅថា វិហាររបស់សង្ឆ ។

[១២] ផ្ទើរ (ដែលគេធ្វើខ្ពស់) មិនទង្គិចក្បាលមជ្ឈិមបុរស ហៅថាថ្នាក់ ។ ត្រែដែលមានជើងគ្រាន់តែស៊ីកចូលក្នុងមេហើយតាំងទុក ហៅថាត្រែដែលមានជើងគ្រាន់តែស៊ីកទុក ។ តាំងដែលមានជើងគ្រាន់តែស៊ីក

បីបំ អង្ដ្ដ ១ ១ ១

ចូលក្នុងមេ ហៅថា តាំងដែលមានជើងគ្រាន់តែស៊ីកទុក ។ ពាក្យថា អង្គុយសង្កត់ គឺភិក្ខុអង្គុយសង្កត់លើគ្រែ ឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ដេកសង្កត់ គឺភិក្ខុដេកសង្កត់លើគ្រែ ឬតាំងនោះ ត្រូវអាបត្តិ បាចិត្តិយ ។

[១៣] វិហាររបស់សង្ឆ ភិក្ខុសំគាល់ថា ជារបស់សង្ឆមែន ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើង គ្រាន់តែស៊ីកទុកក្នុងមេ (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិ បាចិត្តិយ ។ វិហាររបស់សង្ឆភិក្ខុមានសេចក្តីសង្ស័យ ហើយអង្គុយសង្កត់ ឬដេកសង្កត់ លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊ីកទុកក្នុងមេ (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់ សង្ឆ ភិក្ខុសំគាល់ថា ជារបស់បុគ្គលវិញ ហើយអង្គុយសង្កត់ ឬដេក សង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊ីកទុកក្នុងមេ (ដែល គេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថា ជារបស់សង្ឆវិញ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល

បុក្ខលិកសញ្ញី អញ្ញស្ស បុក្ខលិកេ អាបត្តិ ទុក្ការស្ស ។ អត្តនោ បុក្ខលិកេ អនាបត្តិ ។

[១៤] អនាបត្តិ អវេហាសកុដិយា សីសយ្ហាយ ហេដ្ឋា អបរិភោគំ ហោតិ បឋវសញ្ជ្ញិតំ ហោតិ បជាណិ ជិន្ន ហោតិ តស្មឹ ឋិតោ ឧណ្ហាតិ វា លក្ខេតិ វា ឧម្មត្តកស្ស អាជិកម្ម្ជិកស្ស ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុសំគាល់ថា ជារបស់បុគ្គលដដែល ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គលនៃភិក្ខុដទៃ គឺវិហាររបស់គេ ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះ វិហារជារបស់ខ្លួន គឺវិហាររបស់ខ្លួនឯង ។

[១៤] អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយ ឬដេកសង្កត់លើគ្រែ ក្តី តាំងក្តី ដែលគេតម្កល់ទុកលើទីដែលមិនមែនថ្នាក់ លើទីទាបដែល ដើរទង្គិចក្បាលទីដែលមិនបានប្រើប្រាស់ខាងក្រោមឲ្យជាទីនៅ ទីដែល គេក្រាលជិតដោយរនាប លើគ្រែ ឬតាំងនោះ ដែលគេជាក់គន្ធ៏ះហើយ ដល់ភិក្ខុដែលឈរនៅលើគ្រែ ឬតាំងនោះ ហើយកាន់យក ឬញ្ជូរនូវបរិក្ខារ ដល់ភិក្ខុឆ្លត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

នវមសិក្ខាបទំ

[១៥] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មតោ ឆន្នស្ស ឧបដ្ឋាកោ មហាមត្តោ អាយស្ម-តោ ឆន្នស្ស វិហារំ ការាបេតិ ។ អថខោ អាយស្មា ឆន្នោ ភតបរិយោសិតំ វិហារំ បុនប្បុនំ ឆាទាបេសិ[១] បុនប្បុនំ លិម្បាបេសិ[២] អតិការិកោ[៣] វិហារោ បរិប-តិ ។ អថខោ អាយស្មា ឆន្នោ តិណញ្ច ភុជ្ជញ្ច សង្ក-ឌ្ឍន្តោ អញ្ញតរស្ស ព្រាហ្មណស្ស យវខេត្តំ ឱ្ចរិ ។ អថខោ សោ ព្រាហ្មណោ ឧជ្ឌាយតិ ខីយតិ វិចាចេតិ ភិក្ខុ ហិ នាម ភគ្គវ្ហា អម្ហាកំ យវខេត្តំ ឱ្ចរិស្សន្តី-តិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស ព្រាហ្មណស្ស ឧជ្ឌាយន្តស្ស ខីយន្តស្ស វិចាចេន្តស្ស ។ យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឌាយន្តិ ខីយន្តិ វិចាចេន្តិ ភិក្ខុ ហិ នាម អាយស្មា ឆន្នោ ភតបរិយោសិតំ

---

១ ឱ.ម. ឆាទាបេតិ ។ ២ លិម្ពាបេតិ ។ ៣ អតិការិតោ ។

សិក្ខាបទទី ៩

[១៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង មហាមាត្យជាឧបដ្ឋាករបស់ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេធ្វើវិហារប្រគេនឆន្នភិក្ខុដ៏មានអាយុ ។ លំដាប់នោះ ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេប្រក់និងបូកលាបវិហារដែលគេធ្វើស្រេចហើយនោះញយ ។ វិហារនោះធ្ងន់ហួសកំណត់ ក៏បាក់រលំចុះមក ។ គ្រានោះ ឆន្នភិក្ខុដ៏មានអាយុ ក៏ជញ្ជូនយកស្មៅ និងឈើទៅធ្វើ (វិហារទៀត) បៀតបៀនស្រែស្រូវរបស់ព្រាហ្មណ៍ម្នាក់ ឲ្យខូចខាតទៅ ។ ទើបព្រាហ្មណ៍នោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា លោកម្ចាស់ទាំងឡាយ មិនសមបើនឹងមកបៀតបៀនស្រែស្រូវរបស់យើងឲ្យខូចខាតទៅសោះ ។ ភិក្ខុទាំងឡាយ បានឮពាក្យរបស់ព្រាហ្មណ៍នោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ឆន្នភិក្ខុដ៏មានអាយុ មិនគួរនឹងឲ្យគេប្រក់រឿយ ។

វិហារំ បុនប្ប៉ុនំ ធាតាបេស្សតិ បុនប្ប៉ុនំ លិម្ផាបេស្សតិ អតិការិកោ វិហារេ បរិបតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឆន្ន កតបរិយោសិតំ វិហារំ បុនប្ប៉ុនំ ធាតាបេសិ បុនប្ប៉ុនំ លិម្ផាបេសិ អតិការិកោ វិហារេ បរិបតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ឆេ ហិ ជាម ត្វំ មោឃបុរិស ឆតបរិយោសិតំ វិហារំ បុនប្ប៉ុនំ ធា-ធាបេស្សសិ បុនប្ប៉ុនំ លិម្ផាបេស្សសិ អតិការិកោ វិហារេ បរិបតិ ឌេតំ មោឃបុរិស អប្ប្ស្ណានំ វ បសាធាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខា-បទំ ឧទ្ទិសេយ្យាថ មហាសុ្ងកំ បន ភិក្ខុធ វិហារំ ការយមានេន យាវ ទ្វារកោសា អត្ត ១ ១ ១

បូកលាបរឿយ ៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះ ធ្ងន់ហួសកំណត់ បាក់រលំចុះមកសោះ ។ ភិក្ខុអម្ចាលណោះនាំគ្នា ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះដ៏មាន ព្រះភាគត្រាស់សួរថា ម្នាលឆន្ន ឮថា អ្នកឯងឲ្យគេប្រក់រឿយ ៗ និង បូកលាបរឿយ ៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារ នោះធ្ងន់ហួសកំណត់ បាក់រលំចុះមកពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងឲ្យគេប្រក់រឿយ ៗ និងបូកលាបរឿយ ៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះ ធ្ងន់ហួសកំណត់ បាក់រលំចុះមកទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើ នេះមិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើវិហារធំ គប្បីឈរ (លាបបូកញ្ចាយ ៗ បាន) កំណត់ទី មានឱកាសត្រឹមតែសន្ទឹកទ្វារ[១] (និងសន្ទឹកបង្ហូច) ដើម្បីទុកប្រើប្រាស់ នូវទ្វារ និងដើម្បីបរិកម្មនូវសន្ទឹកបង្ហូច ឯដំបូលភិក្ខុត្រូវឈរក្នុង

---

១ ក្នុងមហាបច្ចរីថា មានទំហំមួយហត្ថមួយចំអាម រាប់អំពីមេទ្វារចេញទៅ ក្នុងកុរុន្ទិថា កំណត់ត្រឹមសន្ទឹកទ្វារទាំងពីរជាប្រមាណ ក្នុងមហាអដ្ឋកថាថា សន្ទឹកទ្វារនោះមួយហត្ថមួយ ចំអាមក៏មាន ពីរហត្ថក៏មាន ពីរហត្ថមួយចំអាមក៏មាន ។

អបហរិតេ ឋិតេន អធិដ្ឋាតព្ពំ តតោ ចេ ឧត្តរឺ[1] អបហ-
រិតេបិ ឋិតោ អធិដ្ឋហេយ្យ ចាចិត្តិយន្តិ ។

[១៦] មហាលូកោ ជាម រិហាវោ សស្ស្ជាមិកោ
រុច្ចតិ ។ រិហាវោ ជាម ឧលូ្ចត្តោ វ លោតិ អវលិត្តោ
វ ឧលូ្ចត្តាវលិត្តោ វ ។ ការយមានេជាតិ ការោណ្ដោ
វ ការាបេណ្ដោ វ ។ យាវ ទ្វារកោសាតិ ឋិដ្ឋិ-
សជ្ជ្ជាជ្ជ សាមណ្ដ ហាត្ថចាសា ។ អត្ត្ជ្ជ្ជ្ជ្ជ្ជ-
យាតិ ទ្វារជ្ជ្ជ្ជ្ជ ។ អាលោកសន្ធ្ជ្ជ្ជ្ជ្ជ
ឋានចានជ្ជ្ជ្ជ ។ ។ ។

ទីដែលគ្មានដំណាំ (នោះទើប) ប្រក់បានត្រឹមពីរ ឬបីជាន់ បើភិក្ខុប្រក់ឲ្យច្រើនលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ ក៏គង់ត្រូវអាបត្តិបាចិត្តិយ ។

[១៦] ដែលហៅថា វិហារធំ សំដៅយកវិហារដែលមានទាយកជាម្ចាស់របស់ ។ ដែលហៅថា វិហារ គឺវិហារដែលគេបូកខាងក្នុងក្តី បូកខាងក្រៅក្តី បូកទាំងខាងក្នុង ខាងក្រៅក្តី ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ។ ពាក្យថា កំណត់ទីមានឱកាសត្រឹមតែសន្ទឹកទ្វារ គឺកំណត់ត្រឹមហត្ថបាសដោយជុំវិញនៃក្របទ្វារ ។ ពាក្យថា ដើម្បីទុកប្រើប្រាស់នូវទ្វារ គឺដើម្បីបើកបិទនូវទ្វារ ។ ពាក្យថា ដើម្បីបរិកម្មនូវសន្ទឹកបង្ហួច សេចក្តីថា (តថាគតអនុញ្ញាត) នូវវត្ថុមានពណ៌ស ពណ៌ខ្មៅ ពណ៌រង់ ក្បាច់ក្ងីផ្កា ក្បាច់ក្ងីវល្ល៍ ក្បាច់ធ្នេញមករ និងក្បាច់ឈ្នោះបញ្ចបដ្ឋិក[1] ដើម្បីបរិកម្មនូវសន្ទឹកបង្ហួច ។ ពាក្យថា ឯដំបូលភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ (នោះទើប) ប្រក់បានត្រឹមពីរបីជាន់ ឯដំណាំនោះបានដល់វត្ថុដែលត្រូវស៊ីមុន (គឺស្រូវ ៧ ប្រការ មានស្រូវសស្រូវក្រហមជាដើម) និងវត្ថុដែលត្រូវស៊ីក្រោយ (បានដល់សណ្តែកបាយ សណ្តែករាជមាសជាដើម) ។ បើភិក្ខុឈរធ្វើការប្រក់ក្នុងទីមានដំណាំ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុប្រើឲ្យគេប្រក់ម្តងរួចទៅហើយ

---

១ ក្បាច់ដែលមានស្រទាប់ ៥ ឬជាន់ ៥ ។

ធាតេន្ត្ស្ស ទ្ធ មក្ត អធិដ្ឋហិត្វា តតិយំ មក្ខំ អាណា-
ភេត្វា បក្ត្ត្ថមិតព្ពំ ។ ឧបរិយាយេន ធាតេន្ត្ស្ស ទ្ធ
ឧបរិយាយ អធិដ្ឋហិត្វា តតិយំ ឧបរិយាយំ អាណាភេត្វា
ឧបក្ត្ត្ថមិតព្ពំ ។

[១៧] តតោ ចេ ឧត្ត្ត្ថ អបហរិតេ ឧ ឧ ធ-
ហេយ្យាតិ ឥដ្ឋកាយ ធាតេន្ត្ស្ស ឥដ្ឋកិដ្ឋកាយ
អាបត្តិ ទ្ធ ។ ១ លាយ ធាតេន្ត្ស្ស ១ លាយ
១ លាយ អាបត្តិ ទ្ធ ។ ១ ជាយ ធាតេន្ត្ស្ស
ឧ ឧ អាបត្តិ ទ្ធ ។ ១ ណេ ធ-
ធ ១ ១ អាបត្តិ ទ្ធ ។ ១ ណ
ធាតេន្ត្ស្ស ១ ១ អាបត្តិ ទ្ធ ។

[១៨] ១ ១ ១ ១ ១
ធ ១ ១ ១ ១

ត្រូវប្រក់ខ្ជួនឯងបានត្រឹមពីរដង ដល់គ្រាទីបីត្រូវបង្ហាប់គេ ហើយចៀសចេញទៅ ។ កាលភិក្ខុប្រើឲ្យគេប្រក់មួយជាន់រួចហើយ ត្រូវប្រក់ខ្ជួនឯងបានត្រឹមពីរជាន់ ដល់ជាន់ទីបីត្រូវបង្ហាប់គេហើយចៀសចេញទៅ ។

[១៧] ត្រង់ពាក្យថា បើភិក្ខុប្រក់ឲ្យច្រើនលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ សេចក្ដីថា កាលភិក្ខុប្រើគេឲ្យប្រក់ដោយក្បឿង ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ ផែនក្បឿង ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយថ្ម ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ ផែនថ្ម ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយកំបោរ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ ដុំកំបោរ ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្មៅ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ កណ្ដាប ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្លឹកឈើ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ សន្ទឹក ។

[១៨] វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសំគាល់ថា លើសមែនហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសង្ស័យហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសំគាល់ថា ខ្វះវិញ ហើយធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសំគាល់ថា លើស ហើយ (ធ្វើថែម) ត្រូវអាបត្តិទុក្កដ ។

ជុក្ខ្ជ ។ ឩនកទ្វិត្តិបរិយាយេ ឯមតិកោ អាបត្តិ ជុក្ខ្ជ ។ ឩនកទ្វិត្តិបរិយាយេ ឩនកសញ្ញី អនាបត្តិ ។

[១៩] អនាបត្តិ ទ្វិត្តិបរិយាយេ ឩនកទ្វិត្តិបរិ-យាយេ លេណោ កុហាយ តិណកុដិកាយ អញ្ញ-ស្ស្ត្ថាយ អត្តនោ ឆនេន ភាសាការ បមេត្វា សពូត្ត អនាបត្តិ ឧម្មត្តកស្ស អាទិកម្ម្ិកស្ស្ត្ថ ។

នវមសិក្ខាបទ ។

វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសំគាល់ថា មិនទាន់ដល់មែន មិនត្រូវអាបត្តិ ។

[១៩] អាបត្តិមិនមាន ដល់ភិក្ខុដែលបូកប្រក់វិហារត្រឹមពីរបីជាន់ ដល់ភិក្ខុដែលបូកប្រក់វិហារមិនដល់ពីរបីជាន់ ដល់ភិក្ខុដែលបូកប្រក់លេណ (ទីពួន) គុហា កុដិប្រក់ដោយស្មៅ ធ្វើដើម្បីប្រយោជន៍ ដល់អ្នកដទៃ ធ្វើដោយទ្រព្យរបស់ខ្លួន ទីសេនាសនៈទាំងពួង រៀរលែងតែកុដិសម្រាប់នៅរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[២០] តេន សមយេន ពុទ្ធោ ភគវា អាឧ្យវិយំ វិហរតិ អក្ការ្ជ្ជវ ចេតិយ ។ តេន ខោ បន សមយេន អាឧ្យវិកា ភិក្ខូ ជរ្ជកម្ម៉ ការ្ជ្ជ ជាន៎ សប្ជ្ជាណ្ជ ឧ១ កំ តិណ្ជ ម្ជ មត្ត ម្ជ សិ ញ្ជ ន្ត ម្ជ សិ ញ្ជ ប ន្ត ម្ជ ។ យ ត ភិ ក្ខូ ។ ប ។ ត ឧ ជ ្ជ យ ន្ត ទ ី ន្ត ។ ។ ។

សិក្ខាបទទី ១០

[២០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងអគ្គាឡវចេតិយ ទៀបស្រុកអាឡវី ។ គ្រានោះឯង ភិក្ខុស្រុកអាឡវីទាំង-ឡាយកាលធ្វើនូវនវកម្ម (កម្មទើបតែកសាងថ្មី) ដឹងថា ទឹកមានសត្វ ក៏ស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកភិក្ខុស្រុកអាឡវីដឹងថា ទឹកមានសត្វហើយមិនសមបើនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ សោះឡើយ ។ ទើបភិក្ខុទាំងនោះ នាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងថា ទឹកមានសត្វ ហើយស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងដឹងថា ទឹកមានសត្វហើយមិនសមបើនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះទេ នែមោឃបុរសទាំងឡាយ អំពើដែល

ឌេតំ មោឃបុរិសា អប្ឋសន្ថានំ វា បសាឌាយ បសន្ថានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ សប្ឋាណាកំ ឧទកំ តិណំ វា មត្តិកំ វា សិញ្ចេយ្ យ វា សិញ្ចាបេយ្ យ វា ចាចិត្តិយន្តិ ។

[២១] យោ បជានាតិ យោ យាឌិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ឋេតោ ភិក្ខូតិ ។ ជានំ ជាម សាមំ វា ជានាតិ អញ្ញ វា ឥស្ស អាហេចេន្តិ ។

[២២] សិញ្ចេយ្យាតិ សយំ សិញ្ចតិ អាបត្តិ ចា-ចិត្តិយស្ស ។ សិញ្ចាបេយ្យាតិ អញ្ញ អាណាបេតិ អាបត្តិ ចាចិត្តិយស្ស ។ សកឹ អាណាត្តោ ពហុកំបិ សិញ្ចតិ អាបត្តិ ចាចិត្តិយស្ស ។ សប្ឋាណាកេ សប្ឋាណាកសញ្ញ តិណំ វា មត្តិកំ វា សិញ្ចតិ វា សិញ្ចាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។ សប្ឋាណាកេ ឋេមតិកោ តិណំ វា មត្តិកំ វា សិញ្ចតិ វា សិញ្ចាបេតិ វា អាបត្តិ ទុក្ខ្ជ ស្ស ។ សប្ឋាណាកេ អប្ឋាណាកសញ្ញ តិណំ វា មត្តិកំ

អ្នកធ្វើនេះមិនគាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬ មួយញ៉ាំងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបានទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងថា ទឹកមានសត្វហើយស្រោចឯងក្ដី ប្រើគេឲ្យស្រោចក្ដី នូវស្មៅឬដី ត្រូវអាបត្តិបាចិត្តិយ ។

[២១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុដឹងដោយខ្លួនឯងក្ដី ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះក្ដី ឈ្មោះថា ភិក្ខុដឹង ។

[២២] ត្រង់ពាក្យថា ស្រោចឯង គឺភិក្ខុស្រោចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើគេឲ្យស្រោច គឺភិក្ខុបង្គាប់អ្នកដទៃឲ្យស្រោច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រើតែម្តង ហើយអ្នកទទួលបង្គាប់ទៅស្រោចច្រើនដង ភិក្ខុអ្នកប្រើត្រូវអាបត្តិបាចិត្តិយ ។ (ទឹក) មានសត្វ ភិក្ខុសំគាល់ថា (ទឹក) មានសត្វមែន ហើយស្រោចឯងក្ដី ប្រើគេឲ្យស្រោចក្ដី នូវស្មៅឬដី ត្រូវអាបត្តិបាចិត្តិយ ។ (ទឹក) មានសត្វ ភិក្ខុមានសេចក្ដីសង្ស័យ ហើយស្រោចឯងក្ដី ប្រើគេឲ្យស្រោចក្ដី នូវស្មៅឬដី ត្រូវអាបត្តិទុក្កដ ។ (ទឹក) មានសត្វ ភិក្ខុសំគាល់ថាគ្មានសត្វវិញ ហើយស្រោចឯងក្ដី ប្រើគេឲ្យស្រោចក្ដី នូវស្មៅឬដី

ឯ សិញ្ចតិ ឯ សិញ្ចាបេតិ ឯ អជាបត្តិ ។ អប្ជាណកេ
សប្ជាណកសញ្ញី អាបត្តិ ទុក្កដស្ស ។ អប្ជាណកេ
វេមតិកោ អាបត្តិ ទុក្កដស្ស ។ អប្ជាណកេ អប្ជា-
ណកសញ្ញី អជាបត្តិ ។

[២៣] អជាបត្តិ អសញ្ចិច្ច អសតិយា អជា-
ជន្តស្ស ឧម្មត្តកស្ស អាទិកម្មិកស្ជាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ភូតគាមវគ្គោ ទុតិយោ ។

មិនត្រូវអាបត្តិអ្វីឡើយ ។ (ទឹក) មិនមានសត្វ ភិក្ខុសំគាល់ថា មានសត្វ ត្រូវអាបត្តិទុក្កដ ។ (ទឹក) មិនមានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ (ទឹក) មិនមានសត្វ ភិក្ខុសំគាល់ថា មិនមានសត្វ មិនត្រូវអាបត្តិអ្វីឡើយ ។

[២៣] អាបត្តិមិនមាន ដល់ភិក្ខុមិនភ្លេង ដល់ភិក្ខុមិនមានស្មារតី ដល់ភិក្ខុមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

ភូតគាមវគ្គទី ២ ចប់ ។

បាចិត្តិយកណ្ឌ ភូតគាមវគ្គស្ស ឧទ្ទានំ

តស្ស ឧទ្ទានំ

ភូតំ អញ្ញាយ ឧជ្ឌាយំ
បក្ខ្លមន្តេន តេ ទុវេ
បុពេ្ព និក្ខ្លឆ្ឌាមាចូ ទ្វារំ
សប្ប្ណាណាកេ[1] ចាតិ ។

---

១ ឌ. ម. ទ្វារសប្ប្ណាណាកេន ។

បាចិត្តិយកណ្ឌ ភ្ជុតគាមវគ្គ ឧទ្ទាន

ចំនួនសិក្ខាបទក្នុងភ្ជុតគាមវគ្គនោះ គឺ

ភិក្ខុធ្វើភ្ជុតគាមឲ្យដាច់ចាកទី ១ ភិក្ខុយករឿងដទៃមកបន្ទប់ដើម្បីបិទបាំងទោសខ្លួន ១ ភិក្ខុលើកទោសភិក្ខុអ្នកធ្វើការសង្ឆ ១ ភិក្ខុយកគ្រែតាំងពួកកៅអីរបស់សង្ឆទៅចោលក្នុងទីវាល ហើយចៀសចេញទៅ ១ ភិក្ខុយកកម្រាលរបស់សង្ឆទៅក្រាលចោលហើយចៀសចេញទៅ ១ ភិក្ខុដេកបៀតច្រៀតភិក្ខុអ្នកនៅមុនក្នុងកុដិសង្ឆ ១ ភិក្ខុខឹងនឹងភិក្ខុឯទៀតហើយបណ្តេញចាកវិហាររបស់សង្ឆ ១ ភិក្ខុអង្គុយ ឬដេកលើគ្រែមានជើងស៊ីកទុក ១ ភិក្ខុលាបបូកវិហារញ្ចុយ ៗ បានកំណត់ត្រឹមសន្ទឹកទ្វារ ឬសន្ទឹកបង្ហូចដោយជុំវិញ ១ ភិក្ខុយកទឹកមានសត្វស្រោចស្មៅ ឬដី ១ ។

ឱវាទវគ្គស្ស បឋមសិក្ខាបទំ

[២៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តា
លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្ប-
ច្ចយភេសជ្ជបរិក្ខារានំ ។ អថខោ ឆព្ភក្ខិយានំ ភិក្ខូនំ
ឯតទហោសិ ឯតរហិ ខោ អាវុសោ ថេរា ភិក្ខូ
ភិក្ខុនិយោ ឱវទន្តា លាភិនោ ហោន្តិ ចីវរបិណ្ឌបាត-
សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ហន្ទ មយំ
ឯ ភិក្ខុនិយោ ឱវទាមាតិ ។ អថខោ ឆព្ភក្ខិយា
ភិក្ខូ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ ឯ ១ អម្ហេ
ភគិនិយោ ឧបសង្កមថ មយំ ឱវទិស្សាមាតិ ។ អថខោ
តា ភិក្ខុនិយោ យេន ឆព្ភក្ខិយា ភិក្ខូ តេនុបសង្កមិ
ឧបសង្កមិត្វា ឆព្ភក្ខិយេ ភិក្ខូ អភិវាទេត្វា ឯ ១ មន្តំ
 និសីទិ ។ អថខោ ឆព្ភក្ខិយា ភិក្ខូ ភិក្ខុនីនំ ១ ១ ១
ឯ ១ ១ ១

ឱវាទវគ្គ សិក្ខាបទទី ១

[២៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈ ទាំងឡាយទូន្មានភិក្ខុនីទាំងឡាយ ក៏បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ។ លំដាប់នោះ ពួកឆព្វគ្គិយ-ភិក្ខុបានគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយ ទូន្មានពួកភិក្ខុនីបានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យ ដល់មនុស្សឈឺ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងទាំងឡាយ ក៏ទូន្មានពួកភិក្ខុនីដែរ ។ វេលានោះ ពួកឆព្វគ្គិយភិក្ខុនាំគ្នា ចូលទៅរក ភិក្ខុនីទាំងឡាយហើយបាននិយាយយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរមករកពួកយើង ។ នឹងទូន្មាន ។ គ្រានោះ ភិក្ខុនីទាំងឡាយ នោះ ក៏ចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយបាន ថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយហើយអង្គុយក្នុងទីគួរមួយ ។ ពួកឆព្វគ្គិយ-ភិក្ខុធ្វើធម្មីកថាបន្តិចបន្តួច ដល់ពួកភិក្ខុនី ហើយក៏ពោលតិរច្ឆានកថាឲ្យ កន្ធងអស់ ១ ថ្ងៃ រួចបញ្ជូនពួកភិក្ខុនីឲ្យត្រឡប់ទៅវិញ ដោយពាក្យថា

ឧយ្យោជេសុំ តញ្ច ភតិនិយោតិ ។ អថខោ តា
ភិក្ខុនិយោ យេន ភគវា តេនុបសង្កមិសុ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា
ខោ តា ភិក្ខុនិយោ ភគវា ឯតទវោច កច្ចិ ភិក្ខុនិយោ
ឱវាទោ ឥច្ឆា អហោសីតិ ។ ក្យាតោ ភន្តេ ឱវាទោ ឥច្ឆា
ភវិស្សតិ អយ្យា ឆព្ភិក្ខិយា បរិត្តំយេវ ឆម្ម៉ឹ ភណ្ដ ភត្ថា
ជិវសំ តិរច្ឆានកថាយ រីតិនាមេត្ថា ឧយ្យោជេសុន្តិ ។
អថខោ ភគវា តា ភិក្ខុនិយោ ឆម្ម៉ិយា កថាយ សន្ធ-
ស្ស្ស្ស្ស្ស សមាទបេសិ សមុត្តេជេសិ សម្ប្ប្ប្ប្ប្ប ។
អថខោ តា ភិក្ខុនិយោ ភគវតា ឆម្ម៉ិយា កថាយ
សន្ធ្ស្ស្ស្ស្ស សមាទបិតា សមុត្តេជិតា សម្ប្ប្ប្ប្ប្ប
ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណ្ណ ភត្ថា
បក្ក្ក្ក្ក ។ អថខោ ភគវា ឯតស្ម៉ឹ ជិតាតេ ឯតស្ម៉ឹ
បការណ ភិក្ខុសង្ឆ្ស សន្ធ្ជិតាតាបេត្ថា ឆព្ភិក្ខិយ ភិក្ខ
បដិបុច្ឆ្ជ សចំ ភ្ជ ត្ថ ភិក្ខ ភិក្ខ្ជ ជ ជ
យេ ឆម្ម៉ឹ ភណ្ដ ភត្ថា ជិវសំ តិរច្ឆានកថាយ

ម្នាលប្អូនស្រីទាំងឡាយពួកនាងចូរទៅវិញចុះ ។ គ្រានោះ ភិក្ខុនីទាំងឡាយ
នោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយបានថ្វាយ
បង្គំព្រះដ៏មានព្រះភាគហើយឈរក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ
ទ្រង់ត្រាស់សួរពួកភិក្ខុនីនោះ ដែលឈរក្នុងទីដ៏សមគួរដោយពុទ្ធដីកាយ៉ាង
នេះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទ (នោះ) បានបរិបូរណ៍សម្រេចហើយឬ ។
ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឱវាទ (នោះ) នឹងបរិបូណ៌
សម្រេចមកពីណា ព្រោះលោកម្ចាស់ធព្ទគ្ពិយទាំងឡាយ ធ្វើធម្មីកថាតែ
បន្តិចបន្តួចប៉ុណ្ណោះ ហើយពោលតិរច្ឆានកថាឲ្យកន្ទ្ងអស់ ១ ថ្ងៃ រួចក៏បញ្ជូន
ខ្ញុំព្រះអង្គទាំងឡាយឲ្យត្រឡប់មកវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគ
ទ្រង់ពន្យល់ភិក្ខុនីទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាច
ហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ភិក្ខុនីទាំងឡាយនោះ
លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យ
អាចហាន ឲ្យរីករាយដោយធម្មីកថាហើយក៏ក្រោកចាកអាសនៈថ្វាយបង្គំ
ព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណាចៀសចេញទៅ ។ ព្រោះនិទាន
នេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឆហើយ ត្រាស់សួរ
បញ្ជាក់ធព្ទគ្ពិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំង-
ឡាយធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយតិចណាស់ ពោលតែតិរច្ឆានកថា

រីតិជាមេត្វា ឧយ្យោជេថាតិ ។ សចេ ភគវាតិ ។ រីតរហិ ពុទ្ធោ ភគវា ឥមំ ហិ ជាម តុម្ហេ មោយ-
បុរិសា ភិក្ខុនីនំ បរិត្តំយេវ ធម្មឿ ឥមំ ឥត្ថា ជិវសំ តិរច្ឆានកថាយ រីតិជាមេត្វា ឧយ្យោជេស្ស
ជេតំ មោយបុរិសា អប្ប្ សន្ថានំ វ បសាជាយ
បសន្ថានំ វ ភិយ្យោភាវាយ ។ បេ ។ រីតរហិត្វា ធម្មឿ
ឥមំ ឥត្ថា ភិក្ខូ អាមន្ត្តេសិ អនុជានាមិ ភិក្ខវេ
ភិក្ខុនោវាទកំ សម្ម ន្ធិតុំ ឯវញ្ច បន ភិក្ខវេ សម្ម ន្ធិតព្ពោ
បឋមំ ភិក្ខុ យាចិតព្ពោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា
បដិពលេន សង្ឆោ ញ្ញាបេតព្ពោ សុណាតុ មេ ភន្ត
សង្ឆោ យទិ សង្ឆ្ស ្ស បត្តកល្ល ំ សង្ឆោ ឥត្ថន្ថាមំ
ភិក្ខុំ ភិក្ខុនោវាទកំ សម្ម ន្ធេយ្យ ។ ឯសា ញ្ត្តិ ។

ឲ្យកន្ធ១អស់ ១ ថ្ងៃ ហើយក៏បញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃ-បុរសទាំងឡាយ ពួកអ្នកឯងមិនសមបើនឹងធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយ តិចពេក ពោលតែតិរច្ឆានកថាឲ្យកន្ធ១អស់ ១ ថ្ងៃ ហើយបញ្ជូនភិក្ខុនីទាំងឡាយឲ្យត្រឡប់ទៅវិញសោះ នែមោឃបុរសទាំងឡាយ អំពើដែលអ្នករាល់គ្នាធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលអ្នកដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបាន ។ បេ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលហើយ ក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆសន្ធតភិក្ខុ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវសន្ធតភិក្ខុ ឲ្យជាអ្នកឲ្យឱវាទ ដល់ភិក្ខុនីយ៉ាងនេះ សង្ឆត្រូវអាវាធនាភិក្ខុ (នោះ) ជាមុនសិន ។ លុះអាវាធនារួចហើយ ភិក្ខុអ្នកឈ្វាស អង់អាច គប្បីញ៉ាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ បើសម្មតិកម្មនេះមានកាលដ៏សមគួរដល់សង្ឆហើយ សង្ឆគប្បីសន្ធតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ នេះជាវាចាប្រកាសសង្ឆឲ្យដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ

សុណាតុ មេ ភន្តេ សង្ឆោ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្ជតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភិក្ខុនោវាទកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្ឆិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្ឆិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឆោ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្ជតិ ។ យស្សា-យស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភិក្ខុនោ-វាទកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឆេន ឥត្ថន្នាមោ ភិក្ខុ ភិក្ខុនោវាទកោ ។ ខមតិ សង្ឆស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ភគវា ឆព្វគ្គិយេ ភិក្ខូ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អសម្មតោ

សង្ឆសន្ទតកិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ ការសម្មតភិក្ខុ ឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី សមគួរដល់លោកដ៏មាន អាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀមនៅ មិនគួរដល់ លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះអស់វារៈពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះ អស់វារៈបីដងផង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្តាប់ខ្ញុំ សង្ឆសន្ទតកិក្ខុឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ ការសម្មតភិក្ខុ ឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុ អង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឆបានសន្ទតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីហើយ ។ សម្មតិកម្មនេះគួរ ដល់សង្ឆ ហេតុនោះ បានជាសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។ ត្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលនូវឆព្វគ្គិយភិក្ខុទាំងឡាយដោយបរិយាយជាច្រើន ។ បេ ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែង ឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដែលសង្ឆមិនបានសន្ទត

ភិក្ខុនិយោ ឱវទេយ្យ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២៥] តេន ខោ បន សមយេន ថេរា ភិក្ខូ សម្មតា ភិក្ខុនិយោ ឱវទន្តា តថេវ លាភិនោ ហោន្តិ ចីវរបិណ្ឌាចាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារ-ានំ ។ អថខោ ឆព្ពគ្គិយានំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ អាវុសោ ថេរា ភិក្ខូ សម្មតា ភិក្ខុនិយោ ឱវទន្តា តថេវ លាភិនោ ហោន្តិ ចីវរបិណ្ឌាចាតសេនា-សនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ហន្ទ្ទាវុសោ មយំបិ ជិស្សាមំ តត្ថ អញ្ញមញ្ញ ភិក្ខុនោវាទកំ សម្មន្ត្វិនា ភិក្ខុនិយោ ឱវទាមាតិ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ ជិស្សាមំ តត្ថ អញ្ញមញ្ញ ភិក្ខុនោវាទកំ សម្មន្ត្វិនា ភិក្ខុនិយោ ឧបសង្ក្រមិត្វា ឯតទវោចុំ មយំបិ ភគិនិយោ សម្មតា អម្ហេ ឧបសង្ក្រមថ មយំបិ ឱវទិស្សាមាតិ ។ អថខោ តា ភិក្ខុនិយោ យេន ឆព្ពគ្គិយា ភិក្ខូ តេនុបសង្ក្រមិំសុ ឧបសង្ក្រមិត្វា ឆព្ពគ្គិយេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ ជិសីទិំសុ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនីនំ

ហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយ ដោយប្រការយ៉ាងនេះ ។

[២៥] សម័យនោះឯង ភិក្ខុជាថេរៈទាំងឡាយដែលសង្ឆបានសន្ទនរួចហើយ ក៏ទៅប្រដៅភិក្ខុនីទាំងឡាយក៏បានចីវរ បិណ្ឌបាត សេនាសនៈនិងភេសជ្ជបរិក្ខារជាបច្ច័យដល់ភិក្ខុឈឺយ៉ាងនោះដដែល ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ បានគិតគ្នាថា អាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយ ដែលសង្ឆបានសន្ទនហើយ ក៏ទៅប្រដៅភិក្ខុនីទាំងឡាយ បានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់ភិក្ខុឈឺយ៉ាងនោះដដែល អាវុសោ បើដូច្នោះ មានតែពួកយើងទៅកាន់ទីគ្មានសីមា ហើយសន្ទនគ្នាទៅវិញទៅមក ឲ្យជាអ្នកប្រដៅភិក្ខុនី រួចប្រដៅពួកភិក្ខុនី ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុនាំគ្នាទៅកាន់ទីគ្មានសីមា ហើយសន្ទនគ្នាទៅវិញទៅមក ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយចូលទៅរកភិក្ខុនីទាំងឡាយពោលយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ សង្ឆបានសន្ទនពួកយើងហើយ នាងទាំងឡាយ ចូរមករកពួកយើងចុះ យើងនឹងប្រដៅទូន្មាន ។ ទើបភិក្ខុនីទាំងឡាយនោះ ចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ

បរិត្តំយេវ ជម្មឿ ភាសំ ភាត្វា ជិវសំ តិរច្ឆានកថាយ រីតិជាមេត្វា ឧយ្យោជេសុំ ឥច្ចេ ភគិនិយោតិ ។ អថខោ តា ភិក្ខុនិយោ យេន ភគវា តេនុបសង្ក្រមឿសុ ឧបសង្ក្រមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ភិក្ខុនិយោ ភគវា ឯត-ឧវាច ភាចិ ភិក្ខុនិយោ ឱវាទោ ឥត្ថោ អហោសីតិ ។ ភុតោ ភន្តេ ឱវាទោ ឥត្ថោ ភវិស្សតិ អយ្យ ធម្ម្ភិយ បរិត្តំយេវ ជម្ម ភាសំ ភាត្វា ជិវសំ តិរច្ឆាន-ភថាយ រីតិជាមេត្វា ឧយ្យោជេសុន្តិ ។ អថខោ ភគវា តា ភិក្ខុនិយោ ជម្ម្ភិយ ភថាយ សន្ទ្ធេ្ស្ស្ស្ស សមាធបេសិ សមុត្តេជេសិ សម្ម្ហាសេសិ ។ អថខោ តា ភិក្ខុនិយោ ភគវតា ជម្ម្ភិយ ភថាយ សន្ទ-ស្ស្ស្ស តា សមាធបិតា សមុត្តេជិតា សម្ម្ហាសិតា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ ភាត្វា បក្ក្ម្ភិសុ ។ អថខោ ភគវា ឯតស្ម្ភ ជិជាតេ ឯតស្ម្ភ បការណោ ភិក្ខុសង្ឆ្យ សន្ធ្ជ្ជ្ជ្ជ្ជ ធម្ម្ភិយ

ធ្វើធម្មីកថាបន្ដិចបន្ដួចដល់ភិក្ខុនីទាំងឡាយ ហើយពោលតិរច្ឆានកថា ឲ្យ
កន្ទ្ធងអស់ ១ ថ្ងៃទៅ រួចក៏បញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញ ដោយ
ពាក្យថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរទៅវិញចុះ ។ ទើបភិក្ខុនី
ទាំងនោះនាំគ្នាចូលទៅកាន់ទីគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់
ហើយបានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។
ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុនីទាំងឡាយ ដែលឈរនៅក្នុងទី
ដ៏សមគួរនោះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទបានសម្រេចបរិបូណ៌ឬ
ទេ ។ ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឱវាទនឹងបាន
សម្រេចបរិបូណ៌មកពីឯណា លោកម្ចាស់ឆព្វគ្គិយទាំងឡាយ ធ្វើធម្មីកថា
បន្ដិចបន្ដួច ហើយពោលតែតិរច្ឆានកថា ឲ្យកន្ទ្ធងអស់ ១ ថ្ងៃ រួចក៏បញ្ជូន
យើងខ្ញុំឲ្យត្រឡប់មកវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់
ភិក្ខុនីទាំងឡាយនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីក-
រាយដោយធម្មីកថា ។ ភិក្ខុនីអម្បាលនោះ លុះព្រះដ៏មានព្រះភាគទ្រង់
ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយព្រះ
ធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយ
ធ្វើប្រទក្សិណាចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ
ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឆរួចសួរបញ្ជាក់ពួកឆព្វគ្គិយភិក្ខុថា

ភិក្ខូ បដិបុច្ឆិ សចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុនីនំ
បរិត្តំយេវ ឆម្មឹ ភកំ ភត្វា ជិវសំ តិរច្ឆានកថាយ
រីតិជាមេត្វា ឧយ្យោជេថាតិ ។ សចំ ភគវាតិ ។
រិតរហិ ពុទ្ធោ ភគវា ភកំ ហិ ជាម តុម្ហេ មោ-
ឃបុរិសា ភិក្ខុនីនំ បរិត្តំយេវ ឆម្មឹ ភកំ ភត្វា
ជិវសំ តិរច្ឆានកថាយ រីតិជាមេត្វា ឧយ្យោជេស្សថ
ឆេតំ មោឃបុរិសា អប្ប្ សន្ថានំ វ បសាជាយ ប-
សន្ថានំ វ ភិយ្យោភាវាយ ។ បេ ។ រិតរហិត្វា ឆម្ម ភកំ
ភត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អដ្ឋហង្គេហិ
សមន្ថាគតំ ភិក្ខុ ភិក្ខុនោវាទកំ សម្ម ន្ធិតុំ សីលវា
ហោតិ ចាតិមោក្ខ សំវរ សំវុតោ ១ ១ ១ អាចារ ១ ១ ១

ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយធ្វើធម្មីកថា ដល់ភិក្ខុនីទាំងឡាយ បន្ទិចបន្ទួច ហើយពោលតិរច្ឆានកថា ឲ្យកន្ទ្រងអស់មួយថ្ងៃ រួចក៏បញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះ-ដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបីនឹងធ្វើធម្មីកថាបន្ទិចបន្ទួចដល់ពួកភិក្ខុនី ហើយពោលតិរច្ឆានកថា ឲ្យកន្ទ្រងអស់មួយថ្ងៃ រួចបញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញសោះ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមួយញ៉ាំងបុគ្គលដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបានទេ ។ បេ ។ ទ្រង់តិះដៀលហើយ ក៏ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆ្ស សន្ទ្ធតភិក្ខុដែលប្រកបដោយអង្គ ៨ ឲ្យជាអ្នកប្រដៅភិក្ខុនី គឺភិក្ខុជាអ្នកមានសីលសង្រ្ដមតាមបាតិមោក្ខសំវរ: បរិបូណ៌ដោយអាចារ (មារយាទ) និងទីគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ភិក្ខុជាពហុស្សូត ទ្រទ្រង់ពុទ្ធវចន: សន្សំនូវពុទ្ធវចន: ធម៌ទាំងឡាយណា ពីពោះខាងដើម ពីពោះកណ្ដាល ពីពោះខាងចុង តែងប្រកាសនូវព្រហ្មចរិយធម៌

អកិវនន្តិ តថារូចាស្ស ឆម្ហា ពហុស្សុតា ហោន្តិ ឆតា
វចសា បរិចិតា មនសានុបេក្ខិតា ឌិដ្ឋិយា សុប្បដិវិទ្ធា
ឧភយានិ ខោ បនស្ស ចាតិមោក្ខានិ វិត្ថារេន ស្វាគ-
តានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ[1] សុវិនិច្ឆិតានិ
សុត្តសោ អនុព្យញ្ជនសោ កល្យាណវាចោ ហោតិ
កល្យាណវាក្ការណো យេកុយ្យេន ភិក្ខុនីនំ ឧបិយো
ហោតិ មធុរាចោ បដិពលো ហោតិ ភិក្ខុនិយো ឱវទិតុំ
ន ខោ បនេតំ ភគវន្តំ ឧទ្ទិស្ស បព្ជិតាយ កាសាយ-
វត្ថវសនាយ ករុឆម្ចំ អជ្ឌាបន្ទបុព្ជো ហោតិ រីសតិវស្សោ
វា ហោតិ អតិរេការីសតិវស្សោ វា អនុជានាមិ ភិក្ខវេ
ឥមេហិ អដ្ឌហង្គេហិ សមន្ជាគតំ ភិក្ខុំ ភិក្ខុនោ-
វាទកំ សម្ជន្ទិតុន្តិ ។

[២៦] យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឿ អត្ថេ អធិប្ជេតោ ភិក្ខូតិ ។
អសម្ជតោ នាម ញត្តិចតុត្ថេន កម្ជេន អសម្ជតោ ។
ភិក្ខុនិយោ នាម ឧភតោសង្ឆេ ឧបសម្ជន្ជា ។

---

1 សុប្ជវត្តានីតិបិ បាឬោ ។

ព្រមទាំងអត្ថទាំងព្យញ្ជនៈឲ្យបរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពយ៉ាងនេះ ភិក្ខុនោះចាំច្រើនហើយ ទ្រទ្រង់ហើយ សន្សំហើយ ដោយវាចាដ៏ស្អាត់រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ត្រូវល្អដោយទិដ្ឋិ ១ ចំណែកបាតិមោក្ខទាំងពីរ ភិក្ខុនោះក៏ចេះចាំដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្អាត់រត់មាត់ កាត់សេចក្តីបានដោយល្អ ដោយសុត្ត (គឺខន្ធកៈ និងបរិវារៈ) ដោយអនុព្យញ្ជនៈ ១ ភិក្ខុនោះ មានវាចាពោលត្រឹមត្រូវដោយសិថិលធនិតជាដើម មានសំឡេងពីរោះ ១ ភិក្ខុនោះជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន ១ ភិក្ខុនោះ ជាអ្នកអាចដើម្បីនឹងប្រដៅភិក្ខុនីបាន ១ ភិក្ខុនោះមិនធ្លាប់ប្រព្រឹត្តកន្ទ្ធគរុធម៌នឹងភិក្ខុនីដែលស្ទៀកដណ្តប់សំពត់ជ្រលក់ដោយទឹកចត់ បួសចំពោះព្រះដ៏មានព្រះភាគនេះ ១ ភិក្ខុនោះមានវស្សាម្តេ ឬមានវស្សាជាងម្តេ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆសន្ទ្ធតនូវភិក្ខុដែលប្រកបដោយអង្គទាំងឡាយ ៨ នេះឲ្យជាអ្នកប្រដៅភីក្ខុនី ។

[២៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុដែលឈ្មោះថា សង្ឆមិនបានសន្ទ្ធតនោះ គឺសង្ឆមិនបានសន្ទ្ធតដោយញត្តិចតុត្ថកម្មវាចា ។ ពួកស្រីដែលឈ្មោះថា ភិក្ខុនីនោះ បានដល់ស្រីដែលបានឧបសម្បទាហើយក្នុងឧភតោសង្ឆ ។

[២៧] ឱវនេយ្យាតិ អដ្ឋហិ ករុណម្ភេហិ ឱវនតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញេន ធម្មេន ឱវនតិ អាបត្តិ ទុក្កដស្ស ។ ឯកតោ ឧបសម្ផន្នំ ឱវនតិ អាបត្តិ ទុក្កដស្ស ។

[២៨] តេន សម្ផតេន ភិក្ខុនា បរិវេណំ សម្ផជ្ជិត្វា ចានីយំ បរិភោជនីយំ ឧបដ្ឋាបេត្វា អាសនំ បញ្ញាបេត្វា ទុតិយំ ឧបាហនេ ជិសីទិតព្ពំ ។ ភិក្ខុនីហិ ឥត្ត ឧត្ត តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ ជិសីទិតព្ពំ ។ តេន សម្ផតេន[1] ភិក្ខុនា បុច្ឆិតព្ពា សមក្ខត្ត ភតិនិយោតិ ។ សចេ សមក្ខម្ភាយ្យាតិ ភណ្ឌន្តិ ១ត្ត ១ ភតិនិយោ អដ្ឋ ករុណម្ភាតិ ។ សចេ ១ត្ត ១ អយ្យាតិ ភណ្ឌន្តិ ឯសោ ភតិនិយោ ឱវាទោតិ ជិយ្យាទេតព្ពោ ។ សចេ ១ ១ត្ត ១ អយ្យាតិ ភណ្ឌន្តិ ឱសារេតព្ពា ១ស្ស១ត្ត-សម្ផជ្ជាយ ភិក្ខុនិយា ១ឧ១ហ១ សម្ផ១ជ្ជ១ស្ស ភិក្ខុនោ អភិវាទនំ ១ ១ ១

[២៧] ត្រង់ពាក្យថា ប្រដៅ គឺកិក្ខុទូន្មានដោយគរុធម៌ ៨ ត្រូវអាបត្តិ បាចិត្តិយ ។ កិក្ខុប្រដៅដោយធម៌ដទៃ ត្រូវអាបត្តិទុក្កដ ។ កិក្ខុប្រដៅកិក្ខុនី ដែលបានឧបសម្បទា ក្នុងសំណាក់សង្ឆតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។

[២៨] កិក្ខុដែលសង្ឆសន្ទតនោះ គប្បីបោសច្រាសនូវទីបរិវេណ រួចត្រូវតាំងទឹកធាន់និងទឹកប្រើប្រាស់តែងតាំងនូវអាសនៈទុក ហើយនាំយកកិក្ខុជាគម្រប់ពីរទៅអង្គុយនៅចុះ ។ កិក្ខុនីទាំងឡាយ គប្បីទៅក្នុងទីនោះ ហើយថ្វាយបង្គំនូវកិក្ខុនោះ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ កិក្ខុដែលសង្ឆសន្ទតនោះ គប្បីសួរកិក្ខុនីទាំងឡាយថា ម្នាលនាងទាំងឡាយ ពួកនាងព្រមព្រៀងគ្នាហើយឬ ។ បើកិក្ខុនីទាំងឡាយពោលថា លោកម្ចាស់ យើងខ្ញុំទាំងឡាយព្រមព្រៀងគ្នាហើយ កិក្ខុគប្បីសួរថា ម្នាលនាងទាំងឡាយ គរុធម៌ ៨ ចាំស្ទាត់រត់មាត់ហើយឬ ។ បើកិក្ខុនីទាំងឡាយពោលតបថា បពិត្រលោកម្ចាស់ ចាំស្ទាត់រត់មាត់ហើយ កិក្ខុគប្បីប្រគល់ឱវាទ ដោយពាក្យថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ ។ បើកិក្ខុនីទាំងឡាយពោលថា គរុធម៌មិនទាន់ស្ទាត់ទេ លោកម្ចាស់ កិក្ខុគប្បីសូត្រប្រាប់កិក្ខុនីថា កិក្ខុនីឧបសម្បទាហើយបានមួយរយវស្សាត្រូវធ្វើអភិវាទន-កម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្មដល់កិក្ខុ (សូម្បី) ឧបសម្បទាហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលកិក្ខុនីត្រូវធ្វើឲ្យល្អ គោរព រាប់អាន បូជា

អនតិក្លមនីយោ ។ ន ភិក្ខុនិយា អភិក្ខុកេ អាវាសេ
វស្សំ វសិតព្ពំ អយម្បិ ឧម្មោ សក្ត្វា ករុកត្វា
មានេត្វា ឬជេត្វា យាវជីវំ អនតិក្លមនីយោ ។ អឌ្ឍ-
មាសំ ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្ម បច្ចាសីសិតព្ពា
ឧចោសថបុច្ឆកញ្ច ឱវាទុបសង្កមនញ្ច អយម្បិ ឧម្មោ
សក្ត្វា ករុកត្វា មានេត្វា ឬជេត្វា យាវជីវំ អនតិក្លម-
នីយោ ។ វស្សំ វុត្ថាយ ភិក្ខុនិយា ឧភតោសង្ឆេ
តីហិ ឋានេហិ បវារេតព្ពំ ទិដ្ឋេន វ សុតេន វ បរិសង្កាយ
វ អយម្បិ ឧម្មោ សក្ត្វា ករុកត្វា មានេត្វា
ឬជេត្វា យាវជីវំ អនតិក្លមនីយោ ។ ករុធម្មំ អជ្ឈា-
បជ្ជាយ ភិក្ខុនិយា ឧភតោសង្ឆេ បក្ខមានត្តំ ចរិតព្ពំ
អយម្បិ ឧម្មោ សក្ត្វា ករុកត្វា មានេត្វា ឬជេត្វា
យាវជីវំ អនតិក្លមនីយោ ។ ទ្វេ វស្សានិ ឆសុ
ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឆេ
ឧបសម្បទា បរិយេសិតព្ពា អយម្បិ ឧម្មោ សក្ត្វា
ករុកត្វា មានេត្វា ឬជេត្វា យាវជីវំ អនតិក្លមនីយោ ។
ន ភិក្ខុនិយា កេនចិ បរិយាយេន ភិក្ខុ អក្កោសិតព្ពោ

*កុំប្រព្រឹត្តកន្ទ*ង*ដ*រ*ាបអ*ស*់*មួ*យ*ជ*ីវ*ិ*ត ១ ។ *ភ*ិ*ក*្ខ*ុ*ន*ីម*ិ*ន*ត*្រ*ូ*វ*ន*ៅ*ចំ*រ*ុ*ស*្ម*ា*ក*ន*្ម*ង*អ*ា*រ*ាស ដ*ែ*ល*គ*្ម*ា*ន*ភ*ិ*ក*ខ*ុ* *ន*េ*ះ*ជ*ា*ធ*ម*៌*ដ*ែ*ល*ភ*ិ*ក*ខ*ុ*ន*ីត*្រ*ូ*វ*ធ*្វ*ើ*ឲ*យ*ល*្ម*គ*ោ*រ*ព*ា*ប*ៃ*ម*ា*ន*ប*ូ*ជ*ា* *ក*ុ*ំ*ប*្រ-ព*្រ*ឹ*ត*្ត*ក*ន*្ទ*ង*ដ*រ*ាបអ*ស*់*មួ*យ*ជ*ីវ*ិ*ត ១ ។ *ភ*ិ*ក*ខ*ុ*ន*ីត*្រ*ូ*វ*ប*្រ*ា*ជ*ញ*ា*ធ*ម*៌*ព*ី*រ*ប*្រ*ា*ក*ារ *ค*ឺ*ក*ា*រ* *ส*ា*ក*ស*ួ*រ*ន*ូ*វ*ឧ*ប*ោ*ស*ថ ១ *ก*ា*រ*ចូ*ล*ទ*ៅ*ទ*ទ*ួ*ล*ឱ*ว*ាទ ១ *អ*ំ*ព*ី*ภ*ิ*ก*ข*ุ*ส*ง*ฆ*ค*ร*ป*ๆ *ก*ន*ฺ*ร*ะ*ข*ๆ *น*េ*ះ*ជ* า*ธ*ม*ฺ*ด*ล*ภ*ิ*ก*ข*ุ*น*ีต*ร*ฺ*ว*ธ*ฺ*ว*ี*ย*ล*ฺ*ม*ค*ร*ว*ร*ก*ป*ฺ*ป*ม*ส*ฺ*ม*ู*ช*ว *ก*ุ*ำ*ป*ร*ฺ*ก*ฺ*ร*ฺ*ม*ฺ*ต*ฺ *ก*ฺ*น*ฺ*ท*ฺ*ง*ฺ*ด*ฺ*ร*ฺ*ป*ฺ*ห*ฺ*ม*ฺ*ส*ฺ*ม*ฺ*ู*ช*ฺ*ว*ฺ*ิ*ต*ฺ *ข*ฺ*ร*ฺ*ป*ฺ*ห*ฺ*ม*ฺ*ส*ฺ*ม*ฺ*ู*ช*ฺ*ว*ฺ*ิ*ต*ฺ *ก*ฺ*ร*ฺ*ม*ฺ

បរិកាសិតញ្ចេ អយម្ប៎ ឆម្ចោ សក្ក្ជ្ជ្ជ

នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្ទ្ធងដរាបអស់មួយជីវិត ១ ។ ពួកភិក្ខុនីមិនត្រូវស្តីប្រដៅពួកភិក្ខុឡើយ ។ ពួកភិក្ខុត្រូវស្តីប្រដៅដល់ពួកភិក្ខុនីបាន តាំងអំពីថ្ងៃនេះជាដើម នេះជាធម៌ដែលភិក្ខុ-នីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្ទ្ធងដរាបអស់មួយជីវិត ១ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយព្រម-ព្រៀងគ្នាហើយ ភិក្ខុពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយបែកគ្នាជាពួក ។ ភិក្ខុចេះតែពោលនូវគរុធម៌ ៨ ដដែល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនបានប្រគល់ឱវាទឲ្យដល់ភិក្ខុនី ត្រឡប់ពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ ។

[២៩] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣០] អជ្ឌកម្ម្ យេមតិកោ រត្តំ ភិក្ខុនីសង្ឆំ រត្តសញ្ញី ឱវទតិ ។ បេ ។ យេមតិកោ ឱវទតិ ។ បេ ។ សមត្តសញ្ញី ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។

[៣១] អជ្ឌកម្ម្ ជ្ឌកម្ម្សញ្ញី រត្តំ ភិក្ខុនី-សង្ឆំ រត្តសញ្ញី ឱវទតិ ។ បេ ។ យេមតិកោ ឱវទតិ ។ បេ ។ សមត្តសញ្ញី ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។

[៣២] អជ្ឌកម្ម្ អជ្ឌកម្ម្សញ្ញី សមត្តំ ភិក្ខុនីសង្ឆំ រត្តសញ្ញី ឱវទតិ ។ បេ ។ យេមតិកោ ឱវទតិ ។ បេ ។ សមត្តសញ្ញី ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៣] អជ្ឌកម្ម្ យេមតិកោ សមត្តំ ភិក្ខុនី-សង្ឆំ រត្តសញ្ញី ឱវទតិ ។ បេ ។ យេមតិកោ ឱវទតិ ។ បេ ។ សមត្តសញ្ញី ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។

[៣០] ភិក្ខុសង្ឆ័យក្នុងកម្មមិនជាធម៌ ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ជាពួកមែន ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ឆ័យហើយ ប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិ បាចិត្តិយ ។

[៣១] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌ ភិក្ខុនីសង្ឆ បែកគ្នាជាពួក ភិក្ខុសំគាល់ថា ជាពួកមែន ហើយប្រដៅ ។ បេ ។ ភិក្ខុ សង្ឆ័យហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣២] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឆព្រមព្រៀងគ្នា ភិក្ខុសំគាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ឆ័យហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀង គ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣] កម្មមិនមែនជាធម៌ ភិក្ខុសង្ឆ័យ ភិក្ខុនីសង្ឆព្រមព្រៀង គ្នា ភិក្ខុសំគាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុ សង្ឆ័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយ ប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៤] អ១ម្ម១ម្ម១ ១ម្ម១ម្ម១ញ្ញ១ សមក្ខ១ ១ិ១ម្ម-
ណ១ីសង្ឆ១ំ ១ម្ម១ញ្ញ១ ១ិ១ណ១ិ ។ ១ប ។ ១ម១ិ១ោ ១ិ១ណ១ិ
។ ១ប ។ សមម្ម១ញ្ញ១ ១ិ១ណ១ិ ១ាប១ិ ១ាចិ១ិ១ិ១ស្ស ។

[៣៥] ១ម្ម១ម្ម១ ១ម្ម១ម្ម១ញ្ញ១ ១ម្ម១ ១ិ១ម្ម១ណ១ីសង្ឆ១ំ
១ម្ម១ញ្ញ១ ១ិ១ណ១ិ ១ាប១ិ ១ុ១ម្ម១ជ១ស្ស ។ ១ម្ម១ម្ម១
១ម្ម១ម្ម១ញ្ញ១ ១ម្ម១ ១ិ១ម្ម១ណ១ីសង្ឆ១ំ ១ម១ិ១ោ ១ិ១ណ១ិ
១ាប១ិ ១ុ១ម្ម១ជ១ស្ស ។ ១ម្ម១ម្ម១ ១ម្ម១ម្ម១ញ្ញ១ ១ម្ម១
១ិ១ម្ម១ណ១ីសង្ឆ១ំ សមម្ម១ញ្ញ១ ១ិ១ណ១ិ ១ាប១ិ ១ុ១ម្ម១ជ១ស្ស ។

[៣៦] ១ម្ម១ម្ម១ ១ម១ិ១ោ ១ម្ម១ ១ិ១ម្ម១ណ១ីសង្ឆ១ំ
១ម្ម១ញ្ញ១ ១ិ១ណ១ិ ។ ១ប ។ ១ម១ិ១ោ ១ិ១ណ១ិ ។ ១ប ។
សមម្ម១ញ្ញ១ ១ិ១ណ១ិ ១ាប១ិ ១ុ១ម្ម១ជ១ស្ស ។

[៣៧] ១ម្ម១ម្ម១ ១ម្ម១ម្ម១ញ្ញ១ ១ម្ម១ ១ិ១ម្ម១ណ១ីសង្ឆ១ំ
១ម្ម១ញ្ញ១ ១ិ១ណ១ិ ។ ១ប ។ ១ម១ិ១ោ ១ិ១ណ១ិ ។ ១ប ។
សមម្ម១ញ្ញ១ ១ិ១ណ១ិ ១ាប១ិ ១ុ១ម្ម១ជ១ស្ស ។

[៣៤] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនមែនជាធម៌មែន ភិក្ខុនីសង្ឆព្រមព្រៀងគ្នា ភិក្ខុសំគាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ឆរ៉ៃយហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៥] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសង្ឆរ៉ៃយ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៣៦] កម្មជាធម៌ ភិក្ខុសង្ឆរ៉ៃយ ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ជាពួកមែន ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ឆរ៉ៃយ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៣៧] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឆបែកគ្នាជាពួក ភិក្ខុសំគាល់ថា ជាពួកមែន ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ឆរ៉ៃយ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

បាចិត្តិយកណ្ឌ ឱវាទវគ្គស្ស បឋមសិក្ខាបទស្ស អាបត្តិវារោ

[៣៨] ឆម្មកម្មេ អឆម្មកម្មសញ្ញី សមក្តំ ភិក្ខុនី-
សង្ឆំ វក្តសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ
។ បេ ។ សមក្តសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។

[៣៩] ឆម្មកម្មេ វេមតិកោ សមក្តំ ភិក្ខុនីសង្ឆំ
វក្តសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ ។ បេ ។
សមក្តសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។

[៤០] ឆម្មកម្មេ ឆម្មកម្មសញ្ញី សមក្តំ ភិក្ខុនីសង្ឆំ
វក្តសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។ ឆម្មកម្មេ
ឆម្មកម្មសញ្ញី សមក្តំ ភិក្ខុនីសង្ឆំ វេមតិកោ ឱវទតិ
អាបត្តិ ទុក្កដស្ស ។ ឆម្មកម្មេ ឆម្មកម្មសញ្ញី សមក្តំ
ភិក្ខុនីសង្ឆំ សមក្តសញ្ញី ឱវទតិ អនាបត្តិ ។

[៣៨] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនមែនជាធម៌វិញ ភិក្ខុនីសង្ឆ ព្រមព្រៀងគ្នា ភិក្ខុសំគាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៣៩] កម្មជាធម៌ ភិក្ខុមានសេចក្តីសង្ស័យ ភិក្ខុនីសង្ឆព្រមព្រៀងគ្នា ភិក្ខុសំគាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៤០] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឆព្រម-ព្រៀងគ្នា ភិក្ខុសំគាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឆព្រម-ព្រៀងគ្នា ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឆព្រមព្រៀងគ្នា ភិក្ខុសំគាល់ថា ព្រមព្រៀងគ្នាមែន ហើយប្រដៅ មិនត្រូវអាបត្តិអ្វីឡើយ ។

[៤១] អជាបត្តិ ឧទ្ទេសំ ទេន្តោ បរិបុច្ឆំ ទេន្តោ ឱសា-
រេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ បញ្ហ បុច្ឆតិ បញ្ហ
បុដ្ឋោ កថេតិ អញ្ញស្សត្ថាយ ភណន្តំ ភិក្ខុនិយោ
សុណន្តិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស
អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

[៤១] *អាបត្តិមិនមានដល់ភិក្ខុដែលសំដែងនូវបាឡី នៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលសំដែងនូវអដ្ឋកថានៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នាហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។*

សិក្ខាបទទី ១ ចប់ ។

ទុតិយសិក្ខាបទំ

[៤២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆេវ កិក្ខូ កិក្ខុនិយោ ឌ្ឍ្ឍ
ឧ្ឍ្ឍ
ឧ្ឍ្ឍ
ឧ

សិក្ខាបទទី ២

[៤២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេត-
វន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជា
ថេរៈទាំងឡាយប្រដៅពួកភិក្ខុនីដោយវេនជាលំដាប់ ១ ។ សម័យនោះឯង
ព្រះចូឡបន្ថកដ៏មានអាយុត្រូវវេនប្រដៅភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនី
និយាយគ្នាថា ថ្ងៃនេះឱវាទគង់នឹងមិនសម្រេចបរិបូណ៌ទេ លោកម្ចាស់
ចូឡបន្ថកគង់នឹងពោលនូវឧទានៗ ដដែល ១ ឥឡូវហ្នឹង ។ ភិក្ខុនី
ទាំងនោះនាំគ្នាចូលទៅរកព្រះចូឡបន្ថកដ៏មានអាយុ លុះទៅដល់ហើយ
ក៏ថ្វាយបង្គំព្រះចូឡបន្ថកដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។
ឯព្រះចូឡបន្ថកដ៏មានអាយុ បាននិយាយនឹងភិក្ខុនីទាំងនោះ ដែលអង្គុយ
នៅហើយក្នុងទីដ៏សមគួរដោយពាក្យយ៉ាងនេះថា ម្នាលនាងទាំងឡាយ
ពួកនាងព្រមព្រៀងគ្នាហើយឬ ។ ពួកភិក្ខុនីតបថា ព្រមព្រៀងគ្នា
ហើយ លោកម្ចាស់ ។ ព្រះចូឡបន្ថកសួរថា ម្នាលនាងទាំងឡាយ
គរុធម៌ ៨ ចាំស្ទាត់ហើយឬ ។ ពួកភិក្ខុនីតបថា ចាំស្ទាត់ហើយ លោក
ម្ចាស់ ។ ព្រះចូឡបន្ថកប្រាប់ថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ
ហើយបានពោលនូវឧទានៗ ដដែលថា

អនិចេតសោ អប្ប្ជ្ជតោ
មុនិនោ មោនបថេសុ សិក្ខ្ខតោ
សោកា ន ភវន្តិ តាទិនោ
ឧបសន្តស្ស សទា សតីមតោតិ ។

[៤៣] ភិក្ខ្ខុនិយោ ឯវមាហំសុ ន្ត្ជ អ្ជ្ជ ភគ្គ្ជ ន ជានិ អ្ជ ឱ្ជ ឧ ឧ ១ ១ ១

សេចក្ដីសោកទាំងឡាយ រមែងមិនមានដល់មុនីដែលមាន អធិចិត្តមិនប្រមាទ សិក្សានៅក្នុងផ្លូវនៃមានធម៌ (គឺអរហត្ត-ញាណ) មិនញាប់ញ័រ (ដោយលោកធម៌) មានចិត្តស្ងប់ (ចាកកិលេស) តែងមានស្មារតី ជានិច្ច ។

[៤៣] *ភិក្ខុនីទាំងឡាយ បាននិយាយគ្នាយ៉ាងនេះថា យើងទាំង-ឡាយបាននិយាយគ្នាទុកមកហើយថា វេលាថ្ងៃនេះឱវាទគង់នឹងមិនសម្រេចបរិបូណ៌ទេ លោកម្ចាស់ចូឡបន្ថក គង់នឹងពោលនូវឧទាននោះ ឯងដដែល ក្នុងកាលឥឡូវហ្នឹង ។ ព្រះចូឡបន្ថកដ៏មានអាយុបានស្ដាប់ពាក្យនិយាយចរចារនេះរបស់ភិក្ខុនីទាំងឡាយនោះហើយ ។ គ្រានោះ ព្រះចូឡបន្ថកដ៏មានអាយុហោះទៅកាន់វិហាសស្ថានហើយចង្ក្រមខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ បង្ហុយផ្សែងខ្លះ បញ្ចេញពន្លឺភ្លើងខ្លះ បំបាត់ខ្លួនទៅខ្លះ ហើយពោលឧទាននោះទៀតផង និងពុទ្ធវចនៈដទៃជាច្រើនផង ឲ្យដ៏អាកាសវាលទទេ ។ ភិក្ខុនីទាំងឡាយ បាននិយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើងទាំងឡាយ សេចក្ដីអស្ចារ្យ (នេះ) ចំឡែកពេកណាស់ ម្នាលគ្នាយើងទាំងឡាយ ហេតុមិនធ្លាប់កើត ។ ហើយ ឱវាទដែលសម្រេចបរិបូណ៌ ដូចជាឱវាទរបស់លោកម្ចាស់ចូឡបន្ថកយ៉ាងនេះ កាលពីដើមយើងមិនធ្លាប់បាន (ស្ដាប់) ទេ ។ លំដាប់នោះ ព្រះចូឡបន្ថកដ៏មានអាយុ*

ចូឡបន្តកោ តា ភិក្ខុនិយោ យាវ សមន្ធការា ឱវ-
ជិត្វា ឧយ្យោជេសិ ឥច្ឆថ ភគិនិយោតិ ។ អថខោ
តា ភិក្ខុនិយោ ឧតរន្ធារេ ថក្ខិតេ ពហិឧតរេ រសិត្វា
ការាលស្សេ ឧតរំ បរិសន្តិ ។ មនុស្សា ឧជ្ឈាយន្តិ
ខីយន្តិ វិចារេន្តិ អព្រហ្មចារិនិយោ ឥមា ភិក្ខុនិយោ
អារាមេ ភិក្ខូហិ សទ្ធឹ រសិត្វា ឥទានិ ឧតរំ បរិ-
សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ
ឧជ្ឈាយន្តានំ ខីយន្តានំ វិចារេន្តានំ ។ យេ តេ ភិក្ខូ
អប្ឋិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ
កថំ ហិ នាម អាយស្មា ចូឡបន្តកោ អត្តច្ឆតេ
សុរិយេ ភិក្ខុនិយោ ឱវទិស្សតីតិ ។ បេ ។ សច្ចំ
ការ ត្វំ ចូឡបន្តក អត្តច្ឆតេ សុរិយេ ភិក្ខុនិយោ
ឱវទសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម ត្វំ ចូឡបន្តក
អត្តច្ឆតេ សុរិយេ ភិក្ខុនិយោ ឱវទិស្សសិ ឦតំ
ចូឡបន្តក អប្ឋសន្ថានំ វា បសាទាយ ។ បេ ។

ប្រដៅភិក្ខុនីអម្ចាលនោះដរាបដល់យប់ ហើយបញ្ជូនទៅវិញថា ម្នាលនាងទាំងឡាយ ពួកនាងចូរទៅចុះ ។ វេលានោះទ្វារនគរគេបិទហើយ ភិក្ខុនីទាំងនោះ ក៏នៅខាងក្រៅនគរ លុះព្រឹកឡើងទើបចូលទៅកាន់នគរ ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុនីទាំងឡាយនេះ មិនមែនជាព្រហ្មចារិនី (មិនមែនជាអ្នកប្រព្រឹត្តល្អ) ទេ នៅជាមួយនឹងភិក្ខុទាំងឡាយក្នុងអាវាសហើយ ទើបតែចូលមកកាន់នគរក្នុងកាលឥឡូវនេះ ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សអម្ចាលនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ចូឡ-បន្ថក:ដ៏មានអាយុ កាលព្រះអាទិត្យអស្តង្គតហើយ មិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ ។ បេ ។ ព្រះដ៏មានព្រះភាគ ត្រាស់សួរថា ម្នាលចូឡបន្ថក: ឮថាកាលព្រះអាទិត្យអស្តង្គតហើយ អ្នកឯងទៅប្រដៅ ភិក្ខុនីទាំងឡាយ ពិតមែនឬ ។ ព្រះចូឡបន្ថក:ដ៏មានអាយុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលចូឡបន្ថក: កាលព្រះអាទិត្យអស្តង្គតទៅហើយ អ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ ម្នាលចូឡបន្ថក: អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។

ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សម្ឆតោបិ ខេ ភិក្ខុ អត្ថជ្ជតេ សុរិយេ ភិក្ខុនិយោ ឱវទេយ្យ ចាចិត្តិយន្តិ ។

[៤៤] សម្ឆតោ ជាម ញត្តិចតុត្ថេន ភាម្ហេ សម្ឆតោ ។ អត្ថជ្ជតេ សុរិយេតិ ឧភតេ សុរិយេ ។ ភិក្ខុនិយោ ជាម ឧភតោសង្ឆេ ឧបសម្ប្ជន្ន ។ ឱវ-ទេយ្យាតិ អដ្ឋហិ ភ ភរុ ធម្ហេហិ អញ្ញេ ភ ធម្ហេ ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។

[៤៥] អត្ថជ្ជតេ អត្ថជ្ជតសញ្ញ ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។ អត្ថជ្ជតេ ១ម្ហតិ ភោ ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។ អត្ថជ្ជតេ អនត្ថជ្ជតសញ្ញ ឱវទតិ អាបត្តិ ចាចិត្តិយស្ស ។ ឯ ភ ភោ ឧបសម្ប្ជន្ន[1] ឱវទតិ អាបត្តិ ទុក្ខ ជស្ស ។ អនត្ថជ្ជតេ អត្ថជ្ជតសញ្ញ អាបត្តិ ទុក្ខ ជស្ស ។ អនត្ថជ្ជតេ ១ម្ហតិ ភោ អាបត្តិ ទុក្ខ-ជស្ស ។ អនត្ថជ្ជតេ អនត្ថជ្ជតសញ្ញ អ ១ ១ ។

---

1 ១ យេ ១ ១ ១

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុបើទុកជាសង្ឆ បានសន្ទតហើយ កាលបើព្រះអាទិត្យ អស្តង្គតហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។

[៤៤] ដែលហៅថា សង្ឆបានសន្ទតនោះ គឺសង្ឆសន្ទតដោយ ញត្តិចតុត្ថកម្មវាចា ។ ត្រង់ពាក្យថា ព្រះអាទិត្យអស្តង្គតហើយ សេចក្តីថា ព្រះអាទិត្យលិចចុះហើយ ។ ពួកស្រីដែលបានឧបសម្បទាក្នុងជំនុំសង្ឆ ពីរចំណែក ហៅថា ភិក្ខុនី ។ ពាក្យថា ប្រដៅ សេចក្តីថា ភិក្ខុប្រដៅ ភិក្ខុនីដោយគរុធម៌ ៨ ក្តី ដោយធម៌ដទៃក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៤៥] ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសំគាល់ថា អស្តង្គតមែន ហើយទៅប្រដៅ (ភិក្ខុនី) ត្រូវអាបត្តិបាចិត្តិយ ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះ អាទិត្យអស្តង្គតហើយ ភិក្ខុសំគាល់ថា មិនទាន់អស្តង្គត ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រដៅភិក្ខុនីដែលឧបសម្បទាហើយក្នុងជំនុំ សង្ឆមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុ សំគាល់ថា អស្តង្គតហើយ ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុសំគាល់ថា មិនទាន់អស្តង្គត មិនត្រូវអាបត្តិអ្វីឡើយ ។

បាចិត្តិយកណ្ឌោ ឱវាទវគ្គស្ស ទុតិយសិក្ខាបទស្ស អនាបត្តិ

[៤៦] អនាបត្តិ ឧទ្ទេសំ ទេន្តោ បរិបុច្ឆំ ទេន្តោ ឱសារេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ បញ្ហេ បុច្ឆតិ បញ្ហេ បុដ្ឋោ កថេតិ អញ្ញស្សត្ថាយ ភណន្តំ ភិក្ខុនិយោ សុណន្តិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

[*៤៦*] *អាបត្តិមិនមាន ដល់ភិក្ខុដែលសំដែងនូវបាលី នៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលសំដែងនូវអដ្ឋកថានៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នាហើយនៅ្ធយដោះ ដល់ភិក្ខុដែលសំដែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។*

សិក្ខាបទទី ២ ចប់ ។

ततियसिक្ខាបទំ

[៤៧] តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតি កបិលវត្ថុស្មឿ និគ្រោធារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនូបស្សយំ ឧបសង្ក-មិត្វា ឆព្ពគ្គិយា ភិក្ខុនិយោ ឱវទន្តি ។ ភិក្ខុនិយោ ឆព្ពគ្គិយា ភិក្ខុនិយោ ឯតទវោចុំ ឯថ អយ្យេ ឱវាទំ ករិស្សាមាតি ។ យម្ហិ[1] មយំ អយ្យេ ករេយ្យាម ឱវាទស្ស ការណា អយ្យា ឆព្ពគ្គិយា ឥមេ អម្ហេ ឱវទន្តីតি ។ ភិក្ខុនិយោ ឧជ្ឈាយន្តি ខីយន្តি វិចារេន្តি ករំ ហি នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនូបស្សយំ ឧបសង្ក្រមិត្វា ភិក្ខុនិយោ ឱវទន្តីតি ។ អថ ខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្ឆិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តি ខីយន្តি វិចារេន្តি ករំ ហি នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនូបស្សយំ ឧបសង្ក្រមិត្វា ភិក្ខុនិយោ ឱវទន្តីតি ។ បេ ។ សច្ចំ किर

---

1 ឱ. ម. យំ ហি ។

សិក្ខាបទទី ៣

[៤៧] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅនិគ្រោ-ធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនឈ្មោះសក្ក: ។ គ្រានោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ចូលទៅកាន់លំនៅរបស់ភិក្ខុនី ហើយប្រដៅឆព្ព-គ្គិយភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយបាននិយាយបបួលឆព្វគ្គិយភិក្ខុនី យ៉ាងនេះថា ម្នាលនាងទាំងឡាយ ពួកនាងចូរមក យើងនឹងទៅទទួលឱវាទ (ជាមួយគ្នា) ។ ឆព្វគ្គិយភិក្ខុនីនិយាយថា ម្នាលនាងទាំងឡាយ យើងទាំងឡាយ នាំគ្នាទៅព្រោះហេតុនៃឱវាទធ្វើអ្វី ដ្បិតឆព្វគ្គិយភិក្ខុជាម្ចាស់ទាំងឡាយមកប្រដៅពួកយើងក្នុងលំនៅនេះហើយ ។ ភិក្ខុនីទាំង-ឡាយនាំគ្នាពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងចូលដល់លំនៅភិក្ខុនីហើយ ប្រដៅភិក្ខុនីទាំងឡាយទេ ។ លំដាប់នោះ ភិក្ខុនីអម្ចាលនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ ណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនី ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ

តុម្ហេ ភិក្ខវេ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទថាតិ ។ សចេ ភគវាតិ ។ រ៉ាសហិ ពុទ្ធោ ភគវា ភិក្ខុ ហិ ជាម តុម្ហេ មោឃបុរិសា ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទិស្សថ នេតំ មោឃបុរិ-សា អប្បសន្នានំ វ ប្បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទេយ្យ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៨] តេន ខោ បន សមយេន មហាបជាបតិ គោតមី តិណ្ណាជ ហោតិ ។ ថេវ ភិក្ខូ យេន មហាបជាបតិ គោតមី តេនុបសង្កមីសុ ឧបសង្កមិត្វា មហាបជាបតឹ គោតមឹ ឯតទវោចុំ ១ ១ ១

ប្រដៅភិក្ខុនីទាំងឡាយ ចូលដល់លំនៅភិក្ខុនី ពិតមែនឬ ។ ពួកឆព្វគ្គិយ-ភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយ ចូលដល់លំនៅភិក្ខុនីទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីទាំងឡាយ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទនេះ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៤៨] សម័យនោះឯង ព្រះមហាបជាបតិគោតមីភិក្ខុនី មានជំងឺ ។ ភិក្ខុជាថេរៈទាំងឡាយ ចូលទៅកាន់លំនៅព្រះមហាបជាបតិគោតមីភិក្ខុនីលុះចូលទៅដល់ហើយ បាននិយាយសួរព្រះមហាបជាបតិគោតមីភិក្ខុនីយ៉ាងនេះថា ម្នាលព្រះនាងគោតមី សរីរយន្តព្រះនាងល្មមអត់ទ្រាំបានដែរឬទេ ល្មមប្រព្រឹត្តទៅបានស្រួលដែរឬទេ ។ ព្រះមហាបជាបតិគោតមីភិក្ខុនីតបថា លោកម្ចាស់ សរីរយន្តខ្ញុំមិនអាចអត់ទ្រាំបានទេ ខ្ញុំមិនអាច

ខមនីយំ ន យាបនីយំ ឥច្ឆ្យា ឆម្ំ ឧេសេថាតិ ។ ន តាវ ភតិនិ ភាកប្ផតិ ភិក្ខុនូបស្ឃយំ ឧបសង្ក្រមិត្វា ភិក្ខុនិយា ឆម្ំ ឧេសេតុន្តិ ការ្ក្ចាយន្ត ន ឧេសេ-សុំ ។ អថខោ ភតវា បុព្ពណ្ហាសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មហាបជាបតិ គោតមី តេ-ឧុបសង្ក្រមិ ឧបសង្ក្រមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និ-សជ្ជ ខោ ភតវា មហាបជាបតឹ គោតមឹ ឯតទវោច ការ្ចិ តេ គោតមិ ខមនីយំ ការ្ចិ យាបនីយន្តិ ។ បុព្ពេ មេ ភន្តេ ថេរា ភិក្ខូ អាតន្ត្ម ឆម្ំ ឧេសេន្តិ តេន មេ ជាសុ ហោតិ ឥទានិ បន ភតវតា បដិក្ខិត្តន្តិ ការ្ក្ចាយន្ត ន ឧេសេន្តិ តេន មេ ន ជាសុ ហោតីតិ ។ អថខោ ភតវា មហាបជាបតឹ គោតមឹ ឆម្ិយា ការ្ចាយ សន្ទស្ឃ្ត្វា សមាទបេត្វា សមុត្តេ-ជេត្វា សម្ឃហំសេត្វា ឧដ្ឋាយាសនា បការ្ក្ចាមិ ។

ប្រព្រឹត្តទៅបានស្រួលទេ បពិត្រលោកម្ចាស់ទាំងឡាយ ណ្ហើយចុះ សូមពួកលោកម្ចាស់សំដែងធម៌ឲ្យទាន ។ ភិក្ខុទាំងនោះ និយាយថា ម្នាលនាង កិរិយាដែលភិក្ខុចូលមកកាន់លំនៅរបស់ភិក្ខុនី ហើយសំដែងធម៌ដល់ភិក្ខុនី មិនគួរឡើយ ហើយមានសេចក្តីសង្ស័យ (យ៉ាងនេះ) ក៏មិនហ៊ានសំដែងធម៌ឡើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បៃកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរ ក្នុងវេលាព្រឹក ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់ព្រះមហាបជាបតិគោតមី លុះដល់ហើយទ្រង់គង់លើអាសនៈដែលតែងតាំងទុក ។ ព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ទ្រង់ត្រាស់សួរព្រះមហាបជាបតិគោតមីយ៉ាងនេះថា ព្រះនាងគោតមី សរីរយន្ត ព្រះនាងល្មមអត់ទ្រាំបានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានស្រួលដែរឬ ។ ព្រះនាងទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលមុនភិក្ខុជាថេរៈទាំងឡាយ មកសំដែងធម៌ដល់ខ្ញុំព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គមានសេចក្តីសប្បាយ ក៏ឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ហាមឃាត់ហើយ ព្រោះហេតុនោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្តីខ្ជាចក្រែង ទើបមិនហ៊ានសំដែង សេចក្តីមិនសប្បាយមានដល់ខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះមហាបជាបតិគោតមីឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីក-រាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បការណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា តិណានំ ភិក្ខុនឹ ឱវទិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧद्दិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទេយ្យ អញ្ញត្រ សមយា ចាចិត្តិយំ តត្ថាយំ សមយោ តិណានា ហោតិ ភិក្ខុនី អយំ តត្ត សមយោតិ ។

[៤៩] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុនូបស្សយោ[1] នាម យត្ត ភិក្ខុនិយោ ឯការត្តម្បិ វសន្តិ ។ ឧបសង្កមិត្វាតិ តត្ត គន្ត្វា ។ ភិក្ខុនិយោ នាម ឧភតោសង្ឆេ ឧបសម្បន្នា ។ ឱវ-ទេយ្យាតិ អដ្ឋហិ ករុណម្ទេហិ ឱវទតិ អាបត្តិ ចាចិត្តិ-យស្ស ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ តិណានា នាម ភិក្ខុនី ន សក្ខោតិ ឱវាទាយ វា សំវាសាយ វា គន្តុំ ។

1 ភិក្ខុនូបស្សយន្តិបិ បាឋো ។

ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីដែលមានជំងឺ បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទ នេះយ៉ាងនេះថា ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ឯសម័យក្នុង សិក្ខាបទនោះ គឺភិក្ខុនីមានជំងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[៤៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នា ក្នុងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុនីទាំងឡាយនៅក្នុងទីណា សូម្បីអស់រាត្រី ១ ទីនោះហៅថា ទីនៅរបស់ភិក្ខុនី ។ ពាក្យថា ចូលដល់ គឺទៅក្នុងទីនោះ ។ ពួកស្ត្រីដែលបានឧបសម្បទា ក្នុងសង្ឆពីរចំណែក ហៅថា ភិក្ខុនី ។ ពាក្យថា ប្រដៅ គឺភិក្ខុប្រដៅដោយគរុធម៌ ៨ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា រៀរលែងតែមានសម័យ គឺលើកលែងតែមានសម័យ ។ ភិក្ខុនីមិនអាចទៅទទួលឱវាទ ឬទៅនៅរួមសង្ឆកម្មបានហៅថា មានជំងឺ ។

[៤០] ឧបសម្បន្នាយ ឧបសម្បន្នសញ្ញី ភិក្ខុនូប-
ស្សយំ ឧបសង្កមិត្វា អញ្ញត្រ សមយា ឱវទតិ អាបត្តិ
ចាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកោ ភិក្ខុនូបស្ស-
យំ ឧបសង្កមិត្វា អញ្ញត្រ សមយា ឱវទតិ អាបត្តិ
ចាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញី
ភិក្ខុនូបស្សយំ ឧបសង្កមិត្វា អញ្ញត្រ សមយា ឱវទតិ
អាបត្តិ ចាចិត្តិយស្ស ។ អញ្ញេន ឆម្មេន ឱវទតិ អាបត្តិ
ទុក្កដស្ស ។ ឯកតោ ឧបសម្បន្នំ ឱវទតិ អាបត្តិ
ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញី
អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកោ
អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្ន-
សញ្ញី អនាបត្តិ ។

[៥០] ភិក្ខុសំគាល់ភិក្ខុនីដែលបានឧបសម្បទាហើយថា បានឧប-
សម្បទាមែន ហើយចូលទៅដល់លំនៅរបស់ភិក្ខុនីហើយប្រដៅ ត្រូវអាបត្តិ
បាចិត្តិយ រៀងលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងភិក្ខុនីដែលបាន
ឧបសម្បទាហើយ ចូលទៅដល់លំនៅរបស់ភិក្ខុនីហើយប្រដៅ ត្រូវអាបត្តិ
បាចិត្តិយ រៀងលែងតែមានសម័យ ។ ភិក្ខុនីឧបសម្បទាហើយ ភិក្ខុសំគាល់
ថា មិនទាន់បានឧបសម្បទាទេ ហើយចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយ
ប្រដៅ ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ ភិក្ខុប្រដៅភិក្ខុនី
ដោយធម៌ដទៃ (ក្រៅពីគរុធម៌) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រដៅភិក្ខុនីដែលបាន
ឧបសម្បទាក្នុងសង្ឆតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុង
ស្រីមិនទាន់បានឧសម្បទាថា បានឧបសម្បទាហើយ ត្រូវអាបត្តិទុក្កដ ។
ភិក្ខុសង្ស័យក្នុងស្រីដែលមិនទាន់បានឧបសម្បទា ត្រូវអាបត្តិទុក្កដ ។
ភិក្ខុសំគាល់ក្នុងស្រីដែលមិនទាន់បានឧបសម្បទាថា មិនទាន់បានឧបសម្បទា
មែន មិនត្រូវអាបត្តិអ្វីឡើយ ។

បាចិត្តិយកណ្ឌ ឱវាទវគ្គស្ស តតិយសិក្ខាបទស្ស អនាបត្តិវារោ

[៤១] អនាបត្តិ សមយេ ឧទ្ធេសំ ទេន្តោ បរិបុច្ឆំ ទេន្តោ ឋិសារេហិ អយ្យាតិ រុច្ចមានោ ឋិសារេតិ បញ្ហ បុច្ឆតិ បញ្ហ បុដ្ឋោ កថេតិ អញ្ញស្ស្ត្ថាយ ភណ្ឌំ ភិក្ខុនិយោ សុណន្តិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្ស្ត្ថាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

[៥១] *អាបត្តិមិនមាន ដល់ភិក្ខុដែលប្រដៅភិក្ខុនីក្នុងសម័យ ដល់ភិក្ខុដែលសំដែងបាឡីនៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលសំដែងអដ្ឋកថានៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នាហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ដើម្បីអ្នកដទៃហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុដែលប្រដៅធម៌ដល់សិក្ខ-មានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។*

សិក្ខាបទទី ៣ ចប់ ។

ចតុត្ថសិក្ខាបទំ

[៤២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តា លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលាន-ប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឆព្ពគ្គិយា ភិក្ខូ ឯវំ វទេន្តិ[1] ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទិតុំ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ ។ យេ តេ ភិក្ខូ អប្ឌិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ឯវំ វក្ខន្តិ ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទិតុំ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឯវំ វទេថ ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនि-យោ ឱវទិតុំ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ

---

1 ឱ. ម. វទន្តិ ។

សិក្ខាបទទី ៤

[៥២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី តែងបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេ-សជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ។ ពួកឆព្វគ្គិយភិក្ខុ និយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ថ្វីឡើយ ពួកឆព្វគ្គិយភិក្ខុមកនិយាយយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវយកចិត្តទុកដាក់នឹងប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ។ បេ ។ ព្រះដ៏មានព្រះភាគ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយនិយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំង-ឡាយមិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីប៉ុន្ម្មានទេ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ពិតមែនឬ ។

ឱវនន្តីតិ ។ សចេ ភគវាតិ ។ វិតរហិ ពុទ្ធោ ភគវា
ភគវំ ហិ ជាម តុម្ហេ មោឃបុរិសា ឯវំ វក្ខថ
ន ពហុកតា ថេរ ភិក្ខូ ភិក្ខុនិយោ ឱវទិតុំ
អាមិសហេតុ ថេរ ភិក្ខូ ភិក្ខុនិយោ ឱវនន្តីតិ ឆេតំ
មោឃបុរិសា អប្ប្ សន្ធានំ វ បសាទាយ ។ បេ ។
ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ
យោ បន ភិក្ខុ ឯវំ វទេយ្យ អាមិសហេតុ ភិក្ខូ
ភិក្ខុនិយោ ឱវនន្តីតិ ចាចិត្តិយន្តិ ។

[៤៣] យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ប្ បេតោ ភិក្ខូតិ ។
អាមិសហេតូតិ ចីវរហេតុ បិណ្ឌចាតហេតុ សេនាសន-
ហេតុ ឥលានប្ប ច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ
ឥរុការហេតុ មានន ហេតុ វន្ទន ហេតុ ឬជន ហេតុ ។

[៤៤] ឯវំ វទេយ្យាតិ ឧបសម្ប ន្ទ ំ សជ្ជេន សម្ម ន ំ
ភិក្ខុ ដោ ១ ១ ១

ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ក៏ចុះ ឡើយ ពួកអ្នកឯងមកពោលយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវ យកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយ ប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស នែមោឃបុរសទាំងឡាយ អំពើ ដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់បុគ្គលទាំងឡាយដែលមិន ទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែង ឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ពោលយ៉ាងនេះថា ភិក្ខុ ទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ត្រូវអាបត្តិបាចិត្តិយ ។

[៥៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នា ក្នុងសិក្ខា-បទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ព្រោះហេតុតែអាមិស សេចក្ដីថា ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យ ដល់ មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា ។

[៥៤] ពាក្យថា ពោលយ៉ាងនេះ សេចក្ដីថា ភិក្ខុណាប្រាថ្នា ដើម្បីនឹងធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីនឹងធ្វើបង្ហាប់យស ប្រាថ្នា ដើម្បីនឹងធ្វើនូវសេចក្ដីបង្ហាប់បង្អោន ចំពោះឧបសម្បន្នដែលសង្ឃសន្ធត

បិណ្ឌាចាតហេតុ សេនាសនហេតុ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារហេតុ សក្ការហេតុ ឥរិយាបថហេតុ មានន-ហេតុ វណ្ណហេតុ ឧជ្ជនហេតុ ឧវនតីតិ ឧណ្ណាតិ អាបត្តិ ចាចិត្តិយស្ស ។

[៤៥] ធម្មកម្មេ ធម្មកម្មសញ្ញី ឯវំ វទេតិ អាបត្តិ ចាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ឯវំ វទេតិ អាបត្តិ ចាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ឯវំ វទេតិ អាបត្តិ ចាចិត្តិយស្ស ។

[៤៦] ឧបសម្បន្នំ សង្ឆេ អសម្មតំ ភិក្ខុនោ-ភាគកំ អវណ្ណំ ភាសតិ អយសំ ភាសតិ មច្ឆ្លេ ភាសតិ ឯវំ វទេតិ ចីវរហេតុ បិណ្ឌាចាតហេតុ សេនាសនហេតុ គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ ឥរិយាបថហេតុ មានន-ហេតុ វណ្ណហេតុ ឧជ្ជនហេតុ ឧវនតីតិ ឧណ្ណាតិ អាបត្តិ ទុក្កដស្ស ។

[៤៧] អនុបសម្បន្នំ សង្ឆេ សម្មតំ វា អសម្ម-តំ វា ភិក្ខុនោភាគកំ អវណ្ណំ ភាសតិ អយសំ ភាសតិ មច្ឆ្លេ ភាសតិ ឯវំ វទេតិ ចីវរហេតុ

ឲ្យជាអ្នកប្រដៅភិក្ខុនីហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៥៥] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌មែន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនមែនជាធម៌វិញ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។

[៥៦] ភិក្ខុណា ប្រាថ្នាដើម្បីធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីធ្វើបង្ខាំងយស ប្រាថ្នាដើម្បីធ្វើនូវសេចក្ដីបង្ខាំងបង្ហោន ចំពោះឧបសម្បន្នដែលសង្ឆមិនបានសន្ទតឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជ-បរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។

[៥៧] ភិក្ខុណា ប្រាថ្នាដើម្បីធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីធ្វើបង្ខាំងយស ប្រាថ្នាដើម្បីធ្វើនូវសេចក្ដីបង្ខាំងបង្ហោន ចំពោះអនុបសម្បន្ន-បុគ្គលដែលសង្ឆសន្ទតក្ដី មិនបានសន្ទតក្ដី ឲ្យជាអ្នកប្រដៅភិក្ខុនី

បិណ្ឌាចាតហេតុ សេនាសនហេតុ តិលានប្បច្ចយភេ-
សជ្ជបរិក្ខារហេតុ សក្ការហេតុ ឥរុការហេតុ មានន-
ហេតុ វណ្ណហេតុ ឧជ្ជនហេតុ ឱវទតីតិ ភណ្ឌតិ
អាបត្តិ ទុក្កដស្ស ។

[៤៨] អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្ក-
ដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។
អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៤៩] អនាបត្តិ បកតិយា ចីវរហេតុ បិណ្ឌាចាត-
ហេតុ សេនាសនហេតុ តិលានប្បច្ចយភេសជ្ជបរិក្ខារ-
ហេតុ សក្ការហេតុ ឥរុការហេតុ មានណហេតុ វណ្ណ-
ហេតុ ឧជ្ជនហេតុ ឱវទន្តំ ភណ្ឌតិ ឧម្មត្តកស្ស
អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

ហើយពោលយ៉ាងនេះ គឺពោលថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។

[៥៨] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនមែនជាធម៌ ត្រូវអាបត្តិទុក្កដ ។

[៥៩] អាបត្តិមិនមាន ដល់ភិក្ខុដែលពោលចំពោះភិក្ខុផងគ្នា ដែលជាអ្នកប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជ-បរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជាដោយប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

បញ្ចមសិក្ខាបទំ

[៦០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ អញ្ញ-តរិស្សា រិសិទាយ បិណ្ឌាយ ចរតិ ។ អញ្ញតរាបិ ភិក្ខុនី តស្សា រិសិទាយ បិណ្ឌាយ ចរតិ ។ អថ ខោ សោ ភិក្ខុ តំ ភិក្ខុនឹ ឯតទវោច តច្ឆ ភគិនិ អមុកស្មឹ ឋិកាសេ ភិក្ខា ឌីយតីតិ ។ សាបិ ឯវមាហ តច្ឆ អយ្យ អមុកស្មឹ ឋិកាសេ ភិក្ខា ឌីយតីតិ ។ តេ អភិណ្ហាទស្សនេន សន្ធិដ្ឋា អហេសុំ ។ តេន ខោ បន សមយេន សជ្ជ្ស្ស ចីវរំ ភាជ៎យតិ ។ អថ ខោ សា ភិក្ខុនី ឋ៎ានំ គន្ត្វា យេន សោ ភិក្ខុ តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ តំ ភិក្ខុនឹ សោ ភិក្ខុ ឯតទវោច អយំ មេ ភគិនិ ចីវរប្ឌ៎ជ៎ិ សោ សាឌ៎ិយ៎ិ ស្ស៎ សីតិ ។ អាម អយ្យ

សិក្ខាបទទី ៥

[៦០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយ រូបត្រាច់ទៅបិណ្ឌបាត តាមផ្លូវ ឬច្រកមួយ ក្នុងក្រុងសាវត្ថី ។ មានភិក្ខុនី មួយរូបទៀត ក៏ត្រាច់ទៅបិណ្ឌបាតតាមផ្លូវ ឬច្រកនោះដែរ ។ ទើបភិក្ខុនោះ និយាយនឹងភិក្ខុនីនោះយ៉ាងនេះថា ម្នាលនាង នាងចូរទៅក្នុងឱកាស ឯណោះ គេប្រគេនភិក្ខា ។ ឯភិក្ខុនីនោះ ក៏និយាយយ៉ាងនេះថា បពិត្រ លោកម្ចាស់ លោកម្ចាស់ចូរទៅក្នុងឱកាសឯណោះចុះ គេប្រគេនចង្ហាន់ ។ ភិក្ខុនិងភិក្ខុនីនោះបានស្គាល់គ្នា ព្រោះបានឃើញគ្នាញឹកញយ ។ គ្រា នោះឯង សង្ឆ្យកំពុងចែកចីវរគ្នា ។ លំដាប់នោះ ភិក្ខុនីនោះកាលទៅទទួល ឱវាទ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយថ្វាយបង្គំភិក្ខុនោះហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ ភិក្ខុនោះ បាននិយាយនឹងភិក្ខុនីដែលឋិត នៅក្នុងទីដ៏សមគួរនោះយ៉ាងនេះថា ម្នាលនាង ចំណែកចីវរនេះរបស់យើង នាងនឹងត្រូវការដែរឬទេ ។ ភិក្ខុនីនោះធ្វើយថា ករុណាលោកម្ចាស់

ឧព្ភលចីវរម្ហីតិ ។ អថខោ សោ ភិក្ខុ តស្សា ភិក្ខុនិយា
ចីវរំ អជាសិ ។ សោបិ ខោ ភិក្ខុ ឧព្ភលចីវរោ ហោតិ ។
ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ ឥមេ ហិ ជានិ តេ អាវុសោ
ចីវរន្តិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោ-
ចេសិ ។ យេ តេ ភិក្ខូ អប្ប្ឯិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ភិក្ខុ ភិក្ខុ-
និយា ចីវរំ ឧស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ ភិក្ខុ-
និយា ចីវរំ អជាសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា
តេ ភិក្ខុ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។
អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ
បដិរូបំ វា អប្ប្ដិរូបំ វា សន្តំ វា អសន្តំ វា ឥមេ
ហិ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា
ចីវរំ ឧស្ស្ជិ ដេតំ មោឃបុរិស អប្ប្ដិសន្ថានំ វា
ឧបសាទាយ ។ បេ ។ ឯវញ្ច ឧត ភិក្ខវេ ឥមំ សិក្ខា-
បទំ ឧទ្ទិសេយ្យាថ យោ ឧត ភិក្ខុ អញ្ញាតិកាយ

ខ្ញុំកវុណា មានចីវរចាស់ហើយ ។ ភិក្ខុនោះឲ្យចីវរដល់ភិក្ខុនីនោះ ។ ចំណែកភិក្ខុនោះ ជាអ្នកមានចីវរទុព្វលភាព ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរធ្វើចីវររបស់អ្នកក្នុងកាលឥឡូវនេះចុះ ។ ភិក្ខុនោះប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុមិនសមគួរនឹងឲ្យចីវរដល់ភិក្ខុនីទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងបានឲ្យចីវរដល់ភិក្ខុនី ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលតបថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ភិក្ខុនីនោះ ជាញាតិរបស់អ្នកឯង ឬមិនមែនញាតិទេ ។ ភិក្ខុនោះទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនីនោះមិនជាញាតិទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរស ប្រុសមិនមែនជាញាតិ រមែងមិនដឹងនូវកម្មដ៏សមគួរ ឬមិនសមគួរ ល្អិតល្អ ឬមិនល្អិតល្អរបស់ស្ត្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនគួរនឹងឲ្យចីវរដល់ភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យចីវរ

ភិក្ខុនិយា ចីវរំ ឧនេយ្យ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៦១] តេន ខោ បន សមយេន ភិក្ខូ ការុញ្ញតា-យន្តា ភិក្ខុនីនំ ចារិត្តកំ ចីវរំ ន ទេន្តិ ។ ភិក្ខុនិយោ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ការណំ ហិ នាម អយ្យា អម្ហាកំ ចារិត្តកំ ចីវរំ ន ឧស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តាសំ ភិក្ខុនីនំ ឧជ្ឈាយន្តីនំ ខីយន្តីនំ វិចារេន្តីនំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បការណេ ធម្មឹ ការណំ ការ្យា ភិក្ខូ អាមន្តេសិ អនុ-ជានামិ ភិក្ខវេ បញ្ចន្នំ ចារិត្តកំ ទាតុំ ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស សាមណេ-រិយា អនុជានামិ ភិក្ខវេ ឥមេសំ បញ្ចន្នំ ចារិត្តកំ ទាតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិការយ ភិក្ខុនិយា ចីវរំ ឧនេយ្យ អញ្ញត្រ ចារិត្តកា ចាចិត្តិយន្តិ ។

ដល់ភិក្ខុនីដែលមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៦១] សម័យនោះឯង ភិក្ខុទាំងឡាយសង្ឃរ៉ាយមិនហ៊ានផ្ទាស់ប្តូរចីវរនឹងភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីនាំគ្នា ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា លោកម្ចាស់ទាំងឡាយមិនសមបីនឹងមិនហ៊ានផ្ទាស់ប្តូរចីវរនឹងពួកយើងសោះ ។ ភិក្ខុទាំងឡាយបានឮពួកភិក្ខុនីនោះ ពោលទោស តិះដៀលបន្ទុះបង្ហាប់ហើយ ។ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថាហើយ ទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្ទាស់ប្តូរចីវរនឹងសហធម្មិកទាំង ៥ គឺ ភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្ទាស់ប្តូរចីវរនឹងសហធម្មិកទាំង ៥ នេះបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ លើកតែផ្ទាស់ប្តូរគ្នា ។

បាចិត្តិយកណ្ឌ ឱវាទវគ្គស្ស បញ្ចមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

[៦២] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុតា អសម្ពន្ធា[1] ។ ភិក្ខុនី នាម ឧភតោសង្ឆេ ឧបសម្បន្នា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ[2] ។ អញ្ញត្រ ចារិវដ្ដកាតិ បហេត្វា ចារិវដ្ដកំ ឧតិ អាបត្តិ ចាចិត្តិយស្ស ។

[៦៣] អញ្ញាតិកាយ អញ្ញាតិកសញ្ញី ចីវរំ ឧតិ អញ្ញត្រ ចារិវដ្ដកា អាបត្តិ ចាចិត្តិយស្ស ។ អញ្ញាតិ-កាយ វេមតិកោ ចីវរំ ឧតិ អញ្ញត្រ ចារិវដ្ដកា អាបត្តិ ចាចិត្តិយស្ស ។ អញ្ញាតិកាយ ញាតិកសញ្ញី ចីវរំ ឧតិ អញ្ញត្រ ចារិវដ្ដកា អាបត្តិ ចាចិត្តិយស្ស ។ ឯកតោ ឧបសម្បន្នាយ ចីវរំ ឧតិ អញ្ញត្រ ចារិវដ្ដកា អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី

---

១ អសម្ពន្ធាតិបិ បាឬ ទិស្សតិ ។ ២ ឌ. វិកប្បនុបគបច្ឆិមំ ។

[៦២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទ ១ នៃបាវាជិកកណ្ឌ ។ ភិក្ខុនីដែលមិនបានសម្ពន្ធជាប់រវាងគ្នាមកអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគូនៃជីដូនជីតាជាគរប់ ៧ ហៅថា មិនមែនជាញាតិ ។ ស្រីដែលបានឧបសម្បទាហើយក្នុងសង្ឆពីរចំណែក ហៅថា ភិក្ខុនី ។ បណ្តាចីវរ ៦ យ៉ាងចីវរណាមួយ យ៉ាងតូចបំផុតដ៏គួរដល់រិកប្ប៉ាបាន ហៅថា ចីវរ ។ ពាក្យថា រៀរលែងតែផ្ទាស់ប្តូរគ្នា សេចក្តីថា ភិក្ខុឲ្យ (ចីវរដល់ភិក្ខុនីមិនមែនញាតិ) ត្រូវអាបត្តិបាចិត្តិយ លើកលែងតែផ្ទាស់ប្តូរគ្នា ។

[៦៣] ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែផ្ទាស់ប្តូរគ្នា ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែផ្ទាស់ប្តូរគ្នា ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែផ្ទាស់ប្តូរគ្នា ។ ភិក្ខុឲ្យចីវរដល់ភិក្ខុនីដែលបានឧបសម្បទាអំពីសង្ឆមួយចំណែក ត្រូវអាបត្តិទុក្កដ រៀរលែងតែផ្ទាស់ប្តូរគ្នា ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិ

អាបត្តិ ឧក្កេ្ខ ។ ញាតិកាយ ឯមតិកោ អាបត្តិ ឧក្កេ្ខ ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។

[៦៤] អនាបត្តិ ញាតិកាយ ចារិត្តកំ បរិត្តេន វ វិបុលំ វិបុលេន វ បរិត្តំ ភិក្ខុនី វិស្ស្ជ្ជ តណ្ហាតិ តាវកាលិកំ តណ្ហាតិ ចីវរំ បមេត្វា អញ្ញ បរិក្ខារំ ទេតិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្ស្ជ្ជាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិអ្វីឡើយ ។

[៦៤] អាបត្តិមិនមាន ដល់ភិក្ខុដែលឲ្យចីវរដល់ភិក្ខុនីជាញាតិ ដល់ភិក្ខុដែលផ្ទាស់ប្តូរចីវរគ្នា ដល់ភិក្ខុដែលប្តូរយកចីវរមានតម្លៃច្រើនដោយចីវរមានតម្លៃតិច ឬចីវរមានតម្លៃតិចដោយចីវរមានតម្លៃច្រើន ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវររបស់ខ្លួនដោយសេចក្តីស្និទ្ធស្នាល ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវរជារបស់ខ្លីគ្នា ដល់ភិក្ខុដែលឲ្យបរិក្ខារដទៃវៀរលែងតែចីវរ ដល់ភិក្ខុដែលឲ្យចីវរដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទ ទី ៥ ចប់ ។

ឆដ្ឋសិក្ខាបទំ

[៦៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ បច្ឆោ ហោតិ ចីវរកម្មំ ការាតុំ ។ អញ្ញតរា ភិក្ខុនី យេនាយស្មា ឧទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឿ ឯតទវោច សាធុ មេ ភន្តេ អយ្យោ ចីវរំ សិព្វេតូតិ ។ អថខោ អាយស្មា ឧទាយិ តស្សា ភិក្ខុនិយា ចីវរំ សិព្វ-ត្វា សុវត្ថំ សុបរិកម្មកតំ កត្វា មជ្ឈេ បដិការណចិត្តំ រុន្ធាបេត្វា សំហរិត្វា និក្ខិបិ ។ អថខោ សា ភិក្ខុនី យេនាយស្មា ឧទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឿ ឯតទវោច ការេ[1] តេ ភន្តេ ចីវ-រន្តិ ។ ហន្ទ ភគិនិ ឥមំ ចីវរំ យថាសំហដំ ហរិត្វា និក្ខិបិត្វា យទា ភិក្ខុនីសង្ឆោ ឱរាជំ អាគច្ឆតិ តទា ឥមំ ចីវរំ ចារុបិត្វា ភិក្ខុនីសង្ឆស្ស បិដ្ឋិតោ បិដ្ឋិតោ អាគច្ឆាតិ ។ អថខោ សា ភិក្ខុនី តំ ចីវរំ

---

១ ការេ តេតិបិ ១ ។ ឱ.ម. ការេ ។

សិក្ខាបទទី ៦

[៦៥] *សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ឧទាយិ ដ៏មានអាយុជាអ្នកប្រសប់ធ្វើចីវរកម្ម ។ មានភិក្ខុនី ១ រូប ចូលទៅកាន់ទីដែល ឧទាយិដ៏មានអាយុនៅ លុះចូលទៅដល់ហើយ បាននិយាយនឹងឧទាយិ ដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ដេរ ចីវរឲ្យខ្ញុំផង ។ គ្រានោះ ឧទាយិដ៏មានអាយុក៏ដេរចីវរ ហើយធ្វើកិច្ច ជ្រលក់គក់ពោកដ៏ល្អ រួចធ្វើរូបគំនូរ[១] ត្រង់កណ្ដាលចីវរ ស្រេចហើយបត់ ទុកឲ្យភិក្ខុនីនោះ ។ គ្រានោះ ភិក្ខុនីនោះ ទៅកាន់លំនៅឧទាយិដ៏មាន អាយុ លុះទៅដល់ហើយបាននិយាយនឹងឧទាយិដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ ចីវររបស់លោកម្ចាស់នោះដូចម្តេចទៅ ។ ឧទាយិធ្វើយ ថា ម្នាលប្អូនស្រី ហ៏ នាងចូរនាំយកចីវរនេះទៅទាំងផ្ទត់ហើយទុក កាល ណាភិក្ខុនីសង្ឆមកទទួលឱវាទ ចូរដណ្ដប់ចីវរនេះដើរទៅតាមក្រោយ ។*

---

១ អដ្ឋកថាថា គូររូបភាពបុរសស្ត្រី ធ្វើសន្ដរ:គ្នា មានឧបាយលាយដោយវត្ថុពណ៌ផ្សេង ។ តាមគំនិតរបស់ខ្លួន ត្រង់កណ្ដាលចីវរ ។

យថាសំហដំ ហរិត្វា ឯកិ្ខបិត្វា យថា កិ្ខ្ជនីសង្ខ្យោ ឧ្ភាដំ អាកឌ្ឍតិ តថា តំ ចីវរំ ចារុបិត្វា កិ្ខ្ជនីសជ្ឈ្យ្ជ បិដ្ឋិតោ បិដ្ឋិតោ អាកឌ្ឍតិ ។ មនុស្ស ឧជ្ឈ្យាយន្តិ ទីយន្តិ ឧ្ជ្ជាយន្តិ យាវ ច ្ជ ្ជ ្ជ

ភិក្ខុនីសង្ឆ ក្នុងកាលណោះ ។ លំដាប់នោះ ភិក្ខុនីនោះនាំយកចីវរនោះ ទៅទាំងផ្នត់ហើយទុក កាលណាភិក្ខុនីសង្ឆមកទទួលឱ្យ នាងក៏ដណ្តប់ចីវរនោះដើរទៅតាមក្រោយ ។ ភិក្ខុនីសង្ឆ ក្នុងកាលណោះ ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុនីអម្បាលនេះជាស្ត្រីគ្មានកោតញ្ញើត ជាស្ត្រីអ្នកលេង គ្មានអៀនខ្មាស មិនសមបើនឹងគួរគំនូរក្នុងចីវរសោះ ។ ភិក្ខុនីទាំងឡាយបាននិយាយសួរគ្នាយ៉ាងនេះថា នេះជាការងាររបស់អ្នកណា ។ ភិក្ខុនីទាំងឡាយឆ្លើយថា នេះជាការងាររបស់លោកម្ចាស់ឧទាយិ ។ ពួកភិក្ខុនីនិយាយគ្នាថា ជនទាំងឡាយណាជាអ្នកគ្មានសេចក្ដីកោតញ្ញើត ជាអ្នកលេង ជាអ្នកគ្មានសេចក្ដីអៀនខ្មាស កម្មមានសភាពយ៉ាងនេះ ក៏គង់មិនល្អដល់ជនទាំងឡាយនោះ នឹងពោលទៅថ្វីដល់លោកម្ចាស់ឧទាយិ ។ ពួកភិក្ខុនីនោះនាំគ្នាប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះ-ដៀល បន្ទុះបង្ហាប់ថា ឧទាយិដ៏មានអាយុមិនគួរនឹងដេរចីវរដល់ភិក្ខុនីសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧទាយិ ឮថាអ្នកឯងដេរចីវរឲ្យភិក្ខុនី ពិតមែនឬ ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោសពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែឧទាយិ ភិក្ខុនីនោះជាញាតិ

តេ ឧជាយិ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា ចាសាទិកំ វា អប្ប្ាសាទិកំ វា ឥមំ ហិ ជាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្ពេស្ស្ាសិ ឥតិ មោឃបុរិស អប្ប-សន្ថានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្ពេយ្យ វា សិព្ព-ាបេយ្យ វា ចាចិត្តិយន្តិ ។

[៦៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ប្ាតោ ភិក្ខូតិ ។ អញ្ញាតិកា ជាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុតា អសម្ពន្ធា[1] ។ ភិក្ខុនី ជាម ឧភតោសង្ឆ្យ ឧបសម្ប្ជ្ជ ។ ចីវរំ ជាម ឆន្ទំ ចីវ្ាវ្ាជ្ជ អញ្ញតរំ ចីវរំ វិកប្ប្ជ្ជ ។ សិព្ពេយ្យាតិ សយំ សិព្ពតិ អ្ាវ្ាបតេ អ្ាវ្ាបតេ អ្ាបត្តិ

1 អសម្ពន្ធ្ាតិបិ ១ាហ ទិស្ស្ាតិ ។

របស់អ្នកឯង ឬមិនមែនជាញាតិទេ ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស មិនមែនជាញាតិទេ ។ ព្រះដ៏មានព្រះភាគ ត្រាស់ថា នែមោឃបុរស ប្រុសដែលមិនមែនជាញាតិ រមែងមិនស្គាល់កម្មដ៏សមគួរក្តី មិនសមគួរក្តី កម្មជាទីជ្រះថ្លាក្តី មិនជាទីជ្រះថ្លាក្តី របស់ស្ត្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនសមគួរនឹងដេរចីវរឲ្យភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ដេរឯង ឬប្រើគេឲ្យដេរនូវចីវរឲ្យភិក្ខុនីមិនមែនញាតិ (ភិក្ខុនោះ) ត្រូវអាបត្តិ បាចិត្តិយ ។

[៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ភិក្ខុនីដែលមិនបានជាប់តវង្សគ្នាមកអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគូជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនញាតិ ។ ស្ត្រីដែលបានឧបសម្បទាហើយក្នុងសង្ឆពីរចំណែក ហៅថា ភិក្ខុនី ។ បណ្តាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមកែកប្ជបាន ហៅថា ចីវរ ។ ពាក្យថា ដេរឯង គឺភិក្ខុដេរដោយខ្លួនឯង

ចាចិត្តិយស្ស ។ សិញ្ចាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ ចាចិត្តិយស្ស ។ សកឹ អាណាត្តោ ពហុកំបិ សិញ្ចេតិ អាបត្តិ ចាចិត្តិយស្ស ។

[៦៧] អញ្ញាតិកាយ អញ្ញាតិកសញ្ញី ចីវរំ សិញ្ចេតិ វា សិញ្ចាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។ អញ្ញាតិកាយ វេមតិកោ ចីវរំ សិញ្ចេតិ វា សិញ្ចាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។ អញ្ញាតិកាយ ញាតិកសញ្ញី ចីវរំ សិញ្ចេតិ វា សិញ្ចាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។ ឯកតោ ឧបសម្បន្នាយ ចីវរំ សិញ្ចេតិ វា សិញ្ចាបេតិ វា អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។

[៦៨] អនាបត្តិ ញាតិកាយ ចីវរំ បវេណ្ឌា អញ្ញំ បរិក្ខារំ សិញ្ចេតិ វា សិញ្ចាបេតិ វា សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

ត្រូវអាបត្តិបាចិត្តិយរាល់ ១ ផ្នូរម្ជុល ។ ពាក្យថា ប្រើគេឲ្យដេរ គឺកិក្ខុបង្គាប់អ្នកដទៃឲ្យដេរ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់ដេរច្រើនដង ត្រូវអាបត្តិបាចិត្តិយ (តែមួយ) ។

[៦៧] កិក្ខុនីមិនមែនញាតិ កិក្ខុសំគាល់ថា មិនមែនញាតិមែន ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុនីមិនមែនញាតិ កិក្ខុមានសេចក្តីសង្ស័យ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តី នូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុនីមិនមែនញាតិ កិក្ខុសំគាល់ថា ជាញាតិ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តី នូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរដើម្បីកិក្ខុនីដែលបានឧបសម្បទាអំពីសង្ឆតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។ កិក្ខុនីជាញាតិ កិក្ខុសំគាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ កិក្ខុនីជាញាតិ កិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កិក្ខុនីជាញាតិ កិក្ខុសំគាល់ថា ជាញាតិមែន មិនត្រូវអាបត្តិអ្វីឡើយ ។

[៦៨] អាបត្តិមិនមាន ដល់កិក្ខុដែលដេរចីវរដល់កិក្ខុនីជាញាតិ ដល់កិក្ខុដែលដេរឯង ឬប្រើគេឲ្យដេរនូវបរិក្ខារដទៃក្រៅពីចីវរ (ឲ្យកិក្ខុនី) ឲ្យសិក្ខមានា ឬសាមណេរី ដល់កិក្ខុឆ្កួត ដល់កិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

សត្តមសិក្ខាបទំ

[៦៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ភិក្ខុនីហិ
សទ្ធឹ សំវិធាយ ឯកច្ឆានមត្តំ បដិបជ្ជន្តិ ។ មនុស្សា
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ យថេវ មយំ សប្ប-
ជាបតិកា[1] អាហិណ្ឌាម ឯវមេវិមេ សមណា សក្យ-
បុត្តិយា ភិក្ខុនីហិ សទ្ធឹ អាហិណ្ឌន្តីតិ ។ អស្សោសុំ
ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ
វិចារេន្តានំ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម
ឆព្ភក្ខិយា ភិក្ខូ ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកច្ឆានមត្តំ
បដិបជ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ
ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកច្ឆានមត្តំ បដិបជ្ជថាតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម

---

1 ឩ. ម. សបជាបតិកា ។

សិក្ខាបទទី ៧

[៦៩] សម័យនោះឯង ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វាយមួយ ជា-មួយគ្នា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្ទុះបង្ហាប់ថា យើងទាំងឡាយមានប្តីប្រពន្ធដើរទៅយ៉ាងណា សមណៈទាំងឡាយនេះ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រដើរទៅមួយអន្ទើដោយភិក្ខុនីទាំងឡាយ យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា មិនសមបីបើឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វាយមួយជាមួយគ្នាទេ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វាយមួយជាមួយគ្នា ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបបួលភិក្ខុនី

តុម្ហេ មោឃបុរិសា ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកច្ឆា-ឌមក្តំ បដិបជ្ជិស្សថ ឌេតំ មោឃបុរិសា អប្ប្ សន្ធានំ ភ បសាធាយ ។ ២ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកច្ឆានមក្តំ បដិបជ្ជេយ្យ អន្តមសោ តាមន្តរម្ប៎ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៧០] ឌេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ច ភិក្ខុនិយោ ច សាកេតា សាវត្ថឺ អច្ឆានមត្តប្ប្ដិបជ្ជា ហោន្តិ ។ អថខោ តា ភិក្ខុនិយោ ឌេ ភិក្ខូ បស្ប៎ិត្វា ឯតទវោចុំ មយំបិ អយ្យេហិ សទ្ធឹ ឌមិស្ប្ដាមាតិ ។ ២ ភគិនិ ឌកប្ប្ដិ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកច្ឆា-ឌមក្តំ បដិបជ្ជិតុំ តុម្ហេ ភ បឋមំ ឌចួថ មយំ ភ ឌមិស្ប្ដាមាតិ ។ អយ្យា ភន្ដេ អត្ដបុរិសា អយ្យា ២ បឋមំ ឌចួន្ដ្ដិ ។ អថខោ តាសំ ភិក្ខុនីនំ បច្ឆា ឌចួន្ដ្ដីនំ អន្ដ្ដ១ាមឌ្ដ ចោ១ អច្ឆិន្ដ្ដឺសុ ២ៅ

ដើរទៅកាន់ផ្លូវធ្វើយមួយជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វើយមួយជាមួយគ្នា ដោយហោចទៅសូម្បីកាន់ទីជាលង្វែកនៃស្រុក ១ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៧០] សម័យនោះឯង ភិក្ខុនិងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅកាន់ផ្លូវធ្វើយអំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី ។ កាលនោះ ភិក្ខុនីទាំងឡាយនោះ ឃើញពួកភិក្ខុនោះហើយ បានពោលពាក្យនេះថា យើងទាំងឡាយនឹងទៅជាមួយនឹងលោកម្ចាស់ទាំងឡាយ ។ ភិក្ខុទាំងនោះធ្វើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វើយមួយជាមួយគ្នាមិនគួរទេ នាងទាំងឡាយទៅមុនឬ ។ យើងទាំងឡាយនឹងទៅមុន ។ ភិក្ខុនីទាំងឡាយធ្វើយថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ទាំងឡាយជាបុរសដ៏ប្រសើរ គួរតែលោកម្ចាស់ទាំងឡាយនិមន្តទៅមុន ។ កាលភិក្ខុនីទាំងនោះ ដើរទៅជាខាងក្រោយនៃភិក្ខុទាំងឡាយដល់ពាក់កណ្តាលផ្លូវ ចោរទាំងឡាយក៏ដណ្តើមយក (ចាត្រនិងចីវរ) ផង

ទូសេសុញ្ញ[1] ។ អថខោ តា ភិក្ខុនិយោ សាវត្ថី
គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខុនិយោ
ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯត-
មត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ
ឯតស្មឹ បការណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ
អនុជានামិ ភិក្ខវេ សត្តកមនីយេ មក្តេ សាសង្ក្លិសម្ មតេ
សប្បដិភយេ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកទ្ធានមក្តំ
បដិបជ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ
សំវិធាយ ឯកទ្ធានមក្តំ បដិបជ្ជេយ្យ អន្តមសោ គា-
មន្តរម្ប៎ អញ្ញត្រ សមយា ចាចិត្តិយំ ។ តត្ថាយំ
សមយោ សត្តកមនីយោ ហោតិ មក្តោ សាសង្ក្លិសម្ មតោ
សប្បដិភយោ អយំ តត្ត សមយោតិ ។

[៧១] យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ប៎តោ
ភិក្ខូតិ ។ ភិក្ខុនី នាម ឧភតោសង្ឆេ ឧបសម្ប៎ន្នា ។

---

1 ឱ. ម. អច្ឆិន្ទឹសុ ច ទូសេសុំ ច ។

ប្រទុស្ដផង (កំហែងធ្វើសេវនកិច្ច) ក្នុងកាលនោះឯង ។ ទើបភិក្ខុនី ទាំងនោះទៅដល់ក្រុងសាវត្ថី ក៏ប្រាប់សេចក្ដីនុ៎ះដល់ពួកភិក្ខុនី ។ ពួកភិក្ខុនី ប្រាប់សេចក្ដីនុ៎ះដល់ពួកភិក្ខុ ។ ពួកភិក្ខុក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មាន ព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថាហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យអ្នកទាំងឡាយបបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វាយជា មួយគ្នា ក្នុងផ្លូវដែលគួរនឹងទៅដោយមានគ្នីគ្នាជាពួកដែលគេសន្ មតថា ប្រកបដោយសេចក្ដីរង្គៀស ប្រកបដោយភ័យចំពោះមុខ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុ ណាមួយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវធ្វាយមួយជាមួយគ្នា ដោយហោចទៅ សូម្បីទៅកាន់ទីជាលង្វែកនៃស្រុក ១ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ រៀរ លែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺផ្លូវដែលគួរនឹងទៅ ដោយមានគ្នីគ្នាជាពួក ១ ដែលគេសន្ មតថាប្រកបដោយសេចក្ដីរង្គៀស ១ ដែលប្រកបដោយភ័យចំពោះមុខ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[៧១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ភិក្ខុនី គឺស្ត្រីដែលបានឧបសម្បទា

សទ្ធិន្តិ ឯកតោ ។ សំវិជាយាតិ កច្ចាម ភតិនិ កច្ចាម អយ្យ កច្ចាម អយ្យ កច្ចាម ភតិនិ អជ្ជ ភ ហិយ្យោ ភ បរេ ភ កច្ចាមាតិ សំវិជហាតិ អាបត្តិ ឧក្កាជ្ជ ។ អន្ដមសោ តាមន្ដរម្ប៊ីតិ ឧក្ការ្ជ្ជ សម្ប្ជាតេ តាមេ តា-មន្ដរេ[1] អាបត្តិ ចាចិត្ដ្ដិយ ។ អតាមកេ អ្ជ្ជ អ្ជ្ជ យោ ជ ជ ។ ។ ។

ក្នុងឧកតោសង្ឆ ។ ពាក្យថា ជាមួយគ្នា សេចក្ដីថា ពួកជាមួយគ្នា ។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងទាំងឡាយនឹងទៅ បពិត្រ លោកម្ចាស់ យើងទាំងឡាយនឹងទៅ បពិត្រលោកម្ចាស់ យើងទាំង-ឡាយនឹងទៅ ម្នាលនាង យើងទាំងឡាយនឹងទៅ យើងទាំងឡាយនឹងទៅ ក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ ។ ពាក្យ ថា ដោយហោចទៅសូម្បីទៅកាន់ទីជាលង្វែកនៃស្រុក ១ សេចក្ដីថា (ភិក្ខុ បបួលភិក្ខុនីដើរជាមួយគ្នាទៅ) ក្នុងទីជាចន្ទោះនៃស្រុក ក្នុងស្រុកមាន ចម្ងាយល្មមមាន់ហើរទៅដល់ (គឺ ១ រយៈមាន់ហើរ) ត្រូវអាបត្តិបាចិត្តិយ ។ (ភិក្ខុបបួលភិក្ខុនីដើរជាមួយគ្នាទៅ) ក្នុងព្រៃដែលមិនមែនស្រុក ត្រូវអាបត្តិ បាចិត្តិយគ្រប់ ១ កន្ទះយោជន៍ ។ ពាក្យថា រៀរលែងតែមានសម័យ សេចក្ដីថា លើកទុកតែមានសម័យ ។ ដែលហៅថា ផ្លូវដែលគួរនឹងទៅ ដោយមានគ្នីគ្នាជាពួក គឺផ្លូវដែលបុគ្គលឥតមានគ្នីគ្នាមិនអាចដើរទៅបាន ។ ដែលហៅថា ផ្លូវប្រកបដោយសេចក្ដីរង្គៀស គឺកន្លែងដែលចោរអាស្រ័យ នៅក៏ប្រាកដ កន្លែងដែលចោរបរិភោគអាហារក៏ប្រាកដ កន្លែងដែល ចោរឈរនៅក៏ប្រាកដ កន្លែងដែលចោរអង្គុយក៏ប្រាកដ កន្លែងដែល ចោរដេកក៏ប្រាកដ ក្នុងផ្លូវនោះ ។ ដែលហៅថា ផ្លូវប្រកបដោយ ភ័យចំពោះមុខ គឺផ្លូវនោះដែលចោរទាំងឡាយ សម្ងាប់មនុស្សក៏ប្រាកដ

ជិស្សន្តិ វិលុត្តា ជិស្សន្តិ អាកោដិតា ជិស្សន្តិ ។ សប្ប-ដិកយំ កត្វា អប្បដិកយំ បស្សិត្វា[1] ឧយ្យោជេតញ្ច កច្ចជ ភកិនិយោតិ ។

[៧២] សំវិធហិតេ សំវិធហិតសញ្ញី ឯកង្ខាណមត្តំ បដិបជ្ជតិ អន្តមសោ តាមន្តរម្ប៎ អញ្ញត្រ សមយា អាបត្តិ ចាចិត្តិយស្ស ។ សំវិធហិតេ វេមតិកោ ឯ-កង្ខាណមត្តំ បដិបជ្ជតិ អន្តមសោ តាមន្តរម្ប៎ អញ្ញត្រ សមយា អាបត្តិ ចាចិត្តិយស្ស ។ សំវិធហិតេ អសំវិធ-ហិតសញ្ញី ឯកង្ខាណមត្តំ បដិបជ្ជតិ អន្តមសោ តាមន្ត-រម្ប៎ អញ្ញត្រ សមយា អាបត្តិ ចាចិត្តិយស្ស ។ ភិក្ខុ សំវិធហតិ ភិក្ខុនី ន សំវិធហតិ អាបត្តិ ទុក្កដស្ស ។ អសំវិធហិតេ សំវិធហិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អសំវិធហិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសំ-វិធហិតេ អសំវិធហិតសញ្ញី អនាបត្តិ ។

---

១ ឱ. ទស្សិត្វា ។ ម. ទស្សេត្វា ។

ឫន់មនុស្សក៏ប្រាកដ រាយដំមនុស្សក៏ប្រាកដ ។ ភិក្ខុដើរទៅកាន់ផ្លូវដែលប្រកបដោយភ័យចំពោះមុខ ហើយឃើញផ្លូវមិនប្រកបដោយភ័យចំពោះមុខវិញ ត្រូវបញ្ជូនភិក្ខុនីទៅ ដោយពាក្យថា ម្នាលនាងទាំងឡាយ នាងទាំងឡាយចូរទៅចុះ ។

[៧២] ភិក្ខុបបួលគ្នាហើយសំគាល់ថា បបួលមែន ដើរទៅកាន់ផ្លូវធ្វាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាលង្វែកនៃស្រុក ១ ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងការដែលបានបបួលគ្នា ហើយដើរទៅកាន់ផ្លូវធ្វាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្ទោះនៃស្រុក ១ ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ ភិក្ខុបបួលគ្នា ហើយសំគាល់ថា មិនបានបបួល ដើរទៅកាន់ផ្លូវធ្វាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្ទោះនៃស្រុក ១ ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ ភិក្ខុបបួល តែភិក្ខុនីមិនបបួល (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនបានបបួលគ្នា ហើយសំគាល់ថា បានបបួល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងការដែលមិនបានបបួល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ថា មិនបានបបួលក្នុងការដែលមិនបានបបួល មិនត្រូវអាបត្តិឡើយ ។

[៧៣] អជាបត្តិ សមយេ អសំវិធហិត្វា គច្ឆន្តិ ភិក្ខុនី សំវិធហតិ ភិក្ខុ ន សំវិធហតិ វិសង្ខ្លេតេន គច្ឆន្តិ អាបជ្ជាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

[៧៣] អាបត្តិមិនមាន ដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនីហើយដើរទៅ ដល់ភិក្ខុដែលភិក្ខុនីបបួល តែភិក្ខុមិនបានបបួល ដល់ភិក្ខុនិងភិក្ខុនីដែលទៅដោយខុសសង្កេត ដល់ភិក្ខុដែលទៅ (ជាមួយនឹងភិក្ខុនី) ដោយមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

អដ្ឋមសិក្ខាបទំ

[៧៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិ-
យំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភិក្ខុ-
នីហិ សទ្ធឹ សំវិធាយ ឯកាវាសំ អភិរូហន្តិ ។ មនុស្សា
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ យថេវ មយំ សប្បជាប-
តិកា ឯកាវាសយ ភីឧ្បាម ឯវមេវិមេ សមណា
សក្យបុត្តិយា ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកាវាសយ
ភីឧ្ប្ជន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ
ឧជ្ឈាយន្តានំ ខីយន្តានំ វិចារេន្តានំ ។ យេ តេ ភិក្ខូ
អប្ប៎ិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ
ភគវំ ហិ ជាម ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីហិ សទ្ធឹ
សំវិធាយ ឯកាវាសំ អភិរូហិស្ស្ជន្តីតិ ។ អថ ខោ
តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថ-
ខោ ភគវា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ ភិរ
តុម្ហេ ភិក្ខវេ ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកាវាសំ

សិក្ខាបទទី ៨

[៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេត-
វន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង
ឆព្វគ្គិយភិក្ខុទាំងឡាយ បបួលពួកភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា ។ មនុស្ស
ទាំងឡាយ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា យើងទាំងឡាយមានប្តី
ប្រពន្ធជិះលេងលើទូក ១ យ៉ាងណា សមណៈទាំងឡាយនេះ ជាកូនចៅព្រះ
ពុទ្ធជាសក្យបុត្របបួលពួកភិក្ខុនីជិះលេងលើទូក ១ ជាមួយគ្នាយ៉ាងនោះ
ឯង ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល
បន្ទុះបង្ហាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។
ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ឆព្វគ្គិយភិក្ខុ
ទាំងឡាយ មិនគួរបើនឹងបបួលពួកភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នាទេ ។ ទើប
ភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះ
ដ៏មានព្រះភាគជាម្ចាស់ទ្រង់សួរចំពោះឆព្វគ្គិយភិក្ខុទាំងឡាយ ក្នុងពេល
នោះថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយបបួលពួកភិក្ខុនីឡើងជិះទូក

អកិរូហេ ១ សចេ ១ ១ ១

ជាមួយគ្នា ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រ ព្រះដ៏មានព្រះភាគ ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹង បបួលពួកភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាង នេះថា ភិក្ខុណាមួយបបួលភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា ទៅប្រាសទឹកក្តី ទៅបណ្តាយទឹកក្តី (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះ ដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៧៥] សម័យនោះឯង ភិក្ខុនិងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅ កាន់ផ្លូវឆ្ងាយ អំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី ។ ក្នុងទីកណ្តាល ផ្លូវមានស្ទឹង ១ ដែលគេតែងតែឆ្លង ។ ទើបភិក្ខុនីទាំងឡាយនោះ បាន ពោលពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា យើងទាំងឡាយនឹងឆ្លងមួយ អន្ទើដោយលោកម្ចាស់ទាំងឡាយដែរ ។ ភិក្ខុទាំងឡាយនោះធ្វើយថា ម្នាល នាង ការដែលភិក្ខុបបួលភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា មិនគួរទេ (បើ ដូច្នោះ) នាងទាំងឡាយឆ្លងទៅមុនឬ ។ យើងទាំងឡាយនឹងឆ្លងទៅមុន ។

[១០៦] តេន ខោ បន សមយេន មនុស្សា ចីវរទានសមយេ សចីវរកត្តំ បដិយាទេត្វា ភិក្ខូ និមន្តេន្តិ ភោជេត្វា ចីវរេន អច្ឆាទេស្សាមាតិ ។ ភិក្ខូ ឥកុក្ខុច្ចាយន្តា ជានិវាសេន្តិ បដិក្ខិត្តំ ភគវតា បរម្ប-ភោជនន្តិ ។ ចីវរំ បរិត្តំ ឧប្ផជ្ជតិ ។ ភគវតោ ឯតមត្តំ អាហេចេសុំ ។ អនុជានামិ ភិក្ខវេ ចីវរទានសមយេ បរម្ប្ប្ប

សម័យដែលកិក្ខុមានជំងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់កិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៦] សម័យនោះឯង មនុស្សទាំងឡាយ តាក់តែងភត្ត ព្រមទាំងចីវរក្នុងសម័យនៃចីវរទាន ហើយនិមន្តកិក្ខុទាំងឡាយថា ពួកយើងនឹងនិមន្តលោកម្ចាស់ទាំងឡាយធាន់រួច (នឹងប្រគេន) ចីវរឲ្យស្មៀកដណ្ដប់ ។ កិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា បរម្ប្ររភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ចីវរក៏កើតឡើងដល់កិក្ខុដោយស្ហួចស្ដើង ។ កិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលកិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកិក្ខុធាន់បរម្ប្ររភោជនក្នុងសម័យនៃចីវរទានបាន ម្នាលកិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះធាន់បរម្ប្ររភោជន រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺ សម័យដែលកិក្ខុមានជំងឺ ១ សម័យនៃចីវរទាន ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់កិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៧] សម័យនោះឯង មនុស្សទាំងឡាយ និមន្តពួកកិក្ខុជាអ្នកធ្វើចីវរឲ្យធាន់ចង្ហាន់ ។ កិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា

ជានិ្យាសេន្តិ បដិក្ខិត្តំ ភគ្គវតា បរម្ប្ស្ យ្ យ ភោជនន្តិ ។ ភគ្គវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវ្ យ ការ្ យ សមយេ បរម្ប្ស្ យ ភោជនំ ភុញ្ជិតុំ ឯ្ យ ញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ្ យ សេ យ្ យ ាថ បរម្ប្ស្ យ ភោជនេ អញ្ញ ត្រ សមយា ចាចិ ត្តិ យ ។ ត ត្ថ យ សមយោ ។ ។ ។

បរម្ករភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធាន់បរម្ករភោជន ក្នុងសម័យជាទីធ្វើនូវចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះធាន់បរម្ករភោជនវៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលភិក្ខុមានជំងឺ ១ សម័យនៃចីវរទាន ១ សម័យជាទីធ្វើនូវចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៨] គ្រានោះ ពេលបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរ មានព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ ព្រះអង្គទ្រង់យាងចូលទៅកាន់ត្រកូល ១ លុះចូលទៅហើយ ក៏ទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយ ។ ទើបមនុស្សទាំង-ឡាយនោះបានថ្វាយភោជន ដល់ព្រះដ៏មានព្រះភាគផង ដល់ព្រះអានន្ទដ៏មានអាយុផង ។ ព្រះអានន្ទដ៏មានអាយុ សង្ស័យមិនហ៊ានទទួល ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ អ្នកទទួលចុះ ។ ព្រះអានន្ទក្រាបទូលថា

ភគវា អត្ថិ មេ ភត្តប្ចាសាតិ ។ តេនហានន្ទ
វិកប្ប្ធ្ងា កណ្ហាហីតិ ។ អថខោ ភគវា ឯតស្មឺ
 និ្ជ្ជ ឯតស្ម ឺ ២ ២ ២

សូមទ្រង់មេត្តាប្រោស ក្រែងមិនគួរ ព្រោះខ្ញុំព្រះអង្គមានចង្ហាន់គេបម្រុងនឹងប្រគេនហើយ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរកំណត់ (ចង្ហាន់នោះ ដល់ភិក្ខុឯទៀត) ហើយទទួលយក (ចង្ហាន់នេះ) ចុះ ។ ព្រោះនិទានេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកំណត់នូវចង្ហាន់ ដែលគេបម្រុងដើម្បីខ្ជូនដល់ភិក្ខុឯទៀត ហើយធាន់បរម្ប្ររភោជនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីកំណត់ដោយពាក្យយ៉ាងនេះថា ខ្ញុំឲ្យនូវភត្តដែលគេបម្រុងទុកដើម្បីខ្ញុំដល់ភិក្ខុឈ្មោះនេះ ។

[១០៥] ដែលហៅថា បរម្ប្ររភោជន គឺ (ភិក្ខុ) ដែលគេនិមន្ត ដោយភោជន ៥ យ៉ាង ភោជនណាមួយ ហើយវៀរភោជននោះ បែរទៅ ធាន់ភោជន ៥ យ៉ាង ភោជនណាមួយ នៅទីដទៃ ភោជនន៏ុះហៅថា បរម្ប្ររភោជន ។ ពាក្យថា វៀរតែមានសម័យ គឺលើកទុកតែមានសម័យ (គឺហេតុដែលគួរនឹងធាន់បាន) ។ ដែលហៅថា សម័យ ដែលភិក្ខុមានជំងឺ គឺភិក្ខុមិនអាចនឹងអង្គុយធាន់ដរាបទាល់ផ្ទៃតលើអាសនៈ: មួយ ។ ភិក្ខុដឹងថា ខ្ជូនមានសម័យឈឺក្តាត់ហើយ គប្បីធាន់ (បរម្ប្ររភោជនបាន) ។ ដែលហៅថា សម័យនៃចីវរទាន គឺបើភិក្ខុមិនបានក្រាល

ឥមិនេ វស្សានស្ស បច្ឆិមោ មាសោ អត្ថតេ ឥមិនេ
បញ្ច មាសា ។ ចីវរជានសមយោតិ ឥមិ ។
ចីវរការសមយោ ជាម ចីវរេ ការិយមានេ ។ ចីវរការ-
សមយោតិ ឥមិ ។ អញ្ញត្រ សមយា ឥមិ ។ ឥមិ-
មីតិ បជិក្ខណ្ហាតិ អាបត្តិ ទុក្ខ្ជស្ស ។ អជ្ឌ្យោហារេ
អជ្ឌ្យោហារេ អាបត្តិ ចាចិត្តិយស្ស ។

[១១០] បរម្ប្ស្ភោជនេ បរម្ប្ស្ភោជនសញ្ញ្ជ អញ្ញត្រ
សមយា ឥមិ អាបត្តិ ចាចិត្តិយស្ស ។ បរម្ប្ស-
ភោជនេ ឥមិ ។ អញ្ញត្រ សមយា ឥមិ អាបត្តិ
ចាចិត្តិយស្ស ។ បរម្ប្ស្ភោជនេ ជបរម្ប្ស្ភោជនសញ្ញ្ជ
អញ្ញត្រ សមយា ឥមិ អាបត្តិ ចាចិត្តិយស្ស ។
ជបរម្ប្ស្ភោជនេ បរម្ប្ស្ភោជនសញ្ញ្ជ អាបត្តិ ទុក្ខ្ជស្ស ។
ជបរម្ប្ស្ភោជនេ ឥមិ អាបត្តិ ទុក្ខ្ជស្ស ។
ជបរម្ប្ស្ភោជនេ ជបរម្ប្ស្ភោជនសញ្ញ្ជ អជ្ឌ្ជ ។

កឋិនទេ សម័យចីវរទានមានតែ ១ ខែ គឺខែជាទីបំផុតនៃវស្សានរដូវ បើភិក្ខុបានក្រាលកឋិន សម័យនៃចីវរទានមាន ៥ ខែ ។ ភិក្ខុដឹងថា សម័យនៃចីវរទានគប្បីធាន់ (បរម្ប្ររភោជនបាន) ។ ដែលហៅថា សម័យជាទីធ្វើនូវចីវរ គឺកាលដែលភិក្ខុកំពុងធ្វើចីវរ ។ ភិក្ខុដឹងថា សម័យជាទីធ្វើនូវចីវរគប្បីធាន់ (បរម្ប្ររភោជនបាន) ។ ភិក្ខុទទួល (បរម្ប្ររភោជន) ដោយគិតថា អញនឹងធាន់ ត្រូវអាបត្តិទុក្កដ រៀរលែងតែមានសម័យ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ រាត្រីដែលលេប ។

[១១០] ភិក្ខុសំគាល់ ក្នុងបរម្ប្ររភោជនថា បរម្ប្ររភោជនមែន ហើយធាន់ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ភិក្ខុ មានសេចក្តីសង្ស័យក្នុងបរម្ប្ររភោជន ហើយធាន់ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ភិក្ខុសំគាល់ ក្នុងបរម្ប្ររភោជនថា មិនមែន បរម្ប្ររភោជន ហើយធាន់ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ មិនមែនបរម្ប្ររភោជន ភិក្ខុសំគាល់ថា បរម្ប្ររភោជន ត្រូវអាបត្តិទុក្កដ ។ មិនមែនបរម្ប្ររភោជន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនបរម្ប្ររភោជន ភិក្ខុសំគាល់ថា មិនមែនជាបរម្ប្ររភោជន មិនត្រូវ អាបត្តិឡើយ ។

បាចិត្តិយកណ្ឌ ភោជនវគ្គស្ស តតិយសិក្ខាបទស្ស អនាបត្តិវារោ

[១១១] អនាបត្តិ សមយេ វិកប្បេត្វា ភុញ្ជតិ ទ្វេ តយោ និមន្តនេ ឯកតោ ភុញ្ជន្តិ និមន្តនបដិ-ចាដិយា ភុញ្ជតិ សកលេន តាមេន និមន្តិតោ តស្មឹ តាមេ យត្ត ភត្តចិ ភុញ្ជតិ សកលេន ឃូកេន និមន្តិតោ តស្មឹ ឃូកេ យត្ត ភត្តចិ ភុញ្ជតិ និមន្តិយមានោ ភិក្ខុ ភហិស្សាមីតិ ភណតិ និចូ-ភត្តេ សលាកភត្តេ បក្ខិកេ ឧចោសថិកេ ចាដិ-បទិកេ បញ្ចេ ភោជនានិ បវេត្វា សព្ចត្ត អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

[១១១] *អាបត្តិមិនមាន ដល់(ភិក្ខុដែលធាន់បវម្ប្ជរភោជន) ក្នុងសម័យ ដល់ភិក្ខុដែលបានកំណត់ (បវម្ប្ជរភោជនដល់ភិក្ខុឯទៀត) ហើយធាន់ ដល់ភិក្ខុពីរបីអង្គធាន់ជាមួយគ្នាក្នុងទីដែលគេនិមន្ត ដល់ភិក្ខុធាន់តាមលំដាប់លំដោយដែលគេនិមន្ត ដល់ភិក្ខុដែលអ្នកស្រុកទាំងអស់និមន្ត ហើយធាន់ក្នុងទីណាមួយក្នុងស្រុកនោះ ដល់ភិក្ខុដែលប្រជុំជនទាំងអស់និមន្តហើយធាន់ក្នុងទីណាមួយក្នុងប្រជុំជននោះ ដល់ភិក្ខុដែលគេនិមន្ត ហើយពោលថា អាត្មានឹងទទួលតែចង្ហាន់ (ដែលបានមកដោយត្រាច់បិណ្ឌបាត) ដល់ភិក្ខុដែលធាន់និច្ចភត្ត សលាកភត្ត បក្ខិកភត្ត ឧបោ-សថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមាន ដល់ភិក្ខុដែលធាន់ភោជនទាំងពួងក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្លួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។*

សិក្ខាបទទី ៣ ចប់ ។

ចតុត្ថសិក្ខាបទំ

[១១២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន កាណមាតា ឧចាសិកា សទ្ធា ហោតិ បសន្នា ។ កាណា តាមកេ អញ្ញតរស្ស បុរិសស្ស ជិន្នា ហោតិ ។ អថខោ កាណា មាតុយា អតមាសិ កេនចិទេវ ការណីយេន ។ អថខោ កាណាយ សាមិកោ កាណាយ សន្តិកេ ទូតំ ចាហេសិ អាគច្ឆតុ កាណា ឥច្ឆាមិ កាណាយ អាគតន្តិ ។ អថខោ កាណមាតា ឧចាសិកា កិស្មឺ វិយ វិត្តហត្ថំ គន្ត្វុន្តិ ឃ្លាំ បចិ ។ បក្ខ្លេ ឃ្លាវ អញ្ញតរោ បិណ្ឌាចារិកោ ភិក្ខុ កាណមាតាយ ឧចាសិកាយ ជិវ-សនំ ចារិសិ ។ អថខោ កាណមាតា ឧចាសិកា តស្ស ភិក្ខុនោ ឃ្លាំ ជាបេសិ ។ សោ ជិក្ខមិត្វា អញ្ញស្ស អាចិក្ខិ ។ តស្សាបិ ឃ្លាំ ជាបេសិ ។ សោ ជិក្ខមិត្វា អញ្ញស្ស អាចិក្ខិ ។ តស្សាបិ ឃ្លាំ ជាបេសិ ។

សិក្ខាបទទី ៤

[១១២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង
ឧបាសិកាជាមាតារបស់នាងកាណា ជាស្ត្រីមានសទ្ធាជ្រះថ្លា ។ (ឧបាសិកា
នោះ) បានឲ្យនាងកាណាជាកូន ទៅបុរស ១ នាក់ នៅក្នុងស្រុកតូច ១ ។
គ្រានោះ នាងកាណា បានទៅផ្ទះមាតា ដោយកិច្ចអ្វីនីមួយដែលខ្លួន
ត្រូវធ្វើ ។ ទើបប្តីនាងកាណាប្រើបម្រើទៅក្នុងសំណាក់នាងកាណាថា
នាងកាណាចូរមក អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ។ កាលនោះ
ឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេ ដូចម្តេច
នឹងកើត (គិតដូច្នោះហើយ) នាងក៏ចំអិននំ ។ ដល់នំធ្ងិនមានកិក្ខុអ្នក
ត្រាច់បិណ្ឌបាត ១ អង្គចូលទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាង
កាណា ។ ទើបឧបាសិកា ជាមាតារបស់នាងកាណា ឲ្យគេប្រគេននំ
ដល់កិក្ខុនោះ ។ កិក្ខុនោះចេញទៅប្រាប់ដល់កិក្ខុឯទៀត ។ (មាតារបស់នាង
កាណា) ឲ្យគេប្រគេននំដល់កិក្ខុនោះទៀត ។ កិក្ខុនោះចេញទៅប្រាប់ដល់
កិក្ខុដទៃ ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់កិក្ខុនោះទៀត ។

យថាបដិយត្តំ ឃ្លាំ បរិក្ខិយ៎ អកមាសិ ។ ទុតិយម្ពិ ខោ ការណាយ សាមិកោ ការណាយ សន្ត្ពិកេ ទូតំ ចាហេសិ អាគច្ឆតុ ការណា ឥច្ឆាមិ ការណាយ អាគតន្ត្ពិ ។ ទុតិយម្ពិ ខោ ការណមាតា ឧចាសិកា ការិស្ម៎ រ៎ិយ រ៎ិត្តហត្ថំ ឥន្ត្ពុន្ត្ពិ ឃ្លាំ បចិ ។ បក្ត្ពេ ឃ្លាវ អញ្ញតរោ ២ិណ្ណ្ជាចារ៎ិកោ ភ៎ិក្ខុ ការណមា-តាយ ឧចាសិការ៎ យ ២ិវ៎ាសនំ ចារ៎ិសិ ។ អថ ខោ ការណមាតា ឧចាសិកា ត១ ភ៎ិក្ខុ ២ោ ឃ្លាំ ជាបេសិ ។ សោ ២ិក្ខ៎ិ ២ិ ១ ២ ១ អ ១ ១ ២ ១ ២ ១ ២

នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយយ៉ាងណា ក៏អស់គ្មានសល់ ។ ស្វាមីរបស់នាងកាណាប្រើបម្រើទៅ ក្នុងសំណាក់នាងកាណា ជាគម្រប់ពីរដងថា នាងកាណាចូរមកវិញ អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ។ ឧបាសិកា ជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេដូចម្តេចនឹងកើត (គិតដូច្នោះហើយ) ក៏ចំអិននំអស់វារៈជាគម្រប់ពីរដង ។ កាលនំឆ្អិន មានភិក្ខុ ១ អង្គអ្នកត្រាច់ទៅ ដើម្បីបិណ្ឌបាតចូលទៅកាន់លំនៅរបស់ឧបាសិកា ជាមាតានាងកាណា ។ ទើបឧបាសិកាជាមាតារបស់នាងកាណា ឲ្យគេប្រគេននំដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ (ឧបាសិកា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ (ឧបាសិកា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ នំដែលឧបាសិកាបានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់ ។ ស្វាមីរបស់នាងកាណា ក៏ប្រើបម្រើទៅក្នុងសំណាក់នាងកាណា ជាគម្រប់បីដងថា នាងកាណាចូរមកវិញ អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ថាបើនាងកាណាមិនត្រឡប់មកវិញទេ អញនឹងយកប្រពន្ធឯទៀតហើយ ។ ឧបាសិកា ជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេដូចម្តេចនឹងកើត (គិតដូច្នោះហើយ)

តន្តុន្តិ ឃ្លាំ បចិ ។ បក្ខេ ឃ្លាវ អញ្ញតរោ បិណ្ឌាចារិ-
កោ ភិក្ខុ កាណមាតាយ ឧចាសិកាយ និវេសនំ
ចារិសិ ។ អថខោ កាណមាតា ឧចាសិកា
តស្ស ភិក្ខុនោ ឃ្លាំ ឌាបេសិ ។ សោ និក្ខមិត្វា
អញ្ញស្ស អាចិក្ខិ ។ តស្សាបិ ឃ្លាំ ឌាបេសិ ។
សោ និក្ខមិត្វា អញ្ញស្ស អាចិក្ខិ ។ តស្សាបិ ឃ្លាំ
ឌាបេសិ ។ យថាបដិយត្តំ ឃ្លាំ បរិក្ខយំ អគមា-
សិ ។ អថខោ កាណាយ សាមិកោ អញ្ញ បជា-
បតឺ អានេសិ ។ អស្សោសិ ខោ កាណា តេន
ការ បុរិសេន អញ្ញ បជាបតិ អានីតាតិ ។ សា
ភេឧន្តី អដ្ឋាសិ ។ អថខោ ភគវា បុព្ពណ្ហសមយំ
និវាសេត្វា បត្តចីវរមាឌាយ យេន កាណមាតាយ ឧចា-
សិកាយ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ
អាសនេ និសីឌិ ។ អថខោ កាណមាតា ឧចាសិកា
យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ
អភិវាឌេត្វា ឯកមន្តំ និសីឌិ ។ ឯកមន្តំ និសិន្នំ
ខោ កាណមាតរំ ឧចាសិកំ ភគវា ឯតឧវោច

ក៏ចំអិននំអស់វារៈ ជាគម្រប់បីដង ។ កាលនំឆ្ពិន មានភិក្ខុអ្នកត្រាប់ទៅ ដើម្បីបិណ្ឌបាត ១ អង្គចូលទៅកាន់លំនៅរបស់ឧបាសិកា ជាមាតារបស់ នាងកាណា ។ ទើបឧបាសិកា ជាមាតារបស់នាងកាណាឲ្យគេប្រគេននំ ដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ (មាតារបស់ នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញ ទៅប្រាប់ដល់ភិក្ខុនោះទៀត ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំ ដល់ភិក្ខុនោះទៀត ។ នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយ ទាំងប៉ុន្មាន ក៏អស់គ្មានសល់ ។ កាលនោះ ស្វាមីរបស់នាងកាណា ក៏ យកប្រពន្ធ ១ ទៀត ។ នាងកាណាបានដឹងច្បាស់ថា ឦថាបុរសនោះ យកប្រពន្ធទៀតហើយ ។ នាងកាណានោះ ក៏ឈរយំ ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិង ចីវរអំពីព្រឹក យាងទៅកាន់លំនៅរបស់ឧបាសិកា ជាមាតានាងកាណា លុះយាងទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានចាត់ចែងថ្វាយ ។ ទើបឧបាសិកា ជាមាតារបស់នាងកាណា ចូលទៅគាល់ព្រះដ៏មានព្រះ ភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅ ក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងឧបា-សិកា ជាមាតារបស់នាងកាណា ដែលបានអង្គុយនៅក្នុងទីដ៏សមគួរថា

កិស្សាយ៎ កាណា ហេឧតីតិ ។ អថខោ កាណមាតា ឧចាសិកា ភតវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភតវា កាណមាតរំ ឧចាសិកំ ឧម្ម៉ាយ កថាយ សន្ទ្ធេស្ស្ធ្ងា សមាឧបេត្ងា សមុត្តេជេត្ងា សម្ប្ប៎ហ៎ាសេត្ងា ឧដ្ឋាយាសនា បក្ការ៎ាមិ ។

[១១៣] តេន ខោ បន សមយេន អញ្ញតរោ សត្ថ្ងោ ភ១ត១ហ៎ា បដិ១ាលោកំ ១ន្ត្ងុ១ាមោ ហ៎ោតិ ។ អញ្ញតរោ បិណ្ឌ១ារិ១ោ ភិ១ុ ១ំ សត្ថ្ងំ បិណ្ឌ១ាយ ១ារ១ិ ។ អញ្ញតរោ ឧ១ាសកោ ១ស្ស ភិ១ុ១ោ សត្ថ្ងុ ១ាបេសិ ។ សោ ១ិ១ុ១ិ១ា អញ្ញ១ស្ស អ១ិ១ុ ។ ១ស្ស១ិ សត្ថ្ងុ ១ាបេសិ ។ សោ ១ិ១ុ១ិ១ា អញ្ញ១ស្ស អ១ិ១ុ ។ ១ស្ស១ិ សត្ថ្ងុ ១ាបេសិ ។ យ១ាបដិយត្ថ្ងំ ១ាបេយ្យ៎ បរិ១ុ១យ៎ អ១មាសិ ។ អ១ខោ សោ ឧ១ា-សកោ ១េ មនុ១ស្ស ឯ១ឧ១ោ១ អ១ុ១ណ្ហោ អ១ា

នាងកាណានេះ ហេតុអ្វីបានជាយំ ។ ឧបាសិកាជាមាតារបស់នាងកាណា ក៏ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគក្នុងពេលនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឧបាសិកាជាមាតារបស់នាងកាណាឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យឧស្សាហ៍ ឲ្យរីករាយ ដោយពុទ្ធដីកាដ៏ប្រកបដោយធម៌ ហើយក្រោកចាកអាសនៈយាងទៅវិញ ។

[១១៣] សម័យនោះឯង មានពួករទេះ ១ ពួកមានសេចក្ដីប្រាថ្នាដើម្បីចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ប្រទេសឈ្មោះបដិយាលោក[1] ។ មានភិក្ខុអ្នកត្រាច់ទៅ ដើម្បីបិណ្ឌបាតមួយអង្គ ចូលទៅរកពួករទេះនោះ ដើម្បីបិណ្ឌបាត ។ មានឧបាសកម្នាក់បានឲ្យគេប្រគេនសដូវដល់ភិក្ខុនោះ ។ ភិក្ខុនោះ ចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ ឧបាសកនោះឲ្យគេប្រគេនសដូវដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះ ចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ ឧបាសកនោះ ឲ្យគេប្រគេនសដូវដល់ភិក្ខុនោះទៀត ។ ស្បៀងដែលឧបាសកនោះ បានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់ ។ ទើបឧបាសកនោះ បាននិយាយពាក្យនេះនឹងមនុស្សទាំងនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ សូមអ្នកម្ចាស់រង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន (ព្រោះ)

---

១ គឺប្រទេសនៅទិសខាងលិចចំព្រះអាទិត្យអស្តង្គត ។

អាតមេថ យថាបដិយត្តំ ចាវេយ្យុំ អយ្យានំ ជិន្នំ ចាវេយ្យុំ បដិយាវេស្សាមីតិ ។ ជាយ្យ[1] សក្ខា អាតមេតុំ បយោគោ សត្ថោតិ អតមំសុ ។ អថខោ តស្ស ឧចាសកស្ស ចាវេយ្យុំ បដិយាវេត្វា បច្ចា តច្ចន្ត្ស ចោរ អច្ចិន្ទ្ធីសុ ។ មនុស្ស ឧជ្ឌាយន្ត្ដ ទីយន្ត្ដ វិចាវេន្ត្ដ តកំ ហិ ជាម សមណា សក្ស-បុត្ដិយ ន មត្ដ ជានិត្វា បដិក្ដហេស្ស្ដ អយ ឥមេសំ ឧត្វា បច្ចា តច្ចន្ដ ចោរេហិ អច្ចិន្ទ្ធោតិ ។ អស្ស្ដ ខោ ភិក្ខូ ដេសំ មនុស្ស្ដ ឧជ្ឌាយន្ដ ទីយន្ដ វិចាវេន្ដ ។ អថខោ ដេ ភិក្ខូ ភគ្ដ ឯតមត្ដ អ្ដ្ដ ។ អថខោ ភគ្ដ ឯតស្ម ជិ ជ ឯតស្ម ២ ១ ២ ១ ២ ១

ស្បៀងដែលខ្ញុំបានចាត់ចែងហើយទាំងប៉ុន្មាន ខ្ញុំប្រគេនដល់លោកម្ចាស់ទាំងឡាយអស់ទៅហើយ ខ្ញុំនឹងចាត់ចែងស្បៀង (ថ្មីទៀត) ។ មនុស្សទាំងនោះនៃ្ចយថា បពិត្រអ្នកម្ចាស់ យើងមិនអាចនឹងរង់ចាំបានទេ (ព្រោះ) ពួករនេះចេញទៅហើយ (ថាដូច្នោះហើយ) ក៏នាំគ្នាទៅ ។ កាលឧបាសកនោះចាត់ចែងស្បៀងហើយ ក៏ទៅក្រោយគេ ចោរទាំងឡាយក៏ដណ្តើមយក (របស់ទ្រព្យ) ក្នុងពេលនោះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា សមណៈទាំងឡាយជាសក្យ-បុត្រ មិនសមបើនឹងមិនដឹងនូវប្រមាណហើយទទួលសោះ ឧបាសកនេះប្រគេនសដ្ឋវដល់សមណៈទាំងនេះ ហើយទៅកាលជាខាងក្រោយ ចោរទាំងឡាយ ក៏ដណ្តើមយក (របស់ទ្រព្យ) ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ (ដូច្នោះ) ហើយ ។ ទើបភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីការប្រពៃដល់សង្ឆ ដើម្បីនៅសប្បាយដល់សង្ឆ ។ បេ ។ ដើម្បីសេចក្តីអនុគ្រោះ

វិនយានុត្តរាយ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុ បនេវ កុលំ ឧបគតំ ឬ ហេហិ វ មន្តេហិ វ អភិហដ្ឋុំ បវារេយ្យ ។ អាកង្ខមានេន ភិក្ខុនា ទ្វិត្តិបត្តបូរា បដិគ្គហេតព្វា ។ តតោ ចេ ឧត្តរី[1] បដិគ្គណ្ហេយ្យ ចាចិត្តិយំ ។ ទ្វិត្តិបត្តបូរេ បដិគ្គ-ហេត្វា តតោ នីហរិត្វា ភិក្ខូហិ សទ្ធឹ សំវិភជិតព្វំ អយំ តត្ថ សាមីចីតិ ។

[១១៤] ភិក្ខុ បនេវ កុលំ ឧបគតន្តិ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណកុលំ វេស្ស-កុលំ សុទ្ទកុលំ ។ ឧបគតន្តិ តត្ថ ឧបគតំ[2] ។ ឬ ជាម យន្តិ ញ្ចិ ឬ ហិណាកត្តាយ បដិយត្តំ ។ ម ជាម យន្តិ ញ្ចិ ចាវេយ្យត្តាយ បដិយត្តំ ។ អភិហដ្ឋុំ បវារេយ្យាតិ យាវតកំ ឥច្ឆសិ តាវតកំ គណ្ហាហី-តិ ។ អាកង្ខមានេនាតិ ឥច្ឆមានេន ។ ទ្វិត្តិបត្តបូរា

---

១ ឱ. ម. ឧត្តរិ ។ ២ ឱ.ម. គតំ ។

ដល់ព្រះវិន័យ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ជនបវារណានូវភិក្ខុដែលចូលទៅកាន់ត្រកូលដោយនំទាំងឡាយក្តី ដោយសម្លរទាំងឡាយក្តី ដើម្បីនាំទៅបាន តាមប្រាថ្នា ។ ភិក្ខុមានសេចក្តីប្រាថ្នា ត្រូវទទួលបានត្រឹមពេញពីរបីបាត្រ ។ បើទទួលឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលបានទទួលនំ ឬសម្លរកំណត់ពេញត្រឹមពីរបីបាត្រហើយ ត្រូវនាំចេញអំពីទីនោះមកចែក មួយអន្ទើដោយភិក្ខុទាំងឡាយ ការចែកនំ ឬសម្លរនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ ។

[១១៤] ត្រង់ពាក្យថា ភិក្ខុដែលចូលទៅកាន់ត្រកូល សេចក្តីថា ដែលហៅថា ត្រកូល បានដល់ត្រកូលមាន ៤ យ៉ាង គឺត្រកូលក្សត្រ ១ ត្រ-កូលព្រាហ្មណ៍ ១ ត្រកូលអ្នកជំនួញ ១ ត្រកូលអ្នកគ្រួ ។ ពាក្យថា ចូលទៅគឺចូលទៅក្នុងត្រកូលទាំងនោះ ។ ដែលហៅថា នំ បានដល់វត្ថុអ្វីនីមួយដែលគេចាត់ចែងដើម្បីបញ្ជូនទៅ ។ ដែលហៅថា សម្លរ បានដល់វត្ថុអ្វីនីមួយដែលគេចាត់ចែងដើម្បីជាស្ឈៀង ។ ពាក្យថា បវារណាដើម្បីនាំទៅតាមប្រាថ្នា សេចក្តីថា (ទាយកនាំមកបវារណាដោយពាក្យថា) លោកប្រាថ្នានូវវត្ថុប៉ុន្មាន លោកយកវត្ថុប៉ុណ្ណោះចុះ ។ ពាក្យថា មានសេចក្តីប្រាថ្នា គឺមានបំណង ។ ពាក្យថា ត្រូវទទួលបានត្រឹមពេញពីរបីបាត្រ

បដិក្ខហេតញ្ចាតិ ទ្វេតយោបត្តបូរា បដិក្ខហេតញ្ចា ។ តតោ ចេ ឧត្តរឺ បដិក្ខណ្ហោយ្យាតិ តទុត្តរឺ[1] បដិក្ខណ្ហាតិ អាបត្តិ ចាចិត្តិយស្ស ។ ទ្វិត្តិបត្តបូរេ បដិក្ខហេត្វា តតោ ជិក្ខមន្តេន ភិក្ខុំ បស្សិត្វា អាចិក្ខិតព្ពំ អមុត្រ មយា ទ្វិត្តិបត្តបូរា បដិក្ខហិតា មា ខោ តត្ត បដិក្ខណ្ហីតិ ។ សចេ បស្សិត្វា ជានិត្វាតិ អាបត្តិ ទុក្កដស្ស ។ សចេ អាចិក្ខិតេ បដិក្ខណ្ហាតិ អាបត្តិ ទុក្កដស្ស ។

[១១៥] តតោ ជីហរិត្វា ភិក្ខូហិ សទ្ធឹ សំវិភ-ជិតព្ពន្តិ បដិក្ខមនំ ជីហរិត្វា សំវិភជិតព្ពំ ។ អយំ តត្ត សាមីចីតិ អយំ តត្ត អនុធម្មតា ។ អតិរេ-ករ្ទ្ធិត្តិបត្តបូរេ អតិរេកសញ្ញី បដិក្ខណ្ហាតិ អាបត្តិ ចាចិត្តិយស្ស ។ អតិរេកទ្ធិត្តិបត្តបូរេ រេមតិកោ ប-ដិក្ខណ្ហាតិ អាបត្តិ ចាចិត្តិយស្ស ។ អតិរេកទ្ធិត្តិបត្តបូរេ ឩនកសញ្ញី បដិក្ខណ្ហាតិ អាបត្តិ ចាចិត្តិយស្ស ។

---

១ ឱ. ម. តតុត្តរិ ។

សេចក្ដីថា គប្បីទទួលយកបានត្រឹមពេញពីរបីបាត្រ ។ ពាក្យថា បើទទួលឲ្យហួសពីកំណត់នោះទៅ សេចក្ដីថា ភិក្ខុទទួលឲ្យលើសលុបពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ (បើ) ភិក្ខុទទួល (នំឫសដូវ) កំណត់ពេញពីរបីបាត្រហើយចេញពីទីនោះមកឃើញភិក្ខុ (ឯទៀត) ត្រូវប្រាប់ថា ក្នុងទីឯណោះខ្ញុំទទួល (នំឫសដូវ) ពេញពីរបីបាត្រមកហើយ លោកកុំទៅទទួលក្នុងទីនោះឡើយ ។ បើភិក្ខុឃើញហើយមិនប្រាប់ ត្រូវអាបត្តិទុក្កដ ។ បើប្រាប់ហើយ ភិក្ខុនៅតែទៅទទួល ត្រូវអាបត្តិទុក្កដ ។

[១១៥] ត្រង់ពាក្យថា ត្រូវនាំចេញអំពីទីនោះហើយចែកមួយអន្ទៀ ដោយភិក្ខុទាំងឡាយ សេចក្ដីថា ក្នុងពេលដែលត្រឡប់មកត្រូវនាំយក (នំឫសដូវ)នោះ មកចែកគ្នា ។ ពាក្យថា ការចែកនំឫសដូវនេះ ជាសាមី-ចិកម្មក្នុងសិក្ខាបទនោះ សេចក្ដីថា ការចែកនំ ឫសដូវនេះ ជាទំនៀមដ៏សមគួរក្នុងសិក្ខាបទនោះ ។ ភិក្ខុសំគាល់ក្នុងនំឫសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រថា ច្រើនជាងមែន ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងនំឫសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសំគាល់ក្នុងនំឫសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រថា ខ្ះនៅវិញហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។

ឩនកទ្វិត្តិបត្តបូរេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកទ្វិត្តិបត្តបូរេ រេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកទ្វិត្តិបត្តបូរេ ឩនកសញ្ញី អនាបត្តិ ។

[១១៦] អនាបត្តិ ទ្វិត្តិបត្តបូរេ បដិក្ខណ្ហាតិ ឩនកទ្វិត្តិបត្តបូរេ បដិក្ខណ្ហាតិ ន បហិណាកត្តាយ ន ចាវេយ្យត្តាយ បដិយត្តំ ទេន្តិ បហិណាកត្តាយ វា ចាវេយ្យត្តាយ វា បដិយត្តសេសកំ ទេន្តិ តមេ បដិប្ផស្សេ ទេន្តិ ញាតកានំ ឧបាសិកានំ អញ្ញស្ស-ត្តាយ អត្តនោ ឆនេន ឧម្មត្តកស្ស អាធិកម្មិកស្ស-ត្តិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុសំគាល់ក្នុងនំឫសដូវដែលមិនពេញកំណត់ពីរបីបាត្រថា លើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងនំឫសដូវដែលមិនពេញពីរបីបាត្រ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងនំឫសដូវដែលមិនពេញពីរបីបាត្រថា មិនពេញមែន មិនត្រូវអាបត្តិ ។

[១១៦] អាបត្តិមិនមាន ដល់ភិក្ខុដែលទទួលនំឫសដូវកំណត់ពេញត្រឹមតែពីរបីបាត្រ ដល់ភិក្ខុដែលទទួលនំឫសដូវមិនពេញពីរបីបាត្រ ដល់ភិក្ខុដែលទទួលវត្ថុ (ឯណានីមួយ) ដែលជនមិនតាក់តែង ដើម្បីបញ្ជូនទៅ (ញាតិ) មិនតាក់តែង ដើម្បីជាស្បៀង ដល់ភិក្ខុដែលទទួលវត្ថុដ៏សេសសល់អំពីនំ ឫសដូវដែលគេចាត់ចែងដើម្បីបញ្ជូនទៅ (ញាតិ) ក្តី ដើម្បីជាស្បៀងក្តី ដល់ភិក្ខុដែលទទួលនំឫសដូវអំពីជនដែលគេមានដំណើរប្រុងនឹងទៅហើយខានវិញ ដល់ភិក្ខុដែលទទួលនំឫសដូវរបស់ញាតិ ដល់ភិក្ខុដែលទទួលនំឫសដូវ របស់ជនដែលបវារណា ដល់ភិក្ខុដែលទទួលនំឫសដូវដើម្បីអ្នកដទៃ ដល់ភិក្ខុដែលទទួលនំឫសដូវ ដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

បញ្ចមសិក្ខាបទំ

[១១៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន អញ្ញតរោ ព្រាហ្មណো ភិក្ខូ
ឧិមន្តេត្វា ភោជេសិ ។ ភិក្ខូ ភុត្តាវី បវារិតា ញាតិ-
ការណិ តត្ថ ឯកចេ ភុញ្ជិំសុ ឯកចេ បិណ្ឌាចារំ
អាគាយ អគមំសុ ។ អថខោ សោ ព្រាហ្មណো បដិ-
វិស្សកេ ឯតទវោច ភិក្ខូ មយា អយ្យា សន្តប្បិតា
ឯថ តុម្ហេបិ សន្តប្បេស្សាមីតិ ។ តេ ឯវមាហំសុ ភ
ន្តំ អយ្យ អម្ហេ សន្តប្បេស្សសិ យេបិ តយា ឧិមន្ត្តិ
តេបិ អម្ហាកំ ឃរានិ អាគត្វា ឯកចេ ភុញ្ជិំសុ ឯ-
កចេ បិណ្ឌាចារំ អាគាយ អគមំសូតិ ។ អថខោ
សោ ព្រាហ្មណো ឧជ្ឌាយតិ ខីយតិ វិចាវេតិ ភ
ហិ ជាម ភទ្ទន្ត អម្ហាកំ ឃរេ ភុញ្ជិត្វា អញ្ញត្រ
ភុញ្ជិស្សន្តិ ន ចាហំ បដិពលោ យាវទត្ថំ ទាតុន្តិ ។

សិក្ខាបទទី ៥

[១១៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់និមន្តភិក្ខុទាំងឡាយឲ្យធាន់ ។ ពួកភិក្ខុធាន់ហើយបានហាមភត្តហើយ ក៏ទៅកាន់ត្រកូលញាតិទាំងឡាយ ភិក្ខុពួកខ្លះ ក៏ធាន់ ភិក្ខុពួកខ្លះកាន់យកបិណ្ឌបាតទៅ ។ គ្រានោះ ព្រាហ្មណ៍នោះបានពោលពាក្យនេះនឹងពួកជនជាអ្នកស្និទ្ធស្នាលថា បពិត្រអ្នកម្ចាស់ទាំងឡាយ ភិក្ខុទាំងឡាយ ខ្ញុំបានប្រគេនចង្ហាន់ធាន់បរិបូណ៌ហើយ សូមអ្នកទាំងឡាយ អញ្ជើញមក ខ្ញុំនឹងអង្គាសអ្នកពាល់គ្នាទៀត ។ អ្នកស្និទ្ធស្នាលទាំងនោះ ពោលយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកនឹងអង្គាសយើងទាំងឡាយឲ្យឆ្អែតដូចម្តេចបាន អម្បាលភិក្ខុទាំងឡាយណា ដែលអ្នកនិមន្តមកហើយ ភិក្ខុទាំងនោះមកកាន់ផ្ទះពួកយើង ខ្លះធាន់ ខ្លះកាន់យកបិណ្ឌបាតហើយទៅ ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្ទុះបង្ហាប់ថា លោកដ៏ចម្រើនទាំងឡាយ មិនសមនឹងធាន់ក្នុងផ្ទះយើងទាំងឡាយហើយទៅធាន់ក្នុងទីដទៃទៀតសោះ ហាក់ដូចជាខ្ញុំមិនអាចដើម្បីប្រគេនលោកធាន់ឲ្យឆ្អែតបាន ។

បាចិត្តិយកណ្ឌ ភោជនវគ្គស្ស បញ្ចមសិក្ខាបទស្ស បឋមប្ញញ្ញត្តិ

អស្សោសុំ ខោ ភិក្ខូ ឥស្ស ព្រាហ្មណស្ស ឧជ្ឈា-
យន្តស្ស ខីយន្តស្ស វិចោចេន្តស្ស ។ យេ តេ ភិក្ខូ
អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចោចេន្តិ កថំ
ហិ នាម ភិក្ខូ ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជិស្សន្តីតិ
។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ភុត្តាវី បវារិតា អញ្ញ-
ត្រ ភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា
កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ភុត្តាវី បវា-
រិតា អញ្ញត្រ ភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្ឋសន្ធានំ វា
បសាទាយ បសន្ធានំ វា កិយ្យោការាយ ។ បេ ។
ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ
យោ បន ភិក្ខុ ភុត្តាវី បវារិតោ ខាទនីយំ វា
ភោជនីយំ វា ខាទেយ្យ វា ភុញ្ជেយ្យ វា ចាចិត្តि-
យន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ
បញ្ញត្តំ ហោតិ ។

ពួកភិក្ខុឮព្រាហ្មណ៍នោះពោលទោស តិះដៀល បន្ទុះបង្ហាប់ (ដូច្នោះ) ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុទាំងឡាយ ឆាន់ហើយហាមភត្តរួចហើយ មិនគួរនឹងទៅឆាន់ក្នុងទីដទៃទៀតសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយ ឆាន់ហើយហាមភត្តហើយ រួចទៅឆាន់ក្នុងទីដទៃទៀត ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ ឆាន់ហើយហាមភត្តរួចហើយ ហេតុអ្វី ក៏ទៅឆាន់ក្នុងទីដទៃទៀត ម្នាលភិក្ខុទាំងឡាយ ការណ៍នេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឆាន់ហើយហាមភត្តហើយ ទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១១៨] តេន ខោ បន សមយេន ភិក្ខូ តិលា-
ជានំ ភិក្ខូនំ បណីតេ បិណ្ឌាចាតេ ឌីហរន្តិ ។ តិលាជា
ន ចិត្តរូបំ ភុញ្ជន្តិ ។ តានិ ភិក្ខូ ឆឌ្ឌេន្តិ ។ អស្សោសិ
ខោ ភគវា ឧច្ចាសទ្ទំ មហាសទ្ទំ ការាការវសទ្ទំ សុ-
ត្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ ការុ ខោ សោ
អានន្ទ ឧច្ចាសទ្ទោ មហាសទ្ទោ ការាការវសទ្ទោតិ ។
អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោ-
ចេសិ ។ ភុញ្ជេយ្យុំ បជានន្ទ ភិក្ខូ តិលាជាតិវិត្តន្តិ ។
ន ភុញ្ជេយ្យុំ ភគវាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ
ឯតស្មឹ បការណេ ធម្មឹ ការំ ការ្យា ភិក្ខូ អាមន្តេសិ
អនុជានামិ ភិក្ខវេ តិលានសួ ច អតិលានសួ ច
អតិវិត្តំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ អតិវិត្តំ ការ្តព្ពំ
អលមេតំ សព្ពន្តិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ

[១១៨] សម័យនោះឯង ភិក្ខុទាំងឡាយ នាំយកនូវបិណ្ឌបាតដ៏ឧត្តមទៅឲ្យពួកភិក្ខុឈឺ ។ ពួកភិក្ខុឈឺធាន់មិនបានដោយស្រួល ។ ពួកភិក្ខុនាំគ្នាចោលបិណ្ឌបាតដ៏ឧត្តមទាំងនោះ ។ ព្រះដ៏មានព្រះភាគ បានឮសំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ជ្រៀវនៃក្អែក លុះឮហើយទ្រង់ហៅព្រះអានន្ទដ៏មានអាយុហើយត្រាស់សួរថា ម្នាលអានន្ទ សំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ជ្រៀវនៃក្អែក សំឡេងនោះ ជាសំឡេងអ្វីហ្ន៎ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ពួកភិក្ខុធាន់ភោជនដ៏សល់អំពីភិក្ខុឈឺ ពិតមែនឬ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពួកភិក្ខុមិនធាន់ទេ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធាន់ភោជនដ៏សល់អំពីភិក្ខុឈឺក្ដី ភិក្ខុមិនឈឺក្ដី ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវធ្វើភោជនដ៏សល់ (អំពីភិក្ខុឈឺ) ដោយពាក្យយ៉ាងនេះថា ភោជនទាំងអស់នេះសមគួរហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយធាន់ហើយ

ឧទ្ធិសេយ្យាថ យោ បន ភិក្ខុ ភុត្តាវី បវារិតោ អនតិរិត្តំ ខាទនីយំ វា ភោជនីយំ វា ខាទেយ្យ វា ភុញ្ជেយ្យ វា បាចិត្តិយន្តិ ។

[១១៩] យោ បជានាតិ យោ យាជិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថে អធិប្ប្បেតো ភិក្ខូ-តិ ។ ភុត្តាវី ជាម បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ អន្តមសো ភុសក្ខেនបិ ភុត្តំ ហোតি ។ បវារিতো ជាម អសនং បញ្ញាយតি ភোជনং បញ្ញាយតি ហত্থপাসে ঠিতো অভিহারতি পটিক্খেপো পঞ্ঞায়তি । অনতিরিত্তং

បានហាមភោជនហើយ ទំពាស៊ីក្ដី ឆាន់ក្ដី នូវខាទនីយាហារ ឬភោជនី-យាហារដែលជាអនតិរិត្ត គឺជាវត្ថុដែលមិនបានធ្វើវិនយកម្ម និងមិនមែនសល់អំពីភិក្ខុឈឺ ត្រូវអាបត្តិបាចិត្តិយ ។

[១១៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ បេ ។ ដែលហៅថា ឆាន់ហើយ គឺឆាន់ភោជន ៥ យ៉ាង ភោជនណាមួយ ដោយហោចទៅសូម្បីតែភោជនប្រមាណប៉ុនចុងស្លរ ។ ដែលហៅថា ហាមភោជន (គឺហាមប្រកបដោយអង្គ ៥ យ៉ាង) គឺភិក្ខុកំពុងឆាន់ ១ គេយកភោជនមកប្រគេនទៀត ១ គេនៅក្នុងហត្ថបាស ១ គេបង្ហោនភោជនមកចំពោះ ១ ភិក្ខុហាមភោជន ១ ។ ដែលហៅថា អនតិរិត្ត[1]

---

១ អដ្ឋកថា ដែលហៅថា អនតិរិត្តភោជន បានដល់ភោជនដែលមិនគួរដល់អាការនៃវិនយកម្ម ៧ យ៉ាង និងភោជន ដែលមិនមែនសល់អំពីភិក្ខុឈឺ ។

ឯអាការដែលមិនគួរដល់វិនយកម្ម ៧ យ៉ាងនោះ អធិប្បាយថា

១ វត្ថុទាំងឡាយមានផ្លែនិងមើមជាដើម ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរដល់សមណកប្បក្ដី និងសាច់ដែលមិនគួរក្ដី ភោជនដែលមិនគួរក្ដី ហៅថាអកប្បិយទាំងអស់ ភិក្ខុអ្នកធ្វើវិនយកម្ម យកអកប្បិយវត្ថុទាំងនេះមកធ្វើជាវិនយកម្មថា វត្ថុទាំងអស់នេះ ជារបស់គួរហើយ ។

២ វត្ថុដែលភិក្ខុអ្នកធ្វើវិនយកម្មមិនទាន់បានទទួលមកទេ ហើយធ្វើវិនយកម្មថា វត្ថុទាំងអស់នេះគួរហើយ ។

៣ វត្ថុដែលភិក្ខុកាន់មកដើម្បីឲ្យភិក្ខុអ្នកធ្វើវិនយកម្ម ធ្វើឲ្យជារបស់គួរតែមិនបានលើកឡើង ឬមិនបានបង្ហោនទៅ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

ជាម អកប្ជិយកតំ ហោតិ អប្ជដិក្ខិតកតំ ហោតិ

អនុច្ចារិតកតំ ហោតិ អហាត្ជចាសេ កតំ ហោតិ អ-

ភុត្ជាវិជា កតំ ហោតិ ភុត្ជាវិជា ឧវារិតេជ អាសជា

ឧដ្ឋិតេជ កតំ ហោតិ អលមេតំ សព្ជន្ដិ អវុត្ដំ ហោតិ

ជ កិលាជាតិវិត្ដំ ហោតិ ឯតំ អជតិវិត្ដំ ជាម ។ អតិវិត្ដំ

ជាម កប្ជិយកតំ ហោតិ ឧដិក្ខិតកតំ ហោតិ

បានដល់វត្ថុដែលមិនបានធ្វើវិនយកម្ម (ដោយអាការ ៧ យ៉ាង) គឺរបស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ ១ របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុមិនបានលើកឡើង (ឬ) មិនបានបង្ហោនចូលទៅជិតដើម្បីឲ្យភិក្ខុធ្វើឲ្យជារបស់គួរ ១ ភិក្ខុមិនបិតនៅខាងក្នុងហត្ថបាសហើយធ្វើ ១ ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ ១ ភិក្ខុឆាន់ហើយបានហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ១ និងវត្ថុដែលមិនមែនជារបស់សល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះហៅថា អនតិរិត្ត ។ ដែលហៅថាអតិរិត្តនោះ បានដល់វត្ថុដែលបានធ្វើវិនយកម្ម (ដោយអាការ ៧ យ៉ាង)

---

៤ ភិក្ខុកាន់យកវត្ថុមកដើម្បីឲ្យភិក្ខុផងគ្នាធ្វើវិនយកម្មឲ្យ តែភិក្ខុអ្នកធ្វើវិនយកម្មនោះបិតនៅខាងក្រៅហត្ថបាសហើយ ធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

៥ ភិក្ខុណាមួយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ តែភិក្ខុអ្នកធ្វើវិនយកម្មនោះឯងមិនទាន់ឆាន់ភោជននៅឡើយ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

៦ ភិក្ខុអ្នកធ្វើវិនយកម្មបានឆាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈហើយ ទៅធ្វើវិនយកម្មឲ្យគេថា របស់ទាំងអស់នេះគួរហើយ ។

៧ ភិក្ខុអ្នកធ្វើវិនយកម្ម មិនបានបញ្ជូញវចីភេទថា របស់ទាំងអស់នេះគួរហើយ ។

និងភោជន ៥ យ៉ាង ភោជនណាមួយដែលមិនមែនសល់អំពីភិក្ខុឈឺ ។ វត្ថុដែលមិនគួរដល់អាការនៃវិនយកម្មទាំង ៧ យ៉ាងនេះក្តី ភោជនដែលមិនមែនសល់អំពីភិក្ខុឈឺក្តី ទាំងពីរចំណែកនេះហៅថា អនតិរិត្តភោជន ។

ឧច្ចារិតកតំ ហោតិ ហត្ថចាសេ កតំ ហោតិ ភុត្តាវិនា កតំ ហោតិ ភុត្តាវិនា បវារិតេន អាសនា អុដ្ឋិតេន កតំ ហោតិ អលមេតំ សព្វន្តិ រុត្តំ ហោតិ តិលានា-តិរិត្តំ ហោតិ ឯតំ អតិរិត្តំ ជាម ។ ខាទនីយំ ជាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ បបេត្វា អវសេសំ ខាទនីយំ ជាម ។ ភោជនីយំ ជាម បញ្ច ភោជនានិ ឧិនោ ភុម្ហាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោ-ហារេ អាបត្តិ ចាចិត្តិយស្ស ។

[១២០] អនតិរិត្តេ អនតិរិត្តសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិយស្ស ។ អនតិរិត្តេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចា-ចិត្តិយស្ស ។ អនតិរិត្តេ អតិរិត្តសញ្ញី ខាទនីយំ វា

គឺ របស់ដែលគេធ្វើឲ្យជាវត្ថុគួរ ១ របស់ដែលភិក្ខុបានទទួលហើយធ្វើ ឲ្យជារបស់គួរ ១ របស់ដែលភិក្ខុលើកឡើង ឬបានបង្ហោនទៅជិត ដើម្បី ធ្វើឲ្យជារបស់គួរ ១ ភិក្ខុនៅក្នុងហត្ថបាសហើយធ្វើ ១ ភិក្ខុឆាន់រួចហើយ ទើបធ្វើ ១ របស់ដែលភិក្ខុឆាន់ហើយហាមភោជនហើយ មិនទាន់ក្រាក ចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុពោលថា របស់ទាំងអស់នេះគួរ ហើយ ១ និងរបស់ដែលសល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះ ហៅថា អតិរិត្ត ។ ដែលហៅថា ខាទនីយាហារនោះ បានដល់របស់ទាំងអស់ រៀរលែងតែភោជន ៥ យ៉ាង និងរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយាហារ ។ ដែលហៅថា ភោជនីយាហារ នោះ បានដល់ភោជន ៥ យ៉ាងគឺ បាយ នំស្រស់ នំក្រៀម ត្រី សាច់ ។ ភិក្ខុទទួលដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិ ទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ វារៈដែលលេបចូល ។

[១២០] *ខាទនីយភោជនីយាហារ ជាអនតិរិត្ត ភិក្ខុសំគាល់ថា ជា អនតិរិត្តពិតមែន ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនី-យាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងខាទនីយភោជនីយាហារ ជាអនតិរិត្ត ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារ ជាអនតិរិត្ត*

ភោជនីយំ វ ខាទតិ វ ភុញ្ជតិ វ អាបត្តិ ចាចិត្តិ-
យស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវ-
ជីវិកំ អាហារត្ថាយ បដិក្ខណ្ហាតិ អាបត្តិ ទុក្កដស្ស ។
អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ទុក្កដស្ស ។ អតិរិត្តេ
អនតិរិត្តសញ្ញី អាបត្តិ ទុក្កដស្ស ។ អតិរិត្តេ វេមតិកោ
អាបត្តិ ទុក្កដស្ស ។ អតិរិត្តេ អតិរិត្តសញ្ញី អនាបត្តិ ។

[១២១] អនាបត្តិ អតិរិត្តំ ការាបេត្វា ភុញ្ជតិ អតិរិត្តំ
ការាបេត្វា ភុញ្ជិស្សាមីតិ បដិក្ខណ្ហាតិ អញ្ញស្សត្ថាយ
ហរន្តោ ឧច្ចតិ កិលាសស្ស សេសកំ ភុញ្ជតិ យាម-
កាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ
បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

ថា ជាអតិរិត្តទៅវិញ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬ ភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ ៗ វារៈដែលលេបចូល ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្តថា ជាអនតិរិត្តទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងខាទនីយភោជនីយាហារ ដែលជាអតិរិត្ត ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្តថា ជាអតិរិត្តពិតមែន មិនត្រូវអាបត្តិ ។

[១២១] អាបត្តិមិនមាន ដល់ភិក្ខុដែលឲ្យគេធ្វើវិនយកម្មហើយធាន់ ដល់ភិក្ខុដែលទទួលរបស់ដោយគិតថា អញនឹងឲ្យគេធ្វើវិនយកម្មហើយធាន់ ដល់ភិក្ខុដែលនាំយករបស់ទៅដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលធាន់របស់ដ៏សេសសល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលធាន់របស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកដោយមានហេតុ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

ឆដ្ឋសិក្ខាបទំ

[១២២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ទ្វេ ភិក្ខូ កោសលេសុ ជនបទេសុ សាវត្ថឿ អទ្ធានមគ្គប្បដិបន្ន ហោន្តិ ។ ឯកោ ភិក្ខុ អនាចារំ អាចរតិ ។ ទុតិយោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច មា អាវុសោ ឯវរូបំ អកាសិ នេតំ កប្បតីតិ ។ សោ តស្មឿ ឧបនន្ទិ ។ អថខោ តេ ភិក្ខូ សាវត្ថឿ អតមំសុ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរស្ស ឃូតស្ស សជ្ជ្ជកត្តំ ហោតិ ។ ទុតិយោ ភិក្ខុ ភុត្តាវី ឧបរិ-តោ ហោតិ ។ ឧបនន្ទោ ភិក្ខុ ញាតិកុលំ គន្ត្វា បិណ្ឌាចារំ អាចាយ យេន សោ ភិក្ខុ តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា តំ ភិក្ខុំ ឯតទវោច ភុញ្ជាហិ អាវុសោតិ ។ អលំ អាវុសោ ឧបរិបុណ្ណោម្ហីតិ ។ សុន្ទរោ អាវុសោ ឧបរិបុណ្ណោ ភុញ្ជាហីតិ ។ អថខោ សោ

សិក្ខាបទទី ៦

[១២២] កាលណោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុពីររូបដើរផ្ទូវធ្វាយទៅក្រុងសាវត្ថីក្នុងកោសលជនបទ ។ ភិក្ខុ ១ រូប ប្រព្រឹត្តអនាចារ ។ ភិក្ខុជាគម្រប់ពីរបាននិយាយពាក្យនេះ (ឃាត់) ភិក្ខុនោះ ថា ម្នាលលោកដ៏មានអាយុ លោកកុំធ្វើអំពើយ៉ាងនេះ អំពើដែលលោក ធ្វើនេះ មិនគួរទេ ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះ ក៏ចង់ពៀរនឹងភិក្ខុអ្នក ឃាត់នោះ ។ គ្រានោះ ភិក្ខុទាំងនោះ បានទៅកាន់ក្រុងសាវត្ថី ។ សម័យ នោះឯង ក្នុងក្រុងសាវត្ថីមានប្រជុំជនមួយពួក (ធ្វើ) សង្ឆ្យកត្ត ។ ភិក្ខុ ជាគម្រប់ពីរបានធាន់សង្ឆ្យកត្តរួចហើយហាមកត្តហើយ ។ ភិក្ខុដែលចង់ពៀរ ទៅកាន់ត្រកូលជាញាតិហើយទទួលបិណ្ឌបាត រួចហើយក៏ចូលទៅរកភិក្ខុ ដែលហាមកត្តនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុ អ្នកហាមកត្តនោះថា ម្នាលលោកដ៏មានអាយុ លោកចូរធាន់ (ចង្ហាន់ នេះ) ចុះ ។ ភិក្ខុអ្នកហាមកត្ត ក៏ប្រកែកថា កុំអាវុសោ ខ្ញុំធាន់បរិបូណ៌ ហើយ ។ ភិក្ខុដែលចង់ពៀរ ក៏អង្វរថា ម្នាលអាវុសោ បិណ្ឌបាត (នេះ) ល្អ លោកចូរធាន់ទៅ ។ កាលបើភិក្ខុអ្នកចង់ពៀរនោះ ជម្រុលខ្លាំងពេក

ភិក្ខុ តេន ភិក្ខុនា ឌិប្បីឌ្ឍិយមានោ តំ បិណ្ឌាចា-
តំ ភុញ្ជ[1] ។ ឧបនន្ទោ[2] ភិក្ខុ តំ ភិក្ខុំ ឯតទវោច
ត្វំ ហិ ណាម អាវុសោ មំ វត្តុំ មញ្ញសិ យំ ត្វំ
ភុត្តាវី បវារិតោ អនតិរិត្តំ ភោជនំ ភុញ្ជសីតិ ។ ន-
ន្ទ អាវុសោ អាចិក្ខិតព្ពន្តិ ។ ន ន្ទ អាវុសោ បុច្ឆិតព្ពន្តិ ។
អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។
យេ តេ ភិក្ខូ អប្ឌិច្ឆា ។ បេ ។ តេ ឧជ្ឌាយន្តិ
ខីយន្តិ វិចារេន្តិ កថំ ហិ ណាម ភិក្ខុ ភិក្ខុំ
ភុត្តាវឺ បវារិតំ អនតិរិត្តេន ភោជនេន អភិហដ្ឋុំ
បវារេស្ឍតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ ភិក្ខុំ
ភុត្តាវឺ បវារិតំ អនតិរិត្តេន ភោជនេន អភិហដ្ឋុំ
បវារេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ ណាម ត្វំ មោឃបុរិស ភិក្ខុំ ភុត្តាវឺ
បវារិតំ អនតិរិត្តេន ភោជនេន អភិហដ្ឋុំ បវារេស្ឍសិ
នេតំ មោឃបុរិស អប្ឌសន្ធានំ វា បសាទាយ

---

១ ឱ.ម. ភុញ្ជតិ ។ ២ ឱ. ម. ឧបនន្ទោ ។

ភិក្ខុអ្នកហាមភត្តនោះ (ទ្រាំមិនបាន) ក៏ធាន់បិណ្ឌបាតនោះទៅ ។ ភិក្ខុដែលចង់ពៀរ ក៏ពោលពាក្យនេះនឹងភិក្ខុអ្នកហាមភត្តនោះថា ម្នាលអាវុសោ លោកសំគាល់មកខ្ញុំថាជាបុគ្គលដែលគេត្រូវតែស្តីថា ឬអ្វី ក៏រូបលោកធាន់រួចហើយហាមភត្តហើយ ម្តេចឡើយ ក៏នៅតែធាន់អនតិរិត្តភោជន ។ ភិក្ខុអ្នកហាមភត្តនោះតបថា ម្នាលអាវុសោ ហេតុម្តេច លោកមិនប្រាប់ (ខ្ញុំ) ផង ។ ភិក្ខុអ្នកចង់ពៀរ ក៏ឆ្ងើយថា ហេតុម្តេច លោកមិនសួរ (ខ្ញុំជាមុន) ។ ភិក្ខុអ្នកហាមភត្តនោះ ក៏ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយក្នុងខណៈនោះ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុមិនគួរនឹងនាំកត្តទៅហើយបវ-រណាបង្ខំភិក្ខុដែលធាន់ហើយហាមភត្តហើយ ឲ្យធាន់នូវអនតិរិត្តភោជន (ដូច្នេះ) សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងបាននាំកត្តទៅបវារណាបង្ខំភិក្ខុដែលធាន់ហើយ ហាមភោជនហើយ ឲ្យធាន់អនតិរិត្តភោជន ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងនាំកត្តទៅបវារណាបង្ខំភិក្ខុដែលធាន់ហើយហាមភត្តហើយ ឲ្យធាន់អនតិរិត្តភោជនទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា

បសន្នានំ វា កិយ្យាការាយ ។ បេ ។ ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ភុត្តាវី បវារិតំ អនតិរិត្តេន ខាទនីយេន វា ភោជនី-យេន វា អភិហដ្ឋុំ បវារេយ្យ ហន្ទ ភិក្ខុ ខាទ វា ភុញ្ជ វាតិ ជានំ អាសាទនាបេក្ខោ ភុត្តស្មឿ ចាចិត្តិយន្តិ ។

[១២៣] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឿ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញេ ភិក្ខុំ ។ ភុត្តាវី នាម បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ អន្តមសោ ភុ-សត្ថេនបិ ភុត្តំ ហោតិ ។ បវារិតោ នាម អសនំ បញ្ញាយតិ ភោជនំ បញ្ញាយតិ ហត្ថបាសេ ឋិតោ អភិហរតិ បដិក្ខេបោ បញ្ញាយតិ ។ អនតិរិត្តំ នាម អកប្ប្យិយកតំ ហោតិ អប្ប្យដិក្ខិត្តកតំ ហោតិ អនុច្ចារិតកតំ ហោតិ អហត្ថបាសេ កតំ ហោតិ

ឬនាំពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងហើយរំពៃរកទោសនាំកត្តទៅបវារណាបង្ខំភិក្ខុដែលធាន់ហើយហាមកត្តហើយ ឲ្យទំពាស៊ីក្ដី បរិភោគក្ដី នូវអនតិរិត្តភោជន ដោយពាក្យថា នែភិក្ខុ អ្នកចូរទំពាស៊ីក្ដី បរិភោគក្ដីដូច្នេះ និមិត្តតែភិក្ខុនោះធាន់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[១២៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ ដែលហៅថា ធាន់ហើយ គឺភិក្ខុបានធាន់នូវភោជនទាំង ៥ យ៉ាង ភោជនណាមួយ ដោយហោចទៅ សូម្បីតែប៉ុនចុងស្លាវភ្ជាំង ។ ដែលហៅថា ហាមកត្ត (គឺហាមប្រកបដោយអង្គ ៥ យ៉ាង) គឺភិក្ខុកំពុងធាន់ ១ គេយកភោជនមកប្រគេនទៀត ១ គេបិតនៅក្នុងហត្ថបាស ១ គេបង្ហោនភោជនមកចំពោះ ១ ភិក្ខុហាមភោជន ១ ។ ដែលហៅថា អនតិរិត្ត បានដល់វត្ថុដែលមិនបានធ្វើវិនយកម្ម ដោយ (អាការ ៧ យ៉ាង) គឺរបស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ ១ របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុមិនបានលើកឡើង (ឬមិនបានបង្ហោនចូលទៅជិតដើម្បីធ្វើឲ្យជារបស់គួរ) ១ ភិក្ខុមិនស្ថិតនៅខាងក្នុងហត្ថបាសហើយធ្វើ ១

អកុត្តាវិនា ឆេតំ ហោតិ កុត្តាវិនា បហារិតេន អាសនា
រុដ្ឋិតេន ឆេតំ ហោតិ អលមេតំ សព្វន្តិ អវុត្តំ ហោតិ
ន តិលាជាតិវិត្តំ ហោតិ ឯតំ អជតិវិត្តំ ជាម ។
ខាទនីយំ ជាម បញ្ចេ ភោជនានិ យាមកាលិកំ
សត្តាហកាលិកំ យាវជីវិកំ បវេត្វា អវសេសំ ខាទ-
នីយំ ជាម ។ ភោជនីយំ ជាម បញ្ចេ ភោជនានិ
ឧិនោ ឆុម្ហាសោ សត្ត មញ្ជា មំសំ ។ អកិហាដ្ដ
បហារេយ្យាតិ យាវតកំ ឥច្ឆសិ តាវតកំ ឆណ្ហាហីតិ ។
ជានាតិ ជាម សាមំ វ ជានាតិ អញ្ញេ វ ឥស្ស
អារោចេន្តិ សោ វ អារោចេតិ ។ អាសាទនាបេក្ខោតិ
ឥមិនា ឥមំ ចោទេស្សាមិ សារេស្សាមិ បដិចោទេស្សាមិ
បដិសារេស្សាមិ មង្ខ្ញុ ការិស្សាមីតិ អកិហរតិ អាបត្តិ
ទុក្ខ្ជស្ស ។ ឥស្ស រចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ

ភិក្ខុមិនទាន់ធាន់ហើយធ្វើ ១ ភិក្ខុធាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ១ និងវត្ថុដែលមិនមែនជារបស់សល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះហៅថា អនតិរិត្ត ។ ដែលហៅថា ខាទនីយ (នោះ) បានដល់វត្ថុទាំងអស់ លើកលែងភោជនទាំង ៥ យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិកចេញ ហៅថា ខាទនីយ ។ ដែលហៅថា ភោជនីយ បានដល់ភោជន ៥ យ៉ាងគឺ បាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ពាក្យថា នាំកត្តទៅបវារណា (នោះ) គឺភិក្ខុនិយាយថា លោកចង់បានប៉ុន្មាន និមន្តយកប៉ុណ្ណោះចុះ ។ ដែលហៅថា ដឹង (នោះ) គឺភិក្ខុដឹងខ្លួនឯង ឬពួកជនដទៃប្រាប់ដល់ភិក្ខុអ្នកចោទនោះ ឬក៏ភិក្ខុអ្នកហាមភោជននោះប្រាប់ ។ ពាក្យថា រំពៃរកទោស (នោះ) គឺ ភិក្ខុនាំយក (ខាទនីយ ឬភោជនីយ) ទៅដោយគិតថា អញនឹងចោទ នឹងរំលឹកភិក្ខុនេះ ដោយវត្ថុនេះ អញនឹងចោទចំពោះ នឹងរំលឹកចំពោះភិក្ខុនេះ ដោយវត្ថុនេះ អញនឹងធ្វើភិក្ខុនេះឲ្យអាប់មុខ ដោយវត្ថុនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកហាមភោជនទទួល ដោយគិតថា អញនឹងទំពាស៊ី នឹងធាន់

បដិក្ខណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោ-
ហារេ អាបត្តិ ទុក្កដស្ស ។ ភោជនបរិយោសានេ
អាបត្តិ ចាចិត្តិយស្ស ។

[១២៤] បវារិតេ បវារិតសញ្ញី អនតិរិត្តេន ខាទនី-
យេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេតិ អាបត្តិ
ចាចិត្តិយស្ស ។ បវារិតេ វេមតិកោ អនតិរិត្តេន
ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេតិ
អាបត្តិ ទុក្កដស្ស ។ បវារិតេ អប្ប្ឌារិតសញ្ញី[១] អនតិ-
រិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេតិ
អនាបត្តិ ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ
អាហារត្ថាយ អភិហរតិ អាបត្តិ ទុក្កដស្ស ។ តស្ស
វចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិក្ខណ្ហាតិ អាបត្តិ
ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ទុក្ក-
ដស្ស ។ អប្ប្ឌារិតេ[២] បវារិតសញ្ញី អាបត្តិ ទុក្កដស្ស ។
អប្ប្ឌារិតេ[៣] វេមតិកោ អាបត្តិ ទុក្កដស្ស ។ អប្ប-
ារិតេ[៤] អប្ប្ឌារិតសញ្ញី[៥] អនាបត្តិ ។

១-២-៣-៤-៥ ឱ. ម. អបវារិតេ ។

តាមពាក្យរបស់លោកអ្នកចោទ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ខណៈដែលលេប ។ លុះភិក្ខុនោះ ធាន់រួចស្រេច ភិក្ខុអ្នកបង្ខំ ត្រូវអាបត្តិបាចិត្តិយ ។

[១២៧] ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទសំគាល់ថា ហាមហើយ ក៏នាំខាទនីយឬភោជនីយដែលជាអនតិរិត្តទៅបង្ខំ (ភិក្ខុនោះ) ឲ្យធាន់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទមានសេចក្តីសង្ស័យ ក៏នាំខាទនីយឬភោជនីយដែលជាអនតិរិត្តទៅបង្ខំឲ្យធាន់ ត្រូវអា-បត្តិទុក្កដ ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទសំគាល់ថា មិនទាន់ហាម ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំឲ្យធាន់ មិនត្រូវអាបត្តិ ។ ភិក្ខុអ្នកចោទបង្ហោនរបស់ដែលជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកហាមភោជនទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពាស៊ីនឹងធាន់ តាមពាក្យរបស់លោកអ្នកចោទនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដរាល់ ៗ ខណៈដែលលេប ។ ភិក្ខុមិនហាមភោជនទេ តែភិក្ខុអ្នកចោទសំគាល់ថា ហាម ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនហាមភោជនទេ ភិក្ខុអ្នកចោទសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទាន់ហាមភោជន ភិក្ខុអ្នកចោទក៏សំគាល់ថា មិនទាន់ហាមមែន មិនត្រូវអាបត្តិ ។

[១២៤] អជ្ឌាបត្តិ អតិរិត្តំ ការេត្វា ឧតិ អតិរិត្តំ ការាបេត្វា ភុញ្ជាហីតិ ឧតិ អញ្ញស្ស ត្តាយ ហារេ្ជ ឧ ច្ឆាហីតិ ឧតិ តិលានស្ស សេសកំ ឧតិ យាម-ការ្ជ លិកំ សត្តាហការ្ជ លិកំ យាវជីវិកំ សតិ ២ ចូ យ ២ ២ ២

[១២៥] អាបត្តិមិនមាន ដល់ភិក្ខុដែលឲ្យភិក្ខុផងគ្នា ធ្វើវិនយកម្ម ហើយឲ្យ ដល់ភិក្ខុដែលឲ្យដោយពាក្យថា លោកចូរឲ្យគេធ្វើឲ្យជាវិនយ-កម្មហើយនិមន្តធាន់ចុះ ដល់ភិក្ខុដែលឲ្យដោយពាក្យថា លោកចូរនាំ (ខាទនីយភោជនីយាហារនេះ) ទៅដើម្បីប្រយោជន៍ដល់អ្នកដទៃចុះ ដល់ភិក្ខុដែលឲ្យរបស់ដ៏សល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឲ្យរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដោយពាក្យថា កាលបើមានហេតុចូរលោកធាន់ចុះ ដល់ភិក្ខុធ្ពត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

សត្តមសិក្ខាបទំ

[១២៦] តេន សមយេន ពុទ្ធោ ភគវា ភាគ្គវោ
វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ
បន សមយេន ភាគ្គវោ តិរត្តសមច្ឆោ ហោតិ ។ សត្ត-
រសវត្ថុយា ភិក្ខូ តិរត្តសមជ្ជំ ឧស្សាយ អតមំសុ ។
មនុស្សា សត្តរសវត្ថុយេ ភិក្ខូ បស្សិត្វា ឧហាបេត្វា
វិលិម្បេត្វា ភោជេត្វា ខាទនីយំ អទំសុ ។ សត្តរសវត្ថុ-
យា ភិក្ខូ ខាទនីយំ អាទាយ អារាមំ គន្ត្វា ឆព្ភក្ខិ-
យេ ភិក្ខូ ឯតទវោចុំ គណ្ហាថាវុសោ ខាទនីយំ ខាទ-
ថាតិ ។ ឥតោ តុម្ហេហិ អាវុសោ ខាទនីយំ លទ្ធន្តិ ។
សត្តរសវត្ថុយា ភិក្ខូ ឆព្ភក្ខិយានំ ភិក្ខូនំ ឯតមត្ថំ
អារោចេសុំ ។ កិំ បន តុម្ហេ អាវុសោ វិកាលេ
ភោជនំ ភុញ្ជថាតិ ។ ឯវមាវុសោតិ ។ ឆព្ភក្ខិយា ភិក្ខូ
ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សត្ត-
រសវត្ថុយា ភិក្ខូ វិកាលេ ភោជនំ ភុញ្ជិស្សន្តីតិ ។

សិក្ខាបទទី ៧

[១២៦] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង
ក្រុងរាជគ្រឹះលេងមហោស្រពលើកំពូលភ្នំ ។ ពួកសត្តរសវគ្គិយភិក្ខុ
ក៏បានទៅដើម្បីមើលមហោស្រពដែលគេលេងលើកំពូលភ្នំ (នោះ) ។
មនុស្សទាំងឡាយ បានឃើញពួកសត្តរសវគ្គិយភិក្ខុហើយ និមន្តឲ្យស្រង់
ទឹក ឲ្យលាប ឲ្យធាន់ ស្រេចហើយ ក៏ប្រគេននូវខាទនីយៈ ។ ពួកសត្តរស-
វគ្គិយភិក្ខុ កាន់យកខាទនីយៈទៅអារាម ហើយនិយាយពាក្យនេះប្រាប់ពួក
ឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ចូរទទួល
យកខាទនីយៈទៅធាន់ចុះ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះសួរថា ម្នាលអាវុ-
សោទាំងឡាយ ពួកលោកបានខាទនីយៈមកពីណា ។ ពួកសត្តរស-
វគ្គិយភិក្ខុបានប្រាប់រឿងនុ៎ះដល់ឆព្វគ្គិយភិក្ខុទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុ
សួរថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ បានធាន់ភោជនក្នុង
ពេលដែលមិនគួរមែនឬ ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា មែនអាវុសោ
ទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួក
សត្តរសវគ្គិយភិក្ខុ មិនគួរនឹងធាន់ភោជនក្នុងពេលវិកាល (ដូច្នេះ) សោះ ។

អថខោ ឆព្ភិក្ខូ ភិក្ខូ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្ប៎ិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម សត្ត្ថសារក្ខិយា ភិក្ខូ វិកាលេ ភោជនំ ភុញ្ជិ៎ស្ស្ន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ វិកាលេ ភោជនំ ភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគ-ហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុ៎ិសា វិកាលេ ភោជនំ ភុញ្ជិ៎ស្ស្ថ នេតំ មោឃបុ៎ិសា អប្ប-សន្ថានំ វ បសាទាយ បសន្ថានំ វ កិ៎យ្យាការាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទि-សេយ្យាថ យោ បន ភិក្ខុ វិកាលេ ខាទនីយំ វ ភោជនីយំ វ ខាទេ៎យ្យ វ ភុ៎ញ្ជេ៎យ្យ វ ចាចិ៎ត្តិ៎យន្តិ ។

[១២៧] យោ បនាតិ យោ យាទិ៎សោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មិ៎ អត្ថេ អធិ៎ប្ប៎ត្តោ ភិក្ខូតិ ។ វិកាលោ នាម មជ្ឈ៎ន្ទិ៎កេ រ៎ីតិ៎ត្តេ យាវ អរុ-ណុ៎ត្ត៎មនា ។ ខាទនីយំ នាម បញ្ចេ ភោជនានិ

ខណៈនោះឯង ពួកឆព្វគ្គិយភិក្ខុបានប្រាប់រឿងនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកសត្តរសវគ្គិយភិក្ខុ មិនគួរឆាន់ភោជនក្នុងពេលវិកាល (ដូច្នេះ) ទេ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយឆាន់ភោជនក្នុងពេលវិកាល ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងឆាន់ភោជនក្នុងពេលវិកាលទេ នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា នឹងមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលជ្រះថ្លា ស្រាប់ហើយឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះ ដូច្នេះថា ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ក្នុងពេលវិកាល ត្រូវអាបត្តិបាចិត្តិយ ។

[១២៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងបឋមបារាជិកសិក្ខាបទ ។ វេលាដែលព្រះអាទិត្យជ្រៃពីត្រង់ទៅទល់នឹងអរុណរះឡើង ហៅថា ពេលវិកាល ។ ដែលហៅថា ខាទនីយៈ (នោះ)

យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ បវេត្វា អវសេសំ ខាទនីយំ ជាម ។ ភោជនីយំ ជាម បញ្ចូ ភោជនានិ ឧិនោ ភុម្ហាសោ សត្តុ មន្ថោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ចាចិត្តិយស្ស ។

[១២៨] វិកាលេ វិកាលសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិយស្ស ។ វិកាលេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិ-យស្ស ។ វិកាលេ កាលសញ្ញី ខាទនីយំ វា ភោជ-នីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អា-ហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោ-ហារេ អជ្ឌោហារេ អាបត្តិ ទុក្កដស្ស ។ កាលេ

បានដល់របស់ទាំងអស់ រៀងលែងភោជនទាំង ៥ យ៉ាង និងវត្ថុជា យាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយៈ ។ ដែលហៅថា ភោជនីយៈ បានដល់ភោជន ៥ យ៉ាងគឺបាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ វារៈដែលលេបចូលទៅ ។

[១២៨] ពេលវិកាល ភិក្ខុក៏សំគាល់ថា ពេលវិកាល ហើយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ ពេលវិកាល ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទ-នីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ ពេលវិកាល ភិក្ខុសំគាល់ថា កាលគួរ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិ បាចិត្តិយ ។ ភិក្ខុទទួលវត្ថុ ជាយាមកាលិក សត្តាហកាលិក និងយាវជីវិក ទុកសម្រាប់ជាប្រយោជន៍ដល់អាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវ អាបត្តិទុក្កដ គ្រប់ ១ ខណៈដែលលេបចូលទៅ ។ ពេលជាកាលគួរ

វិកាលសញ្ញី អាបត្តិ ទុក្កដស្ស ។ កាលេ វេមតិ-
កោ អាបត្តិ ទុក្កដស្ស ។ កាលេ កាលសញ្ញី
អនាបត្តិ ។

[១២៩] អនាបត្តិ យាមកាលិកំ សត្តាហកា-
លិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្ត-
កស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុសំគាល់ថា ពេលវិកាល ត្រូវអាបត្តិទុក្កដ ។ ពេលជាកាលគួរ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ពេលជាកាលគួរ ភិក្ខុសំគាល់ថា កាលគួរមែន មិនត្រូវអាបត្តិឡើយ ។

[១២៩] អាបត្តិមិនមាន ដល់ភិក្ខុដែលធាន់តែវត្ថុ ជាយាមកាលិក សត្តាហកាលិក និងយាវជីវិកដោយមានហេតុដែលគួរធាន់បាន ដល់ភិក្ខុ ឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

អដ្ឋមសិក្ខាបទំ

[១៣០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មតោ អានន្ទស្ស ឧបជ្ឌាយោ អាយស្មា ឆព្ពគ្គសីសោ[១] អរញ្ញេ វិហរតិ ។ សោ បិណ្ឌាយ ចរិត្វា ពហុំ បិណ្ឌចាតំ លភិត្វា[២] សុក្ខំ[៣] ក្ករំ អារាមំ ហរិត្វា សុក្ខាបេត្វា ឯកិ្ខបតិ យថា អាហារេន អត្ថো ហោតិ តថា ឧឌកេន តេមេត្វា ភុញ្ជតិ ចិរេន តាមំ បិណ្ឌាយ បវិសតិ ។ ភិក្ខូ អាយស្មន្តំ ឆព្ពគ្គសីសំ ឯតទវោចុំ កិស្ស ត្វំ អាវុសោ ចិរេន តាមំ បិណ្ឌាយ បវិសសីតិ ។ អថ ខោ អាយស្មា ឆព្ពគ្គសីសោ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។

---

១ ឱ. ម. ពេលដ្ឋសីសោ ។ ២ ពហុំ បិណ្ឌបាតំ លភិត្វាតិបិ មរម្ម ឱរោបិយ ឧបាត្ត ឧកេ ន ត្ថិ ។ ៣ ឱ. ម. សុក្ខ ក្ខ ។

សិក្ខាបទទី ៨

[១៣០] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះវេឡដ្ឋសីស:ដ៏មានអាយុ ជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងព្រៃ ។ ព្រះថេរ:នោះត្រាច់ទៅបិណ្ឌបាត លុះបានអាហារបិណ្ឌ-បាតជាច្រើនហើយ ក៏នាំយកបាយសុទ្ធ[1] មកកាន់អារាម រួចហាលបាយនោះឲ្យស្ងួតក្រៀមហើយទុកដាក់ កាលណាមានសេចក្តីត្រូវការដោយអាហារទើបយកបាយក្រៀមនោះមកត្រាំទឹក ហើយក៏ឆាន់ក្នុងកាលនោះ យូរ ។ បានលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្តង ។ ភិក្ខុទាំងឡាយ បាននិយាយពាក្យនេះនឹងព្រះវេឡដ្ឋសីស:ដ៏មានអាយុថា ម្នាលអាវុសោ ចុះហេតុអ្វីបានជាយូរ ។ ទើបលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្តង ។ ទើបព្រះវេឡដ្ឋសីស:ដ៏មានអាយុក៏ដំណាលរឿងនុ៎ះ ប្រាប់ភិក្ខុទាំងឡាយ ។

---

១ អដ្ឋកថា គឺបាយតែម្យ៉ាង មិនមានសម្ល និងម្ហូបក្រៀមលាយជាមួយផង ។

ក៏ បន តំ អាវុសោ សន្ធិ្ធិការកំ ភោជនំ ភុញ្ជសី-
តិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្ឆិន្ធា ។ បេ ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម អា-
យស្មា វេឡ្ឍសីសោ សន្ធិ្ធិការកំ ភោជនំ ភុញ្ជិ្ជ-
ឬតិ ។ បេ ។ សចេ ភិរ តំ ។ ១ ១ ១

ពួកភិក្ខុទាំងនោះក៏សួរថា ម្នាលអាវុសោ បើដូច្នោះ មានតែលោកធាន់ភោជនដែលខ្ជូនទុកដាក់ឲ្យកន្ទ្ធងរាត្រី ឬអ្វី ។ ព្រះវេឡដ្ឋសីស:ឆ្វើយថា យ៉ាងហ្នឹងហើយ អាវុសោ ។ ពួកភិក្ខុណា ដែលមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះវេឡដ្ឋសីស:ដ៏មានអាយុ មិនសមបើនឹងធាន់ភោជនដែលខ្ជូនទុកដាក់ឲ្យកន្ទ្ធងរាត្រី (ដូច្នេះ) ទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលវេឡដ្ឋសីស: ឮថាអ្នកឯងបានធាន់ភោជនដែលខ្ជូនទុកដាក់ឲ្យកន្ទ្ធងរាត្រី ពិតមែនឬ ។ ព្រះវេឡដ្ឋសីស:ក្រាបទូលថា សូមទ្រង់មេត្តាប្រោសពិតមែន ។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលវេឡដ្ឋសីស: អ្នកឯងមិនសមបើនឹងធាន់ភោជនដែលខ្ជូនទុកដាក់ឲ្យកន្ទ្ធងរាត្រី (ដូច្នេះ) ទេ ម្នាលវេឡដ្ឋសីស: អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំពួកជនដែលជ្រះថ្លាស្រាប់ហើយឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយ: ឬភោជនីយ:ជាសន្និធិការក: គឺវត្ថុដែលខ្ជូនទុកដាក់ឲ្យកន្ទ្ធងរាត្រី ត្រូវអាបត្តិបាចិត្តិយ ។

បាចិត្តិយកណ្ឌ ភោជនវគ្គស្ស អដ្ឋមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

[១៣១] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សន្និធិការកំ នាម អជ្ជ បដិគ្គហិតំ អបរជ្ជុ ខាទិតំ ហោតិ ។ ខាទនីយំ នាម បញ្ចភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ចាចិត្តិយស្ស ។

[១៣២] សន្និធិការកេ សន្និធិការកសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិយស្ស ។ សន្និធិការកេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិយស្ស ។ សន្និធិការកេ អសន្និធិការកសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាចិត្តិយស្ស ។ យាមកាលិកំ សត្តាហកាលិកំ

[១៣១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹង សិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ខ្ជួនទុកដាក់ឲ្យ កន្ធង៣ត្រី (បានដល់ខាទនីយៈ ឬភោជនីយៈ) ដែលខ្ជួនទទួលទុកក្នុងថ្ងៃនេះ ហើយធាន់ក្នុងថ្ងៃខាងក្រោយ ។ ដែលហៅថា ខាទនីយៈ (នោះ) បានដល់វត្ថុទាំងអស់ សម្រាប់ទំពាស៊ី លៀងលែងតែភោជនទាំង ៥ យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយៈ ។ ដែលហៅថា ភោជនីយៈ បានដល់ភោជនទាំង ៥ យ៉ាង គឺ បាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[១៣២] របស់ដែលជាសន្និធិការកៈ ភិក្ខុក៏សំគាល់ថា ជាសន្និ-ធិការកៈមែន ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ របស់ដែលជាសន្និធិការកៈ ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ របស់ដែលជាសន្និធិការកៈ ភិក្ខុសំគាល់ថា មិនមែនជាសន្និធិការកៈ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលវត្ថុ ជាយាមកាលិក សត្តាហកាលិក

យាវជីវិកំ អាហារត្ថាយ បដិក្ខណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ទុក្កដស្ស ។ អសន្និ-ធិការកេ សន្និធិការកសញ្ញី អាបត្តិ ទុក្កដស្ស ។ អសន្និធិការកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសន្និធិការកេ អសន្និធិការកសញ្ញី អនាបត្តិ ។

[១៣៣] អនាបត្តិ យាវកាលិកំ យាវកាលេ និធហិត្វា ភុញ្ជតិ យាមកាលិកំ យាមេ និធហិត្វា ភុញ្ជតិ សត្តាហកាលិកំ សត្តាហំ និធហិត្វា ភុញ្ជតិ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឌមសិក្ខាបទំ និដ្ឌិតំ ។

យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ ៗ ខណៈដែលលេបចូលទៅ ។ របស់ដែលមិនមែនជាសន្និធិការកៈ ភិក្ខុសំគាល់ថា ជាសន្និធិការកៈ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនជាសន្និ-ធិការកៈ ភិក្ខុក៏សំគាល់ថា មិនមែនជាសន្និធិការកៈ មិនត្រូវអាបត្តិឡើយ ។

[១៣៣] អាបត្តិមិនមាន ដល់ភិក្ខុដែលទុកដាក់វត្ថុ ជាយាវកាលិក[១] ហើយធាន់ត្រូវតាមកំណត់កាល ដល់ភិក្ខុដែលទុកដាក់វត្ថុ ជាយាម-កាលិក[២] ហើយធាន់ត្រូវតាមកំណត់យាម (គឺថ្ងៃ ១ យប់ ១) ដល់ភិក្ខុដែលទុកដាក់វត្ថុ ជាសត្តាហកាលិក[៣] ហើយធាន់អស់ត្រឹម ៧ ថ្ងៃ ដល់ភិក្ខុដែលធាន់វត្ថុ ជាយាវជីវិក[៤] ព្រោះមានហេតុដែលគួរធាន់បាន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

---

១ អដ្ឋកថា អាហារមានបាយជាដើម ដែលអ្នកបួសគប្បីឆាន់បានតាំងពីព្រឹកទៅដល់ថ្ងៃត្រង់ ហៅថា យាវកាលិក ។ ២ ទឹក ៨ យ៉ាងមានទឹកស្វាយជាដើម ដែលអ្នកបួសគប្បីឆាន់បានត្រឹមថ្ងៃ ១ យប់ ១ ហៅថា យាមកាលិក ។ ៣ ភេសជ្ជៈ ៥ យ៉ាង មានទឹកដោះថ្លាជាដើម ដែលអ្នកបួសគប្បីទុកឆាន់បានក្នុងរវាង ៧ ថ្ងៃ ហៅថា សត្តាហកាលិក ។ ៤ វត្ថុឯទៀតក្រៅពីកាលិកទាំង ៣ ខាងដើម ដែលអ្នកបួសគប្បីរក្សាទុកឆាន់បានដរាបទាល់អស់មួយជីវិត ហៅថា យាវជីវិក ។

នវមសិក្ខាបទំ

[១៣៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ
បន សមយេន ឆព្ភក្ខិយា ភិក្ខូ បណីតភោជនានិ
អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មនុស្សា ឧជ្ឈា-
យន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម សមណា សក្យ-
បុត្តិយា បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា
ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន មនាបំ កស្ស សាធុំ
ន រុច្ចតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ
ឧជ្ឈាយន្តានំ ខីយន្តានំ វិចាចេន្តានំ ។ យេ តេ ភិក្ខូ
អប្ឋិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ
កថំ ហិ នាម ឆព្ភក្ខិយា ភិក្ខូ បណីតភោជនានិ
អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សន្តីតិ ។ បេ ។
សច្ចំ កិរ តុម្ហេ ភិក្ខវេ បណីតភោជនានិ អត្តនោ
អត្ថាយ វិញ្ញាបេត្វា ភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។

សិក្ខាបទទី ៩

[១៣៧] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង
ពួកឆព្វគ្គិយភិក្ខុ សូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន
ហើយធាន់ ។ ពួកមនុស្ស ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកសម-
ណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមនឹងសូមភោជនដ៏ឧត្តមទាំង
ឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនហើយធាន់សោះ អ្នកណាមួយមិនគាប់ចិត្ត
នឹងភោជនដែលសម្ផូរ អ្នកណាមួយ មិនចូលចិត្តនឹងភោជនដែលមានរស
ឆ្ងាញ់ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះ កំពុងពោលទោស
តិះដៀល បន្ទុះបង្ហាប់ហើយ ។ ពួកភិក្ខុណា ដែលមានសេចក្តីប្រាថ្នាតិច
។ បេ ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួក
ឆព្វគ្គិយភិក្ខុ មិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍
ដល់ខ្លួន ហើយធាន់ដូច្នោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាល
ភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ សូមភោជនដ៏ឧត្តមទាំងឡាយ
មកដើម្បីប្រយោជន៍ដល់ខ្លួន ហើយក៏នាំគ្នាធាន់ ពិតមែនឬ ។
ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។

វិតរហិ ពុទ្ធោ ភគវា ភិក្ខូ ហិ ជាម តុម្ហេ មោឃបុរិសា បណ្ឌិតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សថ នេតំ មោឃបុរិសា អប្ប្ប្

ព្រះសព្វញ្ញូពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលពួកបុរសសោះសូន្យ អ្នកទាំងឡាយ មិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រ-យោជន៍ដល់ខ្លួន ហើយធាន់ដូច្នេះទេ នៃពួកបុរសសោះសូន្យ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ ដូចម្តេច ភោជនដ៏ឧត្តមទាំងនោះគឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយ សូមភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួនហើយធាន់ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៣ថ] សម័យនោះឯង ភិក្ខុទាំងឡាយមានជំងឺ ។ ពួកភិក្ខុអ្នកសួរជំងឺបាននិយាយពាក្យនេះនឹងភិក្ខុឈឺទាំងឡាយថា ម្នាលអាវុសោ លោកអាចអត់ទ្រាំបានឬទេ អាចប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុឈឺឆ្វើយថា ម្នាលអាវុសោ ក្នុងកាលមុន យើងទាំងឡាយ បានសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួនហើយធាន់ ព្រោះហេតុនោះ

ហោតិ ឥជានិ បន ភគវតា បដិក្ខិត្តន្តិ ការុញ្ញាយ្ជ
ន វិញ្ញាបេម តេន ណោ ន ជាសុ ហោតីតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ
ឯតស្មឹ បការណេ ធម្មឹ ការំ ការ្ជ កិក្ខូ អាមន្តេសិ
អនុជានាមិ ភិក្ខវេ តិណានេន ភិក្ខុនា បណីតភោ-
ជានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិតុំ ឯវញ្ជ បន
ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន
តានិ បណីតភោជនានិ សេយ្យថីទំ សប្បិ នវនីតំ
តេលំ មធុ ផាណិតំ មច្ឆា មំសំ ខីរំ ទធិ ។ យោ
បន ភិក្ខុ ឯវ្ជ្ជ្ជ

ទើបយើងទាំងឡាយមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ហាមហើយ យើងទាំងឡាយខ្វាចក្រែង មិនហ៊ានសូមទៀត ទើប សេចក្តីមិនសប្បាយ មានដល់យើងទាំងឡាយដោយហេតុនោះ ។ ភិក្ខុទាំង ឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុង ពេលនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺ សូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួនហើយធាន់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាង នេះថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ ដូច-ម្តេច ភោជនដ៏ឧត្តមទាំងនោះគឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយ គ្មាន ជំងឺសូមភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ ដល់ខ្លួនហើយធាន់ ត្រូវអាបត្តិបាចិត្តិយ ។

[១៣៦] ត្រង់ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ គឺទឹកដោះថ្លារបស់គោក្តី ទឹកដោះថ្លារបស់ពពែក្តី

មហិសសប្ប៊ វ[1] យេសំ មំសំ ភក្ខ្យតិ តេសំ សប្ប៊ ។ ជវនីតំ ជាម តេសំយេវ ជវនីតំ ។ តេលំ ជាម តិលតេលំ សាសបតេលំ មធុកតេលំ ឯរណ្ឌតេលំ វសាតេលំ ។ មធុ ជាម មក្ខ្ជិកាមធុ ។ ផាណ៊ិតំ ជាម ឧច្ចុម្ហា ជ៊ិ ពូ ត្ត ។ មច្ឆោ ជាម ឧទ្ធ ចរ ភ[2] ១ ២ ។ ១ ២ ១ ២ ១ ២

ទឹកដោះថ្លារបស់ក្របីក្តី ហៅថា ទឹកដោះថ្លា ឬសប្បិនិងសាច់របស់ពួកសត្ត
ណាដ៏គួរ (ដល់វិនយបញ្ញត្តិ) ទឹកដោះថ្លារបស់ពួកសត្តនោះ ហៅថា ទឹក
ដោះថ្លា ឬសប្បិ ។ ទឹកដោះខាប់របស់សត្តអម្បាលនោះឯង ហៅថា ទឹក
ដោះខាប់ ឬនវនីត ។ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្ទៃ និង
ប្រេងគីឌ្ងាញ់រាវ ហៅថា ប្រេង ។ ទឹកផ្អែមរបស់មេឃ្មុំ ហៅថា ទឹកឃ្មុំ ។
ទឹកផ្អែមដែលកើតអំពីអំពៅ ហៅថា ទឹកអំពៅ ឬស្ករអំពៅ ។ សត្តដែល
ត្រាច់ទៅក្នុងទឹក ហៅថា ត្រី ឬមច្ឆជាតិ ។ សាច់នៃពួកសត្តណាក៏គួរ
(ដល់វិនយបញ្ញត្តិ) សាច់នៃពួកសត្តទាំងនោះ ហៅថា សាច់ ឬមំសៈ ។ ទឹក
ដោះស្រស់របស់គោក្តី ទឹកដោះស្រស់របស់ពពែក្តី ទឹកដោះស្រស់របស់
ក្របីក្តី ហៅថា ទឹកដោះស្រស់ ឬខីរៈ សាច់របស់ពួកសត្តណាដ៏គួរ (ដល់វិ-
នយបញ្ញត្តិ) ទឹកដោះស្រស់របស់ពួកសត្តទាំងនោះ ហៅថា ទឹកដោះស្រស់
ឬខីរៈ ។ ទឹកដោះជូររបស់ពួកសត្តទាំងនោះ ហៅថា ទឹកដោះជូរ ឬទធិ ។

[១៣៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា នឹងបឋមបា-
រាជិកសិក្ខាបទ ។ ពាក្យថា ភោជនដ៏ឧត្តមទាំងឆ្ងាយមានសភាពយ៉ាងនេះ
គឺភោជនដ៏ថ្លៃថ្លាទាំងឆ្ងាយមានសភាពដូច្នោះ ។ ភិក្ខុណារៀរភោជន
ដ៏ឧត្តមទាំងឆ្ងាយហើយនៅជាសប្បាយបាន ភិក្ខុនោះហៅថា គ្មានជំងឺ ។

កិលាដោ ជាម យស្ស វិជា បណីតភោជនានិ ន ជាសុ ហោតិ ។ អកិលាដោ អត្តនោ អត្ថាយ វិញ្ញា-បេតិ បយោគេ ទុក្កដំ ។ បដិលាភេន ភុញ្ជិស្សា-មីតិ បដិក្ខណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ចាចិត្តិយស្ស ។

[១៣៨] អកិលាដោ អកិលានសញ្ញី បណីត-ភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ អកិលាដោ វេមតិកោ បណី-តភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ អកិលាដោ កិលានសញ្ញី បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ កិលាដោ អកិលានសញ្ញី អាបត្តិ ទុក្កដស្ស ។ កិលាដោ វេមតិកោ អាបត្តិ ទុក្កដស្ស ។ កិលាដោ កិលានសញ្ញី អនាបត្តិ ។

ភិក្ខុណាវៀរចាកភោជនដ៏ឧត្តមទាំងឡាយហើយ នៅសប្បាយមិនបាន ភិក្ខុនោះហៅថាមានជំងឺ ។ ភិក្ខុគ្មានជំងឺ សូមភោជនទាំងនោះ ដើម្បីប្រយោជន៍ដល់ខ្លួន ត្រូវអាបត្តិទុក្កដ ពាល់ប្រយោគ ។ ភិក្ខុទទួលដោយតាំងចិត្តថា អញនឹងធាន់ ត្រូវអាបត្តិទុក្កដ ក្នុងខណៈដែលបានមក ។ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[១៣៨] ខ្លួនមិនឈឺ ភិក្ខុសំគាល់ថា ខ្លួនមិនឈឺ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយធាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនឈឺ ភិក្ខុមានសេចក្តីសង្ស័យ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយធាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនឈឺ ភិក្ខុសំគាល់ថា ខ្លួនឈឺ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយធាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនឈឺ ភិក្ខុសំគាល់ថា ខ្លួនមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុសំគាល់ថា ខ្លួនឈឺ មិនត្រូវអាបត្តិ ។

[១៣៩] អជាបត្តិ តិលានស្ស តិលានោ ហុត្វា វិញ្ញ-
ាបេត្វា អតិលានោ ភុញ្ជតិ តិលានស្ស សេសកំ
ភុញ្ជតិ ញាតកានំ បវារិតានំ អញ្ញស្ស្ត្ថាយ អត្ត-
នោ ជនេន ឧម្មត្តកស្ស អាជិកម្ម្ជិកស្ស្ជាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

[១៣៩] អាបត្តិមិនមាន ដល់ភិក្ខុឈឺ ដល់ភិក្ខុដែលមានជំងឺហើយ សូម លុះសូមបានមកក៏បាត់ជំងឺនោះហើយធាន់ ដល់ភិក្ខុដែលធាន់ភោជនដ៏សល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលធាន់ភោជនរបស់ពួកញាតិ ដល់ភិក្ខុដែលធាន់ភោជនរបស់ពួកជនដែលបានបវារណា ដល់ភិក្ខុដែលសូមដើម្បីប្រយោជន៍ដល់អ្នកឯទៀត ដល់ភិក្ខុដែលធាន់ភោជនដែលកើតដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[១៤០] តេន សមយេន ពុទ្ធោ ភគវា វេសាលិ-
យំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ
បន សមយេន អញ្ញតរោ ភិក្ខុ សព្ពមំសុកូលិកោ
សុសានេ វិហរតិ ។ សោ មនុស្សេហិ ឌីយមានំ ន
ឥច្ឆតិ បដិក្ខិបិតុំ ។ សុសានេបិ រុក្ខមូលេបិ ឧម្មារេបិ
អយ្យកោសាជិតកានិ សាមំ តហេត្វា កុញ្ជតិ ។ មនុស្សា
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម អយំ ភិក្ខុ
អម្ហាកំ អយ្យកោសាជិតកានិ សាមំ តហេត្វា កុញ្ជិស្ស-
តិ ថេរោយំ ភិក្ខុ រដ្ឋោ មនុស្សមំសំ មញ្ញេ ខាទ-
តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈា-
យន្តានំ ខីយន្តានំ វិចារេន្តានំ ។ យេ តេ ភិក្ខូ
អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ
កថំ ហិ នាម ភិក្ខុ អនិដ្ឋំ មុខ្ចារំ អាហារំ
អាហរិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ អនិដ្ឋំ

សិក្ខាបទទី ១០

[១៤០] *កាលនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅ*
កូដាគារសាលា ក្នុងមហាវន ក្បែរក្រុងវេសាលី ។ សម័យនោះឯង
មានភិក្ខុ ១ រូបជាអ្នកប្រព្រឹត្តបំសុកូលនូវរបស់គ្រប់យ៉ាង[1] *នៅក្នុងព្រៃ*
ស្មសាន ។ ភិក្ខុនោះមិនប្រាថ្នានឹងទទួលយកវត្ថុដែលមនុស្សទាំងឡាយ
ឲ្យឡើយ ។ ភិក្ខុនោះកាន់យកនូវសំណៃន ក្នុងព្រៃស្មសានខ្លះ ទៀប
គល់ឈើខ្លះ ទៀបធរណីទ្វារខ្លះ ដោយខ្លួនឯង ហើយធាន់ ។ មនុស្ស
ទាំងឡាយ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុនេះមិនគួរបើនឹង
កាន់យកសំណៃនរបស់យើងទាំងឡាយដោយខ្លួនឯង ហើយធាន់ទេ
ភិក្ខុជាថេរៈនេះ មានកាយធាត់ ទំនងជាស៊ីសាច់មនុស្សទេដឹង ។ ភិក្ខុទាំង-
ឡាយបានឮមនុស្សទាំងនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។
ពួកភិក្ខុណា ដែលមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះ ពោល
ទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារ
មាត់ ជាអាហារដែលគេមិនបានប្រគេនសោះ ។ បេ ។ ព្រះដ៏មាន
ព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងស៊ីលេបនូវអាហារ

---

1 អដ្ឋកថា ភិក្ខុនោះប្រព្រឹត្តបំសុកូលគ្រប់ជំពូក ដោយហោចទៅសូម្បីឈើស្ទន់ក៏បំសុកូលយកដែរ ។

មុខទ្វារំ អាហារំ អាហរសីតិ ។ សចេ ភគវាតិ ។ រាតរហិ ពុទ្ធោ ភគវា ភិក្ខុ ហិ ជាម ត្វំ មោឃបុរិស អនិន្ទ្ធំ មុខទ្វារំ អាហារំ អាហរិស្ស្ស្ស ដេតំ មោឃបុរិស អប្ប្ប្

តាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ពិតមែនឬ ។ ភិក្ខុនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន (ដូច្នេះ) ទេ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះ-ថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៤១] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យ ក្នុងទឹកនិងឈើស្ងួន ។ ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកទឹកនិងឈើស្ងួនធាន់ដោយខ្លួនឯងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ លើកលែងតែទឹកនិងឈើស្ងួន ។

បាចិត្តិយកណ្ឌ ភោជនវគ្គស្ស ទសមសិក្ខាបទស្ស វិភង្គោ

[១៤២] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អនិដ្ឋំ នាម អប្បដិក្ខូលតកំ រុច្ចតិ ។ ឥដ្ឋំ នាម ការយេន វា ការយមានេន វា ឧប្បត្តិយេន វា ទេន្តេ ហត្ថចាសេ ឋិតោ ការយេន វា ការយមានេន វា បដិក្ខណ្ហាតិ ឯតំ ឥដ្ឋំ នាម ។ អាហារេ នាម ឧទកទន្តចោណំ ឋបេត្វា យត្ថ្លិញ្ជិ អជ្ឌោហារណីយំ ឯសោ អាហារេ នាម ។ អញ្ញត្រ ឧទកទន្តចោណាតិ ឋបេត្វា ឧទកទន្ត-ចោណំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ តណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ ចាចិត្តិយស្ស ។

[១៤២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា គេមិនបានប្រគេន គឺសំដៅយកវត្ថុ ដែលភិក្ខុមិនបានទទួលប្រគេន ។ ដែលហៅថា របស់ដែលគេប្រគេន គឺកាលបើទាយកឲ្យរបស់ណា ដោយកាយក្តី ដោយរបស់ដែលជាប់នឹងកាយក្តី ដោយបោះឲ្យក្តី ភិក្ខុក៏ស្ថិតនៅក្នុងហត្ថបាសបានទទួល[1] ដោយកាយ ឬដោយរបស់ដែលជាប់នឹងកាយ របស់នេះហៅថា គេប្រគេន ។ ដែលហៅថា អាហារ គឺរបស់ណាមួយដែលគួរលេបចូលទៅបាន រៀវលែងតែទឹកនិងឈើស្ងួន់ របស់នេះហៅថា អាហារ ។ ពាក្យថា រៀវលែងតែទឹកនិងឈើស្ងួន់ គឺលើកលែងតែទឹកនិងឈើស្ងួន់ ។ ភិក្ខុទទួលយកដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ១ ភារៈដែលលេបចូលទៅ ។

---

១ អដ្ឋកថា កិរិយាទទួលប្រគេនប្រកបដោយអង្គ ៥ គឺ ១ វត្ថុដែលបុរសមានកំលាំងយ៉ាងកណ្តាល ល្មមលើកឡើងបាន ។ ២ អ្នកប្រគេនឋិតនៅក្នុងហត្ថបាស ។ ៣ អ្នកប្រគេនបានបង្ហោនខ្លួនចូលមក ។ ៤ ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តីប្រគេន ។ ៥ ភិក្ខុទទួលវត្ថុនោះដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ។

[១៤៣] អប្ផដិក្ខហិតកេ អប្ផដិក្ខហិតកសញ្ញី អនិដ្ឋំ មុខ្ទ្ធារំ អាហារំ អាហរតិ អញ្ញត្រ ឧទក-ឧន្ធចោណា អាបត្តិ ចាចិត្តិយស្ស ។ អប្ផដិក្ខហិតកេ វេមតិកោ អនិដ្ឋំ មុខ្ទ្ធារំ អាហារំ អាហរតិ អញ្ញត្រ ឧទ-កឧន្ធចោណា អាបត្តិ ចាចិត្តិយស្ស ។ អប្ផដិក្ខហិតកេ បដិក្ខហិតកសញ្ញី អនិដ្ឋំ មុខ្ទ្ធារំ អាហារំ អាហរតិ អញ្ញត្រ ឧទកឧន្ធចោណា អាបត្តិ ចាចិត្តិយស្ស ។ បដិក្ខហិតកេ អប្ផដិក្ខហិតកសញ្ញី អាបត្តិ ទុក្កដស្ស ។ បដិក្ខហិតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បដិក្ខ-ហិតកេ បដិក្ខហិតកសញ្ញី អនាបត្តិ ។

[១៤៤] អនាបត្តិ ឧទកឧន្ធចោណេ ចត្តារិ មហា-វិកតានិ សតិ បច្ចយេ អសតិ កប្ប្យិយការកេ សាមំ តហេត្វា បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្ស្ជតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ភោជនវគ្គោ ចតុត្ថោ ។

[១៤៣] *វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុក៏សំគាល់ថា មិនបានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនប្រគេន ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែទឹកនិងឈើស្ទន់ ។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសង្ស័យ ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែទឹកនិងឈើស្ទន់ ។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសំគាល់ថា បានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែទឹកនិងឈើស្ទន់ ។ វត្ថុដែលភិក្ខុបានទទួលប្រគេន ភិក្ខុសំគាល់ថា មិនទាន់បានទទួលប្រគេន ត្រូវអាបត្តិទុក្កដ ។ វត្ថុដែលភិក្ខុទទួលប្រគេន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វត្ថុដែលភិក្ខុទទួលប្រគេនហើយ ភិក្ខុក៏សំគាល់ថា បានទទួលប្រគេនហើយ មិនត្រូវអាបត្តិឡើយ ។*

[១៤៤] *អាបត្តិមិនមាន ដល់ភិក្ខុដែលធាន់ទឹកនិងឈើស្ទន់ ដល់ភិក្ខុដែលកាន់យកថ្នាំមហាវិកត ៤ យ៉ាង*[1] *ដោយខ្លួនឯងហើយធាន់ ព្រោះមានហេតុហើយគ្មានកប្ប្យិយការក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។*

សិក្ខាបទទី ១០ ចប់ ។

ភោជនវគ្គទី ៤ ចប់ ។

---

១ មហាវិកត ៤ គឺ មូត ១ គូថ ១ ផេះ ១ ដី ១ ។

បាចិត្តិយកណ្ឌ ភោជនវគ្គស្ស ឧទ្ទានំ

តស្សុទ្ទានំ

បិណ្ឌោ ១ កណ្ឌ ១ បរំ ២ ឫ ១

ទ្វេ ២ ច ១ ១ ១

បាចិត្តិយកណ្ឌ ភោជនវគ្គ ឧទ្ទាន

ចំនួនសិក្ខាបទក្នុងភោជនវគ្គនោះមាន ១០ យ៉ាងគឺ

បិណ្ឌ (សិក្ខាបទ) ១	*គណ (សិក្ខាបទ) ១*
បរ (សិក្ខាបទ) ១	*ឋូ (សិក្ខាបទ) ១*
បវារណា (សិក្ខាបទ) ពីរ	*ព្រះដ៏មានព្រះភាគពោលហើយ*
វិកាល (សិក្ខាបទ) ១	*សន្និធិការ (សិក្ខាបទ) ១*
បណីត (សិក្ខាបទ) ១	*ទ្វារក (សិក្ខាបទ) ១ ។*

អចេលកវគ្គស្ស បឋមសិក្ខាបទំ

[១៤៥] តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សង្ឆស្ស ខាទនីយំ ឧប្បន្នំ ហោតិ ។ អថ ខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ តេនហ ភិក្ខវេ ភិក្ខូ ភគវតោ ឯតមត្ថំ ១ តេនហ ភិក្ខវេ ១ ១ ១

អចេលកវគ្គ សិក្ខាបទទី ១

[១៤ថ] កាលនោះ ព្រះសព្វញ្ញូពុទ្ធដ៏មានជាគ គង់នៅ
ក្នុងគារសាលាក្នុងព្រៃមហាវន ទៀបក្រុងវេសាលី ។ សម័យនោះឯង
របស់ដែលបុគ្គលគប្បីទំពាស៊ីកើតឡើងដល់សង្ឆ ។ ព្រះអានន្ទដ៏មាន
អាយុ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ
ទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរឲ្យនំដល់ពួកមនុស្សអ្នកស៊ី
ដែលចុះ ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកាថា បពិត្រព្រះអង្គ
ដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ក៏ឲ្យពួកមនុស្សដែលជាអ្នកស៊ីដែលអង្គុយជាជួរ
ហើយក៏ឲ្យនំមួយ ។ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាង
បរិព្វាជិកាម្នាក់ ដោយសំគាល់ថា ឲ្យនំមួយដូចគេទាំងពួងដែរ ។ ពួកនាង
បរិព្វាជិកា (ដែលនៅ) ជុំវិញ បាននិយាយពាក្យនេះនឹងនាងបរិព្វាជិកានោះ
ថា សមណានោះ ជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះ ឆ្លើយថា
សមណានោះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថា ឲ្យនំមួយដល់
ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ ភរៈជាគម្រប់ពីរដង ព្រះអានន្ទដ៏មាន
អាយុ ឲ្យនំមួយ ។ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាង
បរិព្វាជិកាដដែលនោះ ដោយសំគាល់ថា ឲ្យនំមួយដូចគេទាំងពួងដែរ ។

សាមណ្ណ បរិញ្ញាជិកាយោ តំ បរិញ្ញាជិកំ ឯតទវោចុំ ជាវោ តេ ឯសោ សមណោតិ ។ ន មេសោ សម-ណោ ជាវោ ឯកំ មញ្ញមានោ ទ្វេ ឃ្លវ អជាសីតិ ។ តតិយម្ឪ ខោ អាយស្មា អានន្ទោ ឯកេកំ ឃ្លវ ទេន្ត តស្ឪាយេវ បរិញ្ញាជិកាយ ឯកំ មញ្ញមានោ ទ្វេ ឃ្លវ អជាសិ ។ សាមណ្ណ បរិញ្ញាជិកាយោ តំ បរិញ្ញាជិកំ ឯតទវោចុំ ជាវោ តេ ឯសោ សមណោតិ ។ ន មេសោ សមណោ ជាវោ ឯកំ មញ្ញមានោ ទ្វេ ឃ្លវ អជាសីតិ ។ ជាវោ ន ជាវោតិ ឧឃ្ជណ្ហីសុ ។ អញ្ញត-វោបិ អាជីវកោ បរិវេសនំ អកមាសិ ។ អញ្ញតវោ ភិក្ខុ បហ្ជតេន សប្ឪិជ ឱ១ន១ មទ្ធ្ជិ ត្ជ តស្ឪ អាជីវកស្ឪ មហន្តំ ឃ្ជ ១ ១ ១

ពួកនាងបរិព្វាជិកា (ដែលនៅ) ជុំវិញ ក៏និយាយពាក្យនេះ នឹងនាងបរិព្វាជិកានោះថា សមណៈនុ៎ះជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះ ឆ្លើយថា សមណៈនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថា ឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ វារៈជាគម្រប់បីដងទៀត ព្រះអានន្ទដ៏មានអាយុ ឲ្យនំមួយ ។ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសំគាល់ថា ឲ្យនំមួយដូចគេទាំងពួងដែរ ។ ពួកនាងបរិព្វាជិកា (ដែលនៅ) ជុំវិញ ក៏និយាយពាក្យនេះ នឹងនាងបរិព្វាជិកានោះថា សមណៈនុ៎ះជាសហាយរបស់នាងឬ ។ នាងបរិ-ព្វាជិកានោះឆ្លើយថា សមណៈនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថា ឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ ពួកនាងបរិព្វាជិកាទាំងនោះ ក៏នាំគ្នានិយាយចម្ងកថា (សមណៈនុ៎ះ) សហាយឬមិនមែនសហាយ ។ (វេលានោះ) មានអាជីវកម្នាក់ដើរទៅកាន់ទីដែលគេអង្ក្នាស ឬចែក (នំ) ។ (ពេលនោះ) មានកិក្ខុមួយរូប កំពុងច្របាច់បាយលាយដោយទឹកដោះថ្លាដ៏ច្រើន ហើយក៏ឲ្យដុំបាយ ១ ដុំធំដល់អាជីវកនោះ ។ លំដាប់នោះ អាជីវកនោះ ក៏កាន់យកដុំបាយនោះហើយដើរទៅ ។ (ពេលនោះ) មានអាជីវកម្នាក់ទៀតបានពោលពាក្យនេះនឹងអាជីវកនោះថា

តយា អាវុសោ បិណ្ឌោ លព្ភោតិ ។ តស្ស្ចាវុសោ
សមណាស្ស គោតមស្ស មុណ្ហកកហាបតិកស្ស ឧបវេ-
សនាយ លព្ភោតិ ។ អស្ស្ចាសុំ ខោ ឧចាសកា
តេសំ អាជីវកានំ ឥមំ កថាសល្ទាបំ ។ អថខោ
តេ ឧចាសកា យេន ភគ្គា តេនុបសង្ក្រមីសុ
ឧបសង្ក្រមិត្វា ភគ្គវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹ-
សុ ។ ឯកមន្តំ និសិន្នា ខោ តេ ឧចាសកា
ភគ្គវន្តំ ឯតទវោចុំ ឥមេ ភន្តេ តិត្ថិយា អវណ្ណ្ណ្ណ្ណ-
មា ពុទ្ធស្ស អវណ្ណ្ណ្ណ្

ម្នាលអាវុសោ អ្នកឯងបានដុំបាយមកពីទីណា ។ អាជីវកដែលបានដុំបាយនោះធ្វើយតបថា ម្នាលអាវុសោ ដុំបាយខ្ញុំបានមកអំពីទីដែលគេអង្ក្នាសនៃមុណ្ណកគហបតី (គហបតីត្រដោល) របស់ព្រះសមណគោតមនោះ ។ ពួកឧបាសកបានឮពាក្យចរចានេះ នៃពួកអាជីវកនោះច្បាស់លាស់ហើយ ។ ទើបពួកឧបាសកទាំងនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំ ព្រះដ៏មានបុណ្យហើយ ក៏អង្គុយក្នុងទី ១ ដ៏សមគួរ ។ ឧបាសកទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយអម្បាលនេះ ប្រាថ្នានឹងពោលទោសដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ បពិត្រព្រះអង្គដ៏ចម្រើន សូមកុំឲ្យលោកម្ចាស់ទាំងឡាយ ឲ្យ (វត្ថុអ្វី ?) ដល់ពួកតិរ្ថិយដោយដៃរបស់ខ្លួនឡើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឧបាសកទាំងនោះ ឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ។ ឯពួកឧបាសកទាំងនោះ កាលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់លាស់ ទ្រង់ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ

បក្ខ្លាមីសុ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ[1] បការណេ ភិក្ខុសង្ឆំ សន្និចាតាបេត្វា ភិក្ខូនំ តទ-នុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញាបេស្សামិ ទស អត្ថវសេ បដិច្ច សង្ឆសុដ្ឋុតាយ សង្ឆផាសុតាយ ។ បេ ។ សទ្ធម្មដ្ឋិតិយា វិនយា-នុគ្គហាយ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អចេលកស្ស វា បរិព្ជាជកស្ស វា បរិព្ជាជិការ្យ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទទេយ្យ ចាចិត្តិយន្តិ ។

[១៤៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អចេលោ នាម យោ កោចិ បរិព្ជាជ-កសមាបន្នោ ឧក្កោ ។ បរិព្ជាជកោ នាម ភិក្ខុញ្ច

---

១ ភិក្ខុសង្ឆំ ។ បេ ។ តទនុលោមិកន្តិបិ មរម្ម ឱរោបិយបោត្ថកេ នត្ថិ ។

ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ព្រោះនិទានេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ឲ្យប្រជុំភិក្ខុសង្ឆ ទ្រង់ធ្វើធម្មីកថាដ៏ល្មមសម-គួរតាមហេតុនោះ ដល់ពួកភិក្ខុ ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា នែភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទ ដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺ ដើម្បីសេចក្ដីល្អដល់សង្ឆ ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឆ ១ ។ បេ ។ ដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ឲ្យវត្ថុដែលបុគ្គលគួរទំពាស៊ី ឬវត្ថុដែលបុគ្គលគួរបរិភោគ ដល់អចេលកក្ដី បរិព្វាជកក្ដី បរិព្វាជិកាក្ដី ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

[១៨៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខា-បទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា អចេលក គឺបុគ្គលដែលបួសជាបរិព្វាជកមានកាយអាក្រាតទាំងអស់ ។ ដែលហៅថា បរិព្វាជក គឺបុរសដែលបួសជាបរិព្វាជកទាំងអស់ លៀងលែងតែភិក្ខុនិងសាមណេរចេញ ។ ដែលហៅថា បរិព្វាជិកា គឺស្ត្រីដែលបួសជាបរិព្វាជិកាទាំងអស់

សាមណេរញ្ចេ បវេត្វា យោ ភោ ចិ បរិញ្ញាជកសមា-
បន្នោ ។ បរិញ្ញាជិកា ជាម ភិក្ខុនិញ្ចេ សិក្ខមានញ្ចេ
សាមណេរិញ្ចេ បវេត្វា យា ភោ ចិ បរិញ្ញាជិកសមា-
បន្នា ។ ខាទនីយំ ជាម បញ្ចេ ភោជនានិ ឧទកទន្ត-
ចោណំ បវេត្វា អវសេសំ ខាទនីយំ ជាម ។ ភោជនីយំ
ជាម បញ្ចេ ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ
មំសំ ។ ទនេយ្យាតិ ភាយេន វា ភាយ្យជ្ជិតេ ទ្ធេ
ន ជ ិ ស្ស ត្ត ិ យេ ន ។ ទ េ ត ិ អ ាប ត្ត ិ ច ាចិ ត្ត ិ យ ស្ស ។

[១៤៧] តិត្ថិយេ តិត្ថិយសញ្ញី សហត្ថា ខាទ-
នីយំ ។ ភោជនីយំ ។ ទ េ ត ិ អ ាប ត្ត ិ ច ាចិ ត្ត ិ យ ស្ស ។
តិត្ថិយេ ឯមតិកោ សហត្ថា ខាទនីយំ ។ ភោជនីយំ
។ ទ េ ត ិ អ ាប ត្ត ិ ច ាចិ ត្ត ិ យ ស្ស ។ តិ ត្ថ ិ យ េ អ ត ិ ត្ថ ិ-
យ ស ញ្ញ ី ស ហ ត្ថ ា ខ ាទ ន ីយ ំ ។ ភ ោ ជ ន ីយ ំ ។
ទ េ ត ិ អ ាប ត្ត ិ ច ាចិ ត្ត ិ យ ស្ស ។ ឧ ទ ក ទ ន្ត ចោ ណ ំ
ទ េ ត ិ អ ាប ត្ត ិ ទ ុ ក្ក ដ ស្ស ។ អ ត ិ ត្ថ ិ យ េ ត ិ ត្ថ ិ យ ស ញ្ញ ី

រៀរលែងតែភិក្ខុនី សិក្ខមានានិងសាមណេរីចេញ ។ ដែលហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ី គឺលើកទុកតែភោជន ៥ យ៉ាងព្រមទាំងទឹកនិងឈើស្ទន់ចេញ ក្រៅពីនោះហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ីទាំងអស់ ។ ដែលហៅថា វត្ថុដែលបុគ្គលគួរបរិភោគ បានដល់ភោជន ៥ យ៉ាង គឺ បាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ពាក្យថា ឲ្យ គឺភិក្ខុឲ្យដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ដោយបោះឲ្យក្តី ត្រូវអាបត្តិបាចិត្តិយ ។

[១៤៧] ជនជាតិរ្ជិយ ភិក្ខុក៏សំគាល់ថា ជាតិរ្ជិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ជនជាតិរ្ជិយ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ជនជាតិរ្ជិយ ភិក្ខុសំគាល់ថា មិនមែនជាតិរ្ជិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុឲ្យទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។ បុគ្គលមិនមែនជាតិរ្ជិយ

អាបត្តិ ទុក្កដស្ស ។ អតិត្តិយេ ឋេមតិកោ អាបត្តិ ទុក្កដស្ស ។ អតិត្តិយេ អតិត្តិយសញ្ញី អនាបត្តិ ។

[១៤៨] អនាបត្តិ ឌាហេតិ ន ឌេតិ ឧបនិក្ខិបិត្វា ឌេតិ ពាហិរលេបំ[១] ឌេតិ ឧម្មត្តកស្ស អាឌិកម្មិ-កស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

---

១ ឱ. ម. ពាហិរាលេបំ ។

ភិក្ខុសំគាល់ថា ជាតិរ្ជិយ ត្រូវអាបត្តិទុក្កដ ។ ជនមិនមែនជាតិរ្ជិយ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ជនមិនមែនជាតិរ្ជិយ ភិក្ខុសំគាល់ថា មិនមែនជាតិរ្ជិយ មិនត្រូវអាបត្តិឡើយ ។

[១៤៨] អាបត្តិមិនមាន ដល់ភិក្ខុដែលប្រើគេឲ្យ មិនឲ្យដោយខ្លួនឯង ដល់ភិក្ខុដែលដាក់[១]វត្ថុទុកឲ្យ ដល់ភិក្ខុដែលឲ្យរបស់ជាគ្រឿងលាបខាងក្រៅ[២] ដល់ភិក្ខុធ្លត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់ ។

---

១ ភិក្ខុដាក់របស់ក្នុងភាជន៍ ហើយលើកយកភាជន៍នោះទៅតម្កល់ទុកលើដី ជិតតិរ្ជិយទាំងនោះ ហើយឲ្យដោយវាចា ។ ២ បានដល់គ្រឿងលាបកាយគ្រប់យ៉ាងមានម្សៅជាដើម ។

ទុតិយសិក្ខាបទំ

[១៤៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ
ភាតុនោ សន្ធិវិហារិកំ កិញ្ចុ ឯតភេច ឯហាវុសោ
តាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស អជាបេត្វា
ឧយ្យោជេសិ តច្ឆាវុសោ ន មេ តយា សទ្ធឹ កថា វ
ជិសជ្ជា វ ផាសុ ហោតិ ឯកកស្ស មេ កថា វ
ជិសជ្ជា វ ផាសុ ហោតីតិ ។ អថខោ សោ ភិក្ខុ
ឧបក្ណេ្ណ ការេ ជាសក្ខិ បិណ្ឌាយ ចរិតុំ បដិក្ក្ណម-
ណេបិ ភត្តវិស្ស្ជ្ជ ន សម្ភាវេសិ ធិន្ធកត្តោ អហោសិ ។
អថខោ សោ ភិក្ខុ អារាមំ គន្ត្ជ ភិក្ខូ ឯតមត្ថំ
អារោចេសិ ។ យេ តេ ភិក្ខូ អប្ប្ជិច្ឆា ។ បេ ។
តេ ឧជ្ឈាយន្ត្ជ ខីយន្ត្ជ វិចារេន្ត្ជ ការ ហិ ជាម
អាយស្មា ឧបនន្ទោ សក្យបុត្តោ ភិក្ខុ ឯហាវុសោ
តាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស អជាបេត្វា

សិក្ខាបទទី ២

[១៤៩] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះនឹងភិក្ខុជាសទ្ធិ-វិហារិករបស់ព្រះថេរៈជាបងប្អូនថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ថាដូច្នេះហើយ ក៏មិនឲ្យគេប្រគេន (អ្វី ។) ដល់ភិក្ខុនោះឡើយ (បែរជា) ប្រើឲ្យត្រឡប់ទៅវិញថា ម្នាលអាវុសោ លោកចូរទៅចុះ ខ្ញុំនឹងនិយាយឬនឹងអង្គុយជាមួយនឹងលោកមិនសប្បាយទេ ខ្ញុំនឹងនិយាយឬនឹងអង្គុយតែម្នាក់ឯងស្រួលជាង ។ គ្រានោះ កាលបើពេលដែលត្រូវធាន់កាន់តែចូលមកជិតហើយ ភិក្ខុនោះមិនអាចនឹងត្រាច់ទៅបិណ្ឌបាតបាន សូម្បីគ្រាន់តែត្រឡប់មកធ្វើកត្តកិច្ចវិញ ក៏មិនទាន់ ជាអ្នកអត់ចង្ហាន់ (មួយពេលនោះឯង) ។ ទើបភិក្ខុនោះទៅកាន់អា-រាមហើយដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើមកបបួលភិក្ខុថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុក

ឧយ្យោជេស្សតីតិ ។ បេ ។ សចេ កិរ ត្វំ ឧបនន្ទ
ភិក្ខុំ ឯហាវុសោ តាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស
អជានេត្វា ឧយ្យោជេសីតិ ។ សចេ ភគវាតិ ។ រាតរហិ
ពុទ្ធោ ភគវា ភេជ្ជ ហិ ជាម ត្វំ មោឃបុរិស ភិក្ខុំ
ឯហាវុសោ តាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស អជា-
នេត្វា ឧយ្យោជេស្សសិ នេតំ មោឃបុរិស អប្ប្ស្ សន្ធានំ
វ បសាទាយ បសន្ធានំ វ ភិយ្យោភាវាយ ។ បេ ។
ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧद्दिसेय्याथ
យោ បន ភិក្ខុ ភិក្ខុំ ឯវំ វទេយ្យ[1] ឯហាវុសោ
តាមំ វ ជិតមំ វ បិណ្ឌាយ បវិសិស្សាមាតិ តស្ស
ជានេត្វា វ អជានេត្វា វ ឧយ្យោជេយ្យ តច្ចាវុសោ
ន មេ តយា សទ្ធឹ ភេជ្ជ វ ជិសន្ធ្ យ ជ ជ ជ ជ

1 ឥទំ បាឋទ្វយំ ឌ. ម. ពោត្ថកេសុ ន ទិស្សតិ ។

ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេប្រគេនអ្វី ៗ ដល់ភិក្ខុនោះ ស្រាប់តែ
បញ្ជូនឲ្យត្រឡប់ទៅវិញ (ដូច្នេះ) សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា
នៃឧបនន្ទ បានឮថា អ្នកឯងបបួលភិក្ខុថា ម្នាលអាវុសោ លោកចូរមក
យើងទាំងឡាយនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេ
(ឲ្យអ្វី ៗ) ដល់ភិក្ខុនោះ (ម្យ៉ាងវិញ) បញ្ជូនឲ្យត្រឡប់ទៅវិញ មែនពិតឬ ។
ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនេះពិតមែន ។
ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នៃមោឃបុរស អ្នកឯងមិនគួរនឹង
បបួលភិក្ខុផងគ្នាថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់
ស្រុកដើម្បីបិណ្ឌបាត ហើយមិនឲ្យគេឲ្យ (អ្វី ៗ) ដល់ភិក្ខុនោះ (ម្យ៉ាងវិញ) បញ្ជូន
ឲ្យត្រឡប់ទៅវិញ ដូច្នេះឡើយ នៃមោឃបុរស អំពើនេះមិនមែននាំឲ្យ
ជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ
ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នក
ទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយនិ-
យាយនឹងភិក្ខុយ៉ាងនេះថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹង
ទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ហើយឲ្យគេឲ្យ ឬមិនឲ្យគេឲ្យ (អ្វី ៗ)
ដល់ភិក្ខុនោះ ហើយបញ្ជូនឲ្យត្រឡប់ទៅវិញដោយពាក្យថា នៃអាវុសោ
លោកចូរទៅវិញចុះ ខ្ញុំនិយាយឬអង្គុយជាមួយនឹងលោកមិនសប្បាយទេ

ហោតិ ឯកកស្ស មេ កថា វ និសជ្ជា វ ផាសុ ហោតីតិ ឯតេវ បច្ចយំ ការិត្វា អនញ្ញ ចាចិត្តិយន្តិ ។

[១៥០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញ ភិក្ខុ ។ ឯហាវុសោ តាមំ វ និតមំ វាតិ តាមោបិ និតមោបិ ឧតរំបិ តាមោ ចេវ និតមោ ច ។ ឥស្ស ជាបេត្វាតិ យាកុំ វ ភត្តំ វ ខាទនីយំ វ ភោជនីយំ វ ជាបេត្វា ។ អជាបេត្វាតិ ន ភិញ្ជ ជា-បេត្វា ។ ឧយ្យោជេយ្យាតិ មាតុក្ការមេន សទ្ធឹ ហាសិតុ-ការាមោ ភីឍ្ឍិតុការាមោ រហោនិសីទិតុការាមោ អជាចារ អាចរិតុការាមោ ឯវ រេតិ ឥច្ឆាវុសោ ន មេ ឥយា សទ្ធឹ ភថា វ និសជ្ជា វ ផាសុ ហោតិ ឯកកស្ស មេ ភថា វ និសជ្ជា វ ផាសុ ហោតីតិ ឧយ្យោជេតិ អាបត្តិ ទុក្ការ ។ ឥស្ស ឧបចារ វ សវ ឧបចារ វ

ខ្ញុំនិយាយឬអង្គុយតែម្នាក់ឯងស្រួលជាង ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវហេតុនុ៎ះឯងឲ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ ។

[១៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា នឹងភិក្ខុ គឺនឹងភិក្ខុដទៃ ។ ពាក្យថា ម្នាលអាវុសោ លោកចូរមក (យើងនឹងទៅ) កាន់ស្រុកឬនិគម (ដើម្បីបិណ្ឌបាត) គឺស្រុកក្តី និគមក្តី នគរក្តី ក៏ហៅថា ស្រុកនិងនិគម (ក្នុងសិក្ខាបទនេះ) ។ ពាក្យថា ឲ្យគេឲ្យ (អ្វី ។) ដល់ភិក្ខុនោះ គឺប្រើគេឲ្យឲ្យយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី (ដល់ភិក្ខុនោះ) ។ ពាក្យថា មិនឲ្យគេឲ្យ គឺមិនឲ្យនរណាឲ្យ (អ្វី ។) សោះ ។ ពាក្យថា បញ្ជូនឲ្យត្រឡប់ទៅវិញ សេចក្តីថា ភិក្ខុប្រាថ្នាដើម្បីសើច ប្រាថ្នាដើម្បីលេង ប្រាថ្នាដើម្បីអង្គុយក្នុងទីស្ងាត់ ប្រាថ្នាដើម្បីប្រព្រឹត្តអនាចារជាមួយនឹងមាតុគ្រាម ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយឬអង្គុយជាមួយនឹងលោកមិនស្រួលទេ ខ្ញុំនិយាយឬអង្គុយតែម្នាក់ឯងស្រួលជាង ថាហើយក៏បញ្ជូនឲ្យត្រឡប់ទៅវិញ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនោះកំពុងលះបង់ទីលួមមើលគ្នាឃើញឬទីលួមស្តាប់ឮ

ជ្ជិមានស្ស អាបត្តិ ទុក្កដស្ស ។ ជ្ជិមានេ អាបត្តិ ចាចិត្តិយស្ស ។ ឯតេវ បច្ចយំ ការិត្វា អនញ្ញាតិ ជ អញ្ញោ ការេតិ បច្ចយោ ហោតិ ឧយ្យោជេតុំ ។

[១៥១] ឧបសម្ផន្នេ ឧបសម្ផន្នសញ្ញី ឧយ្យោ-ជេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ផន្នេ វេមតិកោ ឧយ្យោជេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ផន្នេ អនុ-បសម្ផន្នសញ្ញី ឧយ្យោជេតិ អាបត្តិ ចាចិត្តិយស្ស ។ ការិសាសនំ អាហរេតិ[១] អាបត្តិ ទុក្កដស្ស ។ អនុប-សម្ផន្នំ ឧយ្យោជេតិ អាបត្តិ ទុក្កដស្ស ។ ការិសាសនំ អាហរេតិ[២] អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ ឧបសម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ អនុប-សម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

១-២ ការ្ត្ថ ចិ ១ ១ ១

ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនោះលះបង់ផុត (នូវទីលួមមើលឃើញឬទីលួមស្តាប់ឮ) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើនូវហេតុនុ៎ះឯង ឲ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ សេចក្តីថា មិនមានហេតុនី-មួយដទៃជាបច្ច័យ ក្រៅអំពីហេតុដែលបញ្ជូនទៅនោះឡើយ ។

[១៥១] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនជាឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលើកឡើងនូវពាក្យបញ្ឈឺចិត្ត (ចំពោះឧបសម្បន្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបញ្ជូនអនុបសម្បន្នទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលើកនូវពាក្យបញ្ឈឺចិត្ត (ចំពោះអនុបសម្បន្ន) ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុសំគាល់ថា ជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុក៏សំគាល់ថា មិនមែនជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[១៥២] អជាបត្តិ ឧភោ ឯកតោ ឧ យាបេស្ស-
មាតិ ឧយ្យោជេតិ មហាឆ្ឆ ភណ្ឌា បស្សិត្វា លោភធម្មំ
ឧប្ផាទេស្ស្ផតីតិ ឧយ្យោជេតិ មាតុគ្ភាមំ បស្សិត្វា អន-
ភិរតឺ ឧប្ផាទេស្ស្ផតីតិ ឧយ្យោជេតិ ឥលានស្ស ភ ឥហី-
យកស្ស ភ វិហារចាលស្ស ភ យាកុ ភ ភត្ត ភ[1]
ខាទនីយ ភ ភោជនីយ ភ នីហរតិ ឧយ្យោជេតិ ឧ
អជាចារ អាចរិតុកាមោ សតិ ការណ្ហាយ ឧយ្យោ-
ជេតិ ឧម្ម្ផត្ត ភ អាទិកម្ម្ផិកស្ស្ផតិ ។

ទុតិយសិក្ខាបទ និដ្ឋិត ។

---

១ អយ ១ ១ ១ ១. ១ ១ ១

[១៥២] អាបត្តិមិនមាន ដល់ភិក្ខុដែលបញ្ជូនភិក្ខុផងគ្នាឲ្យត្រឡប់ទៅដោយគិតថា យើងទាំងពីររូបនឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅក្នុងទីជាមួយគ្នាមិនបាន ដល់ភិក្ខុដែលបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយគិតថា ក្រែងភិក្ខុនោះបានឃើញរបស់មានតម្លៃច្រើនហើយ នឹងញ៉ាំងលោភធម៌ឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយគិតថា ក្រែងភិក្ខុនោះបានឃើញមាតុគ្រាមហើយនឹងញ៉ាំងសេចក្តីអផ្សុកឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយពាក្យថា លោកចូរនាំយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី ទៅឲ្យដល់ភិក្ខុមានជំងឺ ឬភិក្ខុដែលនៅក្នុងវត្តឬអ្នកដែលរក្សាវត្ត ដល់ភិក្ខុមិនប្រាថ្នានឹងប្រព្រឹត្តអនាចារទេ (តែ) កាលបើមានកិច្ចហើយ ក៏បញ្ជូនភិក្ខុផងគ្នាទៅ ដល់ភិក្ខុឆ្លួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

ឥតិយសិក្ខាបទំ

[១៩៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សហាយកស្ស ឃរំ គន្ត្វា ឥស្ស បជាបតិយា សទ្ធឹ សយនីយេ និសជ្ជំ កប្បេសិ ។ អថខោ សោ បុរិសោ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ បជាបតឹ ឯតទវោច ទេហាយ្យស្ស ភិក្ខុនិ ។ អថខោ សា ឥត្តី អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ភិក្ខុំ អទាសិ ។ អថខោ សោ បុរិសោ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច តច្ឆថ ភន្តេ យតោ អយ្យស្ស ភិក្ខា ទិន្នាតិ ។ អថខោ សា ឥត្តី សល្ងេត្វា បរិយុដ្ឋិតោ អយំ បុរិសោតិ អាយស្មន្តំ ឧបនន្ទំ

សិក្ខាបទទី ៣

[១៥៣] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុបានដើរទៅផ្ទះរបស់សំឡាញ់ ហើយក៏អង្គុយនៅក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះ ។ ឯបុរសនោះ ក៏ចូលសំដៅទៅត្រង់ទីដែលព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុអង្គុយនោះ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ និយាយពាក្យនេះនឹងប្រពន្ធថា នាងចូរប្រគេនចង្ហាន់ដល់លោកម្ចាស់ចុះ ។ ស្ត្រីនោះ ក៏ប្រគេនចង្ហាន់ដល់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុក្នុងគ្រានោះ ។ លំដាប់នោះ បុរសនោះ ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តទៅចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ ។ ឯស្ត្រីនោះ កំណត់ដឹងថាបុរសនេះមានរាគ:ត្រូបសង្កត់ហើយ ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទ

សក្យបុត្តំ ឯតទវោច ជិសីឧថ ភន្តេ មា អត-
មិត្ថាតិ ។ ទុតិយម្ឫ ខោ សោ បុរិសោ ។ បេ ។
តតិយម្ឫ ខោ សោ បុរិសោ អាយស្ម្ដ ឧបនន្ទំ
សក្យបុត្តំ ឯតទវោច ភច្ជថ ភន្តេ យតោ អយ្ យ-
ស្ស ភិក្ខា ជិន្ទាតិ ។ តតិយម្ឫ ខោ សា ឥត្ថី
អាយស្ម្ដ ឧបនន្ទំ សក្យបុត្តំ ឯតទវោច ជិសីឧថ
ភន្តេ មា អតមិត្ថាតិ ។ អថខោ សោ បុរិសោ ជិក្ខ-
មិត្ថា ភិក្ខ ឧជ្ឈាបេសិ អយ ភន្តេ អយ្យោ ឧបនន្ទោ
មយ្ហ បជាបតិយា សន្ធ្ឫ សយនីយេ ជិសិន្ទោ សោ
មយា ឧយ្យោជ្ជិយមានោ ន ឥច្ឆតិ ភន្ទ ពហុ ភិក្ខ
មយ ពហុ ការណ្ឍ យាតិ ។ យ ត ភិក្ខ អ ម្ឫ ។ បេ ។
ត ឧជ្ឈ ទ ទ ។ ។ ។

ជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅ ។ បុរសនោះ (បាននិយាយ) ជាគម្រប់ពីរដង ។ បេ ។ បុរសនោះ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ជាគម្រប់បីដងថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តទៅវិញចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ ។ ឯស្ត្រីនោះសោតក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ជាគម្រប់បីដងថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅឡើយ ។ ឯបុរសនោះ ក៏ដើរចេញអំពីផ្ទះទៅ ហើយពោលទោសនឹងភិក្ខុទាំងឡាយថា បពិត្រលោកទាំងឡាយដ៏ចម្រើន លោកម្ចាស់ឧបនន្ទនេះទៅអង្គុយក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់ខ្ញុំ ព្រះឧបនន្ទនោះ កាលខ្ញុំបញ្ជូនឲ្យទៅវិញក៏មិនចង់ទៅ យើងខ្ញុំទាំងឡាយជាអ្នកមានកិច្ចច្រើន មានរវល់ច្រើន ។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុអម្ចាស់នោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ (គឺតែប្រុសនិងស្ត្រី) (ដូច្នោះ) សោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងបានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ពិតមែនឬ ។

សចំ ភតវាតិ ។ វិតរហិ ពុទ្ធោ ភតវា ភិក្ខូ ហិ ជាម-
ត្ថំ មោឃបុរិស សភោជនេ ភុសេ អនុប្ប១ជ្ជ និសជ្ជ-
ភិក្ខុ ។ ១ តតោ ១ ១ ១

ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ដំណើរនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូល ដែលមានជនតែពីរនាក់ (ដូច្នោះ) ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ចូលទៅសម្រេចការអង្គុយនៅ ក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។

[១៥៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា ត្រកូលដែលមានជនតែពីរនាក់ គឺមានតែស្រីនិងប្រុសប៉ុណ្ណោះ ។ ជនទាំងពីរនាក់មិនទាន់ចេញទៅ ហើយជនទាំងពីរនាក់នោះ ជាមនុស្សមានរាគ:នៅឡើយ ។ ពាក្យថា ចូលទៅ គឺដើរចូលទៅ ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថា ភិក្ខុលះហត្ថបាសនៃមេទ្វារឬធរណីក្នុងផ្ទះធំ ហើយអង្គុយនៅ ត្រូវអាបត្តិបាចិត្តិយ ។ (បើ) ក្នុងផ្ទះតូច ភិក្ខុចូលហួសមេដំបូល[1] ទៅហើយអង្គុយ ត្រូវអាបត្តិបាចិត្តិយ ។

---

១ អដ្ឋកថា អធិប្បាយថា ភិក្ខុចូលទៅហួសពាក់កណ្តាលផ្ទះ គឺហួសមេដំបូលផ្ទះ ។

[១៥៥] សយនីយេ សយនីយសញ្ញី សភោជនេ
ភុសេ អនុប្ប១ជ្ជ និសជ្ជំ ភបេ្ជតិ អាបត្តិ ចាចិត្តិ-
យស្ស ។ សយនីយេ វេមតិកោ សភោជនេ ភុសេ
អនុប្ប១ជ្ជ និសជ្ជំ ភបេ្ជតិ អាបត្តិ ចាចិត្តិយស្ស ។
សយនីយេ ឧសយនីយសញ្ញី សភោជនេ ភុសេ
អនុប្ប១ជ្ជ និសជ្ជំ ភបេ្ជតិ អាបត្តិ ចាចិត្តិយស្ស ។
ឧសយនីយេ សយនីយសញ្ញី អាបត្តិ ទុក្ខដស្ស ។
ឧសយនីយេ វេមតិកោ អាបត្តិ ទុក្ខដស្ស ។ ឧស-
យនីយេ ឧសយនីយសញ្ញី អនាបត្តិ ។

[១៥៦] អនាបត្តិ មហាល្ភកេ ឃរេ បិដ្ឋិសង្ឆាតស្ស
ហត្ថបាសំ អវិជហិត្វា និសីទតិ ១ុទ្ធភេ ឃរេ បិដ្ឋិវំសំ
អនតិក្ក្រមិត្វា និសីទតិ ភិក្ខុ ១ុតិយោ ហោតិ ១ភោ
និក្ខ្ជ្ជ ហោន្តិ ១ភោ រីតរាគា ឧសយនីយេ ១ម្ម្ជ-
ភស្ស អាទិភម្ម្ជភស្ស្ជាតិ ។

ត្ត្ជ្ជ្ជ

[១៥៥] ផ្ទះសម្រាប់ដេក ភិក្ខុក៏សំគាល់ថា ផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ ផ្ទះសម្រាប់ដេកភិក្ខុសង្ឆ័យ ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ ផ្ទះសម្រាប់ដេក ភិក្ខុសំគាល់ថា មិនមែនផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនផ្ទះសម្រាប់ដេកភិក្ខុសំគាល់ថា ផ្ទះសម្រាប់ដេកត្រូវអាបត្តិទុក្កដ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសង្ឆ័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុក៏សំគាល់ថា មិនមែនផ្ទះសម្រាប់ដេក មិនត្រូវអាបត្តិ ។

[១៥៦] អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយក្នុងផ្ទះធំ មិនលះហត្ថ-បាសនៃមេទ្វារ ឬធរណី ដល់ភិក្ខុអង្គុយក្នុងផ្ទះតូច មិនហួសមេដំបូល ដល់ភិក្ខុដែលមានភិក្ខុជាគម្រប់ពីរអង្គុយនៅផង ដល់ភិក្ខុដែលអង្គុយនៅតែជនទាំងពីរនាក់គេចេញទៅហើយ ដល់ភិក្ខុដែលអង្គុយនៅជាមួយនឹងជនទាំងពីរនាក់ជាបុគ្គលមិនមានពាគ: ដល់ភិក្ខុអង្គុយនៅក្នុងផ្ទះ ដែលមិនមែនជាផ្ទះសម្រាប់ដេក ដល់ភិក្ខុឆ្ងត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់ ។

ចតុត្ថសិក្ខាបទំ

[១៥៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សហាយកស្ស ឃរំ គន្ត្វា តស្ស បជាបតិយា សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេសិ ។ អថ ខោ សោ បុរិសោ ឧជ្ឈាយតិ ខីយតិ វិចារេតិ កថំ ហិ នាម អយ្យោ ឧបនន្ទោ មយ្ហំ បជាបតិយា សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិចារេន្តស្ស ។ យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ មាតុក្តាមេន សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ មាតុក្តាមេន សទ្ធឹ រហោ បដិច្ឆន្នេ

សិក្ខាបទទី ៤

[១៥៧] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថនៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានទៅកាន់ផ្ទះរបស់បុរសជាសំឡាញ់ ហើយក៏សម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះ ។ គ្រានោះ បុរសនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនគួរបើនឹងហ៊ានមកសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់ខ្ញុំ (ដូច្នេះ) សោះ ។ ភិក្ខុទាំងឡាយបានឮសំដីនៃបុរសនោះ និយាយពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម (ដូច្នោះ) ទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង

អាសនេ និសជ្ជំ កប្បេយ្យសីតិ ។ សចេ ភគ-
វតិ ។ វិតរហិ ពុទ្ធោ ភគវា ភិក្ខូ ហិ ជាម តុ
មោយបុរិស មាតុគ្គាមេន សទ្ធឹ រហោ បដិច្ឆន្ន
អាសនេ និសជ្ជំ កប្បេស្ស្ស្ស ដេតំ មោយបុរិស
អប្ប្ សន្ថានំ វ បសាជាយ បសន្ថានំ ។ ១ ។ ១ ។
ភាវាយ ។ ១ ។ ១ ។ ១

ជាមួយនឹងមាតុគ្រាម ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម (ដូច្នោះ) ទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង មួយអន្ទើដោយមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។

[១៥៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺស្ត្រីមនុស្ស មិនមែនជាយក្សស្ត្រី មិនមែនជាប្រេតស្ត្រី មិនមែនតិរច្ឆានញ្ជី ដោយហោចទៅសូម្បីតែក្មេងស្ត្រីដែលទើបនឹងកើតបាន ១ ថ្ងៃ មិនបាច់និយាយទៅថ្ងៃដល់ស្ត្រីធំទេ ។ ពាក្យថា មួយអន្ទើ គឺជាមួយគ្នា ។ ដែលហៅថា ទីស្ងាត់ គឺទីដែលស្ងាត់ភ្នែក ស្ងាត់ត្រចៀក ។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី

 វ និទ្ទិយមានេ ភមុកំ វ ឧក្ខិបិយមានេ សីសំ វ ឧក្ខិបិយមានេ បស្សិតុំ ។ សោតស្ស រហោ ជាមន សណ្ហា ហោតិ បកតិកថា សោតុំ ។ បដិច្ឆន្នំ ជាម អាសនំ ឥត្ថន្នេ វ ឥត្ថាគារេ វ ឥត្ថិសញ្ជេ វ សាណិប្បាការេ វ រុក្ខេ វ ថម្ភេ វ ឧទ្ធម្ពេ វ ឧទ្ធម្ពិយា វ យេន ឥមិនា ចិ បដិច្ឆន្នំ ហោតិ ។ និសជ្ជំ ឥមិនា ឥមិយ្យាតិ មាតុគ្គាមេ និសិន្នេ ភិក្ខុ ឧបនិ-សិន្នោ វ ហោតិ ឧបនិបន្នោ វ អាបត្តិ ចាចិត្តិយស្ស ។ ភិក្ខុ និសិន្នេ មាតុគ្គាមោ ឧបនិសិន្នោ វ ហោតិ ឧបនិបន្នោ វ អាបត្តិ ចាចិត្តិយស្ស ។ ឧភោ វ និ-សិន្នា ហោន្តិ ឧភោ វ និបន្នា អាបត្តិ ចាចិត្តិយស្ស ។

[១៥៩] មាតុគ្គាមេ មាតុគ្គាមសញ្ញី រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ ឥមិនា អាបត្តិ ចាចិត្តិយស្ស ។ មាតុគ្គាមេ វេមតិកោ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ ឥមិនា អាបត្តិ ចាចិត្តិយស្ស ។ មាតុគ្គា-មេ អមាតុគ្គាមសញ្ញី រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ ឥមិនា អាបត្តិ ចាចិត្តិយស្ស ។ យក្ខិយា វ

ញ្ជាក់ចិញ្ចើមក្តី ងក់ក្បាលក្តី បុគ្គលដទៃមិនអាចឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺទីដែលបុគ្គលដទៃមិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ដែលហៅថា អាសនៈជាទីកំបាំង គឺអាសនៈដែលគេបិទបាំងដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលផ្ទៃងក្តី ដោយរនាំង ឬវាំង-ननក្តី ដោយឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ឬដោយវត្ថុណាមួយ ។ ពាក្យថា សម្រេចការអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិត ឬ ដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីរអង្គុយក្តី ជនទាំងពីរដេកក្តី (ឯភិក្ខុ) ត្រូវអាបត្តិបាចិត្តិយ ។

[១៥៩] មាតុគ្រាម ភិក្ខុក៏សំគាល់ថា មាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងយក្សស្រីក្តី

ឬ ១ ១ ១

ប្រេតស្រីក្តី ខ្ទើយក្តី តិរច្ឆានញីដែលមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ ។

[១៦០] អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយនៅ មានបុរសណា-មួយដែលជាមនុស្សដឹងក្តី (នៅ) ជាគម្រប់ពីរ ដល់ភិក្ខុឈរមិនបានអង្គុយ ដល់ភិក្ខុបានក្រឡេកគយគន់រកទីមិនស្ងាត់ហើយអង្គុយ ដល់ភិក្ខុមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃហើយអង្គុយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

បញ្ចមសិក្ខាបទំ

[១៦១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សហាយកស្ស ឃរំ គន្ត្វា តស្ស បជាបតិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសិ ។ អថ ខោ សោ បុរិសោ ឧជ្ឈាយតិ ខីយតិ វិចារេតិ កថំ ហិ នាម អយ្យោ ឧបនន្ទោ មយ្ហំ បជាបតិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិចារេន្តស្ស ។ យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស

សិក្ខាបទទី ៥

[១៦១] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ដើរទៅកាន់ផ្ទះរបស់សំឡាញ់ ហើយក៏សម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះតែម្នាក់និងម្នាក់ ។ គ្រានោះ បុរសនោះ ក៏ពោលទោស តិះ-ដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាម្ចាស់មិនសមបើនឹងហ៊ានមកសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់ខ្ញុំតែម្នាក់និងម្នាក់ (ដូច្នេះ) សោះ ។ ភិក្ខុទាំងឡាយបានឮពាក្យសំដីនៃបុរសនោះកំពុងពោលទោស តិះដៀល បន្ទុះបង្ហាប់ (ដូច្នោះ) ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់ទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់ ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស

មាតុក្ការមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ
កប្បេស្សសិ ឣតំ មោយបុរិស អប្បសន្ធានំ វា
បសាទាយ បសន្ធានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ហ
បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន
ភិក្ខុ មាតុក្ការមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ
កប្បេយ្យ ចាចិត្តិយន្តិ ។

[១៦២] យោ បជានតិ យោ យានិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថ អធិប្បេតោ
ភិក្ខូតិ ។ មាតុក្ការមោ ជាម មនុស្សិត្ថី ន យក្ខី ន
ប្រេតី ន តិរច្ឆានគតា វិញ្ញូ បដិពលា សុភាសិតទុព្ភា-
សិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។ សទ្ធិន្តិ ឯកតោ ។
ឯកោ ឯកាយាតិ ភិក្ខុ ចេវ ហោតិ មាតុក្ការមោ ច ។
រហោ ជាម ចក្ខុស្ស រហោ សោតស្ស រហោ ។
ចក្ខុស្ស រហោ ជាម ន សក្លា ហោតិ អក្ខីនិ វា
និខនិយមានេ ភមុកំ វា ឧក្ខិបិយមានេ សីសំ វា
ឧក្ខិបិយមានេ បស្សិតុំ ។ សោតស្ស រហោ ជាម

អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់ (ដូច្នេះ) ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ មួយអន្ទើដោយមាតុគ្រាមតែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។

[១៦២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺចំពោះតែស្ត្រីមនុស្ស មិនមែនជាយក្សស្ត្រី មិនមែនជាប្រេតស្ត្រី មិនមែនជាតិរច្ឆានញ្ជីជាអ្នកដឹងក្តី ជាអ្នកអាចដើម្បីស្គាល់ពាក្យសំដី ដែលបុគ្គលនិយាយល្អ ឬអាក្រក់ ពាក្យអាសគ្រាម ឬមិនមែនអាសគ្រាម ។ ពាក្យថា មួយអន្ទើ គឺជាមួយគ្នា ។ ពាក្យថា តែម្នាក់និងម្នាក់ គឺមានតែភិក្ខុនិងមាតុគ្រាមប៉ុណ្ណោះ ។ ដែលហៅថា ទីស្ងាត់ គឺទីស្ងាត់ភ្នែក ស្ងាត់ត្រចៀក ។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញ្ជាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ជនដទៃមិនអាចឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក

ន សណ្ហា ហោតិ បកតិកថា សោតុំ ។ និសជ្ជំ កប្ប-
យ្យាតិ មាតុគ្គាមេ និសិន្នេ ភិក្ខុ ឧបនិសិន្នោ វា
ហោតិ ឧបនិបន្នោ វា អាបត្តិ ចាចិត្តិយស្ស ។
ភិក្ខុ និសិន្នេ មាតុគ្គាមោ ឧបនិសិន្នោ វា ហោតិ
ឧបនិបន្នោ វា អាបត្តិ ចាចិត្តិយស្ស ។ ឧភោ វា
និសិន្នា ហោន្តិ ឧភោ វា និបន្នា អាបត្តិ ចាចិត្តិយស្ស ។

[១៦៣] មាតុគ្គាមេ មាតុគ្គាមសញ្ញី ឋកោ
ឋកាយ រហោ និសជ្ជំ កប្បេតិ អាបត្តិ ចាចិត្តិយស្ស ។
មាតុគ្គាមេ វេមតិកោ ឋកោ ឋកាយ រហោ និសជ្ជំ
កប្បេតិ អាបត្តិ ចាចិត្តិយស្ស ។ មាតុគ្គាមេ អមាតុ-
គ្គាមសញ្ញី ឋកោ ឋកាយ រហោ និសជ្ជំ កប្បេតិ
អាបត្តិ ចាចិត្តិយស្ស ។ យក្ខិយា វា បេតិយា វា
បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហិត្ថិយា វា សទ្ធឹ
ឋកោ ឋកាយ រហោ និសជ្ជំ កប្បេតិ អាបត្តិ
ទុក្កដស្ស ។ អមាតុគ្គាមេ មាតុគ្គាមសញ្ញី អាបត្តិ
ទុក្កដស្ស ។ អមាតុគ្គាមេ វេមតិកោ អាបត្តិ ទុក្កដស្ស ។
អមាតុគ្គាមេ អមាតុគ្គាមសញ្ញី អនាបត្តិ ។

គឺទីដែលបុគ្គលមិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ពាក្យថា សម្រេចការអង្គុយគឺកាលដែលមាតុគ្រាម អង្គុយហើយ ភិក្ខុអង្គុយជិតឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិតឬដេកជិត (ភិក្ខុ) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិងស្រីទាំងពីរនាក់ អង្គុយក្តី ដេកក្តី (ភិក្ខុ) ត្រូវអាបត្តិបាចិត្តិយ ។

[១៦៣] មាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយ ក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងយក្សស្រីក្តី ប្រេតស្រីក្តី ខ្ទើយក្តី តិរច្ឆានញីដែលមានរាងកាយដូចមនុស្សក្តី តែម្នាក់និងម្នាក់ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម មិនមានអាបត្តិ ។

[១៦៤] អជ្ឌាបត្តិ យោ កោចិ ឯ្ហ បុរិសោ ឧតិយោ ហោតិ តិដ្ឋតិ ន និសីទតិ អរហោបេក្ខោ អញ្ញាវិហិតោ និសីទតិ ឧម្មត្តកស្ស អាទិកម្មិ-
កស្ស្ជាតិ ។

[១៦៤] *អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយនៅ មានបុរសណា*

ម្នាក់ជាអ្នកដឹងសេចក្តីនៅជាគម្រប់ពីរ ដល់ភិក្ខុឈរមិនបានអង្គុយ ដល់ភិក្ខុ

បានក្រឡេកគយគន់រកទីមិនស្ងាត់ហើយអង្គុយនៅ ដល់ភិក្ខុមានចិត្តបញ្ជូន

ទៅកាន់អារម្មណ៍ដទៃអង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

ឆដ្ឋសិក្ខាបទំ

[១៦៥] តេន សមយេន ពុទ្ធោ ភគវា ភាគ្គវោ
វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន
សមយេន អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស
ឧបដ្ឋាកកុលំ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ភត្តេន
និមន្តេសិ អញ្ញេបិ ភិក្ខូ ភត្តេន និមន្តេសិ ។ តេន
ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ
បុរេភត្តំ កុលានិ បយិរុចាសតិ ។ អថខោ តេ ភិក្ខូ
តេ មនុស្ស ឯតទវោចុំ ឧេបាសកា ភត្តន្តិ ។ អាត-
មេថ ភន្តេ យាវ អយ្យោ ឧបនន្ទោ អាគច្ឆតីតិ ។
ទុតិយម្ឃិ ខោ តេ ភិក្ខូ តេ មនុស្ស ឯតទវោចុំ ឧ-
ឧបាសកា ភត្តន្តិ ។ អាតមេថ ភន្តេ យាវ អយ្យោ ឧប-
នន្ទោ អាគច្ឆតីតិ ។ តតិយម្ឃិ ខោ តេ ភិក្ខូ តេ

សិក្ខាបទទី ៦

[១៦៥] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថនៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ត្រកូលជាឧបដ្ឋាករបស់ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ និមន្តព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុដោយកត្ត ហើយក៏និមន្ត ពួកភិក្ខុឯទៀតដោយកត្តដែរ ។ សម័យនោះឯង ព្រះឧបនន្ទជាសក្ស-បុត្រដ៏មានអាយុ អាល័យតែចូលទៅរកត្រកូលទាំងឡាយ ក្នុងពេលមុនធាន់ ។ ឯភិក្ខុទាំងឡាយនោះ ក៏បាននិយាយពាក្យនេះនឹងមនុស្សអម្បាលនោះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់ (មក) ។ ពួកមនុស្សអម្បាលនោះ ក៏និយាយឃាត់ថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ រង់ចាំសិន ទម្រាំព្រះឧបនន្ទជាម្ចាស់លោកនិមន្តមក ។ ភិក្ខុទាំងឡាយនោះ បាននិយាយពាក្យនេះនឹងពួកមនុស្សអម្បាលនោះជាគម្រប់ពីរដងថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់មក ។ ពួកមនុស្សអម្បាលនោះ ក៏និយាយឃាត់ថា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូមព្រះករុណាទាំងឡាយ រង់ចាំសិនចុះ ទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមក ។ ពួកភិក្ខុអម្បាលនោះ ក៏និយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះ ជាគម្រប់បីដងថា

មនុស្ស ឯតទវោចុំ ឧបាសកា ភត្តំ បុរេ ការាលោ
អតិក្ក្ហមតីតិ ។ យម្ហិ មយំ ភន្តេ ភត្តំ ការិម្ហា អយ្យស្ស
ឧបនន្ទស្ស ការណា អាគមេថ ភន្តេ យាវ អយ្យោ
ឧបនន្ទោ អាគច្ឆតីតិ ។ អថ ខោ អាយស្មា ឧបនន្ទោ
សក្យបុត្តោ បុរេភត្តំ ឧបាសកានិ បយិរុបាសិត្វា ឯវ
អាគច្ឆតិ ។ ភិក្ខូ ន ចិត្តរូបំ ភុញ្ជិសុ ។ យេ តេ
ភិក្ខូ អប្ប្ហិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបា-
ចេន្តិ ឧបាសកា ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ
ឯវមាហ ។ ១ សកត្តោ សមានោ បុរេភត្តំ ឧបាសកានិ ចារិត្តំ
អាបជ្ជិស្សតីតិ ។ បេ ។ សច្ចំ ភិក្ខវ ត្វំ ឧបនន្ទ ឯវមាហ-
ត្តោ សកត្តោ សមានោ បុរេភត្តំ ឧបាសកានិ ចារិត្តំ
អាបជ្ជសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា
ឧបាសកា ហិ នាម ត្វំ មោឃបុរិស ឯវមាហ ។ ១ សកត្តោ

ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរប្រគេនចង្ហាន់មក (នឹងបង្ហិនៅ) ក្រែងហួសពេលធាន់ ។ មនុស្សទាំងឡាយក៏និយាយថា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន យើងខ្ញុំទាំងឡាយបានធ្វើកត្តទាំងប៉ុន្ម្មានព្រោះតែព្រះឧបនន្ទជាម្ចាស់ (ទេតើ) បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូមព្រះករុណាទាំងឡាយរង់ចាំទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្ត មកសិន ។ លំដាប់នោះ ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ អាល័យតែចូលទៅគួរសមនឹងត្រកូលទាំងឡាយ ក្នុងពេលមុនធាន់ ហើយក៏មកក្នុងវេលាថ្ងៃពេក ។ ភិក្ខុទាំងឡាយ ក៏ធាន់ចង្ហាន់មិនល្មមដល់ចិត្ត ។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ បានទទួលនិមន្តគេ ជាអ្នកមានកត្តហើយ មិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងពេលមុនធាន់ (ដូច្នេះ) សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងបានទទួលនិមន្តគេ ជាអ្នកមានកត្តហើយ ។ ត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងពេលមុនធាន់ ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្ដីនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃ-បុរស អ្នកឯងបានទទួលនិមន្តគេ ជាអ្នកមានកត្តហើយ មិនគួរនឹងត្រាច់ទៅ

សមាណោ បុរេភត្តំ ការណេ ចារិត្តំ អាបជ្ជិស្ស សិ ណេតំ មោឃបុរិស អប្ប្ សន្ថានំ វ ២ សាធ្ យ ២ ២ ២

ក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងពេលមុនធាន់ (ដូច្នេះ) ទេ នែ
មោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន
ដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លា
ឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បី
សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបានទទួលនិមន្តគេ
ជាអ្នកមានកត្តហើយ ដល់នូវកិរិយាត្រាច់ទៅ ក្នុងត្រកូលទាំងឡាយក្នុង
ពេលមុនធាន់ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ
ទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៦] កាលនោះ ត្រកូលឧបដ្ឋាករបស់ព្រះឧបនន្ទ ជាសក្យបុត្ត
ដ៏មានអាយុ បានបញ្ជូនខាទនីយាហារទៅ ដើម្បីប្រគេនដល់សង្ឆដោយ
ពាក្យថា ខាទនីយៈនេះ អ្នកឯងត្រូវបង្ហាញដល់ព្រះឧបនន្ទជាម្ចាស់ហើយ
សឹមប្រគេនដល់សង្ឆចុះ ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្ត ដ៏
មានអាយុចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ឯពួកមនុស្សអម្បាលនោះ
ទៅកាន់អារាមហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយ
ដ៏ចម្រើន ព្រះឧបនន្ទជាម្ចាស់និមន្តទៅឯណា ។ ពួកភិក្ខុអម្បាលនោះប្រាប់
ថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ
នុ៎ះនិមន្តទៅកាន់ស្រុក ដើម្បីបិណ្ឌបាតហើយ ។ មនុស្សទាំងឡាយ

ឧបនន្ទស្ស ឧស្សេត្វា សជ្ជ្ស្ស ជានតព្ពន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ[១] ។ តេនហិ ភិក្ខវេ បដិក្ខហេត្វា ឯកិក្ខិបថ យាវ ឧបនន្ទោ អាគច្ឆតីតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ ភគវតា បដិក្ខិត្តំ បុរេភត្តំ ការេសុ ចារិត្តំ អាបជ្ជិត្តុន្តិ បច្ឆាភត្តំ ការេសិ ។ ១ ។ ២ ។ ១ ។ ២ ។ ១ ។ ២

ក៏និយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខាទនីយាហារនេះ សូមលោកម្ចាស់ទាំងឡាយបង្ហាញដល់ព្រះឧបនន្ទដ៏មានអាយុ ហើយសឹមប្រគេនដល់សង្ឆ ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយត្រូវទទួលហើយតម្កល់ទុកទម្រាំឧបនន្ទត្រឡប់មកវិញ ។ គ្រានោះ ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុគិតថា ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់មិនឲ្យត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្ត (គិតដូច្នោះហើយ) ក៏ចូលទៅរកត្រកូលទាំងឡាយក្នុងវេលាក្រោយភត្ត ហើយត្រឡប់មកក្នុងវេលាហួសពេល ។ ខាទនីយាហារគេក៏ផ្ញើត្រឡប់ទៅវិញ ។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនគួរបើនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងវេលាក្រោយភត្ត (ដូច្នោះ) សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងវេលាក្រោយភត្ត ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្ដីនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលក្រោយភត្ត (ដូច្នេះ)

មោឃបុរិស អប្ឋសន្ថានំ វា បសាណាយ បសន្ថានំ វា កិយ្យោ ការាយ ។ បេ ។ ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានមត្ត្ជានោ សកត្ថោ សមានោ បុរេភត្តំ វា បច្ឆាភត្តំ វា ការុលេ សុ ចារិត្តំ អាបជ្ជេយ្ យ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគ្ គវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១៦៧] តេន ខោ បន សមយេន ភិក្ខូ ចីវរ ជ-ជ-ជ-

ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះ-ថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំ-ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបានទទួលនិមន្តគេជាអ្នកមានកត្តហើយដល់នូវកិរិយាត្រាច់ទៅ ក្នុងត្រកូលទាំងឡាយក្នុងពេលមុនកត្តក្តី ក្រោយកត្តក្តី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៧] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យ ក្នុងសម័យនៃចីវរទាន ហើយមិនបានចូលទៅរកត្រកូលទាំងឡាយ ។ ចីវរក៏កើតឡើងតិចស្ពួចស្តើង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅរកត្រកូលទាំងឡាយ ក្នុងសម័យនៃចីវរ-ទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេ ជាអ្នកមានកត្ត ហើយដល់នូវកិរិយាត្រេចទៅ ក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនកត្តក្តី ក្រោយកត្តក្តី ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។

តត្ថាយំ សមយោ ចីវរជានសមយោ អយំ តត្ត សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១៦៨] តេន ខោ បន សមយេន ភិក្ខូ ចីវរកម្មំ ករោន្តិ អត្ថោ ច ហោតិ សុចិយាបិ សុត្តេនបិ សត្ថកេនបិ ។ ភិក្ខូ ការុញ្ញតាយ ធ្លា ការុលានិ ន បយិរុចាសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামិ ភិក្ខវេ ចីវរការសមយេ ការុលានិ បយិរុចាសិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឯមត្ថិតោ សកត្ថោ សមានោ បុរេភត្តំ វា បច្ឆាភត្តំ វា ការុ-លេសុ ចារិត្តំ អាបជ្ជេយ្យ អញ្ញត្រ សមយា ចាចិត្តិ-យំ ។ តត្ថាយំ សមយោ ចីវរជានសមយោ ចីវរ-ការសមយោ អយំ តត្ត សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្ត ហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៨] សម័យនោះឯង ភិក្ខុទាំងឡាយធ្វើចីវរកម្ម គឺការដេរចីវរ ក៏មានសេចក្ដីត្រូវការដោយមូលខ្លះ ដោយចេសខ្លះ ដោយកាំបិតខ្លះ ។ ភិក្ខុទាំងឡាយមានសេចក្ដីសង្ស័យ មិនបានចូលទៅរកត្រកូលទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅរកត្រកូលទាំងឡាយ ក្នុងសម័យធ្វើចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេ ជាអ្នកមានកត្តហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលមុនកត្តក្ដី ក្រោយកត្តក្ដី ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុ ទាំងឡាយ យ៉ាងនេះ ។

បាចិត្តិយកណ្ឌ អចេលកវគ្គស្ស ឆដ្ឋសិក្ខាបទស្ស សិក្ខាបទវិភង្គោ

[១៦៩] តេន ខោ បន សមយេន ភិក្ខូ
កិលានា ហោន្តិ អត្តោ ច ហោតិ ភេសជ្ជេហិ ។ ភិក្ខូ
ការុញ្ញាយន្តា ការុណិ ន បយិរុចាសន្តិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អនុជានামិ ភិក្ខវេ សន្តំ ភិក្ខុំ
អាបុច្ឆា ការុណិ បយិរុចាសិតុំ ឯវញ្ច បន ភិក្ខវេ
ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ និ-
មន្តិតោ សភត្តោ សមានោ សន្តំ ភិក្ខុំ អនាបុច្ឆា
បុរេភត្តំ វា បច្ឆាភត្តំ វា ការុណេសុ ចារិត្តំ អាបជ្ជេយ្យ
អញ្ញត្រ សមយា ចាចិត្តិយំ ។ តត្ថាយំ សម-
យោ ចីវរទានសមយោ ចីវរការសមយោ អយំ តត្ថ
សមយោតិ ។

[១៧០] យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ
ភិក្ខូតិ ។ និមន្តិតោ នាម បញ្ចន្នំ ភោជនានំ អញ្ញតរេន
ភោជនេន និមន្តិតោ ។ សភត្តោ នាម យេន និ-
មន្តិតោ តេន សភត្តោ ។ សន្តំ នាម ភិក្ខុំ សក្ការ

[១៦៩] សម័យនោះឯង ភិក្ខុទាំងឡាយមានជំងឺ ក៏មានសេចក្តីត្រូវការដោយកេសជ្ជៈទាំងឡាយ ។ ភិក្ខុទាំងឡាយក៏សង្ស័យមិនបានចូលទៅរកត្រកូលទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលា ឬប្រាប់ភិក្ខុដែលមាននៅ ហើយសឹមចូលទៅរកត្រកូលទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេ ជាអ្នកមានកត្តហើយមិនបានលា ឬប្រាប់ភិក្ខុដែលមាននៅ ហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនកត្តក្តី ក្រោយកត្តក្តី ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺ កាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[១៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា គេនិមន្ត គឺ ជននិមន្ត ដោយភោជនទាំង ៥ យ៉ាង ភោជនណាមួយ ។ ដែលហៅថា ជាអ្នកមានកត្ត គឺភិក្ខុដែលគេនិមន្តដោយកត្តណា ឈ្មោះថា ជាអ្នកមានកត្ត ព្រោះកត្តនោះឯង ។ ដែលហៅថា ភិក្ខុមាននៅនោះ គឺភិក្ខុអាចនឹងលា

ហោតិ អាបុច្ឆា បវិសិតុំ ។ អសន្ថំ ជាម ភិក្ខុ
ន សក្ការ ហោតិ អាបុច្ឆា បវិសិតុំ ។ បុរេភត្តំ
ជាម យេន ជិមន្ថិតោ តំ អកុត្តារី ។ បច្ឆាភត្តំ
ជាម យេន ជិមន្ថិតោ អន្ថមសោ ភុសត្ថេនបិ
ភុត្តំ ហោតិ ។ ភុលំ ជាម ចត្តារិ ភុលានិ
ខត្តិយភុលំ ព្រាហ្មណភុលំ វេស្សភុលំ សុទ្ធភុលំ ។
ភុលេសុ ចារិត្តំ អាបជ្ជេយ្យាតិ អញ្ញស្ស ឃរុបចារ
ឧក្ខ្លមន្ថស្ស អាបត្តិ ទុក្ខ្លជស្ស ។ បឋមំ ចាជ
ឧម្ការ អតិក្ខ្លាមេតិ អាបត្តិ ទុក្ខ្លជស្ស ។ ទុតិយ
ចាជ អតិក្ខ្លាមេតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញត្រ
សមយាតិ បវេត្ថ សមយ ។ ចីវរទានសមយោ
ជាម អនត្ថតេ ភបិនេ វស្សានស្ស បច្ចិមោ មាសោ
អត្ថតេ ភបិនេ បញ្ច មាសា ។ ចីវរការសមយោ
ជាម ចីវរេ ភយិរមានេ ។

ភិក្ខុផងគ្នាហើយចូលទៅកាន់ (ត្រកូល) បាន ។ ភិក្ខុដែលមិនមាននៅ
នោះ គឺភិក្ខុមិនអាចលាភិក្ខុផងគ្នាហើយចូលទៅកាន់ (ត្រកូល) ឡើយ ។
ដែលហៅថា ក្នុងពេលមុនភត្ត គឺជននិមន្តដោយភត្តណា ហើយភិក្ខុមិន
ទាន់បានធាន់ភត្តនោះ ។ ដែលហៅថា ក្នុងពេលក្រោយភត្ត គឺជននិមន្ត
ដោយភត្តណា ភិក្ខុបានធាន់ភត្តនោះហើយ ដោយហោចទៅសូម្បីប៉ុនចុង
នៃស្លរ ។ ដែលហៅថា ត្រកូល គឺត្រកូលទាំងឡាយ ៤ គឺត្រកូលក្សត្រ ១
ត្រកូលព្រាហ្មណ៍ ១ ត្រកូលវេស្ស: (អ្នករកស៊ីជួញប្រៃធ្វើស្រែចំការ) ១
ត្រកូលសុទ្ទ: (អ្នកធ្វើការស៊ីឈ្នួល) ១ ។ ពាក្យថា ដល់នូវកិរិយាត្រេចទៅ
ក្នុងត្រកូលទាំងឡាយ គឺកាលដែលភិក្ខុឈានចូលទៅដល់ឧបចារផ្ទះរបស់
បុគ្គលដទៃទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងជាដំបូងឲ្យកន្ទងហួស
ឆរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងជាគម្រប់ពីរឲ្យកន្ទងហួសទៅ
ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា រៀរលែងតែមានសម័យ គឺលើកទុកតែ
មានសម័យ ។ ដែលហៅថា កាលដែលទាយកប្រគេនចីវរនោះ គឺថា
បើភិក្ខុមិនបានក្រាលកឋិន កំណត់កាល ត្រឹម ១ ខែជាទីបំផុតនៃវស្សានរដូវ
(គឺតាំងពី ១ រោចខែអស្សុជទៅដល់ ១៥ កើតខែកត្តិក) បើភិក្ខុបានក្រាលកឋិន
កំណត់កាលត្រឹម ៥ ខែ (តាំងតែពី ១ រោចខែអស្សុជទៅដល់ ១៥ កើតខែ
ផល្គុន) ។ ដែលហៅថា កាលដែលភិក្ខុធ្វើចីវរនោះ គឺភិក្ខុកំពុងធ្វើចីវរ ។

[១៧១] ជិមន្តិតេ ជិមន្តិតសញ្ញី សន្តំ ភិក្ខុំ អជាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា ការណេ ចារិត្តំ អាបជ្ជតិ អញ្ញត្រ សមយា អាបត្តិ ចាចិត្តិយស្ស ។ ជិមន្តិតេ វេមតិកោ សន្តំ ភិក្ខុំ អជាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា ការណេ ចារិត្តំ អាបជ្ជតិ អញ្ញត្រ សមយា អាបត្តិ ចាចិត្តិយស្ស ។ ជិមន្តិតេ អជិមន្តិត-សញ្ញី សន្តំ ភិក្ខុំ អជាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា ការណេ ចារិត្តំ អាបជ្ជតិ អញ្ញត្រ សមយា អាបត្តិ ចាចិត្តិយស្ស ។ អជិមន្តិតេ ជិមន្តិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អជិមន្តិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អជិមន្តិតេ អជិមន្តិតសញ្ញី អនាបត្តិ ។

[១៧១] មានគេនិមន្តហើយ ភិក្ខុសំគាល់ថា គេនិមន្តហើយ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ មានគេនិមន្តហើយ ភិក្ខុសង្ស័យ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ មានគេនិមន្តហើយ ភិក្ខុសំគាល់ថា មិនទាន់និមន្ត ហើយមិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ គេមិនបាននិមន្ត ភិក្ខុសំគាល់ថា និមន្តហើយ ត្រូវអាបត្តិទុក្កដ ។ គេមិនបាននិមន្ត ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គេមិនបាននិមន្ត ភិក្ខុសំគាល់ថា មិនបាននិមន្ត មិនមានអាបត្តិ ។

[១៧២] អជាបត្តិ សមយេ សន្តំ ភិក្ខុំ អាបុច្ឆា បវិសតិ អសន្តំ ភិក្ខុំ អជាបុច្ឆា បវិសតិ អញ្ញស្ស ឃរេន មត្តោ ហោតិ ឃរុបចារេន មត្តោ ហោតិ អន្តរារាមំ[១] គច្ឆតិ ភិក្ខុនូបស្សយំ គច្ឆតិ តិត្ថិយសេយ្យំ គច្ឆតិ បដិក្ក្រមនំ គច្ឆតិ ភត្តិយឃរំ គច្ឆតិ អាបជ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

---

១ ឱ. អន្តរគាមំ ។

[១៧២] អាបត្តិមិនមាន ដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលបានលាភិក្ខុផង់គ្នាដែលមាននៅហើយចូលទៅ ដល់ភិក្ខុដែលមិនបានលាភិក្ខុផង់គ្នា ព្រោះមិនមានភិក្ខុផង់គ្នាហើយចូលទៅ ដល់ភិក្ខុដែលដើរទៅតាមផ្លូវក្បែរផ្ទះនៃបុគ្គលដទៃ ដល់ភិក្ខុដែលដើរទៅដោយផ្លូវតាមឧបចារៈនៃផ្ទះ ដល់ភិក្ខុដែលទៅកាន់អាវាមដែលមានក្នុងចន្ទោះស្រុក ដល់ភិក្ខុដែលទៅកាន់លំនៅនៃនាងភិក្ខុនី ដល់ភិក្ខុដែលទៅកាន់លំនៅនៃតិរ្ថិយ ដល់ភិក្ខុដែលដើរត្រឡប់មកវិញ ដល់ភិក្ខុទៅកាន់ផ្ទះនៃទាយក ជាម្ចាស់ភត្ត ដល់ភិក្ខុដែលមានសេចក្ដីអន្ដរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

សត្តមសិក្ខាបទំ

[១៧៣] តេន សមយេន ពុទ្ធោ ភគវា សង្ខេ្ក សុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន មហានាមស្ស សក្ក្ស្ស ភេសជ្ជំ ឧស្សន្នំ ហោតិ ។ អថខោ មហានាមោ សក្ក្យោ យេន ភគវា តេនុបសង្ក្មិ ។ ១ ។ ១ ។ ១

សិក្ខាបទទី ៧

[១៧៣] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្ក: ។ សម័យនោះឯង មហានាមសក្ក:[១] មានថ្នាំសម្រាប់កែរោគដ៏បរិបូណ៌ ។ លំដាប់នោះ មហានាមសក្ក:ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហានាមសក្ក:អង្គុយនៅ ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់ បវារណា ព្រះសង្ឆដោយថ្នាំសម្រាប់កែរោគកំណត់ ៤ ខែ ។ ព្រះអង្គ ត្រាស់ថា មហានាម ការនេះប្រពៃពេកហើយ មហានាម បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឆ ដោយថ្នាំសម្រាប់កែរោគកំណត់ ៤ ខែចុះ ។ ពួកភិក្ខុមានសេចក្តីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះការបវារណា

---

១ អដ្ឋកថាថា មហានាមសក្ក:នេះ ជាបុត្រនៃចូឡបិតារបស់ព្រះដ៏មានព្រះភាគចាស់ជាងព្រះដ៏មានព្រះភាគប្រមាណ ១ ខែ ជាអរិយសាវកបានតម្កល់នៅក្នុងផលទាំងពីរ គឺសោតាបត្តិផល និងសកទាគামិផល ។

សាធិតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ មហាជាមំ
សក្ខំ បរិត្តំយេវ[1] ភេសជ្ជំ វិញ្ញាបេន្តិ ។ តថេវ
មហាជាមស្ស សក្ខស្ស ភេសជ្ជំ ឧស្សន្នំ ហោតិ ។
ទុតិយម្បិ ខោ មហាជាមោ សង្ខោ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯ-
កមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហាជាមោ
សង្ខោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សជ្ជុំ
អបរំបិ ចាតុម្មាសំ ភេសជ្ជេន បវារេតុន្តិ ។ សាធុ
សាធុ មហាជាម តេនហិ ត្វំ មហាជាម សជ្ជុំ
អបរំបិ ចាតុម្មាសំ ភេសជ្ជេន បវារេហីតិ ។ ភិក្ខូ
ការុញ្ញុច្ចាយន្តា ជានិវាសេន្តិ ។ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ អនុជានামិ ភិក្ខវេ បុន បវារណំបិ សាធិ-
តុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ មហាជាមំ សក្ខំ
បរិត្តំយេវ ភេសជ្ជំ វិញ្ញាបេន្តិ ។ តថេវ មហាជាមស្ស
សក្ខស្ស ភេសជ្ជំ ឧស្សន្នំ ហោតិ ។ តតិយម្បិ
ខោ មហាជាមោ សង្ខោ យេន ភគវា តេនុបសង្កមិ

1 ឱ. បរិត្តំ ។

ដោយបច្ច័យកំណត់ត្រឹម ៤ ខែ ។ សម័យនោះឯង ភិក្ខុទាំងឡាយទៅ
សូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិច ។ ។ ភេសជ្ជៈរបស់មហានាម
សក្យៈក៏ជារបស់នៅតែបរិបូណ៌ដដែល ។ ឯមហានាមសក្យៈក៏ចូល
ទៅគាល់ព្រះដ៏មានព្រះភាគជាគម្រប់ពីរដងទៀត លុះចូលទៅដល់ហើយ
ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះ
មហានាមសក្យៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះ
ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំ
ព្រះអង្គចង់បវារណាព្រះសង្ឆដោយភេសជ្ជៈកំណត់ ៤ ខែតទៅទៀត ។
ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃហើយ ។ មហានាម
បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឆ ដោយភេសជ្ជៈកំណត់ ៤ ខែតទៅ
ទៀតចុះ ។ ពួកភិក្ខុមានសេចក្តីសង្ស័យ ក៏មិនហ៊ានទទួល ។
ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះ
អង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុ
ត្រេកអរនឹងការបវារណាថែមម្តងទៀត ។ ក៏សម័យនោះឯង ភិក្ខុ
ទាំងឡាយទៅសូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិច ។ ។ ដោយ
ហេតុនោះឯង ភេសជ្ជៈរបស់មហានាមសក្យៈក៏នៅតែបរិបូណ៌ដដែល ។
មហានាមសក្យៈ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ជាគម្រប់បីដងទៀត

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សង្ឆ្យំ យាវជីវំ ភេសជ្ជេន បវារេតុន្តិ ។ សាធុ សាធុ មហានាម តេនហិ ត្វំ មហានាម សង្ឆ្យំ យាវជីវំ ភេសជ្ជេន បវារេហីតិ ។ ភិក្ខូ ភុត្ត្ភុចាយន្តា ជានិវាសេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামិ ភិក្ខវេ និចូ្ចប្ប្ការណ្ឌ្ យ្ យ្ ។

[១៧៤] តេន ខោ បន សមយេន ឆព្ភ្ក្ខិយា ភិក្ខូ ឧន្ទ្ធ្ការ ហោន្តិ ឧ្ប្ការ្ តា អ្ នាកប្ប្ សម្ប្ន្ន ។ មហានាមេ ១ សក្ខ្ ន ១ ១ ១

លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅ
ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យៈអង្គុយនៅក្នុងទីដ៏សមគួរហើយ
បានពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន
ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឆ ដោយកេសជ្ជៈដរាបដល់អស់ជីវិត ។ ព្រះ
អង្គត្រាស់តបថា មហានាម ការនោះប្រពៃហើយ ។ មហានាម បើដូច្នោះ
ចូរមហាវាជបវារណាសង្ឆ ដោយកេសជ្ជៈដរាបដល់អស់ជីវិតចុះ ។ ពួក
ភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយ ក៏ក្រាបទូល
សេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា
ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរនឹងការបវារណាអស់
កាលជានិច្ចក៏បាន ។

[១៧៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ស្ងៀកដណ្ដប់មិន
ត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ មហានាមសក្យៈក៏និយាយថា
បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុដូចម្ដេច បានជាលោកម្ចាស់ទាំងឡាយ
ស្ងៀកដណ្ដប់សំពត់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ (ដូច្នេះ)
ធម្មតាអ្នកបួសគេត្រូវស្ងៀកដណ្ដប់សំពត់ឲ្យត្រឹមត្រូវណ្ហ ហើយមាន
អាកប្បកិរិយា ដ៏សមគួរទេតើ ។ ពួកឆព្វគ្គិយភិក្ខុក៏ចង់ទោសនឹងមហានាម
សក្យៈ ។ សេចក្ដីត្រិះរិះនេះកើតមានដល់ពួកឆព្វគ្គិយភិក្ខុក្នុងវេលានោះ ថា

កេន នុ ខោ មយំ ឧចាយេន មហាជាមំ សក្ខំ មជ្ជិ
ការយ្យាមាតិ ។ អថខោ ធញ្ញិយានំ ភិក្ខូនំ ឯតទ-
ហោសិ មហាជាមេន[1] អាវុសោ សង្ខេន សង្ខ្យោ
ភេសជ្ជេន បរិវារិតោ ហន្ទ មយំ អាវុសោ មហាជាមំ
សក្ខំ សម្ប៊ី វិញ្ញាបេមាតិ ។ អថខោ ធញ្ញិយា ភិក្ខូ
យេន មហាជាមោ សង្ខ្យោ តេនុបសង្ខ្លមីសុ ឧប-
សង្ខ្លមិត្វា មហាជាមំ សក្ខំ ឯតទវោចុំ ឱោណេន
អាវុសោ សម្ប៊ីជ អត្ថោតិ ។ អជ្ជុណ្ហោ ភន្តេ អាតមេថ
មនុស្ស ១ដ៏ តតា សម្ប៊ី អាហរិតុំ ការណ ហរិស្ស-
ថាតិ ។ ទុតិយម្ប៊ិ ខោ ។ បេ ។ ត្ត្ត្ត ខោ
ធញ្ញិយា ភិក្ខូ មហាជាមំ សក្ខំ ឯតទវោចុំ ឱោណេន
អាវុសោ សម្ប៊ីជ អត្ថោតិ ។ អជ្ជុណ្ហោ ភន្តេ អាតមេថ
មនុស្ស ១ដ៏ តតា សម្ប៊ី អាហរិតុំ ការណ ហរិស្ស-
ថាតិ ។ ការ ១ដ៏ ១ តយ អាវុសោ អជ្ជតុការមេន

---

1 ឥតោ បរំ ឱ. ម. ១ដ៏ ១ ១ ១

យើងទាំងឡាយ គួរធ្វើមហានាមសក្យៈឲ្យអាប់អោនដោយឧបាយដូចម្តេចអេះ ។ គ្រានោះ ពួកធម្មគ្គិយកិក្ខុក៏បានប្រឹក្សាគ្នាដូច្នេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ មហានាមសក្យៈបានបវារណាសង្ឆដោយកេសជ្ជៈហើយ ណ្ហើយចុះ ម្នាលលោកដ៏មានអាយុទាំងឡាយ យើងទាំងឡាយទៅសូមសប្បាយអំពីមហានាមសក្យៈចុះ ។ ទើបពួកធម្មគ្គិយកិក្ខុចូលទៅរកមហានាមសក្យៈ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមហានាមសក្យៈថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសប្បាយមួយទោណៈ ។ ឯមហានាមសក្យៈធ្វើយតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់បង្ហង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន មនុស្សទាំងឡាយគេទៅឯក្រាលគោ ដើម្បីនាំសប្បាយមក លោកម្ចាស់ទាំងឡាយនឹងយកសប្បាយនោះទៅក្នុងកាលដ៏គួរ ។ ពួកធម្មគ្គិយកិក្ខុនិយាយសូមជាគម្រប់ពីរដង ។ បេ ។ ធម្មគ្គិយកិក្ខុនិយាយពាក្យនេះនឹងមហានាមសក្យៈជាគម្រប់បីដងថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសប្បាយមួយទោណៈ ។ មហានាមសក្យៈធ្វើយតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់បង្ហង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន មនុស្សទាំងឡាយគេទៅឯក្រាលគោ ដើម្បីនាំសប្បាយមក លោកម្ចាស់នឹងយកសប្បាយនោះទៅក្នុងកាលដ៏គួរ ។ ពួកធម្មគ្គិយកិក្ខុសួរថា ម្នាលអាវុសោ អ្នកបវារណា

បវារិតេន យំ ត្វំ បវារេត្វា ន ឧសីតិ ។ អថ ខោ
មហាជាមោ សង្ហោ ឧជ្ឈាយតិ ខីយតិ វិចារេតិ កថំ
ហិ នាម ភគ្គ្ គ្ គ្ អជ្ជុណ្ហោ ភវ្ តេ អាតមេថាតិ រុចូមានា
ជាតមេស្ស្ ន្ តីតិ ។ អស្ស្ សុ ខោ ភិក្ខូ មហាជាមស្ស
សង្ហស្ស ឧជ្ឈាយ ន្ ស្ ខីយ ន្ ស្ វិចារ ន្ ស្ ។
យ ត ភិក្ខូ អ ្ ។ ។ ។ ត ឧជ្ឈាយ ន្ ។
ខីយ ន្ ។ ។ ។

ដោយកេសជ្ជ:ណាហើយមិនឲ្យវិញ ប្រយោជន៍អ្វីដោយកេសជ្ជ:ដែលអ្នកបវារណាតែមិនចង់ឲ្យនោះ ។ គ្រានោះ មហានាមសក្យ:ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា លោកដ៏ចម្រើនទាំងឡាយ ខ្ញុំបានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្ហង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន ចុះហេតុដូចម្តេចបានជាមិនរង់ចាំ ។ ភិក្ខុទាំងឡាយបានឮមហានាមសក្យ: ពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុកាលដែលមហានាមសក្យ:បានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្ហង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន មិនគួរនឹងមិនរង់ចាំសោះ ។ បេ ។ ព្រះពុទ្ធជាម្ចាស់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ កាលដែលមហានាមសក្យ:បានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្ហង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិនដូច្នេះ ហើយមិនរង់ចាំ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលពួកមោឃបុរស អ្នកទាំងឡាយ កាលដែលមហានាមសក្យ:បានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្ហង់ចាំក្នុងថ្ងៃនេះ ១ ថ្ងៃសិន ហើយមិនសមនឹងមិនរង់ចាំ (ដូច្នេះ) សោះ នៃមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ

ឯ បសាទាយ បសន្នានំ ឯ កិយ្យាការាយ ។ បេ ។ ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អតិលាភេន ភិក្ខុនា ចាតុម្មាសប្បច្ចុយប្បារណា សាទិ-តព្វា អញ្ញត្រ បុនប្បារណាយ អញ្ញត្រ ឯកប្បារណាយ តតោ ចេ ឧត្តរឺ[(១)] សាទិយេយ្យ ចាចិត្តិយន្តិ ។

[១៧៤] អតិលាភេន ភិក្ខុនា ចាតុម្មាសប្បច្ចុ-យប្បារណា សាទិតព្វាតិ កិលានប្បច្ចយប្បារណា សាទិតព្វា បុនប្បារណាបិ សាទិតព្វា យតា កិលានោ ភវិស្សាមិ តតា វិញ្ញាបេស្សាមីតិ ឯកប្ប-ារណាបិ សាទិតព្វា យតា កិលានោ ភវិស្សាមិ តតា វិញ្ញាបេស្សាមីតិ ។

[១៧៦] តតោ ចេ ឧត្តរឺ សាទិយេយ្យាតិ អត្ថិ បារណា ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា អត្ថិ បារណា រត្តិបរិយន្តា ន ភេសជ្ជបរិយន្តា អត្ថិ បារណា ភេសជ្ជ-បរិយន្តា ច រត្តិបរិយន្តា ច អត្ថិ បារណា នេវ ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា ។ ភេសជ្ជបរិយន្តា

១ ឱ. ម. ឧត្តរិ ។

មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាស្រាប់ហើយនោះទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុដែលគ្មានជំងឺត្រូវត្រេកអរនឹងការបវារណា ដោយបច្ច័យកំណត់ត្រឹម ៤ ខែ បើភិក្ខុត្រេកអរក្រៃលែងជាងនោះទៅ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែគេបានបវារណាថែមទៀត រៀរលែងតែគេបានបវារណាជានិច្ច ។

[១៧៥] ត្រង់ពាក្យថា ភិក្ខុដែលគ្មានជំងឺត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម ៤ ខែ សេចក្ដីថា ភិក្ខុគួរត្រេកអរនឹងការបវារណាដោយគិលានបច្ច័យ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាថែមទៀតដោយគិតថា អញជាអ្នកមានជំងឺក្នុងកាលណា អញនឹងសូមក្នុងកាលណោះ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណា ជាប់ជានិច្ចដោយគិតថា អញជាអ្នកមានជំងឺក្នុងកាលណា អញនឹងសូមក្នុងកាលណោះ ។

[១៧៦] ត្រង់ពាក្យថា បើភិក្ខុត្រេកអរក្រៃលែងជាងនោះ សេចក្ដីថា បវារណាកំណត់ភេសជ្ជ: មិនកំណត់ភត្រី បវារណាកំណត់ភត្រី មិនកំណត់ភេសជ្ជ: បវារណាកំណត់ទាំងភេសជ្ជ: កំណត់ទាំងភត្រី បវារណាមិនកំណត់ទាំងភេសជ្ជ: មិនកំណត់ទាំងភត្រី ។ ដែលហៅថា បវារណា

ជាម ភេសជ្ជានិ បរិក្ខហិតានិ ហោន្តិ ឯត្តកេហិ ភេសជ្ជេហិ បវារេមីតិ ។ រត្តិបរិយន្តា ជាម រត្តិយោ បរិក្ខហិតាយោ ហោន្តិ ឯត្តកាសុ រត្តីសុ បវារេ-មីតិ ។ ភេសជ្ជបរិយន្តា ច រត្តិបរិយន្តា ច ជាម ភេសជ្ជានិ ច បរិក្ខហិតានិ ហោន្តិ រត្តិយោ ច បរិក្ខហិតាយោ ហោន្តិ ឯត្តកេហិ ភេសជ្ជេហិ ឯត្ត-កាសុ រត្តីសុ បវារេមីតិ ។ ឥវ ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា ជាម ភេសជ្ជានិ ច អបរិក្ខហិតានិ ហោន្តិ រត្តិយោ ច អបរិក្ខហិតាយោ ហោន្តិ ឯត្ត-កេហិ ភេសជ្ជេហិ ឯត្តកាសុ រត្តីសុ បវារេមីតិ ។

[១៧៧] ភេសជ្ជបរិយន្តេ យេហិ ភេសជ្ជេហិ បវារិតោ ហោតិ តានិ ភេសជ្ជានិ បបេត្វា អញ្ញានិ ភេសជ្ជានិ វិញ្ញាបេតិ អាបត្តិ ចាចិត្តិ-យស្ស ។ រត្តិបរិយន្តេ យាសុ រត្តីសុ បវារិតោ ហោតិ តា រត្តិយោ បបេត្វា អញ្ញាសុ រត្តីសុ វិញ្ញាបេតិ

កំណត់ភេសជ្ជៈ (នោះ) គឺភេសជ្ជៈដែលគេកំណត់ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។ ដែលហៅថា បវារណាកំណត់ពាត្រី គឺពាត្រីដែលគេកំណត់ដោយពាក្យថា ខ្ញុំព្រះករុណាបវារណាអស់ពាត្រីទាំងឡាយមានប្រមាណប៉ុណ្ណោះ ។ ដែលហៅថា បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងពាត្រីនោះ គឺគេកំណត់ភេសជ្ជៈទាំងឡាយផង កំណត់ពាត្រីទាំងឡាយផង ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ អស់ពាត្រីទាំងឡាយមានប្រមាណប៉ុណ្ណោះ ។ ដែលហៅថា បវារណាមិនកំណត់ភេសជ្ជៈ មិនកំណត់ពាត្រី (នោះ) គឺគេមិនកំណត់ភេសជ្ជៈទាំងឡាយ និងមិនកំណត់ពាត្រីទាំងឡាយ ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ និងអស់ពាត្រីទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

[១៧៧] ឯពាក្យដែលថា កំណត់ភេសជ្ជៈនោះ អធិប្បាយថា គេបវារណាភិក្ខុដោយភេសជ្ជៈណា ភិក្ខុត្រឡប់ទៅសូមភេសជ្ជៈទាំងឡាយដទៃវិញ ក្រៅពីភេសជ្ជៈដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយ ។ ឯកំណត់ពាត្រីនោះ គឺគេបវារណាភិក្ខុក្នុងពាត្រីទាំងឡាយណា ភិក្ខុត្រឡប់សូមក្នុងពាត្រីទាំងឡាយឯទៀតវិញ ក្រៅពីពាត្រីដែលគេបវារណានោះ

អាបត្តិ ចាចិត្តិយស្ស ។ ភេសជ្ជបរិយន្តេ ច រត្តិ-
បរិយន្តេ ច យេហិ ភេសជ្ជេហិ បវារិតោ ហោតិ
តានិ ភេសជ្ជានិ បហេត្វា យាសុ រត្តីសុ បវារិតោ
ហោតិ តា រត្តិយោ បហេត្វា អញ្ញានិ ភេសជ្ជានិ
អញ្ញាសុ រត្តីសុ វិញ្ញាបេតិ អាបត្តិ ចាចិត្តិយស្ស ។
ឥមេ ភេសជ្ជបរិយន្តេ ន រត្តិបរិយន្តេ អនាបត្តិ ។

[១៧៨] ន ភេសជ្ជេន ការណីយេ[1] ភេសជ្ជំ វិញ្ញា-
បេតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញេន ភេសជ្ជេន
ការណីយេ[2] អញ្ញំ ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ ចា-
ចិត្តិយស្ស ។ ឥមានិ[3] ឥមានិ ភេសជ្ជានិ ភេសជ្ជំ វិញ្ញាបេតិ
អាបត្តិ ចាចិត្តិយស្ស ។ ឥមានិ ភេសជ្ជានិ ភេសជ្ជំ
វិញ្ញាបេតិ អាបត្តិ ចាចិត្តិយស្ស ។ ឥមានិ ន ឥមានិ-
ភេសជ្ជានិ ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ ចាចិត្តិយស្ស ។

---

១ ឱ.ម. ន ភេសជ្ជការណីយេន ។ ២ ឱ.ម. ការណីយេន ។ ៣ ឥមានិ ។

ត្រូវអាបត្តិបាចិត្តិយ ។ ឯកំណត់ទាំងកេសជ្ជ: កំណត់ទាំងរាត្រីនោះ គឺ គេបវារណាកិក្ខុដោយកេសជ្ជ:ទាំងឡាយណា កិក្ខុវៀរលែងកេសជ្ជ:ទាំង នោះ គេបវារណាកិក្ខុក្នុងរាត្រីណា កិក្ខុវៀរលែងរាត្រីទាំងនោះ ហើយ ត្រឡប់ទៅសូមកេសជ្ជ:ទាំងឡាយដទៃ និងក្នុងរាត្រីទាំងឡាយឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ឯមិនកំណត់កេសជ្ជ: និងមិនកំណត់រាត្រី មិនមានអាបត្តិឡើយ ។

[១៧៨] កាលបើមិនមានកិច្ចដោយកេសជ្ជ: ហើយកិក្ខុទៅសូម កេសជ្ជ: ត្រូវអាបត្តិបាចិត្តិយ ។ កាលបើមានកិច្ចដោយកេសជ្ជ:ឯទៀត ហើយកិក្ខុទៅសូមកេសជ្ជ:ឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ ដែលគេបវារណាហើយ កិក្ខុសំគាល់ថា ហួសកំណត់ដែលគេបវារណា មែន ហើយទៅសូមកេសជ្ជ: ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែល គេបវារណាហើយ កិក្ខុសង្ស័យ ហើយទៅសូមកេសជ្ជ: ត្រូវអាបត្តិ បាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ កិក្ខុសំគាល់ថា មិនហួស កំណត់បវារណាទេ ហើយទៅសូមកេសជ្ជ: ត្រូវអាបត្តិបាចិត្តិយ ។

ឆតឧត្តរិ តឧត្តរិសញ្ញី អាបត្តិ ទុក្កដស្ស ។ ឆត-ឧត្តរិ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឆតឧត្តរិ ឆត-ឧត្តរិសញ្ញី អនាបត្តិ ។

[១៧៩] អនាបត្តិ យេហិ កេសេ ឆេហិ បារិតោ ហោតិ តានិ កេសានិ វិញ្ញាបេតិ យាសុ រត្តីសុ បារិតោ ហោតិ តាសុ រត្តីសុ វិញ្ញាបេតិ ឥមេហិ តយា កេសេ ឆេហិ បារិតម្ហា អម្ហាកញ្ច ឥមិនា ច ឥមិនា ច កេសេ ឆេន អត្ថោតិ អាចិក្ខិត្វា វិញ្ញាបេតិ យាសុ តយា រត្តីសុ បារិតម្ហា តាយោ ច រត្តិយោ រីតិវត្តា អម្ហាកញ្ច កេសេ ឆេន អត្ថោតិ អាចិក្ខិត្វា វិញ្ញាបេតិ ញាតកានំ បារិតានំ អញ្ញស្សត្ថាយ អត្ត-ណো ឆណេ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

មិនទាន់ហួសកំណត់ដែលគេបវារណាទេ ភិក្ខុសំគាល់ថាហួសកំណត់ដែលគេបវារណាហើយ ត្រូវអាបត្តិទុក្កដ ។ មិនទាន់ហួសកំណត់ដែលគេបវារ-ណាទេ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនទាន់ហួសកំណត់ដែលគេបវារណាទេ ភិក្ខុសំគាល់ថាមិនទាន់ហួសកំណត់បវារណា មិនមានអាបត្តិ ។

[១៧៩] អាបត្តិមិនមាន ដល់ភិក្ខុដែលគេបវារណា ដោយកេសជ្ជៈទាំងឡាយណា ភិក្ខុសូមកេសជ្ជៈទាំងឡាយនោះ ដល់ភិក្ខុដែលគេបវារណាក្នុងរាត្រីទាំងឡាយណា ភិក្ខុសូមក្នុងរាត្រីទាំងឡាយនោះ ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយគឺអ្នកបានបវារណាហើយដោយកេសជ្ជៈទាំងឡាយនេះ (ឥឡូវនេះ) យើងទាំងឡាយត្រូវការដោយកេសជ្ជៈនេះផងនេះផងហើយសូម ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយគឺអ្នកបានបវារណាហើយក្នុងរាត្រីទាំងឡាយណា ឯរាត្រីទាំងឡាយនោះកន្ទងហួសទៅហើយ (ឥឡូវនេះ) យើងទាំងឡាយត្រូវការដោយកេសជ្ជៈហើយសូម ដល់ភិក្ខុដែលសូមអំពីពួកញាតិ ដល់ភិក្ខុដែលសូមអំពីពួកទាយកដែលគេបានបវារណា ដល់ភិក្ខុដែលសូមដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ភិក្ខុដែលបានមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្លត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

អដ្ឋមសិក្ខាបទំ

[១៨០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន រាជា បសេនទិ កោសលោ សេនា-
យ អពុយ្ហោ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ឧយ្យុត្តំ សេនំ
ឧស្សជាយ អតមំសុ ។ អទ្ធសា ខោ រាជា បសេន-
ទិ កោសលោ ឆព្វគ្គិយេ ភិក្ខូ ទូរតោ វ អាគច្ឆន្តេ
ឌិស្វាន បង្ហោសាបេត្វា ឯតទវោច កិស្ស តុម្ហេ ភន្តេ
អាគតត្ថាតិ ។ មហារាជានំ មយំ ឧដ្ឋកាមាតិ ។ កឹ
ភន្តេ មំ ឌិជ្ជេន យុទ្ធាភិនន្ទិនំ ឧនុ ភគវា បស្សិ-
តព្ពោតិ ។ មនុស្ស ឧជ្ឈាយន្តិ ទីយន្តិ វិចារេន្តិ
ភវំ ហិ ជាម សមណា សក្យបុត្តិយា ឧយ្យុត្តំ
សេនំ ឧស្សជាយ អាគច្ឆិស្សន្តិ អម្ហាកម្ឪ អលាភា
អម្ហាកម្ឪ ទុលូទ្ធំ យេ មយំ អាជីវស្ស ហេតុ
បុត្តជារស្ស ការណា សេនាយ អាគច្ឆាមាតិ ។
អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ
ទីយន្តានំ វិចារេន្តានំ ។ យេ តេ ភិក្ខូ អប្ឪិច្ឆា

សិក្ខាបទទី ៨

[១៨០] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះបាទ បសេនទិកោសលរាជ ទ្រង់លើកកងទ័ពចេញទៅ ។ ពួកធព្ធគ្គិយភិក្ខុក៏បាន ទៅមើលកងទ័ពដែលស្តេចលើកចេញទៅហើយ ។ ព្រះបាទបសេន-ទិកោសលរាជ បានទតឃើញពួកធព្ធគ្គិយដើរមកពីចម្ងាយ លុះទ្រង់ ឃើញហើយក៏មានបន្ទូលឲ្យនិមន្តមកហើយទ្រង់ត្រាស់សួរដូច្នេះថា បពិត្រ លោកម្ចាស់ដ៏ចម្រើន ពួកលោកនាំគ្នាមកធ្វើអ្វី ។ ពួកធព្ធគ្គិយភិក្ខុធ្វើយថា ពួកអាត្មាមានប្រាថ្នាដើម្បីនឹងមើលមហាបពិត្រ ។ ស្តេចក៏ទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ ការមើលខ្ញុំព្រះករុណាជាអ្នកត្រេកអរក្នុងការច្បាំងនឹង មានប្រយោជន៍អ្វី ពួកលោកត្រូវតែរមិលមើលព្រះដ៏មានព្រះភាគទេតើ ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនគួរនឹងមកមើលកងទ័ព ដែលស្តេចលើកចេញ ទៅសោះ ពួកយើងឯណាមកក្នុងកងទ័ព ព្រោះហេតុតែការចិញ្ចឹម ជីវិតនិងបុត្រភរិយា យើងនោះឈ្មោះថាគ្មានលាភផង ឈ្មោះថាបានរបស់ អាក្រក់ផង ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សនោះពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច

។ បេ ។ តេ ឧជ្ឌាយន្តិ ១ីយន្តិ វិចាចេន្តិ ១ាកចំ ហិ ១ាម ១ព្ធ១ាត្តិយា ១ិ១ ១ុ ១ុ១ាត្តំ ១ៅ ១ ១ស្ស-១ាយ ១ច្ចិ១ស្ស១ន្ត្ដីតិ ។ បេ ។ ១ចំ ១ារ ១ុ១ម្ហ ១ិ១ ១ ១ុ១ាត្តំ ១ៅ ១ ១ស្ស១ាយ ១ច្ច១ាតិ ។ ១ចំ ១ត១ាតិ ។ ១ារ១ហិ ១ុ១ ១ត១ា ១ាកចំ ហិ ១ាម ១ុ១ម្ហ ១ោ១ យ១ ១ុ១ាត្តំ ១ៅ ១ ១ស្ស១ាយ ១ច្ចិ១ស្ស១ ១ៅ១ ១ោ១ យ១ ១ុ១ាសា ១ ១ ១

។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនាំគ្នាទៅមើលកងទ័ពដែលស្តេចលើកចេញទៅសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ ឮថា អ្នកទាំងឡាយនាំគ្នាទៅមើលកងទ័ពដែលស្តេចលើកទៅពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងទៅមើលកងទ័ពដែលស្តេចលើកចេញទៅទេ នែមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទៅ ដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៨១] សម័យនោះឯង ឧ១ពុកធំរបស់ភិក្ខុមួយរូប មានជំងឺក្នុងកងទ័ព ។ អ្នកនោះក៏បញ្ជូនទូតទៅកាន់សំណាក់ភិក្ខុនោះថា ខ្ញុំព្រះករុណាមានជំងឺក្នុងកងទ័ព សូមលោកម្ចាស់និមន្តមក ខ្ញុំព្រះករុណាចង់ឲ្យលោកម្ចាស់និមន្តមកណាស់ ។ លំដាប់នោះ ភិក្ខុនោះមានសេចក្តីត្រិះរិះ

ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ន ឧយ្យុត្តំ សេនំ ឧស្សជាយ គន្តព្វន្តិ អយញ្ហ មេ មាតុលោ សេនាយ កិលាជោ ភវេ ន ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ ជិនាជេ ឯតស្មឹ បការណេ ធម្មឹ ភវេ ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ តថារូបប្ចយា សេនំ[1] គន្តុំ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឧយ្យុត្តំ សេនំ ឧស្សជាយ គច្ឆេយ្យ អញ្ញត្រ តថារូបប្ចយា ចាចិត្តិយន្តិ ។

[១៨២] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឧយ្យុត្តា នាម សេនា ភាមតោ ជិក្ខ-មិត្វា ជិវិដ្ឋា ភ ហោតិ បយាតា ភ ។ សេនា នាម ហត្ថី អស្ស ១ថ បត្តិ ។ ទ្វាឧសបុរិសោ ហត្ថី ។ តិបុរិសោ អស្ស ។ ចតុប្ប្ជិសោ ១ថ ។

1 ឧយ្យុត្តំ សេនន្តិបិ ១ត្ថ ១ចិ ១ោ ១ត្ថ ១ ១ ១ ។

ដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយថា ភិក្ខុមិនត្រូវទៅមើលកងទ័ពដែលគេលើកចេញទៅទេ តែឥឡូវ ឪពុកធំអញនេះមានជំងឺនៅក្នុងកងទ័ព អញត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ទើបភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យទៅកាន់កងទ័ពបាន ព្រោះហេតុមានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទៅ ដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។

[១៨២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌរួចហើយ ។ ដែលហៅថា កងទ័ពដែលគេលើកចេញទៅ គឺកងទ័ពលើកចេញពីស្រុកទៅតាំងសំចតនៅក្តី ចេញទៅហើយចេះតែដើរទៅទៀតក្តី ។ ដែលហៅថា កងទ័ព គឺពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ។ ពលដំរី (មួយ ៗ) មានបុរស ១២ នាក់ ។ ពលសេះ (មួយ ៗ) មានបុរសបីនាក់ ។ ពលរថ (មួយៗ) មានបុរសបួននាក់ ។

ចត្តារោ បុរិសា សរហត្ថា បត្តិ ។ ឧស្សជ្ជាយ កច្ចតិ អាបត្តិ ទុក្កដស្ស ។ យត្ថ បិតោ បស្សតិ អាបត្តិ ចាចិត្តិ-យស្ស ។ ឧស្សជ្ជុបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញត្រ តថារូបប្បច្ចយាតិ បវេត្វា តថារូបប្បច្ចយំ ។

[១៨៣] ឧយ្យុត្តេ ឧយ្យុត្តសញ្ញី ឧស្សជ្ជាយ កច្ចតិ អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ ចាចិត្តិយស្ស ។ ឧយ្យុត្តេ វេមតិកោ ឧស្សជ្ជាយ កច្ចតិ អញ្ញត្រ តថា-រូបប្បច្ចយា អាបត្តិ ចាចិត្តិយស្ស ។ ឧយ្យុត្តេ ឧយ្យុត្តសញ្ញី ឧស្សជ្ជាយ កច្ចតិ អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ ចាចិត្តិយស្ស ។ ឯកមេកំ ឧស្សជ្ជាយ កច្ចតិ អាបត្តិ ទុក្កដស្ស ។ យត្ថ បិតោ បស្សតិ អាបត្តិ ទុក្កដស្ស ។ ឧស្សជ្ជុបចារំ វិជហិត្វា បុនប្បុនំ បស្សតិ

ពលថ្មើរជើង (មួយ ៗ) មានបុរសបួននាក់កាន់ធ្នូសរ ។ ភិក្ខុដើរទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើល (កងទ័ពនោះ) នៅទីណា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ (ក្នុងទីនោះ) ។ ភិក្ខុលះបង់ឧបចារៈសម្រាប់មើលឃើញ ហើយមើលរឿយ ៗ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា រៀងលែងតែមានហេតុមានសភាពយ៉ាងនោះ គឺលើកលែងនូវហេតុមានសភាពយ៉ាងហ្នឹង ។

[១៨៣] កងទ័ពលើកចេញទៅហើយ ភិក្ខុសំគាល់ថា កងទ័ពលើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានហេតុមានសភាពយ៉ាងនោះ ។ កងទ័ពលើកចេញទៅហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយនៅតែដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានហេតុមានសភាពយ៉ាងនោះ ។ កងទ័ពលើកចេញទៅហើយ ភិក្ខុសំគាល់ថា លើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានហេតុមានសភាពយ៉ាងនោះ ។ ភិក្ខុដើរទៅដើម្បីមើលកងទ័ពមួយ ៗ (ក្នុងកងទ័ពទាំង ៤) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលកងទ័ពនៅទីណា ត្រូវអាបត្តិទុក្កដនៅ (ទីនោះ) ។ ភិក្ខុលះបង់នូវឧបចារៈសម្រាប់មើលឃើញ ហើយមើលរឿយ ៗ

អាបត្តិ ទុក្កដស្ស ។ អនុយុត្តេ ឧយ្យុត្តសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុយុត្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុយុត្តេ អនុយុត្តសញ្ញី អនាបត្តិ ។

[១៨៤] អនាបត្តិ អារាមេ ឋិតោ បស្សតិ ភិក្ខុស្ស ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគច្ឆតិ បដិបថំ គច្ឆន្តោ បស្សតិ តថារូបប្បច្ចយា អាបជ្ជាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុសំគាល់ថា លើកចេញទៅហើយ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុសំគាល់ថា មិនទាន់លើកចេញទៅមែន មិនត្រូវអាបត្តិ ។

[១៨៤] អាបត្តិមិនមាន ដល់ភិក្ខុដែលឈរនៅក្នុងអាវាសហើយមើលឃើញ ដល់ភិក្ខុដែលកងទ័ពនោះលើកមកកាន់ទីដែលភិក្ខុឈរនៅ (ក្តី) អង្គុយនៅ (ក្តី) ដេកនៅ (ក្តី) ដល់ភិក្ខុដែលដើរទៅជួបផ្លូវគ្នាបានឃើញកងទ័ព ដល់ភិក្ខុដែលមានហេតុមានសភាពយ៉ាងនោះ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយកើតឡើង[1] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

---

១ បើមានសេចក្តីអន្តរាយដល់ជីវិត ដល់ព្រហ្មចរិយធម៌ ភិក្ខុគិតថា អញទៅក្នុងកងទ័ពនឹងបានរួចសេចក្តីអន្តរាយ ហើយដើរចូលទៅក្នុងកងទ័ព មិនត្រូវអាបត្តិ ។

នវមសិក្ខាបទំ

[១៨៤] តេន សមយេន ពុទ្ធោ ភគវា សាវ-ត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សតិ ការណីយេ សេនំ គន្ត្វា អតិរេកតិរត្តំ សេនាយ វសន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា សេនាយ វសិស្សន្តិ អម្ហាកម្បិ អលាភា អម្ហាកម្បិ ទុល្លទ្ធំ យេ មយំ អាជីវស្ស ហេតុ បុត្តទារស្ស ការណា សេនាយ បដិវសាមាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិចាចេន្តានំ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អតិរេកតិរត្តំ សេនាយ វសិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អតិរេក-តិរត្តំ សេនាយ វសថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា

សិក្ខាបទទី ៩

[១៨៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ឯង ពួកឆព្វគ្គិយភិក្ខុមានកិច្ចធុរ: ក៏នាំគ្នាទៅកាន់កងទ័ព ហើយឈប់ នៅក្នុងកងទ័ពច្រើនជាងបីរាត្រីឡើងទៅ ។ មនុស្សទាំងឡាយ ក៏ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកសមណ:សក្យបុត្រ មិនគួរនឹងនៅក្នុងកងទ័ពទេ ពួកយើងឯណាមកអាស្រ័យនៅក្នុងកង ទ័ព ក៏ព្រោះតែការចិញ្ចឹមជីវិតខ្ជូននិងបុត្រភរិយា យើងទាំងនោះឈ្មោះថា គ្មានលាភផង ឈ្មោះថា បានរបស់អាក្រក់ផង ។ ពួកភិក្ខុ បានឮពួកមនុស្សនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ដូច្នោះ ហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុ នោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរ នឹងនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅសោះ ។ បេ ។ ព្រះដ៏មាន ព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងទៅនៅ ក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុ ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មាន ជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរ

អតិរេកតិរត្តំ សេនាយ វសិស្សថ ឆេតំ មោឃបុរិសា អប្ប្ សន្ថានំ វ បសាទាយ បសន្ថានំ វ កិយ្យាកា-រាយ ។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សិយា ច តស្ស ភិក្ខុនោ ការ្ចិទេវ ២ចូ២យោ សេនំ ១ មមនាយ ២ ទ្វិរត្តតិរត្តំ ១ ១ ១

នឹងនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា (បើ) ភិក្ខុនោះមានហេតុអ្វី ។ គួរនឹងទៅកាន់កងទ័ពនោះ ភិក្ខុនោះត្រូវនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី ។ បើនៅឲ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

[១៨៦] ត្រង់ពាក្យថា (បើ) ភិក្ខុនោះមានហេតុអ្វី ។ គួរនឹងទៅកាន់កងទ័ពគឺថាភិក្ខុមានហេតុ មានកិច្ចធុរៈ (ដែលគួរខានមិនបាន) ។ ពាក្យថា ភិក្ខុនោះគប្បីនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី គឺភិក្ខុត្រូវនៅបានត្រឹមពីរបីយប់ ។ ពាក្យថា បើនៅឲ្យហួសពីកំណត់នោះទៅ សេចក្តីថា កាលព្រះអាទិត្យ អស្តង្គតក្នុងថ្ងៃជាគម្រប់ ៤ ភិក្ខុចេះតែនៅក្នុងកងទ័ពនោះ ត្រូវអាបត្តិបាចិត្តិយ ។

[១៨៧] កាលហួសកំណត់បីរាត្រីហើយ ភិក្ខុសំគាល់ថា ហួសមែន ហើយចេះតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលហួសកំណត់បីរាត្រីហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយចេះតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលហួសកំណត់បីរាត្រីហើយ

ឯកតិរត្តេ ឧនកសញ្ញី សេនាយ វសតិ អាបត្តិ ចាចិត្តិ-
យស្ស ។ ឧនកតិរត្តេ អតិរេកសញ្ញី អាបត្តិ
ទុក្កដស្ស ។ ឧនកតិរត្តេ រេមតិកោ អាបត្តិ ទុក្កដស្ស ។
ឧនកតិរត្តេ ឧនកសញ្ញី អនាបត្តិ ។

[១៨៨] អនាបត្តិ ទ្វេ តិស្សោ រត្តិយោ វសតិ
ឧនកទ្វេតិស្សោ រត្តិយោ វសតិ ទ្វេ រត្តិយោ វសិត្វា
តតិយាយ រត្តិយា បុរារុណា ឯកូនមិត្វា បុន វសតិ
កិលាដោ វសតិ កិលានស្ស ការណាយេន វសតិ
សេនា បដិសេនាយ រុទ្ធា ហោតិ ភេរេ ចិ បលិពុទ្ធោ
ហោតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុសំគាល់ថានៅខ្ទះ ហើយប្រឹងតែនៅក្នុងកងទ័ព ត្រូវអាបត្តិ បាចិត្តិយ ។ កាលមិនទាន់ដល់បីរាត្រី ភិក្ខុសំគាល់ថា ហួសហើយ ត្រូវ អាបត្តិទុក្កដ ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវ អាបត្តិទុក្កដ ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុក៏សំគាល់ថា មិនទាន់ដល់ មិនត្រូវអាបត្តិ ។

[១៨៨] អាបត្តិមិនមាន ដល់ភិក្ខុដែលនៅត្រឹមពីរបីរាត្រី ដល់ភិក្ខុ ដែលនៅមិនទាន់ដល់ពីរបីរាត្រី ដល់ភិក្ខុដែលនៅត្រឹមពីររាត្រីហើយ ក្នុង រាត្រីជាគម្រប់បី បានចេញទៅមុនអរុណរះ ហើយត្រឡប់ទៅនៅវិញទៀត ដល់ភិក្ខុដែលមានជំងឺនៅ (ក្នុងកងទ័ព) ដល់ភិក្ខុដែលនៅដោយកិច្ចរបស់ ភិក្ខុមានជំងឺ ដល់ភិក្ខុដែលនៅក្នុងកងទ័ពហើយ មានកងទ័ពជាសត្រូវមក ចោមព័ទ្ធកងទ័ព (នោះឯង) ដល់ភិក្ខុដែលជាប់ចំពាក់ (ដោយបុគ្គលមាន ពៀរ ឬតស្សរជន) ណាមួយ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុ ឆ្លួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[១៨៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ទ្វិរត្តតិរត្តំ
សេនាយ វសមានា ឧយ្យោធិកាបិ ពលកាបិ សេនា-
ព្យូហាបិ អនីកគ្គសារាបិ គច្ឆន្តិ ។ អញ្ញតរេបិ
ឆព្ភក្ខិយោ ភិក្ខុ ឧយ្យោធិកំ គន្ត្វា ឋានេ ឋិ-
តោ ហោតិ ។ មនុស្សា តំ ភិក្ខុ[1] ឧបសង្កមិត្វា
ឋិតេ ឋានេ សុយុជ្ঝំ អហោសិ ឋានិ ឯ លក្ខានិ
លក្ខានីតិ ។ សោ ភិក្ខុ ឯហិ មនុស្ស ហិ ឧបសង្ហ-
មានោ មង្ក្ អហោសិ ។ មនុស្សា ឧជ្ឈាយន្តិ
ខីយន្តិ វិចារេន្តិ ឋានំ ហិ នាម សមណា សក្យបុត្តិយា
ឧយ្យោធិកំ គច្ឆិស្សន្តិ អម្ហាកម្ចិ
អលាភា អម្ហាកម្ចិ ទុលូ ទ្ធ យេ មយំ អាជីវស្ស
ហេតុ បុត្តទារស្ស ការណា ឧយ្យោធិកំ អាគច្ឆាមាតិ ។
អស្សោសុំ ខោ ភិក្ខូ ឯ មនុស្ស ជ ឧជ្ឈាយន្ត ជ

---

1 បស្សិត្វា ឧបសង្ហមិ ឯ ឯ ចិ ឯ ។

សិក្ខាបទទី ១០

[១៨៩] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្ភ-គ្គិយភិក្ខុ កាលនៅក្នុងកងទ័ពអស់ពីរបីរាត្រី បាននាំគ្នាទៅកាន់ទីដែលគេ ច្បាំងគ្នាខ្លះ ទីគេត្រួតពលខ្លះ ទីតាំងនៅនៃកងទ័ពខ្លះ ទីសម្រាប់មើល គេចាត់ក្បួនទ័ពខ្លះ ។ មានឆព្ភគ្គិយភិក្ខុមួយរូប ទៅកាន់ទីដែលគេច្បាំង ហើយភិក្ខុនោះត្រូវសរ ។ មនុស្សទាំងឡាយក៏ឡកឡឺយឲ្យភិក្ខុនោះថា លោកម្ចាស់ លោកច្បាំងស្រួលឬទេ លោកបានខ្ជាប់ប៉ុន្មានហើយ ។ កាលមនុស្សទាំងឡាយនោះចំអកចំអន់ឲ្យ ភិក្ខុនោះក៏អៀនអន់ ។ មនុស្ស ទាំងឡាយ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកសមណៈជាសក្យ-បុត្រមិនគួរនឹងនាំគ្នាមកមើលចម្បាំងសោះ ឯពួកយើងមកកាន់ចម្បាំង ក៏ ព្រោះតែការចិញ្ចឹមជីវិតនិងបុត្រភរិយា អំពើនេះមិនមែនជាលាភរបស់ យើងទេ គឺទ្រព្យដែលពួកយើងបានមក ឈ្មោះថា បានហើយដោយ អាក្រក់ទេតើ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះ ពោលទោស

ទីយន្តានំ វិចាចេន្តានំ ។ យេ តេ ភិក្ខូ អប្ឆិន្ន ។ បេ ។ តេ ឧជ្ឌាយន្តិ ទីយន្តិ វិចាចេន្តិ ឥមំ ហិ នាម ឆព្ភិក្ខិយា ភិក្ខូ ឧយ្យោជិកំ ឧស្សនាយ ឥច្ឆិស្សន្តីតិ ។ បេ ។ សចេ ការ តុម្ហេ ភិក្ខវេ ឧយ្យោជិកំ ឧស្សនាយ ឥច្ឆថាតិ ។ សចេ ភគវាតិ ។ វិតរហិ ពុទ្ធោ ភគវា ឥមំ ហិ នាម តុម្ហេ មោឃបុរិសា ឧយ្យោជិកំ ឧស្សនាយ ឥច្ឆិស្សថ ឧត្តំ មោឃបុរិសា អប្ឆសន្ថានំ វ បសាទាយ បសន្ថានំ វ ភិយ្យោ-ភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ទ្វិរត្តតិរត្តញ្ច ភិក្ខុ សេនាយ វសមានោ ឧយ្យោជិកំ វ ពលក្ខំ វ សេនាព្យូហំ វ អនីកទស្សនំ វ ឥច្ឆេយ្យ ចាចិត្តិយន្តិ ។

[១៩០] ទ្វិរត្តតិរត្តញ្ច ភិក្ខុ សេនាយ វសមានោតិ ទ្វេ តិស្សោ រត្តិយោ វសមានោ ។ ឧយ្យោជិកំ នាម យត្ត សម្ឆហាវេ ឋិស្សតិ ។ ពលក្ខំ នាម

តិះដៀល បន្ទុះបង្ហាប់ហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងទៅមើលចម្បាំងសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយទៅមើលចម្បាំងពិតមែនឬ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកវាល់គ្នា មិនគួរនឹងទៅមើលចម្បាំងទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើភិក្ខុនៅក្នុងកងទ័ព កំណត់ពីរបីរាត្រីហើយ ទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលគេត្រួតពលក្តី ទីតាំងនៅនៃកងទ័ពក្តី ទីសម្រាប់គេចាត់ក្បួនទ័ពក្តី ត្រូវអាបត្តិបាចិត្តិយ ។

[១៩០] ត្រង់ពាក្យថា បើភិក្ខុនៅក្នុងកងទ័ព កំណត់ពីរបីរាត្រីហើយ សេចក្តីថា ភិក្ខុនៅក្នុងកងទ័ពបានត្រឹមពីរបីយប់ ។ ដែលហៅថា ទីដែលគេច្បាំងគ្នានោះ គឺទីដែលគេប្រហារគ្នា ។ ដែលហៅថា

ឯត្តកា ហត្ថី ឯត្តកា អស្សា ឯត្តកា រថា ឯត្តកា បត្តី ។ សេនាព្យូហំ ជាម ឥតោ ហត្ថី ហោន្តុ ឥតោ អស្សា ហោន្តុ ឥតោ រថា ហោន្តុ ឥតោ បត្តិកា ហោន្តុ ។ អនីកំ ជាម ហត្ថានីកំ អស្ស-នីកំ រថានីកំ បត្តានីកំ ។ តយោ ហត្ថី បច្ចិមំ ហត្ថានីកំ ។ តយោ អស្សា បច្ចិមំ អស្សានីកំ ។ តយោ រថា បច្ចិមំ រថានីកំ ។ ចត្តារោ បុរិសា សរហត្ថា បច្ចិមំ បត្តានីកំ ។

[១៩១] ឧស្សជាយ កច្ចតិ អាបត្តិ ទុក្កដស្ស ។ យត្ត បិតោ បស្សតិ អាបត្តិ ចាចិត្តិយស្ស ។ ឧស្ស-ជុបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ ចាចិត្តិ-យស្ស ។ ឯកមេកំ ឧស្សជាយ កច្ចតិ អាបត្តិ ទុក្កដស្ស ។ យត្ត បិតោ បស្សតិ អាបត្តិ ទុក្កដស្ស ។ ឧស្សជុបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ ទុក្កដស្ស ។

ទីដែលគេត្រួតពលនោះ គឺទីដែលគេរាប់ពលថា ពលដំរីមានប៉ុណ្ណោះ ពលសេះមានប៉ុណ្ណោះ ពលរថមានប៉ុណ្ណោះ ពលថ្មើរជើងមានប៉ុណ្ណោះ ។ ដែលហៅថា ទីតាំងនៅនៃកងទ័ពនោះ គឺពលដំរីនៅត្រង់កន្លែងនេះ ពលសេះនៅត្រង់កន្លែងនេះ ពលរថនៅត្រង់កន្លែងនេះ ពលថ្មើរជើងនៅត្រង់កន្លែងនេះ ។ ដែលហៅថា ក្បួនទ័ពនោះ គឺពួកសេនាដំរី ១ ពួកសេនាសេះ ១ ពួកសេនារថ ១ ពួកសេនាថ្មើរជើង ១ ។ ដំរីបី ហៅថា សេនាដំរីយ៉ាងតិចបំផុត ។ សេះបីហៅថា ពួកសេនាសេះយ៉ាងតិចបំផុត ។ រថបី ហៅថា ពួកសេនារថយ៉ាងតិចបំផុត ។ បុរសបួននាក់កាន់សរគ្រប់ដៃ ហៅថា ពួកសេនាថ្មើរជើងយ៉ាងតិចបំផុត ។

[១៩១] ភិក្ខុទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលះបង់ឧបចារៈនៃទីមើលហើយក៏នៅមើលឃើញរឿយ ๆ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទៅដើម្បីមើលកងទ័ពមួយ ๆ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលះបង់ឧបចារៈនៃទីមើលហើយក៏នៅមើលឃើញរឿយ ๆ ត្រូវអាបត្តិទុក្កដ ។

[១៩២] អនាបត្តិ អារាមេ ឋិតោ ឋបេតិ ភិក្ខុស្ស ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា សម្ឆហាវេ និសីទតិ ឋបិឋបំ ឋបេន្តោ ឋបេតិ សតិ ការណីយេ គន្ត្វា ឋបេតិ អាបជ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

អចេលកវគ្គោ ឋតិយោ ។

ឥស្សុក្ខ្ជានំ

ឋ្ងៃ ការោឋបនន្ធ្ងស្ស
ឥយំឋដ្ឋាការេ ច
មហាជានោ ឋបេនទិ
ឯសោ ១ ១ ១ ១ ១ ១ ។

[១៩២] *អាបត្តិមិនមាន ដល់ភិក្ខុដែលឈរមើលនៅក្នុងអាវាម ដល់ភិក្ខុដែលឃើញចម្បាំងជាដើមដែលគេមកកាន់ទីដែលខ្លួនឈរក្តី អង្គុយក្តី ដេកក្តី ដល់ភិក្ខុដែលដើរទៅប្រទះឃើញតាមផ្លូវ ដល់ភិក្ខុដែលមានកិច្ច (ត្រូវទៅ) ហើយប្រទះឃើញ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។*

សិក្ខាបទទី ១០ ចប់ ។

អចេលកវគ្គ ជាគម្រប់ ៥ ចប់ ។

ឧទ្ទាននៃអចេលកវគ្គនោះមាន ១០ សិក្ខាបទ គឺ

បូវសិក្ខាបទ ១	*កថាសិក្ខាបទ ១*
ឧបនន្ទ ៣ សិក្ខាបទ	*ឧបដ្ឋាកសិក្ខាបទ ១*
មហានាមសិក្ខាបទ ១	*បសេនទិសិក្ខាបទ ១*
សេនាសិក្ខាបទ ១	*វិទ្ធសិក្ខាបទ ១ ។*

សុរាបានវគ្គស្ស បឋមសិក្ខាបទំ

[១៩៣] តេន សមយេន ពុទ្ធោ ភគវា ចេតិយេសុ[1] ចារិកំ ចរមានោ យេន ភទ្ទវតិកា តេន ចាយាសិ ។ អទ្ទសំសុ ខោ គោចាលកា បសុចាលកា ភសកា បថាវិនោ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ជិស្វាន ភគវន្តំ ឯតទវោចុំ មា ខោ ភន្តេ ភគវា អម្ពតិត្ថំ អគមាសិ អម្ពតិត្ថេ ភន្តេ ជដិលស្ស អស្សមេ ជាតោ បជ្ជិ្ជ្ជ្ជ្ជ ឥទ្ធិមា អាសីវិសោ ឃោរវិសោ សោ ភគវន្តំ មា វិហេ្ជ្ជ្ជ្ជ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្ជ្ជ ខោ ។ បេ ។ តតិយម្ជ្ជ ខោ គោចាលកា បសុចាលកា ភសកា បថាវិនោ ភគវន្តំ ឯតទវោចុំ មា ខោ ភន្តេ ភគវា អម្ពតិត្ថំ អគមាសិ អម្ពតិត្ថេ ភន្តេ ជដិលស្ស អស្សមេ ជាតោ បជ្ជ្ជ្ជ ឥទ្ធិមា អាសីវិសោ

---

1 អគ្គាលវេ ចេតិយេ បារិកន្តិ្ជ្ជ ភត្ថ ចិ ឧ្ជ្ជ ។

សុរាបានវគ្គ សិក្ខាបទទី ១

[១៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់ពុទ្ធ-ដំណើរទៅកាន់ចារិក ក្នុងចេតិយជនបទ ហើយយាងទៅកាន់ស្រុកភ-ទ្ទ-វតិកា ។ ពួកអ្នកឃ្វាលគោ ពួកអ្នកឃ្វាលបសុសត្ត (សត្តសម្រាប់ចិញ្ចឹមជាអាហារ) ពួកអ្នកស្រែ ពួកអ្នកដើរផ្លូវ បានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយក៏នាំគ្នាក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគកុំយាងទៅកាន់កំពង់ឈ្នោះអម្ព:ឡើយ បពិត្រព្រះអង្គដ៏ចម្រើន នាគមានរិទ្ធិជាសត្វអាសិ\ីវិស មានពិសដ៏ក្ងៀវក្ងា អាស្រ័យនៅក្នុងអាស្រម របស់ជដិលទៀបកំពង់ឈ្នោះអម្ព: កុំឲ្យនាគនោះបៀតបៀនព្រះដ៏មានព្រះភាគបានឡើយ ។ កាលពួកជនទាំងនោះក្រាបទូលយ៉ាងនេះហើយ ព្រះទ្រង់ជោគជាម្ចាស់ក៏ស្ងៀម ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្ត អ្នកស្រែ អ្នកដើរផ្លូវ បានក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាគម្រប់ពីរដងផង ។ បេ ។ បីដងផងថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គកុំយាងទៅកាន់កំពង់អម្ព:ឡើយ បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះមាន) នាគមានរិទ្ធិជាសត្វអាសិ\ីវិស មានពិសដ៏ក្ងៀវក្ងា អាស្រ័យនៅ

ឃោរវិសោ សោ ភគវន្តំ មា វិហេឋេសីតិ ។ ឥតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ អថខោ ភគវា អនុ-បុព្វេន ចារិកំ ចរមានោ យេន ភទ្ទវតិកា ឥជ្ឌសរិ ។ ឥត្រ សុទំ ភគវា ភទ្ទវតិកាយំ វិហរតិ ។ អថខោ អាយស្មា សាគតោ យេន អម្ពតិត្ថំ[1] ជដិលស្ស អស-មោ តេនុបសង្កមិ ឧបសង្កមិត្វា អក្យាការំ បវិសិត្វា តិណសន្ថារកំ បញ្ញាបេត្វា និសីទិ បល្លঙ្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឺ ឧបដ្ឋបេត្វា ។ អទ្ធសា ខោ សោ ជាតោ អាយស្មន្តំ សាគតំ ប-រិដ្ឋំ ឌិស្ហាន ឧក្ខ្ហ ឧម្ហនោ បធូចាសិ ។ អាយស្មាបិ សាគតោ បធូចាសិ ។ អថខោ សោ ជាតោ មក្ខ្ហ អសហមានោ បជ្ជលិ ។ អាយស្មាបិ សាគតោ តេជោ-ធាតុំ សមាបជ្ជិត្វា បជ្ជលិ ។ អថខោ អាយស្មា សាគតោ ឥស្ស ជាតស្ស តេជសា តេជំ បរិយាទយិត្វា យេន ភទ្ទវតិកា តេនុបសង្កមិ ។ អថខោ ភគវា ភទ្ទវតិកាយំ យថាភិរន្តំ វិហរិត្វា យេន កោសម្ពី

1 ឌ. អម្ពតិត្ថកស្ស ។ ម. អម្ពតិត្ថស្ស ។

ក្នុងអាស្រមរបស់ជដិលទៀបកំពង់អម្ព: កុំឲ្យនាគនោះបៀតបៀនព្រះដ៏មានព្រះភាគបានឡើយ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ស្ងៀម ជាគម្រប់បីដង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ស្រុកកទ្ទវតិកា ។ មានដំណឹងល្បីទៅថាព្រះដ៏មានព្រះភាគគង់នៅក្នុងស្រុកកទ្ទវតិកានោះ ។ គ្រានោះឯង ព្រះសាគត: ដ៏មានអាយុបានចូលទៅកាន់អាស្រមរបស់ជដិលទៀបកំពង់អម្ព: លុះចូលទៅដល់ហើយ ក៏ដើរចូលទៅក្នុងរោងភ្ញើង ក្រាលកម្រាលស្មៅ ហើយក៏អង្គុយពែនភ្នែន តាំងកាយដ៏ត្រង់តម្កល់សតិផ្ទិតផ្ទង់ ។ ឯនាគនោះ បានឃើញព្រះសាគត:ដ៏មានអាយុចូលមកហើយ លុះឃើញហើយក៏កើតទុក្ខទោមនស្សបង្ហុយផ្សែង (ពិសចំពោះសាគតត្ថេរ) ។ ចំណែកខាងព្រះសាគត:ដ៏មានអាយុ ក៏បង្ហុយផ្សែងតបទៅវិញ ។ លំដាប់នោះ នាគនោះខំអត់ទ្រាំនូវសេចក្តីរំលុបលើ (នោះ) មិនបាន ក៏បណ្តាលឲ្យកើតភ្ញើងឡើង ។ ឯព្រះសាគត:ដ៏មានអាយុក៏បានចូលតេជោធាតុ ហើយបណ្តាលភ្ញើងតបទៅវិញ ។ គ្រានោះឯង ព្រះសាគត:ដ៏មានអាយុ ក៏បានគ្របសង្កត់តេជៈរបស់នាគនោះ ដោយតេជៈ (របស់លោក) ហើយក៏ចូលទៅកាន់ស្រុកកទ្ទវតិកា ។ កាលដែលព្រះដ៏មានព្រះភាគ គង់នៅក្នុងស្រុកកទ្ទវតិកា តាមសមគួរដល់ពុទ្ធអធ្យាស្ស័យហើយ

តេន ចារិកំ បក្កាមិ ។ អស្សោសុំ ខោ គោសម្ពិកា ឧចាសកា អយ្យោ កិរ សាកតោ អម្ពតិត្ថកេន ជាតេន សទ្ធឹ សង្ហ្គាមេសីតិ ។ អថខោ ភគវា អនុ-បុព្ពេន ចារិកំ ចរមានោ យេន គោសម្ពី តទវសរិ ។ អថខោ គោសម្ពិកា ឧចាសកា ភគវតោ បច្ចុគ្ក-មនំ ការិត្វា យេនាយស្មា សាកតោ តេនុបសង្ហ្គមឹសុ ឧបសង្ហ្គមិត្វា អាយស្មន្តំ សាកតំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ គោសម្ពិកា ឧចាស-កា អាយស្មន្តំ សាកតំ ឯតទវោចុំ កឹ ភន្តេ អយ្យានំ ឧុល្ហកញ្ចុ មជាបញ្ចុ ឥតិ ។ ឯវំ វុត្តេ ធម្ម្ចក្ខិយា ភិក្ខូ គោសម្ពិកេ ឧចាសកេ ឯតទវោចុំ អត្ថាវុសោ ការោចេតិ ជាម ។ ។ ។

ក៏ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកឯក្រុងកោសម្ពី ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពីបានឮគេនិយាយថា លោកម្ចាស់សាគត:បានច្បាំងគ្នានឹងនាគឈ្មោះអម្ពតិត្ថក: ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ហើយទ្រង់សំដៅទៅឯក្រុងកោសម្ពីនោះ ។ គ្រានោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពីនាំគ្នាទៅទទួលព្រះដ៏មានព្រះភាគ ហើយក៏ចូលទៅរកព្រះសាគត:ដ៏មានអាយុ លុះចូលទៅហើយក៏ថ្វាយបង្គំព្រះសាគត:ដ៏មានអាយុ ហើយក៏ឋិតនៅក្នុងទីដ៏សមគួរ ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពី លុះឋិតនៅក្នុងទីដ៏សមគួរហើយ ទើបនិយាយពាក្យនេះ នឹងព្រះសាគត:ដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន វត្ថុអ្វីដែលលោកម្ចាស់បានដោយកម្រផង ជាទីគាប់ចិត្តផង ពួកយើងខ្ញុំនឹងតាក់តែងវត្ថុអ្វីប្រគេន ។ លុះឧបាសកទាំងនោះ បានពោលពាក្យយ៉ាងនេះហើយ ពួកធម្មគ្គិយភិក្ខុ បាននិយាយពាក្យនេះនឹងពួកឧបាសកដែលនៅក្រុងកោសម្ពីថា ម្នាលអ្នកទាំងឡាយ សុវាជ្ជាឈ្មោះកាបោតិកា (មានពណ៌ក្រហមដូចជើងព្រាប) ដែលភិក្ខុទាំងឡាយរកបានដោយកម្រផង ជាទីគាប់ចិត្តរបស់ពួកភិក្ខុផង ពួកអ្នកឯងចូរតាក់តែងវត្ថុនោះប្រគេនលោកចុះ ។ លំដាប់នោះឯង ពួកឧបាសកនៅក្រុងកោសម្ពីនាំគ្នាតាក់តែងសុវាជ្ជាឈ្មោះកាបោតិកាគ្រប់ ៗ ផ្ទះ បានឃើញព្រះសាគត:

បាចិត្តិយកណ្ឌោ សុរាបានវគ្គស្ស បឋមសិក្ខាបទស្ស និទានំ

អាយស្មន្តំ សាតតំ ឯតទវោចុំ បិវតុ ភន្តេ អយ្យ-
សាតតោ ការោចាតិកំ បសន្នំ បិវតុ ភន្តេ អយ្យ-
សាតតោ ការោចាតិកំ បសន្នន្តិ ។ អថខោ អាយស្ម-
សាតតោ ឃរេ ឃរេ ការោចាតិកំ បសន្នំ បិវិត្វា ឌត-
រម្ហា ជិក្ខមន្តោ ឌតរម្ហាវ បរិបតិ ។ អថខោ ភគ-
សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ឌតរម្ហា ជិក្ខមន្តោ អទ្ធ-
អាយស្មន្តំ សាតតំ ឌតរម្ហាវ បរិបតិតំ ជិស្វាន ភិក្ខូ
អាមន្តេសិ ឥណ្ហាថ ភិក្ខវ សាតតន្តិ ។ ឯវំ ភន្តេតិ
ខោ តេ ភិក្ខូ ភគ្គវតោ បដិស្សុណិត្វា អាយស្មន្តំ សា-
តតំ អាវាមំ ឌេត្វា យេន ភគ្គ-ា តេន សីសំ ឥត្វា
ជិចាតេសុំ ។ អថខោ អាយស្ម-ា សាតតោ បរិវត្តិត្វា
យេន ភគ្គ-ា តេន ចាឌេ ឥត្វា សេយ្យ-ំ ឥប្ប-ិ ។
អថខោ ភគ្គ-ា ភិក្ខូ អាមន្តេសិ ឌតុ ភិក្ខវ សាតតោ
ឥថាតតេ សការ-ោ អ-ោ-ិ ។ ឯវ-ំ

ដ៏មានអាយុកំពុងដើរទៅបិណ្ឌបាត ហើយបាននិយាយពាក្យនេះនឹងព្រះសាគត:ដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់សាគត:និមន្តធាន់សុវាជ្ជាឈ្នោះកាបោតិកាចុះ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់សាគត:និមន្តធាន់សុវាជ្ជាឈ្នោះកាបោតិកាចុះ ។ លំដាប់នោះ ព្រះសាគត:ដ៏មានអាយុ លុះបានធាន់សុវាជ្ជាឈ្នោះកាបោតិកាគ្រប់ ។ ផ្ទះហើយចេញចាកនគរទៅ ក៏ដួលដេកទៀបទ្វារនគរ ។ គ្រានោះ ព្រះដ៏មានព្រះភាគ កាលចេញចាកនគរជាមួយនឹងពួកភិក្ខុជាច្រើនអង្គ បានទតឃើញព្រះសាគត:ដ៏មានអាយុដួលដេកនៅទៀបទ្វារនគរ លុះទ្រង់ឃើញហើយក៏ត្រាស់បង្គាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឯងចូរគ្រាហ៍សាគតភិក្ខុឡើង ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ក៏គ្រាហ៍ព្រះសាគត:ដ៏មានអាយុទៅកាន់អារាម ហើយផ្តេកបែរក្បាលទៅរកព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះសាគត:ដ៏មានអាយុប្រែត្រឡប់ដេកដាក់ជើងទៅរកព្រះដ៏មានព្រះភាគវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពីដើមមកសាគតភិក្ខុមានសេចក្តីគោរពកោតក្រែងដល់តថាគតមែនឬទេ ។ ពួកភិក្ខុក្រាបទូលថា

ភន្តេ ។ អបិ នុ ខោ ភិក្ខវេ សាតតោ ឯតរហិ តថា-
តតេ សតារហោ សប្ប តិ ។ ណ ហោតំ ភន្តេ ។
ជនុ ភិក្ខវេ សាតតោ អម្ពតិត្ថកេ ជ ជ សជ្ជ-
សីតិ ។ ឯវំ ភន្តេ ។ អបិ នុ ខោ ភិក្ខវេ សាតតោ
ឯតរហិ ហ ១ ១ ១

សូមទ្រង់មេត្តាប្រោស ពិតយ៉ាងហ្នឹងហើយ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុមានសេចក្តីគោរពកោតក្រែងដល់តថាគតឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនគោ-រពទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ សាគតភិក្ខុបានច្បាំងនឹងអម្ពតិត្ថកនាគ ពិតមែនឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុ (ដែលដួលដេកមិនដឹងខ្លួនយ៉ាងនេះ) អាចច្បាំងនឹងពស់ទឹក[1] បានឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនបានទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រាសចាកសញ្ញាព្រោះផឹកទឹកណា ទឹកនោះភិក្ខុគួរផឹកឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនគួរផឹកទេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មរបស់សាគតភិក្ខុមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ម្នាលភិក្ខុទាំងឡាយ សាគត-ភិក្ខុមិនគួរនឹងផឹកទឹកស្រវឹងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ

---

១ ពស់ឥតពិស បានដល់ពស់ចន្ទមម និងពស់ព្រលិតជាដើម ។

ភិយ្យោភាវាយ ។ បេ ។ ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សុរាមេរយចានេ ចាចិត្តិយន្តិ ។

[១៩៤] សុរា នាម បិដ្ឋសុរា ឃ្ងាសុរា ឱទនសុរា កិណ្ណាបក្ខិត្តា សម្ភារសំយុត្តា ។ មេរយោ នាម បុប្ផាសវោ ផលាសវោ មធ្វាសវោ គុឡាសវោ សម្ភារសំយុត្តោ ។ បិវេយ្យាតិ[1] អន្តមសោ ឧសក្ខេនបិ បិវតិ អាបត្តិ ចាចិត្តិយស្ស ។

[១៩៥] មជ្ជេ មជ្ជសញ្ញី បិវតិ អាបត្តិ ចាចិត្តិយស្ស ។ មជ្ជេ វេមតិកោ បិវតិ អាបត្តិ ចាចិត្តិយស្ស ។ មជ្ជេ អមជ្ជសញ្ញី បិវតិ អាបត្តិ ចាចិត្តិយស្ស ។ អមជ្ជេ

---

១ អយំ បាឬ វិចារេតព្ពោ មាតិកាយំ អនាគតត្តា ។

ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុផឹកសុរានិងមេរ័យ ត្រូវអាបត្តិបាចិត្តិយ ។

[១៩៤] ដែលហៅថា សុរា គឺសុរាធ្វើដោយមេរ៉ា ១ សុរាធ្វើដោយនំ ១ សុរាធ្វើដោយបាយ ១ សុរាដែលគេដាក់ពូជសុរា ១ សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេង ៗ ១ ។ ដែលហៅថា មេរ័យនោះ គឺទឹកត្រាំដែលគេធ្វើដោយផ្កាឈើ ១ ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ ១ ទឹកត្រាំដែលគេធ្វើដោយផ្ទៃចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ ១ ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ ១ ទឹកត្រាំដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេង ៗ ១ ។ ត្រង់ពាក្យថា ផឹក សេចក្តីថា ដោយហោចទៅសូម្បីតែភិក្ខុផឹកប្រមាណប៉ុនចុងស្លរ ក៏ត្រូវអាបត្តិបាចិត្តិយ ។

[១៩៥] ទឹកស្រវឹង ភិក្ខុសំគាល់ថា ទឹកស្រវឹង ហើយផឹក ត្រូវអាបត្តិបាចិត្តិយ ។ ទឹកស្រវឹង ភិក្ខុមានសេចក្តីសង្ស័យ ហើយផឹក ត្រូវអាបត្តិបាចិត្តិយ ។ ទឹកស្រវឹង ភិក្ខុសំគាល់ថា មិនមែនទឹកស្រវឹង ហើយផឹក ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនទឹកស្រវឹង ភិក្ខុសំគាល់

មជ្ជសញ្ញី អាបត្តិ ទុក្កដស្ស ។ អមជ្ជេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមជ្ជេ អមជ្ជសញ្ញី អនាបត្តិ ។

[១៩៦] អនាបត្តិ អមជ្ជញ្ច ហោតិ មជ្ជវណ្ណោ មជ្ជគន្ធំ មជ្ជរសំ តំ បិវតិ សូបសំចាកេ មំសសំចាកេ តេល-សំចាកេ អាមលកជាណិតេ អមជ្ជំ អវិដ្ឋំ បិវតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

ថា ទឹកស្រវឹង ត្រូវអាបត្តិទុក្កដ ។ មិនមែនទឹកស្រវឹង ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនទឹកស្រវឹង ភិក្ខុសំគាល់ថា មិនមែនទឹកស្រវឹង មិនត្រូវអាបត្តិឡើយ ។

[១៩៦] *ភារៈដែលមិនត្រូវអាបត្តិ* (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចជាទឹកស្រវឹង មានក្លិនដូចជាទឹកស្រវឹង មានរសដូចជាទឹកស្រវឹង ១ ទឹកស្រវឹងដែលគេចំអិនលាយនឹងសម្ង ១ ទឹកស្រវឹងដែលគេចំអិនលាយនឹងសាច់ ១ ទឹកស្រវឹងដែលគេចំអិនលាយនឹងប្រេង ១ ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ធួតព្រៃ ១ ភិក្ខុផឹកថ្នាំអរិដ្ឋ[1] មិនស្រវឹង ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១ ចប់ ។

---

១ ថ្នាំដែលគេធ្វើដោយរសនៃផ្លែឈើ មានផ្លែកន្ធួតព្រៃជាដើម ។

ទុតិយសិក្ខាបទំ

[១៩៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ សត្តរសវត្ថុកំ ភិក្ខុំ អជ្ជុលិប្បតោឧកេន ហាសេសុំ ។ សោ ភិក្ខុ ឧត្តសន្តោ អនស្សាសកោ ការាលមការិ ។ យេ តេ ភិក្ខូ អប្ប៎ិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ការណំ ហិ នាម ឆព្ភក្ខិយា ភិក្ខូ ភិក្ខុំ អជ្ជុលិប្បតោឧ-កេន ហាសេស្ស ន្តីតិ ។ បេ ។ សច្ចំ ការ តុម្ហេ ភិក្ខវេ ភិក្ខុំ អជ្ជុលិប្បតោឧកេន ហាសេថាតិ ។ សច្ចំ ភគ-វាតិ ។ វិគរហិ ពុទ្ធោ ភគវា ការណំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុំ អជ្ជុលិប្បតោឧកេន ហាសេស្ស ថ ឧនតំ មោឃបុរិសា អប្ប៎សន្ថានំ វ បសាឧាយ ប-សន្ថានំ វ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អជ្ជុលិប្បតោឧកេ ចាចិត្តិយន្តិ ។

សិក្ខាបទទី ២

[១៩៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើសត្តរសវគ្គិយភិក្ខុមួយរូប ឲ្យសើចដោយជន្ជ្ញាគឺម្រាមដៃ[1] ។ ភិក្ខុនោះសើចគាំងដកដង្ហើមមិនរួចក៏ធ្វើកាលកិរិយាទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យសើចដោយជន្ជ្ញាគឺម្រាមដៃសោះ ។ បេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងធ្វើភិក្ខុផងគ្នាឲ្យ សើចដោយជន្ជ្ញាគឺម្រាមដៃ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យសើច ដោយជន្ជ្ញាគឺម្រាមដៃទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យ ជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឧ្យ រឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុចាក់ក្រលេកប្រលែង គ្នាដោយជន្ជ្ញាគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។

---

1 គឺយកម្រាមដៃចាក់ក្រលេកលេង ។

[១៩៨] អង្ខុលិប្ផ្ដោនកោ ជាម អង្ខុលិយាបិ តុនន្ដិ ។ ឧបសម្ផ្ជោ ឧបសម្ផ្ជំ ហាស្ផ្ជាធិប្ផ្ជាយោ[1] ការយេន ការយំ អាមសតិ អាបត្ដិ ចាចិត្ដិយស្ផ ។

[១៩៩] ឧបសម្ផ្ជេ ឧបសម្ផ្ជសញ្ញី អង្ខុលិប្ផ-ផ្ដោនកេន ហាសេតិ អាបត្ដិ ចាចិត្ដិយស្ផ ។ ឧប-សម្ផ្ជេ វេមតិកោ អង្ខុលិប្ផ្ដោនកេន ហាសេតិ អាបត្ដិ ចាចិត្ដិយស្ផ ។ ឧបសម្ផ្ជេ អនុបសម្ផ្ជសញ្ញី អង្ខុលិប្ផ្ដោនកេន ហាសេតិ អាបត្ដិ ចាចិត្ដិយស្ផ ។

[២០០] ការយេន ការយប្ផ្ជិតង្ខំ អាមសតិ អាបត្ដិ ទុក្ការ្ជស្ផ ។ ការយប្ផ្ជិតេ្ខន ការយំ អាមសតិ អាបត្ដិ ទុក្ការ្ជស្ផ ។ ការយប្ផ្ជិតេ្ខន ការយប្ផ្ជិតង្ខំ អាមសតិ អាបត្ដិ ទុក្ការ្ជស្ផ ។ និស្ផ្ជ្ជ្ជ

[១៩៨] ដែលហៅថា ជន្ធ្ជ្ញគឺម្រាមដៃនោះ គឺភិក្ខុចាក់ដោយម្រាមដៃ ។ ឧបសម្ប្ន ប៉ង់ដើម្បីសើចលេង ហើយប៉ះត្រូវកាយរបស់ឧបសម្ប្ន្ធផង់គ្នា ដោយកាយរបស់ខ្ជ្ន ត្រូវអាបត្តិបាចិត្តិយ ។

[១៩៩] ឧបសម្ប្ន ភិក្ខុសំគាល់ថា ឧបសម្ប្ន ហើយធ្ជ្ើឲ្យសើចដោយជន្ធ្ជ្ញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្ប្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយធ្ជ្ើឲ្យសើចដោយជន្ធ្ជ្ញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្ប្ន ភិក្ខុសំគាល់ថា ជាអនុបសម្ប្ន្ធទៅវិញ ហើយធ្ជ្ើឲ្យសើចដោយជន្ធ្ជ្ញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។

[២០០] ភិក្ខុពាល់ត្រូវនូវវត្ថុដែលជាប់ដោយកាយ (របស់ភិក្ខុផង់គ្នា) ដោយកាយ (របស់ខ្ជ្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវកាយ (របស់ភិក្ខុផង់គ្នា) ដោយវត្ថុដែលជាប់នឹង៏កាយ (របស់ខ្ជ្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹង៏កាយ (របស់ភិក្ខុផង់គ្នា) ដោយវត្ថុដែលជាប់នឹង៏កាយ (របស់ខ្ជ្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវកាយ (របស់ភិក្ខុផង់គ្នា) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្ជ្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹង៏កាយ (របស់ភិក្ខុផង់គ្នា) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្ជ្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុសម្រាប់បោះចោល (របស់ភិក្ខុផង់គ្នា) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្ជ្ន) ត្រូវអាបត្តិទុក្កដ ។

បាចិត្តិយកណ្ឌ សុរាបានវគ្គស្ស ទុតិយសិក្ខាបទស្ស អនាបត្តិវារោ

[២០១] អនុបសម្បន្នំ កាយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កា-យប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិ-យេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

[២០២] អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[២០៣] អនាបត្តិ ន ហាសុប្ផាទិប្ផាយោ សតិ ការណាយ អាមសតិ ឧម្មត្តកស្ស អាទិកម្មិកស្ផាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

[២០១] *ភិក្ខុពាល់ត្រូវកាយរបស់អនុបសម្បន្ន ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់អនុប-សម្បន្ន) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវកាយ (របស់អនុបសម្បន្ន) ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់ដោយកាយរបស់អនុបសម្បន្ន ដោយវត្ថុដែលជាប់ដោយកាយរបស់ខ្លួន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវកាយ (របស់អនុបសម្បន្ន) ដោយវត្ថុសម្រាប់ចោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់អនុបសម្បន្ន) ដោយវត្ថុសម្រាប់ចោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុសម្រាប់ចោះចោល (របស់អនុបសម្បន្ន) ដោយវត្ថុសម្រាប់ចោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។*

[២០២] *អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។*

[២០៣] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុគ្មានបំណងនឹងសើចលេង ១ ភិក្ខុមានកិច្ចហើយពាល់ត្រូវ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ២ ចប់ ។

ឥតិយសិក្ខាបទំ

[២០៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ អចិរវតិយា
នទិយា ឧទកេ កីឬន្តិ ។ តេន ខោ បន សមយេន
ពាជា បសេនទិ កោសលោ មល្លិការយ ទេវិយា សទ្ធឹ
ឧបរិប្បាសាទវរគតោ ហោតិ ។ អទ្ធសា ខោ ពាជា
បសេនទិ កោសលោ សត្តរសវគ្គិយេ ភិក្ខូ អចិរ-
វតិយា នទិយា ឧទកេ កីឬន្តេ ទិស្វាន មល្លិកំ
ទេវឺ ឯតទវោច ឯតេ ហេ មល្លិកេ អរហន្តោ ឧទកេ
កីឬន្តីតិ ។ ទិស្សាសយំ ខោ មហារាជ ភគវតា
សិក្ខាបទំ អប្ញញ្ញត្តំ តេ ឯ ភិក្ខូ អប្ញកតញ្ញូនោតិ ។
អថខោ រញ្ញោ បសេនទិស្ស កោសលស្ស ឯតទ-
ហោសិ កេន នុ ខោ អហំ ឧចាយេន ភគវតោ
ច ន អារោចេយ្យំ ភគវា ច ជានេយ្យ ឥមេ ភិក្ខូ
ឧទកេ កីឬន្តីតិ ។ អថខោ ពាជា បសេនទិ
កោសលោ សត្តរសវគ្គិយេ ភិក្ខូ បញ្ហាសាបេត្វា

សិក្ខាបទទី ៣

[២០៤] *សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកសត្តរសវគ្គិយ-ភិក្ខុលេងទឹកក្នុងស្ទឹងឈ្មោះអចិរវតី ។ គ្រានោះ ព្រះបាទបសេនទិកោ-សល ទ្រង់គង់នៅលើប្រាសាទដ៏ប្រសើរ ជាមួយនឹងព្រះទេពីព្រះនាម មល្ងិកា ។ ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញពួកសត្តរសវគ្គិយភិក្ខុ កំពុងលេងទឹក ក្នុងស្ទឹងអចិរវតី លុះទ្រង់ឃើញហើយក៏មានព្រះបន្ទូលនឹងនាងមល្ងិកាទេវីយ៉ាងនេះថា នែនាងមល្ងិកា ព្រះអរហន្តទាំងនេះលេងទឹកទេតើ ។ នាងមល្ងិកាទេវីក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គកុំសង្ស័យ ព្រះដ៏មានព្រះភាគមិនទាន់បញ្ញត្តសិក្ខាបទទេ ពុំនោះសោត ភិក្ខុទាំងនោះ ជាអ្នកមិនដឹងនូវសិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តរួចហើយ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រិះរិះយ៉ាងនេះថា ដោយឧបាយដូចម្តេចហ្ន៎ ដែលអញមិនបាច់ក្រាបទូលព្រះដ៏មានព្រះភាគផង ទាំងព្រះដ៏មានព្រះភាគក៏ទ្រង់ជ្រាបថា ភិក្ខុទាំងនេះលេងទឹកផង ។ កាលនោះ ព្រះបាទបសេនទិកោសល ទ្រង់ឲ្យនិមន្តពួកសត្តរសវគ្គិយភិក្ខុមក*

តេសំ មហន្តំ កុឌ្ឍបិណ្ឌំ អជាសិ ឥមំ ភន្តេ កុឌ្ឍបិណ្ឌំ ភគវតោ ទេថាតិ ។ សត្ថុសវត្តិយា ភិក្ខូ តំ កុឌ្ឍបិណ្ឌំ អាជាយ យេន ភគវា តេនុប-សង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ ឯតទវោចុំ ឥមំ ភន្តេ កុឌ្ឍបិណ្ឌំ ភជា ភគវតោ ទេតីតិ ។ កហំ បន តុម្ហេ ភិក្ខវេ ភជា អទ្ធសាតិ ។ អចិរវតិយា នទិយា ភគវា ឧទកេ ក្រីឌ្យន្តេតិ ។ រិតរហិ ពុទ្ធោ ភគវា ភចំ ហិ ជាម តុម្ហេ មោឃបុរិសា ឧទកេ ក្រីឌ្យិស្សថ ទេតំ មោឃបុរិសា អប្ប្សន្ធានំ វ បសាជាយ បសន្ធានំ វ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឧទកេ ហាស្ស្ជម្ម[1] ចាចិត្តិយន្តិ ។

[២០៤] ឧទកេ ហាស្ស្ជម្ម ជាម ឧបរិតោ ១ ១ ១

ហើយប្រគេនដុំស្ករអំពៅមួយដុំធំដល់ពួកភិក្ខុទាំងនោះ ដោយព្រះតម្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយថ្វាយដុំស្ករអំពៅនេះដល់ព្រះដ៏មានព្រះភាគផង ។ ពួកសត្តរសវគ្គិយភិក្ខុយកដុំស្ករអំពៅនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ស្ដេចថ្វាយដុំស្ករអំពៅនេះចំពោះព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្ដេចឃើញពួកអ្នកឯងនៅទីណា ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ស្ដេចទតឃើញពួកខ្ញុំព្រះអង្គកំពុងលេងទឹកក្នុងស្ទឹងអចិរវតី ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងនាំគ្នាលេងទឹកទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុលេងទឹក ត្រូវអាបត្តិបាចិត្តិយ ។

[២០៥] ដែលហៅថា លេងទឹកនោះ គឺភិក្ខុមានបំណងនឹងលេងទឹកដែលជ្រៅជាងភ្នែកគោរឡើងទៅ ទោះមុជចុះក្ដី ងើបឡើងក្ដី ហែលក្ដី ត្រូវអាបត្តិបាចិត្តិយ ។

[២០៦] ឧឌកេ ហាសោ ធម្មេ ហាសោ ធម្មសញ្ញី អាបត្តិ ចាចិត្តិយស្ស ។ ឧឌកេ ហាសោ ធម្មេ វេមតិកោ អាបត្តិ ចាចិត្តិយស្ស ។ ឧឌកេ ហាសោ ធម្មេ អហាសោ ធម្មសញ្ញី អាបត្តិ ចាចិត្តិយស្ស ។

[២០៧] ហេដ្ឋាគោប្ជកេ ឧឌកេ ឬ ឬ ១ ១ ១

[២០៦] លេងទឹក ភិក្ខុសំគាល់ថា លេងទឹក ត្រូវអាបត្តិបាចិត្តិយ ។ លេងទឹក ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ ។ លេងទឹក ភិក្ខុសំគាល់ថា មិនបានលេងវិញ ត្រូវអាបត្តិបាចិត្តិយ ។

[២០៧] ភិក្ខុលេងទឹកពាក់ជាងភ្នែកគោរ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលេងទឹកដោយទូក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រហារទឹកដោយដៃក្តី ជើងក្តី កំណាត់ឈើក្តី អំបែងក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលេងទឹកដែលមានក្នុងភាជន៍ក្តី លេងទឹកបាយក្តី ទឹកដោះស្រស់ក្តី ទឹកដោះជូរក្តី ទឹកជ្រលក់ក្តី ទឹកនោមក្តី ភក់ក្តី ត្រូវអាបត្តិទុក្កដ ។

[២០៨] មិនបានលេងទឹកទេ ភិក្ខុសំគាល់ថា លេង ត្រូវអាបត្តិទុក្កដ ។ មិនបានលេងទឹក ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនបានលេងទឹក ភិក្ខុសំគាល់ថា មិនបានលេង មិនត្រូវអាបត្តិឡើយ ។

បាចិត្តិយកណ្ឌោ សុរាបានវគ្គស្ស តតិយសិក្ខាបទស្ស អនាបត្តិវារោ

[២០៩] អនាបត្តិ ន ហាស្យាធិប្ប្រាយោ សតិ ការណ៌ាយ ឧទកំ ឋិតវិត្វា ជិមុជ្ជតិ វ ឧម្មុជ្ជតិ វ បលវតិ វ ចារំ តច្ជ្ជ្ជ ជិមុជ្ជតិ វ ឧម្មុជ្ជតិ វ បលវតិ វ អាបជ្ជ ឧម្មត្តកស្ស អាជ្ជ- កស្ស្ជ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

[២០៩] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុគ្មានបំណងនឹងលេង ១ ភិក្ខុមានកិច្ចហើយចុះទឹកមុជចុះក្តី ងើបក្តី ហែលក្តី ១ ភិក្ខុធ្លង់ទៅត្រើយនាយ មុជចុះក្តី ងើបក្តី ហែលក្តី ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្គួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៣ ចប់ ។

ចតុត្ថសិក្ខាបទំ

[២១០] តេន សមយេន ពុទ្ធោ ភគវា គោ-
សម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន
សមយេន អាយស្មា ឆន្នោ អជ្ឌាចារំ អាចរតិ ។ ភិក្ខូ
ឯវមាហំសុ មា អាវុសោ ឆន្ន ឯវ្រូបំ អកាសិ នេតំ
កប្បតីតិ ។ សោ អជ្ឌាចរិយំ បដិចូ ១ កវោតិយេវ ។
យេ តេ ភិក្ខូ អប្ប១ិច្ឆា ។ បេ ។ តេ ឧជ្ឌាយន្តិ ១ីយន្តិ
១ិចារ១ន្តិ ១ៅ ១ិ ១ាម អាយស្មា ឆន្នោ អជ្ឌាចរិយំ
ការិស្ស១ីតិ ។ បេ ។ ១ៅ ១ិ ១ាម ១ាយ ១ាយ ១ ១ ១

សិក្ខាបទទី ៤

[២១០] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ធន្ធដ៏មានអាយុតែងតែប្រព្រឹត្ត អនាចារ ។ ភិក្ខុទាំងឡាយក៏និយាយយ៉ាងនេះថា ម្នាលធន្ធដ៏មាន អាយុ លោកកុំធ្វើអំពើមានសភាពដូច្នេះឡើយ អំពើនេះមិនសម គួរទេ ។ ធន្ធភិក្ខុនោះអាស្រ័យនូវសេចក្តីមិនអើពើ ហើយចេះតែធ្វើ (កម្មនោះ) ដដែល ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ធន្ធដ៏មានអាយុ មិនគួរនឹងធ្វើនូវសេចក្តីមិនអើពើសោះ ។ បេ ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា នែធន្ធ ឮថាអ្នកឯងធ្វើនូវសេចក្តីមិនអើពើ ពិតមែនឬ ។ ធន្ធភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធ ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងធ្វើ នូវសេចក្តីមិនអើពើទេ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួក ជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្ល ឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែង ឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

[២១១] អនាឧរិយំ នាម ទ្វេ អនាឧរិយានិ បុក្ក-លានាឧរិយញ្ច ឆម្មានាឧរិយញ្ច ។ បុក្ក្លានាឧរិយំ នាម ឧបសម្ប្ជេន បញ្ញត្តេន រុច្ចមានោ អយំ ឧក្ខិត្តោ វ ធ្ម្ជិតោ វ ករហិតោ វ ឥមស្ស ១ចនំ អកតំ ភវិស្ស-តីតិ អនាឧរិយំ ១ាកេតិ អាបត្តិ ១ាចិត្តិយស្ស ។ ឆម្ម-នាឧរិយំ នាម ឧបសម្ប្ជេន បញ្ញត្តេន រុច្ចមានោ ១ាចាយ ១ ១ស្ស្ជយ្យ វ ១ ១ ១

[២១១] ដែលហៅថា មិនអើពើ បានដល់សេចក្តីមិនអើពើពីរយ៉ាង គឺមិនអើពើនឹងបុគ្គល ១ មិនអើពើនឹងធម៌ ១ ។ ដែលហៅថា មិនអើពើនឹងបុគ្គលនោះ គឺឧបសម្បន្ន កាលបើមានឧបសម្បន្នផងគ្នាពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ។ គិតថា ភិក្ខុនេះ សង្ឆបានលើកវត្តហើយក្តី សង្ឆផ្តាសាហើយក្តី សង្ឆតិះដៀលហើយក្តី ពាក្យរបស់ភិក្ខុនេះ អញនឹងមិនធ្វើតាមទេ ហើយក៏ធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។ ដែលហៅថា មិនអើពើនឹងធម៌នោះ គឺឧបសម្បន្ន កាលបើមានឧបសម្បន្នផងគ្នា ពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តទុកហើយ ។ គិតថា ធ្វើដូចម្តេចហ្ន៎ ធម៌នេះបាត់ទៅក្តី សាបសូន្យទៅក្តី អន្តរធានទៅក្តី ឬមិនចង់សិក្សាធម៌នោះ ហើយក៏ធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

[២១២] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នទៅវិញ ហើយធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

[២១៣] ឧបសម្បន្ន កាលបើមានឧបសម្បន្នផងគ្នា ពោលដាស់តឿនដោយពាក្យឯទៀត ដែលមិនមែនជាវិនយប្ញត្តិ ហើយគិតថា

ន អបចយាយ ន វីរិយារម្ភាយ សំវត្តតីតិ អនាទរិយំ
ករោតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេន បញ្ញត្តេន
វា អប្បញ្ញត្តេន វា រុច្ចមានោ ឥធ ន សល្ទេខាយ ន
ធូតន្តាយ ន ទាសាធិកតាយ ន អបចយាយ ន វីរិយា-
រម្ភាយ សំវត្តតីតិ អនាទរិយំ ករោតិ អាបត្តិ ទុក្កដស្ស ។

[២១៤] អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ
ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ
ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ
ទុក្កដស្ស ។

[២១៥] អនាបត្តិ ឋវំ អម្ហាកំ អាចរិយានំ ឧក្ខេបោ
បរិបុច្ឆាតិ ភណាតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

ពាក្យនេះមិននាំឲ្យចិត្តផ្ទរផង់ មិននាំឲ្យកំចាត់បង់កិលេសវដ្ត មិននាំឲ្យកើតសេចក្ដីជ្រះថ្លា មិនមែននាំឲ្យកើតសេចក្ដីមិនសន្សំនូវកិលេសវដ្ត មិននាំឲ្យប្រារព្ធសេចក្ដីព្យាយាម ហើយធ្វើនូវសេចក្ដីមិនអើពើ ត្រូវអាបត្តិទុក្កដ ។ ឧបសម្ប្ន កាលបើមានអនុបសម្ប្នពោលជាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយក្ដី មិនបញ្ញត្តហើយ[1]ក្ដី ហើយគិតថា ពាក្យនេះមិននាំឲ្យចិត្តផ្ទរផង់ មិននាំឲ្យកំចាត់បង់កិលេសវដ្ត មិននាំឲ្យកើតសេចក្ដីជ្រះថ្លា មិនមែននាំឲ្យកើតសេចក្ដីមិនសន្សំនូវកិលេសវដ្ត មិននាំឲ្យប្រារព្ធសេចក្ដីព្យាយាម ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិទុក្កដ ។

[២១៤] អនុបសម្ប្ន ភិក្ខុសំគាល់ថាឧបសម្ប្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្ប្ន ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្ប្ន ភិក្ខុសំគាល់ថា អនុបសម្ប្ន ត្រូវអាបត្តិទុក្កដ ។

[២១៥] ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុពោលថា បាឡីអដ្ឋកថានៃអាចារ្យទាំងឡាយ របស់យើងយ៉ាងនេះ ១ ភិក្ខុធ្លាត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់ ។

---

១ គឺពាក្យដែលមានមកក្នុងព្រះសូត្រ និងព្រះអភិធម្ម ។

បញ្ចមសិក្ខាបទំ

[២១៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ សត្ត-
រសវត្ថុយេ ភិក្ខូ ភឹសាបេន្តិ ។ តេ ភឹសាបិយមានា
ភេជ្ជន្តិ ។ ភិក្ខូ ឍវមាហំសុ កិស្ស តុម្ហេ អាវុសោ
ភេជ្ជថាតិ ។ ឥមេ អាវុសោ ឆព្ភក្ខិយា ភិក្ខូ អម្ហេ
ភឹសាបេន្តីតិ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ឆព្ភក្ខិយា
ភិក្ខូ ភិក្ខូ ភឹសាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ
តុម្ហេ ភិក្ខវេ ភិក្ខូ ភឹសាបេថាតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃ-
បុរិសា ភិក្ខូ ភឹសាបេស្សថ នេតំ មោឃបុរិសា
អប្ឋសន្ថានំ វា បសាទាយ បសន្ថានំ វា កិយ្យា-
ការាយ ។ បេ ។ ឍវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ភឹសាបេយ្យ
ចាតិ្ដ្ឋយន្តិ ។

សិក្ខាបទទី ៥

[២១៦] *សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ធ្វើសត្តរសវគ្គិយភិក្ខុឲ្យខ្ជាច ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះ កាលបើគេ ធ្វើឲ្យខ្ជាចក៏ស្រែកយំ ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាអ្នកទាំងឡាយស្រែកយំ ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះធ្វើយើងរាល់គ្នាឲ្យខ្ជាច ។ ពួកភិក្ខុ ណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះ ក៏ពោល ទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើភិក្ខុផងគ្នា ឲ្យ ខ្ជាចសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នករាល់គ្នាធ្វើភិក្ខុផងគ្នាឲ្យខ្ជាច ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នករាល់គ្នាមិនគួរនឹងបន្ទាចភិក្ខុផងគ្នាទេ នែ មោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិន ទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទ នេះយ៉ាងនេះថា ភិក្ខុណាមួយធ្វើភិក្ខុផងគ្នាឲ្យខ្ជាច ត្រូវអាបត្តិបាចិត្តិយ ។*

[២១៧] យោ បជានតិ យោ យានិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញ ភិក្ខុំ ។ ភឹសាបេយ្យាតិ ឧបសម្ផន្នោ ឧបសម្ផន្នំ ភឹសាបេតុកាមោ រូបំ វ សទ្ទំ វ គន្ធំ វ រសំ វ ផោដ្ឋព្ពំ វ ឧបសំហរតិ កាយេយ្យ វ សោ ន វ កាយេយ្យ អាបត្តិ ចាចិត្តិយស្ស ។ ចោរកន្ធារំ វ វាឋ្ឍកន្ធារំ វ បិសាចកន្ធារំ វ អាចិក្ខតិ កាយេយ្យ វ សោ ន វ កាយេយ្យ អាបត្តិ ចាចិត្តិយស្ស ។

[២១៨] ឧបសម្ផន្នេ ឧបសម្ផន្នសញ្ញី ភឹសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ផន្នេ វេមតិកោ ភឹសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ផន្នេ អនុប-សម្ផន្នសញ្ញី ភឹសាបេតិ អាបត្តិ ចាចិត្តិយស្ស ។

[២១៩] ឧបសម្ផន្នោ អនុបសម្ផន្នំ ភឹសាបេតុ-កាមោ រូបំ វ សទ្ទំ វ គន្ធំ វ រសំ វ ផោដ្ឋព្ពំ វ ឧបសំហរតិ កាយេយ្យ វ សោ ន វ កាយេយ្យ

[២១៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិក ។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុដទៃ (ក្រៅពីខ្លួន) ។ ពាក្យថា ឲ្យខ្ជាច គឺឧបសម្បន្ន មានបំណងនឹងធ្វើឧបសម្បន្នឲ្យខ្ជាច ហើយសំដែងរូបក្តី សំឡេងក្តី ក្លិនក្តី រសក្តី ផ្សព្វក្តី ទោះបីឧបសម្បន្ននោះខ្ជាចក្តី មិនខ្ជាចក្តី ក៏ត្រូវអាបត្តិបាចិត្តិយ ។ (ឧបសម្បន្នមានសេចក្តីប្រាថ្នាដើម្បីបន្ទាចឧបសម្បន្នផងគ្នា) ហើយប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ទោះបីឧបសម្បន្ននោះខ្ជាចក្តី មិនខ្ជាចក្តី ត្រូវអាបត្តិបាចិត្តិយ ។

[២១៨] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយបន្ទាច ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសង្ស័យ ហើយបន្ទាច ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នទៅវិញ ហើយបន្ទាច ត្រូវអាបត្តិបាចិត្តិយ ។

[២១៩] ឧបសម្បន្ន មានបំណងនឹងបន្ទាចអនុបសម្បន្ន ហើយសំដែងរូបក្តី សំឡេងក្តី ក្លិនក្តី ផ្សព្វក្តី រសក្តី ទោះបីអនុបសម្បន្ននោះខ្ជាចក្តី

អាបត្តិ ទុក្កដស្ស ។ ចោរកន្ត្រាវ ០ ០ឍ្ឍកន្ត្រាវ ០ បិសាចកន្ត្រាវ ០ អាចិក្ខតិ ០យ្យ ០ សោ ០ ០ ០យ្យ អាបត្តិ ទុក្កដស្ស ។

[២២០] អនុបសម្ប្ជ្ជ ឧបសម្ប្ជ្ជ អាបត្តិ ទុក្កដស្ស ។ អនុបសម្ប្ជ្ជ ០ អាបត្តិ ទុក្ក-ដស្ស ។ អនុបសម្ប្ជ្ជ អនុបសម្ប្ជ្ជ អាបត្តិ ទុក្កដស្ស ។

[២២១] អនាបត្តិ ០ ០ សោ ០ ០ ០

មិនខ្វាចក្តី ក៏ត្រូវអាបត្តិទុក្កដ ។ (ឧបសម្បន្នមានសេចក្តីប្រាថ្នា ដើម្បីបន្ទាចអនុបសម្បន្ន) ហើយប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ទោះបីអនុបសម្បន្ននោះខ្វាចក្តីមិនខ្វាចក្តី ត្រូវអាបត្តិទុក្កដ ។

[២២០] *អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។*

[២២១] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុគ្មានបំណងនឹងបន្ទាច ហើយសំដែងរូបក្តី សំឡេងក្តី ក្លិនក្តី រសក្តី ផ្សព្វក្តី ១ ភិក្ខុ (គ្មានបំណងនឹងបន្ទាចហើយ) ប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៥ ចប់ ។

ឆដ្ឋសិក្ខាបទំ

[២២២] តេន សមយេន ពុទ្ធោ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឬវនេ មិគទាយេ ។ តេន ខោ បន សមយេន ភិក្ខូ ហេមន្តិកេ មាសេ អញ្ញតរំ មហន្តំ សុសិរកដ្ឋំ ជោតឹ សមាធហិត្វា វិសិព្ភេសុំ ។ តស្មឹ ច សុសិរេ កណ្ហាសប្បោ អត្ថិ ១ សន្ត្ថោ ជិក្ខមិត្វា ភិក្ខូ បរិចាតេសិ ។ ភិក្ខូ តហឹ តហឹ បធាវឹសុ ។ យេ តេ ភិក្ខូ អប្ប១ិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ១ីយន្តិ ១ិចាចេន្តិ ១ចំ ហិ ១ាម ភិក្ខូ ជោតឹ សមាធហិត្វា ១ិសិព្ភេ១្ឍ្ឌ្ដ្ដ្ដ្ដ ។ បេ ។ ១ចុ១ ១ិ១ ភិក្ខូ ១ ភិក្ខូ ជោតឹ សមាធហិត្វា ១ិសិព្ភ១្ដ្ដ ។ ១ចុ១ ភគ១ាតិ ។ ១ិ១ហិ ពុទ្ធោ ភគ១ា ១ចំ ហិ ១ាម ១ ភិក្ខូ១ ១ោ១ បុ១ិ១ ជោតឹ សមាធហិត្វា ១ិសិព្ភ១្ដ្ដ ១ ១ ១

សិក្ខាបទទី ៦

[២២២] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅកេសកលាវន ជាទីឲ្យអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរ: ក្នុងភគ្គជនបទ ។ សម័យនោះឯង ភិក្ខុទាំងឡាយនាំគ្នាបង្ក្រាត់ភ្ជើងនឹងឈើដែលមានប្រហោង ១ ដុំធំ ហើយនាំគ្នាអាំងក្នុងខ្ទមរបស់ ។ មានពស់ខ្ចៅ ១ នៅក្នុងប្រហោងឈើនោះ លុះត្រូវកំដៅភ្ជើងក៏លូនចេញមក ហើយធ្វើភិក្ខុទាំងឡាយ ឲ្យដួលជាសពាស ។ ភិក្ខុទាំងឡាយក៏ស្ទុះរត់ទៅក្នុងទីនោះ ៗ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀលបន្ទុះបង្ហាប់ថា ភិក្ខុទាំងឡាយមិនគួរនឹងបង្ក្រាត់ភ្ជើងអាំងសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយបង្ក្រាត់ភ្ជើងអាំង ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា នែភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនគួរនឹងបង្ក្រាត់ភ្ជើងអាំងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ

វិសីវណ្ណាបេក្ខោ[១] ជោតឹ សមាធហេយ្យ វ សមាធហា-
ហេយ្យ វ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ
សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២២៣] តេន ខោ បន សមយេន ភិក្ខូ ឥលានា
ហោន្តិ ។ ឥលានបុច្ឆកា ភិក្ខូ ឥលានេ ភិក្ខូ ឯតទវោចុំ
 កច្ចាវុសោ ខមនីយំ ១ កច្ចិ យាបនីយន្តិ ។ បុព្ពេ មយំ
អាវុសោ ជោតឹ សមាធហិត្វា វិសិព្ពេម តេន ណោ ផាសុ
ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ ១ ១ ១

មានបំណងនឹងអាំងភ្លើង បង្ហាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្ហាត់ក្តី នូវភ្លើង ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគ បានទ្រង់បញ្ញត្តសិក្ខាបទនេះ ដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[២២៣] សម័យនោះឯង ភិក្ខុទាំងឡាយមានជំងឺ ។ ឯពួកភិក្ខុអ្នកសួរជំងឺក៏និយាយពាក្យនេះនឹងភិក្ខុដែលមានជំងឺថា ម្នាលអាវុសោ អ្នកទាំងឡាយលួមអត់ធន់បានឬទេ លួមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុមានជំងឺប្រាប់ថា ម្នាលអាវុសោ ពីដើមយើងរាល់គ្នាបង្ហាត់ភ្លើងអាំងបានជាយើងបានសេចក្តីសុខសប្បាយរាល់គ្នា ដោយហេតុបានអាំងភ្លើងនោះ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហេតុនោះទើបយើងមានសេចក្តីខ្វាចក្រែង មិនហ៊ានអាំងភ្លើង បានជាយើងមិនមានសេចក្តីសុខសប្បាយដោយហេតុនោះឯង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជំងឺបង្ហាត់ភ្លើងខ្លួនឯងក្តី ប្រើគេឲ្យបង្ហាត់ក្តី ហើយអាំងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខា-បទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនមានជំងឺ ប្រាថ្នានឹងអាំងភ្លើងហើយ បង្ហាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្ហាត់ក្តី នូវភ្លើង ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[២២៤] តេន ខោ បន សមយេន ភិក្ខូ បធីបេបិ ជោតិកេបិ ជន្ធាយបេបិ ឈាបេន្តិ[1] ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামិ ភិក្ខវេ តថារូប-ប្ប្ចយ ជោតឺ សមាឧហិតុំ សមាឧហាបេតុំ ។ ១ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អតិលាជោ វិសីវនាបេក្ខោ ជោតឺ សមាឧហេយ្យ វ ស-មាឧហាបេយ្យ ។ ១ អញ្ញត្រ តថារូបប្ប្ចយ ចាចិត្តិយន្តិ ។

[២២៥] យោ បជានាតិ យោ យាជិសោ ។ ១ ។ ១ ។ ១

[២២៧] *សម័យនោះឯង ភិក្ខុទាំងឡាយ មានសេចក្តីសង្ស័យ ក្នុងការអុជប្រទីបខ្លះ បង្ហាត់ភ្លើងដុតបាត្រជាដើមខ្លះ ពោងភ្លើងខ្លះ ។ ភិក្ខុទាំង-ឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានហេតុយ៉ាងនោះ តថាគតអនុញ្ញាតឲ្យភិក្ខុបង្ហាត់ភ្លើងខ្លួនឯង ឬប្រើគេឲ្យបង្ហាត់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនមានជំងឺ មានបំណងនឹងអាំងភ្លើង ហើយបង្ហាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្ហាត់ក្តី នូវភ្លើង ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។*

[២២៨] *ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋម-បារាជិក ។ ភិក្ខុណារៀរចាកភ្លើងហើយសប្បាយ ភិក្ខុនោះហៅថា ជាអ្នកមិនមានជំងឺ ។ ភិក្ខុណារៀរចាកភ្លើង ហើយមិនសប្បាយ ភិក្ខុនោះហៅថា អ្នកមានជំងឺ ។ ពាក្យថា មានបំណងនឹងអាំងភ្លើង គឺចង់កំដៅកាយ ។ ដែលហៅថា ភ្លើង គឺភ្លើងធម្មតានោះឯង ។ ពាក្យថា បង្ហាត់ខ្លួនឯង គឺភិក្ខុបង្ហាត់ខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើគេឲ្យបង្ហាត់ គឺភិក្ខុបង្ហាប់អ្នកដទៃ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្ហាប់តែម្តង អ្នកទទួលបង្ហាប់ទៅបង្ហាត់ភ្លើងច្រើនដង (ភិក្ខុអ្នកបង្ហាប់) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា រៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ គឺលើកទុកចំពោះហេតុមានសភាពយ៉ាងនោះ ។*

[២២៦] អតិលាភោ អតិលាភសញ្ញី វិសីវតាបេក្ខោ ជោតឹ សមាធហតិ វ សមាធហាបេតិ វ អញ្ញត្រ តថារូបប្ឋចូយា អាបត្តិ ចាចិត្តិយស្ស ។ អតិលាភោ ឋេមតិកោ វិសីវតាបេក្ខោ ជោតឹ សមាធហតិ វ សមា-ធហាបេតិ វ អញ្ញត្រ តថារូបប្ឋចូយា អាបត្តិ ចាចិត្តិ-យស្ស ។ អតិលាភោ តិលាភសញ្ញី វិសីវតាបេក្ខោ ជោតឹ សមាធហតិ វ សមាធហាបេតិ វ អញ្ញត្រ តថារូបប្ឋចូយា អាបត្តិ ចាចិត្តិយស្ស ។ បដិលាភំ ឧក្ខិបតិ អាបត្តិ ធុក្ការ៉ស្ស ។ តិលាភោ អតិលាភ-សញ្ញី អាបត្តិ ធុក្ការ៉ស្ស ។ តិលាភោ ឋេមតិកោ អាបត្តិ ធុក្ការ៉ស្ស ។ តិលាភោ តិលាភសញ្ញី អនាបត្តិ ។

[២២៧] អនាបត្តិ តិលាភស្ស អញ្ញេ ភាតំ វិសិព្ធេតិ វិតច្ឆិតក្ការ៉ំ វិសិព្ធេតិ បឋីបេបិ ជោតិកោបិ ជ្ជាយបេបិ តថារូបប្ឋចូយា អាបជាសុ ឧម្មត្តកស្ស អាទិកម្ម្ចិកស្ស្ជាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

[២២៦] ខ្ជូនមិនមានជំងឺ ភិក្ខុសំគាល់ថា មិនមានជំងឺ មានបំណងនឹងអាំងភ្លើង ហើយបង្ហាត់ភ្លើងឯងក្តី ប្រើអ្នកដទៃឲ្យបង្ហាត់ក្តី ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។ ខ្ជូនមិនមានជំងឺ ភិក្ខុមានសេចក្តីសង្ស័យ មានបំណងនឹងអាំងភ្លើង ហើយបង្ហាត់ភ្លើងខ្ជូនឯងក្តី ប្រើឲ្យអ្នកដទៃបង្ហាត់ក្តី ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។ ខ្ជូនមិនមានជំងឺ ភិក្ខុសំគាល់ថា មានជំងឺ មានបំណងនឹងអាំងភ្លើង ហើយបង្ហាត់ភ្លើងខ្ជូនឯងក្តី ប្រើអ្នកដទៃឲ្យបង្ហាត់ក្តី ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។ ភិក្ខុចាប់អង្កត់ភ្លើងលើកឡើង ត្រូវអាបត្តិទុក្កដ ។ ខ្ជូនមានជំងឺ ភិក្ខុសំគាល់ថា មិនមានជំងឺ ត្រូវអាបត្តិទុក្កដ ។ ខ្ជូនមានជំងឺ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្ជូនមានជំងឺ ភិក្ខុសំគាល់ថា មានជំងឺ មិនត្រូវអាបត្តិឡើយ ។

[២២៧] *វារៈដែលមិនត្រូវអាបត្តិ* (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមានជំងឺ ១ ភិក្ខុអាំងភ្លើងដែលអ្នកដទៃបង្ហាត់ ១ ភិក្ខុអាំងរងើកភ្លើងដែលគ្មានអណ្តាត ១ ភិក្ខុមានហេតុ មានសភាពយ៉ាងនោះ គឺអុជប្រទីបក្តីបង្ហាត់ភ្លើង (ដើម្បីដុតបាត្រជាដើម) ក្តី បង្ហាត់ភ្លើងក្នុងរោងភ្លើងក្តី ១ ភិក្ខុមានសេចក្តីអន្តរាយ[1] ១ ភិក្ខុឆ្ងត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៦ ចប់ ។

---

១ ភិក្ខុពស់ចឹក ចោរ ឬម្រឹគសាហាវបៀតបៀនជាដើម ហៅថា មានសេចក្តីអន្តរាយ ។

សត្តមសិក្ខាបទំ

[២២៨] តេន សមយេន ពុទ្ធោ ភគវា រាជគហេ
វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ
បន សមយេន ភិក្ខូ តចោនេ ឆ្លាយន្តិ ។ អថខោ
រាជា មាគធោ សេនិយោ ពិម្ពិសារោ សីសំ ឆ្លា-
យិស្សាមីតិ តចោនំ ឥត្វា យាវ អយ្យា ឆ្លាយន្តីតិ
ឯកមន្តំ បដិមានេសិ ។ ភិក្ខូ យាវ សមន្ធការា
ឆ្លាយឹសុ ។ អថខោ រាជា មាគធោ សេនិយោ
ពិម្ពិសារោ រិការាលេ សីសំ ឆ្លាយិត្វា ឧតរត្ថាវ
ថក្ខិតេ ពហិនគរេ រសិត្វា ការាលស្សេវ អសម្ភិន្នេន
រិលេបនេន យេន ភគវា តេនុបសង្ក្រមិ ឧបសង្ក្រ-
មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នំ ខោ រាជានំ មាគធំ សេនិយំ ពិម្ពិ-
សារំ ភគវា ឯតទវោច ភិស្ស ត្វំ មហារាជ ការាលស្សេវ
អាតតោ អសម្ភិន្នេន រិលេបនេនាតិ ។ អថខោ រាជា

សិក្ខាបទទី ៧

[២២៨] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកភិក្ខុនាំគ្នាទៅស្រង់ទឹកឯកំពង់ទឹកឈ្មោះតបោទ ។ គ្រានោះ ព្រះបាទពិម្ពិសារ-សេនិយរាជ ជាឥស្សរៈក្នុងដែនមគធ: ទ្រង់យាងទៅកាន់កំពង់ទឹកឈ្មោះតបោទ ដោយតាំងព្រះហ្ឫទ័យថា នឹងស្រង់ជម្រះព្រះសិរ្ស ហើយក៏ទ្រង់ប្រថាប់ចាំ ក្នុងទីដ៏សមគួរ ដោយតាំងព្រះហ្ឫទ័យថា ចាំលោកម្ចាស់ទាំងឡាយស្រង់ទឹករួចសិន ។ ភិក្ខុទាំងឡាយ ក៏ស្រង់ទឹកទាល់តែយប់ងងឹត ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធ: ស្រង់ជម្រះព្រះសិរ្សក្នុងវេលាវិកាល ពួកជនបិទទ្វារនគរ (ហ្លួស) ទៅ ស្តេចក៏ឋិតនៅខាងក្រៅនគរ លុះដល់ពេលព្រឹកឡើង ស្តេចមានគ្រឿងលាបព្រះអង្គមិនទាន់បានសំអាត ហើយទ្រង់ព្រះដំណើរទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈ: ក្នុងដែនមគធ: គង់ក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រមហារាជ ហេតុអ្វី បានជាព្រះអង្គមានគ្រឿងលាបមិនទាន់បានសំអាត ហើយស្តេចមកក្នុងវេលាព្រឹក (យ៉ាងនេះ) ។ គ្រានោះ ព្រះបាទ

មាតលោ សេនិយោ ពិម្ពិសារោ ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា រាជានំ មាគណ្ឌំ សេនិយំ ពិម្ពិសារំ ធម្មិយា កថាយ សន្ទស្សេសិ សមាទ-បេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា មាគណ្ឌោ សេនិយោ ពិម្ពិសារោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ ជិណាណេ ឯតស្មឹ បការណេ ភិក្ខុសង្ឆំ សន្និចាតាបេត្វា ភិក្ខូ បដិបុច្ឆិ សចំ កិរ ភិក្ខវេ ភិក្ខូ រាជានំបិ បស្សិត្វា ន មត្តំ ជានិត្វា ឆ្លាយន្តីតិ ។ សចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ឆកំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា រាជានំបិ បស្សិត្វា ន មត្តំ ជានិត្វា ឆ្លាយិស្សន្តិ ឆេតំ ភិក្ខវេ អប្ប្ សន្ថានំ រ បសាទាយ បសន្ថានំ រ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន

ពិម្ពិសារសេនិយរាជ ជាតស្សរ:ក្នុងដែនមគធ:ក្រាបទូលសេចក្តីនុ៎ះ ចំពោះ ព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះបាទ ពិម្ពិសារសេនិយរាជ ជាតស្សរ:ក្នុងដែលមគធ: ឲ្យយល់ច្បាស់ ឲ្យកាន់យក ព្រម ឲ្យអាចហ៊ាន ឲ្យរីករាយក្នុងពេលនោះ ដោយធម្មីកថា ។ លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាតស្សរ:ក្នុងដែនមគធ: លុះព្រះដ៏មានព្រះ ភាគទ្រង់ពន្យល់ ឲ្យយល់ច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីក-រាយ ដោយធម្មីកថាហើយ ទ្រង់ក្រោកពីអាសន: ថ្វាយបង្គំព្រះដ៏មាន ព្រះភាគ ធ្វើបទក្សិណាចៀសចេញទៅ ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឆហើយទ្រង់ត្រាស់សួរបញ្ជាក់ ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុបានឃើញស្តេចហើយ ផ្ងួតទឹកមិនដឹងប្រមាណកាល ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់ មេត្តាជ្រាស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ បានឃើញស្តេចហើយ មិនគួរនឹងផ្ងួតទឹកមិនដឹងប្រមាណកាលសោះ ម្នាលភិក្ខុទាំងឡាយ អំពើ នេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជន ដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ

ភិក្ខុ ឱរេនឆ្ឆមាសំ[1] ឆ្លាយេយ្យ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២២៩] តេន ខោ បន សមយេន ភិក្ខូ ឧណ្ហ-សមយេ បរិឬាហសមយេ ការ្ការ្ចាយន្តា ន ឆ្លាយន្តិ សេនតតេន ការ្ត្តេន សយន្តិ ។ ចីវរំបិ សេនាសនំបិ ជុស្ឬតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧណ្ហសមយេ បរិឬាហសមយេ ឱរេនឆ្ឆមាសំ ឆ្លាយិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេ-យ្យាថ យោ បន ភិក្ខុ ឱរេនឆ្ឆមាសំ ឆ្លាយេយ្យ អញ្ញត្រ សមយា ចាចិត្តិយំ ។ ការ្ត្តាយំ សមយោ ឥិយឆ្ឆ-មាសោ សេសោ ការ្ត្តិកាន្តិ រស្ឬានស្ឬ បឋមោ-មាសោ ឥចេ្ចតេ អឆ្ឆតេយ្យមាសា ឧណ្ហសមយោ បរិឬាហសមយោ អយំ ការ្ត្ត សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

---

1 ឱរេនទ្ធមាសន្តិបិ បាឬោ ។

មិនទាន់ដល់កំណត់កន្ទះខែហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

[២២៩] សម័យនោះឯង ភិក្ខុទាំងឡាយសង្ស័យ ក្នុងសម័យក្តៅ ក្នុងសម័យស្ពុះស្ពាប់ ក៏មិនហ៊ានងូតទឹកឡើយ មានខ្ជូនប្រឡាក់ដោយញើសក្អែលហើយក៏ចេះតែសិងទៅ ។ ចីវរក្តី សេនាសនៈក្តី ក៏ប្រឡាក់ប្រឡូស (ដោយហេតុនោះ) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យក្តៅ សម័យស្ពុះស្ពាប់ ទុកជាមិនទាន់ដល់កន្ទះខែ តថាគតអនុ-ញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្ទះខែហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្ទះដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា ២ ខែកន្ទះ ហៅថា សម័យក្តៅ[១] សម័យស្ពុះស្ពាប់[២] នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

១-២ មួយខែកន្ទះខាងចុងគិម្ហរដូវ គឺតាំងពី ១ កើតខែជេស្ឋទៅដល់ ១៥ កើតខែអាសាឡ្ហ នេះជាខេត្តរបស់សម័យក្តៅ ។ ឯមួយខែខាងដើមនៃវស្សានរដូវ គឺតាំងពី ១ រោចខែអាសាឡ្ហទៅដល់ ១៥ កើតខែស្រាពណ៌ នេះជាខេត្តរបស់សម័យស្ពុះស្ពាប់ ។

បាចិត្តិយកណ្ឌោ សុរាបានវគ្គស្ស សត្តមសិក្ខាបទស្ស អនុប្បញ្ញត្តិ

[២៣០] តេន ខោ បន សមយេន ភិក្ខូ កិលាតា ហោន្តិ ។ កិលានបុច្ឆកា ភិក្ខូ កិលានេ ភិក្ខូ ឯតទវោចុំ កច្ចាវុសោ ខមនីយំ កច្ចិ យាបនីយន្តិ ។ បុព្វេ មយំ អាវុសោ ឱរេនឌ្ឍមាសំ ញ្ហាយាម តេន ណោ ផាសុ ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ ភុញ្ជិត្វាយន្តា ន ញ្ហាយាម តេន ណោ ន ផាសុ ហោតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុ-ជានামិ ភិក្ខវេ កិលានេន ភិក្ខុនា ឱរេនឌ្ឍមាសំ ញ្ហាយិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ-សេយ្យាថ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ ញ្ហាយេយ្យ អញ្ញត្រ សមយា ចាចិត្តិយំ ។ តត្ថាយំ សមយោ ជិយណ្ណោ មាសោ សេសោ ហិម្ហានន្តិ រស្ជានស្ជ បឋមោ មាសោ ឥចេ្ចតេ អឌ្ឍតេយ្យមាសា ឧណ្ហាសមយោ

[២៣០] *សម័យនោះឯង ភិក្ខុមានជំងឺជាច្រើនអង្គ ។ ឯពួកភិក្ខុជាអ្នកសួរជំងឺបាននិយាយពាក្យនេះនឹងភិក្ខុដែលមានជំងឺថា ម្នាលអាវុសោ អ្នកទាំងឡាយលួមអត់ធន់បានឬទេ លួមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុមានជំងឺប្រាប់ថា ម្នាលអាវុសោ ពីដើមយើងទាំងឡាយមិនទាន់ដល់កំណត់កន្ទុះខែក៏តែងតែងូតទឹក ព្រោះហេតុនោះ ទើបពួកយើងមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហេតុនេះ យើងទាំងឡាយមានសេចក្តីសង្ស័យមិនហ៊ានងូតទឹកឡើយ បានជាយើងមិនបានសេចក្តីសប្បាយដោយហេតុនោះឯង ។ ទើបភិក្ខុទាំងឡាយនាំសេចក្តីនុ៎ះ ក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជំងឺ ទុកជាមិនទាន់ដល់កំណត់កន្ទុះខែ តថាគតអនុញ្ញាតឲ្យងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្ទុះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្ទុះដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា ២ ខែកន្ទុះ ហៅថា សម័យក្តៅ*

បរិឌ្ឍាហសមយោ កិលានសមយោ អយំ តត្ត សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២៣១] តេន ខោ បន សមយេន ភិក្ខូ ជរាកម្មំ ភត្វា ភុក្ខ្ចុ ចាយន្តា ន ឆ្ងាយន្តិ សេនកតេន ភត្តេន សយន្តិ ។ ចីវរំបិ សេនាសនំបិ ឧស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភត្តសមយេ ឱរេនឌ្ឍមាសំ ឆ្ងាយិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ ឆ្ងាយេយ្យ អញ្ញត្រ សមយា ចាចិត្តិយំ ។ តត្ថាយំ សមយោ ឧិយន្តោ មាសោ សេសោ កិញ្ចាបិ ទ្ធានន្តិ ។ ជ្ជ ។ ឧបមោ មាសោ ឥចេ តេ អឌ្ឍតេយ្យមាសា ឧណ្ហាសមយោ បរិឌ្ឍាហសមយោ កិលានសមយោ ភត្តសមយោ អយំ តត្ត សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

សម័យស្ទុះស្ទាប់ សម័យកិក្ខុមានជំងឺ នេះហៅថា សម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្ត ដល់កិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

[២៣១] សម័យនោះឯង កិក្ខុទាំងឡាយ ធ្វើនវកម្មហើយមានសេចក្តីរង្គៀស (ខ្ជាចក្រែងត្រូវទោស) មិនហ៊ានផ្ងូតទឹកឡើយ ហើយក៏សិងទាំងខ្ជូនប្រឡាក់ ដោយញើសក្អែល ។ ចីវរក្តី សេនាសនៈក្តីក៏សៅហ្មងទៅ ។ កិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកិក្ខុទាំងឡាយ ក្នុងសម័យធ្វើការ-ងារ ទោះមិនទាន់ដល់កំណត់ក១ខែ តថាគតអនុញ្ញាតឲ្យកិក្ខុផ្ងូតទឹកបាន ម្នាលកិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កិក្ខុណាមួយ មិនទាន់ដល់កំណត់ក១ខែ ហើយផ្ងូតទឹកត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខា-បទនោះ គឺមួយខែក១ដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះត្រូវជាពីរខែក១ ហៅថា សម័យក្តៅ សម័យស្ទុះស្ទាប់ សម័យកិក្ខុមានជំងឺ សម័យធ្វើការងារ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្ត ដល់ពួកកិក្ខុយ៉ាងនេះហើយ ។

បាចិត្តិយកណ្ឌ សុរាបានវគ្គស្ស សត្តមសិក្ខាបទស្ស អនុប្បញ្ញត្តិ

[២៣២] តេន ខោ បន សមយេន ភិក្ខូ អជ្ឌាន-មត្តំ តន្ធា ការ្ក្ខុចាយន្ត្ត ន ជ្ជាយន្តិ សេនតតេន តត្ថេន សយន្តិ ។ ចីវរំបិ សេនាសនំបិ ឧស្ស្ជតិ ។ ភគ្ត្ថតោ ឯតមត្ថំ អារ្ភេ ចេ សុ ។ អនុជានាមិ ភិក្ខ្ត្ថ អជ្ឌានតមនសមយេ ឧ្ត្ថ ឆ្ជ្ជ ម ាសំ ជ្ជ ាយ ិ ត ុ ំ ឯ ្ត ្ជ ។ ។ ។

[២៣២] សម័យនោះឯង ភិក្ខុទាំងឡាយ ដើរផ្ទូរធ្វាយ មានសេចក្តីរង្កៀស (ខ្ជាចក្រែងត្រូវទោស) ក៏មិនហ៊ានងូតទឹក ហើយសិងទាំងខ្ជូនដែលសៅហ្មងដោយញើសក្អែល ។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យដើរផ្ទូរធ្វាយ ទោះមិនទាន់ដល់កំណត់កន្ទុះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្ទុះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្ទុះដ៏សេស (ខាងចុង) នៃគិម្ហរដូវ និងមួយខែខាងដើមនៃវស្សានៈ-រដូវ រួមខែទាំងនេះត្រូវជាពីរខែកន្ទុះ ហៅថា សម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជំងឺ សម័យធ្វើការងារ សម័យដើរផ្ទូរធ្វាយ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្ត ដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

[២៣៣] សម័យនោះឯង ភិក្ខុជាច្រើនរូប ធ្វើចីវរកម្មក្នុងទីវាលត្រូវខ្យល់បក់ដោយទាំងធូលីមក ទាំងភ្ជៀងក៏ធ្លាក់ចុះមកត្រូវបន្តិច ៗ ផង ។

ភិក្ខូ ការ្ក្ចុ ចាយ ន ន ្ចាយ ្ចិ ការ ្ចិ ្ចេ ន ការ ្ចេ ន
ការ ្ចិ ។ ចីវ ០ ០ ០

ភិក្ខុទាំងឡាយមានសេចក្តីរង្កៀស (ខ្វាចក្រែងត្រូវទោស) ក៏មិនហ៊ានងូតទឹក សិងទាំងខ្ជូនប្រឡាក់ប្រឡូស (នោះឯង) ។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យខ្យល់និងភ្លៀង ទុកជាមិនទាន់ដល់កំណត់កន្ទុះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្ទុះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ រៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្ទុះដ៏សេស (ខាងចុង) នៃគិម្ហរដូវ និងមួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះត្រូវជាពីរខែកន្ទុះ ហៅថាសម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជំងឺ[១] សម័យធ្វើការងារ[២] សម័យដើរផ្លូវឆ្ងាយ[៣] សម័យខ្យល់និងភ្លៀង[៤] នេះជាសម័យក្នុងសិក្ខាបទនោះ ។

[២៣៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិក ។ ពាក្យថា មិនទាន់ដល់កំណត់កន្ទុះខែ គឺខ្ទុះកន្ទុះខែ ។

១-២-៣-៤ សម័យទាំង ៤ យ៉ាងនេះមិនចំពោះខែណា ថ្ងៃណាទេ ដែលមានកំណត់ពីរខែកន្លះនោះ តែសម័យពីរយ៉ាងខាងដើម ។

ឆ្លាយេយ្យាតិ ចុណ្ណេន វ មត្តិកាយ វ ឆ្លាយតិ
បយោគេ ទុក្កដំ ។ ឆ្លានបរិយោសានេ អាបត្តិ ចាចិត្តិ-
យស្ស ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។
ឧណ្ហសមយោ នាម ឝិយន្ធ្លោ មាសោ សេសោ ឝិម្ហា-
ឝំ ។ បរិឬហាសមយោ នាម វស្សានស្ស ឋបមោ
មាសោ ។ ឥទ្ធេ តេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ
បរិឬហាសមយោតិ ឆ្លាយិតព្ពំ ។ ឝិលានសមយោ
នាម យស្ស ១ នា ឆ្លានេន ន ផាសុ ហោតិ ។ ឝិលាន-
សមយោតិ ឆ្លាយិតព្ពំ ។ ឝ្ចមសមយោ នាម អន្ត-
មសោ ១ ១ ១ សម្ផ្ដ ហោតិ ។ ឝ្ចមសមយោតិ
ឆ្លាយិតព្ពំ ។ អជ្ជានឝ្ចមនសមយោ នាម អឌ្ឍយោជនំ
ឝ្ចមិ ១ ១ ១

ពាក្យថា ងូតទឹក គឺភិក្ខុកំពុងងូតទឹកជុសដោយផង់លំអិតក្តី ដោយដីស្អិតក្តី ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគ ។ លុះងូតរួចស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា រៀរលែងតែមានសម័យ គឺលើកលែងចំពោះសម័យដែលគួរ ។ មួយខែកន្ទុះដ៏សេស (ខាងចុង) នៃគិម្ហរដូវ ហៅថា សម័យក្តៅ ។ មួយខែខាងដើមនៃវស្សានរដូវ ហៅថា សម័យស្ពុះ-ស្ពាប់ ។ រួមខែទាំងនេះ ត្រូវជាពីរខែកន្ទុះ ហៅថា សម័យក្តៅ សម័យស្ពុះស្ពាប់ ភិក្ខុដឹងដូច្នេះហើយ គប្បីងូតទឹកចុះ ។ ភិក្ខុណារៀរចាកការងូតទឹកមានសេចក្តីមិនសប្បាយ ភិក្ខុនោះហៅថា មានសម័យមានជំងឺ ឬថា មានសម័យឈឺក្តាត់ ។ ភិក្ខុដឹងខ្លួនថា មានសម័យឈឺក្តាត់ហើយ គប្បីងូតទឹកចុះ ។ ការងារដោយហោចទៅ សូម្បីតែបោសច្រាស សំអាតបរិវេណ ក៏ហៅថា សម័យធ្វើការងារ ។ ភិក្ខុដឹងខ្លួនថា សម័យធ្វើការ-ងារហើយ គប្បីងូតទឹកចុះ ។ ដែលហៅថា សម័យដើរផ្លូវឆ្ងាយ គឺភិក្ខុគិតថា អញនឹងដើរផ្លូវប្រមាណកន្ទុះយោជន៍ ហើយគប្បីងូតទឹកបាន ភិក្ខុអ្នកដំណើរគប្បីងូតទឹកបាន ភិក្ខុដើរទៅហើយគប្បីងូតទឹកបាន ។ ដែលហៅថា សម័យខ្យល់និងភ្លៀង គឺពួកភិក្ខុត្រូវខ្យល់ប្រកបដោយធូលីហើយ មានតំណក់ទឹកពីរតំណក់ក្តី បីតំណក់ក្តី ធ្លាក់ត្រូវកាយ ។ ភិក្ខុដឹងថា មានសម័យខ្យល់និងភ្លៀង គប្បីងូតទឹកបាន ។

[២៣៥] ឩនកឞ្ឌមាសេ ឩនកសញ្ញី អញ្ញត្រ សមយា ជ្ឈាយតិ អាបត្តិ ចាចិត្តិយស្ស ។ ឩនកឞ្ឌ-មាសេ វេមតិកោ អញ្ញត្រ សមយា ជ្ឈាយតិ អាបត្តិ ចាចិត្តិយស្ស ។ ឩនកឞ្ឌមាសេ អតិរេកសញ្ញី អញ្ញត្រ សមយា ជ្ឈាយតិ អាបត្តិ ចាចិត្តិយស្ស ។ អតិរេកឞ្ឌមាសេ ឩនកសញ្ញី អាបត្តិ ទុក្កដស្ស ។ អតិរេកឞ្ឌមាសេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អតិរេកឞ្ឌមាសេ អតិរេកសញ្ញី អនាបត្តិ ។

[២៣៦] អនាបត្តិ សមយេ អឞ្ឌមាសំ ជ្ឈាយតិ អតិរេកឞ្ឌមាសំ ជ្ឈាយតិ[1] ចារំ កច្ឆន្តោ ជ្ឈាយតិ សព្ឋប្ឋចូឡិមេសុ ជនបទេសុ អាបជ្ជាសុ ឧម្មត្តកស្ស អាទិកម្មិកស្ឋាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

---

១ ឥតោ បរំ កត្ថចិ ឋោត្ថកេ សតិ ករណីយេ ឧទកំ ឱតរិត្វា ន្ហាយតិ ចារំ គច្ឆន្តោ វា អាគច្ឆន្តោ វា ន្ហាយតីតិ ឯវំ ចាហេ អត្ថិ ។

[២៣៥] មិនទាន់ដល់កន្ទុះខ្ចៃ ភិក្ខុក៏សំគាល់ថា មិនទាន់ដល់កន្ទុះខ្ចៃ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ មិនទាន់ដល់កន្ទុះខ្ចៃ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ មិនទាន់ដល់កន្ទុះខ្ចៃ ភិក្ខុសំគាល់ថា លើសហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ រៀងលែងតែមានសម័យ ។ កាលលើសជាងកន្ទុះខ្ចៃ ភិក្ខុសំគាល់ថា ខ្ទុះវិញ ត្រូវអាបត្តិទុក្កដ ។ កាលលើសជាងកន្ទុះខ្ចៃ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលលើសជាងកន្ទុះខ្ចៃ ភិក្ខុសំគាល់ថា លើសមែន មិនត្រូវអាបត្តិឡើយ ។

[២៣៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមានសម័យ ១ កន្ទុះខ្ចៃភិក្ខុងូតទឹកម្តង ១ លើសជាងកន្ទុះខ្ចៃភិក្ខុងូតទឹក ១ ភិក្ខុធ្វង់ទៅត្រើយម្ខាងហើយងូត ១ ភិក្ខុនៅក្នុងជនបទចុងដែនបង្ហ្ស ១ ភិក្ខុមានសេចក្តីអន្តរាយ[1] ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៧ ចប់ ។

---

១ គឺភិក្ខុមានសត្វឃ្មុំជាដើមដេញទិច ហើយមុជទៅក្នុងទឹក ដើម្បីឲ្យផុតពីសេចក្តីអន្តរាយនោះ ហៅថា មានសេចក្តីអន្តរាយ ក្នុងសិក្ខាបទនេះ ។

អដ្ឋមសិក្ខាបទំ

[២៣៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ច បរិញ្ញជកា ច សាកេតា សាវត្ថឺ អជ្ឌានមក្តប្បដិបន្នា ហោន្តិ ។ អន្តរាមគ្តេ ចោរា ជិក្ខូមិត្ថា តេ អច្ជិន្ទឺសុ ។ សាវត្ថិយា រាជភជា ជិក្ខូមិត្ថា តេ ចោរេ សភណ្ណេ តហេត្ថា ភិក្ខូនំ សន្តិកេ ទូតំ ចាហេសុំ អាតច្ជន្ត្ តច្ជ្ជ្ជ្ជ សកំ សកំ ចីវរំ សញ្ជានិត្ថា តណ្ហាន្ត្ជ្ជ ។ ភិក្ខូ ចីវរំ ជ សញ្ជានន្តិ ។ មនុស្ស ឧជ្ជ្ជ្ជ្ជ ទីយន្តិ ទ្ជ្ជ្ជ ចាចេន្តិ ភិកំ ហ ជ្ជ ភ ច្ជ្ជ្ជ អត្ត្ជ្ជ អត្ត្ជ្ជ ចីវរំ ជ សញ្ជានិស្ស ន្ត្ជ្ជ ។ អស្ស្ជ្ជ ខោ ភិក្ខូ ត្ជ្ជ មនុស្ជ្ជ ឧជ្ជ្ជ ទ្ជ្ជ ទ្ជ្ជ ។ អថ ខោ ត្ជ ភិក្ខូ ភ ត ១ ១ ១

សិក្ខាបទទី ៨

[២៣៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កាលនោះឯង ពួកភិក្ខុខ្លះ ពួកបរិព្វាជកខ្លះ ជាច្រើនរូបនាំគ្នាដើរផ្ទូវឆ្ងាយ ពីក្រុងសាកេតទៅក្រុងសាវត្ថី ។ លុះដល់ពាក់កណ្តាលផ្ទូវ មានពួកចោរចេញមកប្លន់ពួកភិក្ខុនិងពួកបរិព្វាជកទាំងនោះ ។ រាជអាមាត្យទាំងឡាយនាំគ្នាចេញពីក្រុងសាវត្ថីមកចាប់ចោរទាំងនោះបានព្រមទាំងទ្រព្យរបស់ ហើយប្រើបម្រើទៅក្នុងសំណាក់ពួកភិក្ខុថា លោកម្ចាស់ទាំងឡាយចូរនិមន្តមកយកចីវររបស់ខ្លួន ។ តាមស្គាល់ចុះ ។ ភិក្ខុទាំងឡាយក៏មិនស្គាល់ចីវរ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា លោកម្ចាស់ទាំងឡាយមិនគួរនឹងមិនស្គាល់ចីវររបស់ខ្លួន ។ សោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្ទុះបង្ហាប់ហើយ ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ

ភិក្ខុសង្ឆំ សន្ធិចាតាបេត្វា ភិក្ខូនំ ឥធនុច្ឆវិកំ ឥធនុ-
លោមិកំ ឆម្មឿ ភបំ ភត្វា ភិក្ខូ អាមន្តេសិ តេនហិ
ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទស អត្ថវសេ
បដិច្ច សង្ឆសុដ្ឋុតាយ សង្ឆផាសុតាយ ។ បេ ។
សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឯវញ្ច បន ភិក្ខវេ
ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ នវ បន ភិក្ខុនា ចីវរ-
លាភេន តិណ្ណំ ពុទ្ធណ្ណការណានំ អញ្ញតរំ ពុទ្ធណ្ណ-
ការណំ អាឆាតព្ពំ ឆីលំ វា ភគ្គមំ វា ភាឍ្ឍសាមំ វា ។
អឆាឆា ចេ ភិក្ខុ តិណ្ណំ ពុទ្ធណ្ណការណានំ អញ្ញតរំ
ពុទ្ធណ្ណការណំ នវ ចីវរំ បរិភុញ្ជេយ្យ ឆាចិត្តិយន្តិ ។

[២៣៨] នវ ឆាម អភតតភប្ប៎ រុច្ចតិ ។ ចីវរំ
ឆាម ឆន្ទំ ចីវរាឆំ អញ្ញតរំ ចីវរំ ។ តិណ្ណំ ពុទ្ធណ្ណការ-
ណានំ អញ្ញតរំ ពុទ្ធណ្ណការណំ អាឆាតព្ពន្តិ អន្ត្ថមសោ
ភុសតេ្ដនបិ អាឆាតព្ពំ ។ ឆីលំ ឆាម ទ្ធ ឆីលានិ

ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឆ ហើយធ្វើធម្មីកថាដ៏ល្មម សមគួរដល់រឿងនោះ ។ ដល់ភិក្ខុទាំងឡាយ ហើយទ្រង់ត្រាស់ហៅពួកភិក្ខុ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ តថាគតនឹងបញ្ញត្ត សិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីប្រពៃដល់សង្ឆ ១ ដើម្បីសប្បាយដល់សង្ឆ ១ ។ បេ ។ ដើម្បីបិត នៅនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះព្រះវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុបានចីវរថ្មីមក ហើយ គប្បីកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង គឺពណ៌ខៀវក្តី ពណ៌ភក់ក្តី ពណ៌ខ្មៅជាំក្តី វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ បើភិក្ខុមិន កាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ណាមួយ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ ។

[២៣៨] ដែលហៅថា ថ្មី គឺចីវរដែលមិនទាន់បានធ្វើកប្ប ។ ដែល ហៅថា ចីវរ គឺបណ្ដាចីវរទាំង ៦ ចីវរណាមួយ ។ ត្រង់ពាក្យថា គប្ប៊ី កាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ណាមួយ សេចក្ដីថា ភិក្ខុត្រូវធ្វើកប្បពិន្ទុដោយកំណត់យ៉ាងតូចបំផុតត្រឹម ប៉ុនចុងស្លរ ។ ដែលហៅថា ពណ៌ខៀវ គឺវត្ថុមានពណ៌ខៀវពីរយ៉ាង

កំសនីលំ បលាសនីលំ ។ ភិក្ខូ ជាម ឋិត-
ោ រុក្ខតិ ។ ភាឧ្យសាមំ ជាម យន្ត្ថ ញ្ចិ ភាឧ្ម-
ាកំ[1] ។ អជាជ ចេ ភិក្ខុ ឥណ្ណ ជុ ពុ ណ្ណ ការ ណ ជ ំ
អ ញ្ញ ត រ ំ ជុ ពុ ណ្ណ ការ ណ ន្ត ិ អ ន្ត ម ស ោ ភ ិ ក ្ ខ ុ ន ត ្ ថ ជ ន ិ
អ ជ ា ន ិ យ ិ ត ្ ា ឥ ណ ្ ណ ជ ុ ព ុ ណ ្ ណ ការ ណ ជ ំ អ ញ ្ ញ ត រ ំ ជ ុ ព ុ ណ ្ ណ -
ការ ណ ំ ជ រ ំ ចី វ រ ំ ប រ ិ ភ ុ ញ ្ ជ ត ិ អ ា ប ត ្ ត ិ ច ា ច ិ ត ្ ត ិ យ ស ្ ស ។

[២៣៩] អ ជ ា ន ិ ន ្ ន អ ជ ា ន ិ ន ្ ន ស ញ ្ ញ ី ប រ ិ ភ ុ ញ ្ ជ ត ិ
អ ា ប ត ្ ត ិ ច ា ច ិ ត ្ ត ិ យ ស ្ ស ។ អ ជ ា ន ិ ន ្ ន ដ ោ ម ត ិ ភ ោ ប រ ិ ភ ុ ញ ្ ជ ត ិ
អ ា ប ត ្ ត ិ ច ា ច ិ ត ្ ត ិ យ ស ្ ស ។ អ ជ ា ន ិ ន ្ ន អ ា ន ិ ន ្ ន ស ញ ្ ញ ី ប រ ិ -
ភ ុ ញ ្ ជ ត ិ អ ា ប ត ្ ត ិ ច ា ច ិ ត ្ ត ិ យ ស ្ ស ។ អ ា ន ិ ន ្ ន អ ជ ា ន ិ ន ្ ន -
ស ញ ្ ញ ី អ ា ប ត ្ ត ិ ជ ុ ក ្ ក ជ ស ្ ស ។ អ ា ន ិ ន ្ ន ដ ោ ម ត ិ ភ ោ អ ា ប ត ្ ត ិ
ជ ុ ក ្ ក ជ ស ្ ស ។ អ ា ន ិ ន ្ ន អ ា ន ិ ន ្ ន ស ញ ្ ញ ី អ ជ ា ប ត ្ ត ិ ។

---

1 ឱ. ម. ភាឧ្យសាមកំ ។

បានដល់ពណ៌ខៀវដូចសម្រ៉ីទ្ធិ ១ ពណ៌ខៀវដូចស្លឹកឈើ ១ ។ ដែលហៅថា ពណ៌កក់ គឺសំដៅយកកក់ដែលនៅក្នុងទឹក ។ ដែលហៅថា ពណ៌ខ្មៅជាំ គឺវត្ថុមានពណ៌ខ្មៅណាមួយ ។ ពាក្យថា បើភិក្ខុមិនកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ សេចក្ដីថា ភិក្ខុមិនធ្វើកប្បពិន្ទុ បណ្ដាវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង ដោយវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ ដោយកំណត់ប្រមាណយ៉ាងតូចបំផុតត្រឹមប៉ុនចុងស្លូវ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ ។

[២៣៩] ចីវរដែលភិក្ខុមិនធ្វើកប្បពិន្ទុ ភិក្ខុសំគាល់ថា មិនទាន់ធ្វើកប្បពិន្ទុ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរមិនទាន់ធ្វើកប្ប-ពិន្ទុ ភិក្ខុមានសេចក្ដីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរមិនទាន់ធ្វើកប្បពិន្ទុ ភិក្ខុសំគាល់ថា ធ្វើកប្បពិន្ទុហើយ ។ ប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុសំគាល់ថា មិនទាន់បានធ្វើកប្បពិន្ទុ ត្រូវអាបត្តិទុក្កដ ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុសំគាល់ថា បានធ្វើកប្បពិន្ទុហើយ មិនត្រូវអាបត្តិឡើយ ។

[២៤០] អជាបត្តិ អាឌិយិត្វា បរិកុញ្ជតិ ឆេជ្ជ ជង្ឆោ ហោតិ ឆេជ្ជ ឆេជ្ជ ជង្ឆោ ជិណ្ណ ជង្ឆោ ហោតិ ឆេជ្ជ ឆេជ្ជ ជង្ឆោ ជិណ្ណ ជង្ឆោ ហោតិ ឆេជ្ជ ឆេជ្ជ ជង្ឆោ ជិណ្ណ ជង្ឆោ ហោតិ ឆេជ្ជ ឆេជ្ជ ជង្ឆោ ជិណ្ណ ជង្ឆោ ហោតិ ។

[២៨០] *ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុបានធ្វើកឋិនៈ ហើយប្រើប្រាស់ ១ កឋិនៈខូចខាតទៅ ១ កន្ទែងដែលធ្វើកឋិនៈគ្រាំគ្រាទៅ ១ ភិក្ខុដេរចីវរដែលមិនបានធ្វើកឋ-ិនៈភ្ជាប់ជាមួយនឹងចីវរដែលបានធ្វើកឋិនៈហើយ ១ ចីវរដែលប៉ះដោយបំណុះថ្មី ១ ចីវរដែលដាក់អនុវាតថ្មី ១ ចីវរចាស់ប្រក់ថែមថ្មី ១ ភិក្ខុឆ្ពិត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៨ ចប់ ។

នវមសិក្ខាបទំ

[២៤១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ
សក្យបុត្តោ ភាតុនោ សន្ធិវិហារិកស្ស កិក្ខុនោ សាមំ
ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជតិ ។ អថ ខោ
សោ កិក្ខុ កិក្ខូនំ ឯតមត្ថំ អារោចេសិ អយំ អាវុសោ
អាយស្មា ឧបនន្ទោ សក្យបុត្តោ មយ្ហំ សាមំ ចីវរំ
វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជតីតិ ។ យេ តេ
កិក្ខូ អប្ប៎ច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចា-
ចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ
កិក្ខុស្ស សាមំ ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជ-
ស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ កិក្ខុស្ស
សាមំ ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជសីតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ

សិក្ខាបទទី ៩

[២៧១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបនន្ទ សក្យបុត្រដ៏មានអាយុបានកៃប្ជចីវររបស់ខ្លួនដោយខ្លួនឯង រួចផ្ញើនឹងភិក្ខុជា សទ្ធិវិហារិករបស់ព្រះថេរៈជាបងប្អូន ហើយមិនបានឲ្យដកកៃប្ជចេញ ក៏ចេះតែប្រើប្រាស់ទៅ ។ ទើបភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ថា ម្នាលអាវុសោ ឧបនន្ទសក្យបុត្រដ៏មានអាយុនេះ បានកៃប្ជចីវរ របស់ខ្លួនដោយខ្លួនឯងផ្ញើនឹងខ្ញុំ ហើយមិនឲ្យដកកៃប្ជ (ជាមុន) ហើយ ចេះតែប្រើប្រាស់ទៅ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នា តិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ឧបនន្ទសក្យបុត្រដ៏មានអាយុមិនគួរនឹងកៃប្ជចីវររបស់ខ្លួនដោយខ្លួនឯង នឹងភិក្ខុផងគ្នា ហើយមិនបានឲ្យដកកៃប្ជចេញសិន ចេះតែប្រើប្រាស់ទៅសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែឧបនន្ទ ឮថា អ្នកឯងបានកៃប្ជ ចីវររបស់ខ្លួនដោយខ្លួនឯងនឹងភិក្ខុផងគ្នា ហើយមិនឲ្យដកកៃប្ជចេញសិន ចេះតែប្រើប្រាស់ទៅ ពិតមែនឬ ។ ឧបនន្ទដ៏មានអាយុក្រាបទូលថា សូម ទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា

ជាម តុំ មោយបុរិស កិក្ខុស្ស សាមំ ចីវរំ វិកប្បេត្វា អប្ប្ចុទ្ធារកំ បរិកុញ្ជិស្ស្ស្ស្ស ដេតំ មោយបុរិស អប្ប្ សន្ធានំ វ បសាជាយ បសន្ធានំ វ កិយ្យោ-ការ្ យ ។ បេ ។ ឯវញ្ចេ បន កិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ្ទ្ទ្ទ្ទ្ទ្ទ្ទ្ទ យោ បន កិក្ខុ កិក្ខុស្ស វ កិក្ខុនិយ្ យ សិក្ខ្ មានាយ វ សាមណេ ស្ស្ ្ ្

នៃមោឃបុរស អ្នកឯងមិនគួរនឹងវិកប្បចីវរបស់ខ្លួនដោយខ្លួនឯងនឹងភិក្ខុផងគ្នា ហើយប្រើប្រាស់ចីវរ ដែលមិនបានឲ្យគេដកវិកប្បចេញសិនទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបានវិកប្បចីវរដោយខ្លួនឯងចំពោះភិក្ខុផងគ្នាក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ហើយប្រើប្រាស់ចីវរដែលមិនទាន់ឲ្យគេដកវិកប្បចេញសិន ត្រូវអាបត្តិបាចិត្តិយ ។

[២៤២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ ។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុឯទៀត ។ ដែលហៅថា ភិក្ខុនី គឺភិក្ខុនីដែលបានឧបសម្បទាក្នុងសង្ឆទាំងពីរពួក ។ ដែលហៅថា សិក្ខមានា គឺស្រីដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង ៦ គ្រប់ពីរឆ្នាំហើយ ។ ដែលហៅថា សាមណេរ គឺកុលបុត្រ (ដែលបានសម្រេចបព្វជ្ជាកម្មហើយ) ទ្រទ្រង់នូវសិក្ខាបទទាំង ១០ ។ ដែលហៅថា សាម-ណេរី គឺស្រី (ដែលបានសម្រេចបព្វជ្ជាកម្មហើយ) ទ្រទ្រង់នូវសិក្ខាបទទាំង ១០ ។ ពាក្យថា ដោយខ្លួនឯង គឺវិកប្បដោយខ្លួនឯង ។ ដែលហៅថា ចីវរ គឺបណ្តាចីវរទាំង ៦ ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេច

បច្ចិមំ ។ វិកប្បនំ ជាម ទ្វេ វិកប្បនា សម្ម៉ុខាវិកប្បនា ច បរម្ម៉ុខាវិកប្បនា ច ។ សម្ម៉ុខាវិកប្បនា ជាម ឥមំ ចីវរំ តុយ្ហំ វិកប្បេមិ ឥត្ថន្នាមស្ស វាតិ ។ បរម្ម៉ុខា-វិកប្បនា ជាម ឥមំ ចីវរំ វិកប្បនត្ថាយ តុយ្ហំ ទម្មីតិ ។ តេន វត្តព្វោ ភោ តេ មិត្តោ វា សន្ធិដ្ឋោ វាតិ ។ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ចាតិ ។ តេន វត្តព្វោ អហំ តេសំ ទម្មិ តេសំ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហីតិ ។ អប្បច្ចុទ្ធារកំ ជាម ឥស្ស វា អនិដ្ឋំ ឥស្ស វា អវិស្សាសេន្តោ បរិភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។

[២៤៣] អប្បច្ចុទ្ធារកេ អប្បច្ចុទ្ធារកសញ្ញី បរិភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ អប្បច្ចុទ្ធារកេ វេមតិកោ បរិភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ អប្បច្ចុទ្ធារកេ

កិច្ចវិកប្បបាន ។ ដែលហៅថា វិកប្ប គឺវិកប្បមានពីរយ៉ាង បានដល់វិកប្បចំពោះមុខ ១ វិកប្បកំបាំងមុខ ១ ។ ដែលហៅថា វិកប្ប ចំពោះមុខ គឺភិក្ខុកំណត់ដោយពាក្យថា ខ្ញុំវិកប្បចីវរនេះចំពោះលោក ឬចំពោះភិក្ខុឈ្មោះនេះ ។ ដែលហៅថា វិកប្បកំបាំងមុខ គឺភិក្ខុកំណត់ដោយពាក្យថា ខ្ញុំឲ្យចីវរនេះដល់លោក ដើម្បីវិកប្បទុក ។ ភិក្ខុនោះ ត្រូវសួរភិក្ខុជាម្ចាស់ចីវរថា លោកណាជាមិត្ររបស់លោក ឬលោកស្គាល់លោកណា ។ ភិក្ខុម្ចាស់ចីវរត្រូវប្រាប់ថា ភិក្ខុឈ្មោះនេះផង ភិក្ខុឈ្មោះនេះផង ។ ភិក្ខុអ្នកទទួលវិកប្បនោះ ត្រូវនិយាយនឹងភិក្ខុម្ចាស់ចីវរថា ខ្ញុំឲ្យចីវរដល់ភិក្ខុទាំងនោះ លោកចូរប្រើប្រាស់ក្តី ឬលោកចូរលះបង់ក្តី លោកចូរធ្វើតាមសមគួរដល់បច្ច័យក្តី នូវចីវររបស់ភិក្ខុទាំងនោះចុះ ។ ដែលហៅថា មិនបានឲ្យគេដកវិកប្ប គឺភិក្ខុជាម្ចាស់ចីវរប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះមិនបានប្រគល់ឲ្យក្តី មិនស្និទ្ធស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះ ហើយប្រើប្រាស់ក្តី ត្រូវអាបត្តិបាចិត្តិយ ។

[២៤៣] ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថា មិនបានឲ្យគេដកវិកប្ប ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុមានសេចក្តីសង្ស័យ ហើយប្រើប្រាស់ ត្រូវអា-បត្តិបាចិត្តិយ ។ ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថា

បចុន្ធារកសញ្ញី បរិកុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ អធិដ្ឋេតិ វា វិស្សជ្ជេតិ វា អាបត្តិ ទុក្កដស្ស ។ បចុន្ធារកេ អប្ប‌ចុន្ធារកសញ្ញី អាបត្តិ ទុក្កដស្ស ។ បចុន្ធារកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បចុន្ធារកេ បចុន្ធារកសញ្ញី អនាបត្តិ ។

[២៤៤] អនាបត្តិ សោ វា ឧតិ តស្ស វា វិស្ស‌ាសេន្តោ បរិកុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្ស‌ាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

បានឲ្យគេដកវិកប្ប ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុអធិដ្ឋានក្តី លះបង់ចោលក្តី ត្រូវអាបត្តិទុក្កដ ។ ចីវរដែលបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថា មិនបានឲ្យគេដកវិកប្បវិញ ត្រូវអាបត្តិទុក្កដ ។ ចីវរដែលបានឲ្យគេដកវិកប្បហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរដែលបានឲ្យគេដកវិកប្បហើយ ភិក្ខុសំគាល់ថា បានឲ្យគេដកវិកប្បហើយ មិនត្រូវអាបត្តិឡើយ ។

[២៤៤] *ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះឲ្យក្តី ភិក្ខុម្ចាស់របស់ស្និទ្ធ-ស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[២៤៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ
បន សមយេន សត្តរសវត្ថុយា ភិក្ខូ អសន្និហិតបរិក្ខា-
រា ហោន្តិ ។ ឆព្ពគ្គិយា ភិក្ខូ សត្តរសវត្ថុយានំ ភិក្ខូនំ
បត្តំបិ ចីវរំបិ អបនិធេន្តិ ។ សត្តរសវត្ថុយា ភិក្ខូ
ឆព្ពគ្គិយេ ភិក្ខូ ឯតទវោចុំ ឧបាសិកា អម្ហាកំ បត្តំបិ
ចីវរំបីតិ ។ ឆព្ពគ្គិយា ភិក្ខូ ហសន្តិ ។ តេ ភេទន្តិ ។
ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ ភេទថាតិ ។
ឥមេ អាវុសោ ឆព្ពគ្គិយា ភិក្ខូ អម្ហាកំ បត្តំបិ ចីវរំបិ
អបនិធេន្តីតិ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ឆព្ពគ្គិយា
ភិក្ខូ ភិក្ខូនំ បត្តំបិ ចីវរំបិ អបនិធេស្សន្តីតិ ។ បេ ។
សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខូនំ បត្តំបិ ចីវរំបិ អបនិធេ-
ថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ
ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខូនំ បត្តំបិ ចីវរំបិ

សិក្ខាបទទី ១០

[២៤៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងអារាមជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុមិនបានទុកគ្រឿងបរិក្ខារដោយស្រួល ។ ពួកឆព្វគ្គិយភិក្ខុលាក់ទុកបាត្រខ្ទះ ចីវរខ្ទះ របស់ពួកសត្តរសវគ្គិយភិក្ខុ ។ ពួកសត្តរសវគ្គិយភិក្ខុក៏និយាយពាក្យនេះនឹងពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោ អ្នកទាំងឡាយចូរឲ្យបាត្រខ្ទះ ចីវរខ្ទះដល់យើង ។ ពួកឆព្វគ្គិយភិក្ខុក៏នាំគ្នាសើច ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះក៏យំ ។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វី បានជាអ្នកទាំងឡាយយំ ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះលាក់ទុកនូវបាត្រខ្ទះ ចីវរខ្ទះ របស់យើង ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀលបន្ទុះបង្ហាប់ថា មិនសម្បើបើពួកឆព្វគ្គិយភិក្ខុលាក់ទុកនូវបាត្រខ្ទះ ចីវរខ្ទះ របស់ភិក្ខុផងគ្នាសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ ឮថា អ្នកទាំងឡាយលាក់ទុកនូវបាត្រខ្ទះ ចីវរខ្ទះ របស់ភិក្ខុផងគ្នាពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ

អបនិធេស្សថ ឆេតំ មោឃបុរិសា អប្ប្ សន្ថានំ វ បសាធាយ បសន្ថានំ វ កិយ្យោ ការាយ ។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ សេយ្យាថ យោ បន ភិក្ខុ ភិក្ខុ ស្ស្ ១ បត្តំ វ ចីវរំ វ និសីទនំ វ សូចិ ឃរំ វ ការ យ ពន្ធនំ វ អ ធិ ធេ ១ យ្ យ ១ ១ ១

ខោ ជាម ត្វំ មោឃបុរិស មយា ឯវំ ធម្មំ ទេសិតំ
អាជានាសិ ជនុ មយា មោឃបុរិស អនេកបរិយាយេន
អន្តរាយិកា ធម្មា វុត្តា អលញ្ច បន តេ បដិសេវតោ
អន្តរាយាយ អប្ប្ស្ សាធ្ យ តាមា វុត្តា មយា ពហុ-
ជុក្ខា ពហូ ចាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិ ការ ្ ្ -
ណ្ឍ ្ ្ ្

នោះមិនអាចធ្វើនូវសេចក្ដីអន្ដរាយដល់អ្នកសេព ដោយប្រការណា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែង ហើយ ដោយប្រការដូច្នោះឯង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោយ-បុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ មកពីអ្នកណា នៃមោយបុរស ធម៌ធ្វើសេចក្ដីអន្ដរាយ តថាគតសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះសោតអាចធ្វើសេចក្ដីអន្ដរាយ ដល់បុគ្គលអ្នកសេពបានពិតមែន តថាគតសំដែងហើយថា កាមទាំងឡាយ មានសេចក្ដីរីករាយតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន តថាគតសំដែងហើយថា កាម ទាំងឡាយមានឧបមាដោយរាងធ្ពឹង ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។ បេ ។ តថាគតសំដែងហើយ ថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើពីស្មៅ ។ បេ ។ តថា-គតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្ដារដើកភ្លើង ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នក យល់សប្ដិ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមា ដោយរបស់ដែលខ្ចីគេ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយ មានឧបមាដោយផ្ទៃឈើ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយ

ការាមា រុត្តា មយា ។ បេ ។ សត្តិសូលូបមា ការាមា
រុត្តា មយា ។ បេ ។ សប្ផសិរូបមា ការាមា រុត្តា មយា
ពហុទុក្ខា ពហូបាយាសា អានិសង្ស ឯត្ថ ភិយ្យោ អថ
ច បន ត្វំ មោឃបុរិស អត្តនា ទុក្ខហិតេន ជិជ្ជិតេន
អម្ហេ ចេវ អញ្ញាចិក្ខសិ អត្តានញ្ច ខនសិ ពហុញ្ច
អបុញ្ញ បសវសិ តញ្ហि តេ មោឃបុរិស ភវិស្សតិ
ទីឃរត្តំ អហិតាយ ទុក្ខាយ ដេតំ មោឃបុរិស
អប្ផសន្ថានំ ឯ បសាទាយ បសន្ថានំ ឯ ភិយ្យោ-
ភាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧद्दិសេយ្យាថ យោ បន ភិក្ខុ ឯវំ វទេយ្យ តថាហំ
ភគវតា ធម្មំ ទេសិតំ អាជានामि យថា យេមេ
អន្តរាយិកា ធម្មា រុត្តា ភគវតា តេ បដិសេវតោ
នាលំ អន្តរាយាយាតិ ។ សោ ភិក្ខុ ភិក្ខូហि ឯវមស្ស
វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ

មានឧបមាដោយកាំបិតនិងជ្រញ់ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។ បេ ។ តថាគត សំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខ ច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយ នោះមានច្រើន នៃមោឃបុរស កាលបើហេតុមានទំនងយ៉ាងនេះ អ្នក ឯងហៅថា ពោលបង្ការ៉ាប់យើងផង ដីកគាស់ខ្ជួនឯងផង បានបាបជា ច្រើនផង ដោយទិដ្ឋិដែលខ្ជួនប្រកាន់ខុស នៃមោឃបុរស ព្រោះថា ទិដ្ឋិរបស់អ្នកឯងនោះ នឹងប្រព្រឹត្តទៅដើម្បីទោសមិនមែនជាប្រយោជន៍ និងទុក្ខ អស់កាលជាអង្វែង នៃមោឃបុរស អំពើនេះមិនមែននាំឲ្យ ជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យ រឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយពោលយ៉ាង នេះថា ធម៌ទាំងឡាយណាតែងធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មាន ព្រះភាគសំដែងហើយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ដែល ព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការយ៉ាងនោះ ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះថា លោកដ៏មានអាយុ លោកចូរ

អញ្ញាចិក្ខិ ន ហិ សាធុ ភគវតោ អញ្ញក្ខានំ ន ហិ ភគវា ឯវំ វទেយ្យ អនেকបរិយាយেন អាវុសো អន្ត-រាយិকা ধম্মা বুত্তা ভগবতা অলং খো পন তে পটিসে-বতো অন্তরায়াযাতি ។ ঔবং[1] সো ভিক্খু ভিক্খূহি বুচ্চ-মানো তথেব পত্তক্ষ্মোযেব সো ভিক্খু ভিক্খূহি যাবততিযং সমনুভাসিতব্বো তস্স পটিনিস্সক্কায ។ যাবততি-যঞ্চে সমনুভাসিযমানো তং পটিনিস্সজ্জেযেব তথেতং কুসলং নো চে পটিনিস্সজ্জেযেব থাচিত্তিযন্তি ។

[២៨១] যো পনাতি যো যাদিসো ។ পে ។ ভিক্খূতি ។ পে ។ អយং ইমস্មিং អত্ថে អধিপ্ផ្ផেতো ভিক្ខূতি ។ ঔবং বদেযযাতি তথাহং ভগবতা ধম্মং দেসিতং আজানামি যথা যেমে অন্তরাযিকা ধম্মা বুত্তা ভগবতা তে পটিসেবতো নালং অন্তরাযাযাতি ។

---

1 ঔ. ম. ঔবঞ্চ পন ។

កុំពោលយ៉ាងនេះឡើយ កុំពោលបង្ការ៉ាប់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្ការ៉ាប់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ ធម៌ទាំងឡាយតែងធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើនូវសេចក្តីអន្តរាយដល់អ្នកសេពមែន ។ ឯភិក្ខុនោះកាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ ក៏នៅតែប្រកាន់មាំយ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈបីដង ដើម្បីឲ្យលះទិដ្ឋិនោះចេញ ។ បើភិក្ខុនោះ កាលភិក្ខុទាំងឡាយសូត្រសមនុភាស-នកម្មអស់វារៈបីដង ហើយលះបង់នូវទិដ្ឋិនោះបាន ។ ការលះបង់បាននេះជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិបាចិត្តិយ ។

[២៨១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ពាក្យថា ភិក្ខុនោះពោលយ៉ាងនេះ គឺភិក្ខុនោះពោលថា ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។

[២៨២] សោ ភិក្ខូតិ យោ សោ ឯវំវាទី ភិក្ខុ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សោ ភិក្ខុ សជ្ឈាយមជ្ឈាបិ អាកង្ខ្យិត្វា វត្តព្វោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន

[២៨២] ពាក្យថា ភិក្ខុនោះ គឺភិក្ខុដែលនិយាយយ៉ាងនេះ នោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ ។ ភិក្ខុទាំងឡាយណាឃើញ ភិក្ខុទាំងឡាយណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយឲ្យភិក្ខុដែលមានទិដ្ឋិអាក្រក់នោះថា នែលោកដ៏មានអាយុ លោកកុំនិយាយយ៉ាងហ្នឹង កុំពោលបង្កាច់ព្រះដ៏មានព្រះភាគយ៉ាងហ្នឹង ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ ម្នាលអាវុសោ ធម៌ទាំងឡាយធ្វើសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពមែន ។ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅឲ្យភិក្ខុមានទិដ្ឋិអាក្រក់នោះអស់វារៈពីរដងផង ត្រូវនិយាយប្រដៅឲ្យអស់វារៈបីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយឮហើយមិននិយាយប្រដៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយត្រូវទាញភិក្ខុនោះមកកាន់ទីកណ្តាលសង្ឆ ហើយនិយាយប្រដៅថា លោកដ៏មានអាយុ លោកកុំពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ ធម៌ទាំងឡាយតែងធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគ

តេ បដិសេវតោ អន្តរាយាតិ ។ ទុតិយម្បិ វត្តព្វោ
តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ
កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

[២៨៣] សោ ភិក្ខុ ភិក្ខូហិ សមនុភាសិតព្វោ ។
ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ ។ ញត្តេន ភិក្ខុនា
បដិពលេន សង្ឆោ ញាបេតព្វោ សុណាតុ មេ ភន្តេ
សង្ឆោ ឥត្ថន្នាមស្ស ភិក្ខុនោ ឯវរូបំ ចាបកំ ឧិដ្ឋិតតំ
ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានামិ យថា
យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ
ន លំ អន្តរាយាយាតិ ។ សោ តំ ឧិដ្ឋឺ ឧប្បដិនិស្សជ្ជតិ ។
យទិ សង្ឆស្ស បត្តកល្លំ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ
សមនុភាសেយ្យ ឥស្ស ឧិដ្ឋិយា បដិនិស្សគ្គាយ ។
ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ ឥត្ថន្នាមស្ស

សំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់អ្នកសេពមែន ។ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅភិក្ខុមានទិដ្ឋិអាក្រក់នោះ អស់វារៈពីដងផង ត្រូវនិយាយប្រដៅ អស់វារៈបីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

[២៨៣] ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយត្រូវសូត្រសមនុភាសនកម្ម (ដល់ភិក្ខុមានទិដ្ឋិអាក្រក់) យ៉ាងនេះ ។ ភិក្ខុដែលឈ្វាសអង់អាចត្រូវផ្ទៀងសង្ឆថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុនោះ មិនលះបង់ទិដ្ឋិនោះ ។ បើកម្មមានកាលគួរដល់សង្ឆហើយ សង្ឆគប្បីសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ

ភិក្ខុនោ ឯវរូបំ ចាបកំ ជីវិតតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ ជាលំ អន្តរាយាតិ ។ សោ តំ ជីវិតា ឧប្ផដ-ជិ្ឌ្ឍតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្ស ជីវិយា បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្ស ជីវិយា បដិនិស្សគ្គាយ សោ តុណ្ហាស្ស យស្ស ឧក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្ប្យិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្ប្យិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ឯវរូបំ ចាបកំ ជីវិ-តតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ ជាលំ អន្តរាយាតិ ។ សោ តំ

ភិក្ខុឈ្មោះនេះមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុនោះមិនលះបង់ទិដ្ឋិនោះ ។ (ឥឡូវនេះ) សង្ឆស្ងូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះ-បង់ទិដ្ឋិនោះ ។ ការសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះ-បង់ទិដ្ឋិនោះគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈបីដងផង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមសង្ឆស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយ ថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុនោះ

ជិដ្ឋឺ ឧប្បជ្ជិនិស្សជ្ជតិ ។ សង្ឆ្យោ ឥត្ថន្នាមំ ភិក្ខុំ
សមនុភាសតិ ឥស្សា ជិដ្ឋិយា បជិនិស្សត្តាយ ។
យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សម-
នុភាសនា ឥស្សា ជិដ្ឋិយា បជិនិស្សត្តាយ សោ
តុណ្ហាស្ស យស្ស នក្ខមតិ សោ ភាសেយ្យ ។
សមនុភដ្ឋោ សង្ឆេន ឥត្ថន្នាមោ ភិក្ខុ ឥស្សា ជិដ្ឋិយា
បជិនិស្សត្តាយ ។ ខមតិ សង្ឆស្ស ឥស្មា តុណ្ហី ។
ឯវមេតំ ធារយាមីតិ ។

[២៨៤] ញត្តិយា ទុក្កដំ ។ ទ្វីហិ កម្ម-
វាចាហិ ទុក្កដា ។ កម្មវាចាបរិយោសានេ អាបត្តិ
ចាចិត្តិយស្ស ។

[២៨៥] ឆម្មកម្មេ ឆម្មកម្មសញ្ញី ឧប្បជ្ជិនិស្សជ្ជតិ
អាបត្តិ ចាចិត្តិយស្ស ។ ឆម្មកម្មេ វេមតិកោ
ឧប្បជ្ជិនិស្សជ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ ឆម្ម-
កម្មេ អឆម្មកម្មសញ្ញី ឧប្បជ្ជិនិស្សជ្ជតិ អាបត្តិ

មិនលះបង់ទិដ្ឋិនោះទេ ។ (ឥឡូវនេះ) សង្ឆសូត្រសមនុភាសនកម្ម ចំពោះកិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះហើយ ។ ការសូត្រសមនុភាសន-កម្ម ចំពោះកិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឆសូត្រសមនុភាសនកម្ម ចំពោះកិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះហើយ ។ ការសូត្រសមនុភាសនកម្មនេះគួរដល់សង្ឆ ហេតុនោះសង្ឆស្ងៀម ។ ខ្ញុំចាំទុកនូវសង្ឆកម្មនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[២៨៤] កិក្ខុត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ។ កិក្ខុត្រូវអាបត្តិទុក្កដទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរ (លើក) ។ កិក្ខុត្រូវអាបត្តិបាចិត្តិយ ក្នុងខណៈចប់កម្មវាចាស្រេច ។

[២៨៥] កម្មប្រកបដោយធម៌ កិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ កិក្ខុមានសេចក្តីសង្ស័យ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ កិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិ

ចាចិត្តិយស្ស ។ អជ្ឌ្ឍកម្ម ជ្ឌ្ឍកម្មសញ្ញី អាបត្តិ ជុក្ខ្ជ ។ អជ្ឌ្ឍកម្ម ១ មតិ ១ អាបត្តិ ជុក្ខ្ជ ។ អជ្ឌ្ឍកម្ម អជ្ឌ្ឍកម្មសញ្ញី អាបត្តិ ជុក្ខ្ជ ។

[២៨៦] អ១ាបត្តិ អ១ាមជ្ឌ្ឍ១ាសន្ត១ាស្ស ១ជ១ិ១ិ១ាស្ស-ជ្ឌ្ឍ១ាសន្ត១ាស្ស ១ម្ម១ាត្ត១ាកាស្ស ១ាជ១ិ១ាកម្ម១ិ១ាកាស្ស ១ាតិ ។

បាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកប ដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[២៨៦] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ សង្ឆមិនសូត្រសមនុភាសនកម្ម ១ ភិក្ខុលះបង់ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៨ ចប់ ។

នវមសិក្ខាបទំ

[២៨៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជានំ តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកជានុងម្នេន តំ ទិដ្ឋឹ អប្ឋដិ-និស្ឋដ្ឋេន សទ្ធឹ សម្ភុញ្ជន្តិបិ សំវសន្តិបិ សហាបិ សេយ្យំ កប្ឋេន្តិ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។ តេ ឧជ្ឈា-យន្តិ ខីយន្តិ វិចារេន្តិ ១ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានំ តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកជានុងម្នេន តំ ទិដ្ឋឹ អប្ឋដិនិស្ឋដ្ឋេន សទ្ធឹ សម្ភុញ្ជិស្ឋន្តិបិ សំវសិស្ឋន្តិបិ សហាបិ សេយ្យំ កប្ឋេស្ឋន្តីតិ ។ បេ ។ សច្ចំ កិរ ១ ១ ១

សិក្ខាបទទី ៩

[២៨៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយដឹងហើយ បរិភោគរួមខ្ទះ នៅរួមខ្ទះ សម្រេចឥរិយាបថ ដេករួមខ្ទះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ មិនបាន ធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះចេញ ។ ភិក្ខុទាំងឡាយណា មាន សេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងហើយមិនគួរនឹងបរិភោគរួមខ្ទះ នៅ រួមខ្ទះ សម្រេចឥរិយាបថដេករួមខ្ទះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោល យ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ ដឹងហើយ បរិភោគរួមខ្ទះ នៅរួមខ្ទះ សម្រេចឥរិយាបថដេករួមខ្ទះជាមួយ នឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ ជាអ្នកមិនបានធ្វើតាមធម៌ ជា អ្នកមិនលះបង់ទិដ្ឋិនោះ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រ ព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោស ថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយដឹងហើយមិនគួរនឹង

តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកជានុនេន តំ ទិដ្ឋិ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជិស្សថាបិ សំវសិស្ស-ថាបិ សហាបិ សេយ្យំ កប្បេស្សថ នេតំ មោឃបុរិសា អប្បសន្ថានំ វ បសាទាយ បសន្ថានំ វ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ-សេយ្យាថ យោ បន ភិក្ខុ ជានំ តថាវាទិនា ភិក្ខុនា អកជានុនេន តំ ទិដ្ឋិ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជេយ្យ វ សំវសេយ្យ វ សហ វ សេយ្យំ កប្បេយ្យ ចាចិត្តិយន្តិ ។

[២៨៨] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វ ជានាតិ អញ្ញេ វ ឥស្ស អារោចេន្តិ សោ វ អារោចេតិ ។ តថាវាទि-នាតិ តថាមាំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ឯវំវាទិនា ។

បរិភោគរួមខ្ទះ នៅរួមខ្ទះ សម្រេចឥរិយាបថដេករួមខ្ទះ ជាមួយនឹងអរិដ្ឋភិក្ខុ ដែលនៅតែពោលយ៉ាងនោះ មិនធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះទេ នែ មោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែល មិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទ នេះយ៉ាងនេះថា ភិក្ខុណាមួយដឹងហើយ បរិភោគរួមក្តី នៅរួមក្តី សម្រេច ឥរិយាបថដេករួមក្តី ជាមួយនឹងភិក្ខុដែលមានប្រក្រតីពោលយ៉ាងនោះ ជា អ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះបង់ទិដ្ឋិនោះ ត្រូវអាបត្តិបាចិត្តិយ ។

[២៨៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋម-បារាជិក ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកភិក្ខុដទៃប្រាប់ ភិក្ខុនោះក្តី ភិក្ខុមានទិដ្ឋិអាក្រក់នោះប្រាប់ក្តី ។ ពាក្យថា មានប្រក្រតីពោល យ៉ាងនោះ គឺនៅតែនិយាយយ៉ាងនេះថា ធម៌ទាំងឡាយណា ដែលព្រះ ដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់ នូវធម៌នោះដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។

អកជានុ្ជម្ហោ ជាម ឧក្ខិត្តោ អនោសារិតោ ។ តំ ជិដ្ឋី
អប្ជជិនិស្ជ្ជេន សទ្ធិន្តិ ឯតំ ជិដ្ឋី អប្ជជិនិស្ជ្ជេន
សទ្ធឹ ។ សម្ភុញ្ជេយ្យ ភាតិ សម្ភោគោ ជាម ទ្វេ
សម្ភោគា អាមិសសម្ភោគោ ច ជម្ជ្ជសម្ភោគោ ច ។
អាមិសសម្ភោគោ ជាម អាមិសំ ទេតិ ភ បជិក្ខណ្ហាតិ
ភ អាបត្តិ ចាចិត្តិយស្ជ ។ ជម្ជ្ជសម្ភោគោ ជាម
ឧទ្ធិសតិ ភ ឧទ្ធិសាបេតិ ភ ។ បទេន ឧទ្ធិសតិ ភ
ឧទ្ធិសាបេតិ ភ បទេ បទេ អាបត្តិ ចាចិត្តិយស្ជ ។
អក្ខ្ជាយ ឧទ្ធិសតិ ភ ឧទ្ធិសាបេតិ ភ អក្ខ្ជរក្ខ្ជាយ
អាបត្តិ ចាចិត្តិយស្ជ ។ សំវសេយ្យ ភាតិ ឧក្ខ្ជិត្តកេន

ភិក្ខុណាដែលសង្ឆលើកវត្ត[១] ហើយសង្ឆមិនបានហៅចូលពួកទេ ភិក្ខុនោះហៅថា មិនធ្វើតាមធម៌ ។ ពាក្យថា ជាមួយនឹង (ភិក្ខុ) មិនលះបង់ទិដ្ឋិនោះ គឺជាមួយនឹង (ភិក្ខុ) ដែលមិនលះបង់នូវទិដ្ឋិនោះឲ្យដាច់ស្រឡះ ។ ពាក្យថា បរិភោគរួមក្តី[២] សេចក្តីថា ដែលហៅថា បរិភោគរួម គឺបរិភោគរួមមានពីរយ៉ាង បរិភោគរួមដោយអាមិសៈ ១ បរិភោគរួមដោយធម៌ ១ ។ ដែលហៅថា បរិភោគរួមដោយអាមិសៈនោះគឺ ភិក្ខុឲ្យអាមិសៈ (ដល់ភិក្ខុនោះក្តី) ទទួលអាមិសៈអំពីភិក្ខុនោះក្តី ត្រូវអាបត្តិបាចិត្តិយ ។ ដែលហៅថា បរិភោគរួមដោយធម៌ គឺភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ) ក្តី ឲ្យ(ភិក្ខុនោះ) សំដែងធម៌ឲ្យស្តាប់ក្តី ។ ភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ) ក្តី ឲ្យ(ភិក្ខុនោះ) សំដែងធម៌ឲ្យស្តាប់ក្តី ដោយបទ ត្រូវអាបត្តិបាចិត្តិយ រាល់ ១ បទ ។ ភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ) ក្តី ឲ្យ(ភិក្ខុនោះ) សំដែងធម៌ឲ្យស្តាប់ក្តី ដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយ រាល់ ១ អក្ខរៈ ។ ពាក្យថា នៅរួមក្តី គឺភិក្ខុ

---

១ គឺភិក្ខុដែលសង្ឆលើកវត្ត ដោយបានសូត្រញត្តិចតុត្ថកម្មវាចា ព្រោះភិក្ខុនោះមិនឃើញអាបត្តិ មិនសំដែងអាបត្តិ មិនលះបង់ទិដ្ឋិ ហៅថា ភិក្ខុដែលសង្ឆលើកវត្ត ឯរូបភិក្ខុនោះមិនត្រូវបរិភោគរួមនឹងសង្ឆឡើយ ។ សេចក្តីពិស្តារក្នុងកម្មក្ខន្ធកៈ គម្ពីរចុល្លវគ្គ ។ ២ បរិភោគ ក្នុងទីនេះចំពោះយកការសេពគប់ ។

សន្ធ្ងី ឧចោសេ ០ បការណ ០ សជ្ជ្ងកម្ម ០ ០ ០

ធ្វើឧបោសថក្តី បវារណាក្តី សង្ឆកម្មក្តី ជាមួយនឹងភិក្ខុដែលសង្ឆលើកវត្ត ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា សម្រេចតវិយាបថដេកក្នុងក្តី គឺកាលបើភិក្ខុដែលសង្ឆលើកវត្តបានដេកហើយ ភិក្ខុក៏ដេកក្នុងទីបិទបាំងជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុដេកហើយ ភិក្ខុដែលសង្ឆលើកវត្ត ក៏ដេកដែរ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ឬថាភិក្ខុទាំងពីររូបដេក (ជាមួយគ្នា) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោកឡើងហើយដេកវិញញ ។ ត្រូវអាបត្តិបាចិត្តិយ ។

[២៨៩] ភិក្ខុដែលសង្ឆលើកវត្តហើយ ភិក្ខុសំគាល់ថា សង្ឆលើកវត្ត ហើយ ។ បរិភោគក្នុងក្តី នៅក្នុងក្តី សម្រេចតវិយាបថដេកក្នុងក្តី ត្រូវអាបត្តិ បាចិត្តិយ ។ ភិក្ខុដែលសង្ឆលើកវត្តហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយបរិភោគក្នុងក្តី នៅក្នុងក្តី សម្រេចតវិយាបថដេកក្នុងក្តី ត្រូវអាបត្តិ ទុក្កដ ។ ភិក្ខុដែលសង្ឆលើកវត្តហើយ ភិក្ខុសំគាល់ថា សង្ឆមិនបាន លើកវត្តទេ ហើយបរិភោគក្នុងក្តី នៅក្នុងក្តី សម្រេចតវិយាបថដេកក្នុងក្តី

អជាបត្តិ ។ អនុក្ខិត្តកេ ឧក្ខិត្តកសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុក្ខិត្តកេ វេមតិកោ អាបត្តិ ទុក្ក-ដស្ស ។ អនុក្ខិត្តកេ អនុក្ខិត្តកសញ្ញី អជាបត្តិ ។

[២៩០] អជាបត្តិ អនុក្ខិត្តោតិ ជានាតិ ឧក្ខិត្តោ ឱសារិតោតិ ជានាតិ ឧក្ខិត្តោ តំ ឋិដ្ឋឹ បដិនិស្សជ្ជោតិ ជានាតិ ឧម្មត្តកស្ស អាឧិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

មិនត្រូវអាបត្តិ ។ ភិក្ខុដែលសង្ឆមិនបានលើកវត្ត ភិក្ខុសំគាល់ថា សង្ឆ លើកវត្តហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលសង្ឆមិនលើកវត្ត ភិក្ខុមាន សេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលសង្ឆមិនលើកវត្ត ភិក្ខុ សំគាល់ថា សង្ឆមិនលើកវត្ត មិនត្រូវអាបត្តិ ។

[២៩០] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុដឹងថា ភិក្ខុនោះសង្ឆមិនលើកវត្ត ១ ភិក្ខុដឹងថា ភិក្ខុដែលសង្ឆ លើកវត្តហើយ ដែលសង្ឆបានសូត្រហៅចូលពួកវិញ ១ ភិក្ខុដឹងថា ភិក្ខុដែលសង្ឆលើកវត្តហើយ ។ បានលះបង់ទិដ្ឋិនោះចេញហើយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[២៩១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន កណ្ហកស្ស ជាម សមណុទ្ទេ-
សស្ស ឆវូបំ ចាបកំ ជិដ្ឋិតតំ ឧប្បន្នំ ហោតិ តថាហំ
ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរ-
យិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ ជាលំ
អន្តរាយាយាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ
កណ្ហកស្ស ជាម ការ សមណុទ្ទេសស្ស ឆវូបំ
ចាបកំ ជិដ្ឋិតតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ
អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា
ភគវតា តេ បដិសេវតោ ជាលំ អន្តរាយាយាតិ ។
អថខោ តេ ភិក្ខូ យេន កណ្ហកោ សមណុទ្ទេសោ
តេនុបសង្កមិំសុ ឧបសង្កមិត្វា កណ្ហកំ សមណុទ្ទេសំ
ឯតទវោចុំ សចំ ការ តេ អាវុសោ កណ្ហក ឆវូបំ

សិក្ខាបទទី ១០

[២៩១] *សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ*
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ
ឯង សមណុទ្ទេស[1] ឈ្មោះកណ្ហក: មានទិដ្ឋិអាក្រក់ មានសភាព
យ៉ាងនេះកើតឡើង (ដូច្នេះ) ថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគ
សំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងថា
ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដី
អន្តរាយដល់បុគ្គលអ្នកសេពនោះទេ ។ ភិក្ខុជាច្រើនបានឮដំណឹង
ថា សមណុទ្ទេសឈ្មោះកណ្ហក: មានទិដ្ឋិអាក្រក់ មានសភាពយ៉ាង
នេះកើតឡើង (ដូច្នេះ) ថា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះ
ភាគសំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះ
ភាគ សំដែងថាជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាច
ធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ ទើបភិក្ខុទាំងឡាយ
នោះ ចូលទៅរកសមណុទ្ទេស ឈ្មោះកណ្ហក: លុះចូលទៅហើយបាន
និយាយពាក្យនេះនឹងកណ្ហកសមណុទ្ទេសថា នែអាវុសោកណ្ហក: ឮថា

---

1 សមណុទ្ទេស ជាពាក្យផ្លាស់ប្ដូរគ្នានឹងពាក្យថា សាមណេរ នឹងហៅថា សមណុទ្ទេសក៏បាន ថាសាមណេរក៏បាន ។

ចាបកំ ជិដ្ឋិកតំ ឧប្ឋដ្ឋំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានামិ យថា យេមេ អន្ដរាយិកា ធម្មា រុត្ដា ភគវតា តេ បដិសេវតោ ជាលំ អន្ដរាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្ដេ ភគវតា ធម្មំ ទេសិតំ អាជានামិ យថា យេមេ អន្ដរាយិកា ធម្មា រុត្ដា ភគវតា តេ បដិសេវតោ ជាលំ អន្ដរាយាតិ ។ មា អាវុសោ ភណ្ដាគ ឯវំ អវច មា ភគវន្ដំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ ភណ្ដាគ អន្ដរាយិកា ធម្មា រុត្ដា ភគវតា អលញ្ចូ បន តេ បដិសេវតោ អន្ដរាយាយ អប្ឋស្ឆាជ ភាមា រុត្ដា ភគវតា ពហុជុក្ខា ពហូចាយាសា អាទីនវោ ឯត្ដ ភិយ្យោ អដ្ដិកន្ដ្ដ្ លូបមា ភាមា រុត្ដា ភគវតា ។ បេ ។

អ្នកឯងមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្ដរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្ដរាយ ដល់បុគ្គលអ្នកសេពទេ ពិតមែនឬ ។ កណ្ហកសមណុទ្ទេសធ្វើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំកុណ្ឌាដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងយ៉ាងនេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគ សំដែងថា ជាធម៌ធ្វើសេចក្ដីអន្ដរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្ដរាយដល់បុគ្គលអ្នកសេព ពិតមែន ។ ភិក្ខុទាំងឡាយនិយាយថា នែអាវុសោកណ្ហក: អ្នកកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ នែអាវុសោកណ្ហក: ធម៌ទាំងឡាយធ្វើសេចក្ដីអន្ដរាយដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្ដីអន្ដរាយ ដល់បុគ្គលអ្នកសេពមែន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងធ្នើ ។ បេ ។

មំសបេសូបមា កាមា វុត្តា ភគវតា ។ បេ ។ តិណុក្កូ-
បមា កាមា វុត្តា ភគវតា ។ បេ ។ អង្គារកាសូបមា
កាមា វុត្តា ភគវតា ។ បេ ។ សុបិនកូបមា កាមា
វុត្តា ភគវតា ។ បេ ។ យាចិតកូបមា កាមា វុត្តា
ភគវតា ។ បេ ។ រុក្ខផលូបមា កាមា វុត្តា ភគវតា
។ បេ ។ អសិសូនូបមា កាមា វុត្តា ភគវតា ។ បេ ។
សត្តិសូលូបមា កាមា វុត្តា ភគវតា ។ បេ ។ សប្បសិ-
រូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា
អាទីនវោ ឯត្ថ ភិយ្យោតិ ។ ឯវំបិ ខោ ភណ្ឌាគោ
សមណុទ្ទេសោ តេហិ ភិក្ខូហិ វុច្ចមានោ តថេវ តំ
ចាបកំ ជិដ្ឋិកតំ ថាមសា បរាមាសា អភិនិវិស្ស
ហោតិ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ

ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ក្ងើង ដែលធ្វើដោយស្មៅ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្ដៅរងើកក្ងើង ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្ដិ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្ទៃឈើ ។ បេ ។ ព្រះដ៏មានព្រះភាគ សំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់ ។ បេ ។ ព្រះដ៏មានព្រះភាគ សំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ។ សមណុទ្ទេសឈ្មោះកណ្ហក: កាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះ ក៏នៅប្រកាន់ទិដ្ឋិអាក្រក់នោះ ដោយសេចក្ដីប្រកាន់ដ៏មាំ ហើយពោលយ៉ាងនោះដដែលថា បពិត្រលោកដ៏ចម្រើន ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគ សំដែងហើយយ៉ាងនេះថា ធម៌ទាំងឡាយណា

អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា រុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ យតោ ខោ តេ ភិក្ខូ ឆាសក្ខីសុ កណ្ហាកំ សមណុទ្ទេសំ ឯតស្មា ចាបកា ឋិដ្ឋិតតា វិវេចេតុំ អថខោ តេ ភិក្ខូ យេន ភគវា តេនុបសង្កមីសុ ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បការណេ ភិក្ខុសង្ឆំ សន្និចាតាបេត្វា កណ្ហាកំ សមណុទ្ទេសំ បដិបុច្ឆិ សច្ចំ កិរ តេ កណ្ហាក ឱរវ្ជបំ ចាបកំ ឋិដ្ឋិតតំ ឧប្ជន្តុ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា រុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អា-ជានាមិ យថា យេមេ អន្តរាយិកា ធម្មា រុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ភាសិ ១ ខោ ១ ១ ១

ដែលព្រះដ៏មានព្រះភាគសំដែងហើយថា ជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឦ្ចាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ ភិក្ខុទាំងឦ្ចាយនោះ មិនអាចនឹងដោះសមណុទ្ទេសឈ្មោះកណ្ហក:ចេញពីទិដ្ឋិអាក្រក់នោះក្នុងកាលណា ភិក្ខុទាំងឦ្ចាយនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងកាលនោះ លុះចូលទៅហើយក្រាបទូលសេចក្តីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឆ ហើយត្រាស់សួរចំពោះកណ្ហកសមណុទ្ទេសក្នុងពេលនោះ ថា នែកណ្ហក: ឮថាអ្នកឯងមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឦ្ចាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឦ្ចាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ពិតមែនឬ ។ កណ្ហកសមណុទ្ទេសនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយយ៉ាងនេះថា ធម៌ទាំងឦ្ចាយណា ដែលព្រះដ៏មានព្រះភាគសំដែងហើយថា ជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឦ្ចាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ

អាជានាសិ ឧនុ មយា មោឃបុរិស អនេកបរិយាយេន អន្តរាយិកា ធម្មា វុត្តា អលញ្ច ខលុ បន តេ បដិសេវតោ អន្តរាយាយ អប្ប្ស្ សាធ ការា វុត្តា មយា ពហុធុក្ខា ពហូចាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា ការា វុត្តា មយា ។ បេ ។ មំសបេសូបមា ការា វុត្តា មយា ។ បេ ។ តិណុក្កូបមា ការា វុត្តា មយា ។ បេ ។ អង្គារការូបមា ការា វុត្តា មយា ។ បេ ។ សុបិនកូបមា ការា វុត្តា មយា ។ បេ ។ យាចិតកូប-មា ការា វុត្តា មយា ។ បេ ។ រុក្ខផលូបមា ការា វុត្តា មយា ។ បេ ។ អសិសូនូបមា ការា វុត្តា មយា ។ បេ ។ សត្តិសូលូបមា ការា វុត្តា មយា ។ បេ ។ សប្ប្ សិរូបមា ការា វុត្តា មយា ពហុធុក្ខា ពហូ-

អំពីបុគ្គលណាមក នៃមោឃបុរស ធម៌ទាំងឡាយដែលធ្វើសេចក្តីអន្តរាយ តថាគតសំដែងហើយដោយបរិយាយជាច្រើន ក៏ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព (មែន) តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងធ្នឹង ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើដោយស្មៅ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់ ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។ បេ ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន

ចាយាសា អាឡីនហ្ៅ ឯត្ត កិយ្យោ អថ ច បន ត្វំ
មោឃបុរិស អត្តនា ឧក្ខិហិតេន ឧិជ្ជិតេន អម្ហេ ចេវ
អញ្ញាចិក្ខសិ អត្តានញ្ច ១ជ្ជសិ ពហុញ្ច អបុញ្ញ បសវសិ
តំ ហិ តេ មោឃបុរិស ភវិស្សតិ ឧីឃរត្តំ អហិតាយ
ឧក្ខាយ ដេតំ មោឃបុរិស អប្ប១ន្ធានំ វា បសាជាយ
បសន្ធានំ វា កិយ្យោ ១ាវាយ អថ ១េ តំ មោឃបុរិស
អប្ប១ន្ធានញ្ហេ អប្ប១ាជាយ បសន្ធានញ្ច ១ាកច្ចានំ
អញ្ញ១ត្តាយាតិ ។ ១ិតរហិត្វា ១ម្ម ១ាកំ ១ាត្វា ១ិក្ខ
អាមន្ដេសិ ដេ១ហិ ១ិក្ខវ សជ្ជ្ហ ១ាណ្ហ១ាកំ សមណ-
ដ្ដ១ំ ១ាសេតុ ១ាវញ្ច បន ១ិក្ខវ ១ាសេ១ញ្ហ អ១ជ្ជ១ដ្ដ

ទោសក្នុងកាមទាំងឡាយនេះមានច្រើន នៃមោឃបុរស កាលបើដូច្នោះ ហើយ អ្នកឯងហៅថា ពោលបង្ការ៉ាប់យើងផង គាស់ក្ដាយខ្ជួនឯងផង សោយបាបជាច្រើនផង ព្រោះទិដ្ឋិដែលខ្ជួនកាន់យកខុស នៃមោឃបុរស ទិដ្ឋិដែលអ្នកឯងកាន់យកអាក្រក់នោះ នឹងបង្ក្ដទោស មិនជាប្រយោជន៍ ជាទុក្ខដល់អ្នកឯង អស់កាលជាអង្ដែង នៃមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលមោឃបុរស ទិដ្ឋិអាក្រក់របស់អ្នកនេះ មានតែនាំមិនឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងដើម្បីសេចក្ដីវាយមាយដល់មនុស្សពួកខ្ះដែលជ្រះថ្លាហើយផង ។ ព្រះដ៏មានព្រះភាគបន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឆចូរញ្ចាំងកណ្ដកសម-ណុទ្ទេសឲ្យវិនាសចុះ[1] ម្នាលភិក្ខុទាំងឡាយ កណ្ដកសមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវឲ្យវិនាសយ៉ាងនេះថា នែអាវុសោកណ្ដក: កាលមាន

---

១ អដ្ឋកថា វិនាសនោះមានបីយ៉ាង គឺសំវាសនាសនា វិនាសទីខានបាននៅរួមជាមួយនឹងសង្ឆ ១ លិង្គនាសនា វិនាសចាកភេទ គឺត្រូវផ្ស៊ីកចេញ ១ ទណ្ឌកម្មនាសនា វិនាសដោយត្រូវទណ្ឌកម្ម មានមិនឲ្យដេកនៅរួមនឹងភិក្ខុអស់ពីរបីរាត្រីជាដើម ១ កណ្ដក:នេះ ត្រូវទណ្ឌកម្ម-នាសនា ។

តេ អាវុសោ កណ្ហាក ន ចេវ សោ ភគវា សត្ថា អប-
ជិសិតញ្ចេ យម្បិចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ
សទ្ធឹ ទ្វិរត្ត តិរត្តំ សហសេយ្យំ សាបិ តេ ជត្តុ ចេ បិវ[1]
រ ជ ន ស ្ យ ា ត ិ ។ អ ថ ខ ោ ស ជ ្ ជ ោ ក ណ ្ ហ ក ំ ស ម ណ ុ ទ ្ ទ េ ស ំ
ជ ា ន េ ស ិ ។

[២៩២] តេ ន ខោ ប ន ស ម យ េ ន ឆ ព ្ ភ ិ យ ា
ភ ិ ក ្ ខ ូ ជ ា ន ំ ត ថ ា ជ ា ស ិ ត ំ ក ណ ្ ហ ក ំ ស ម ណ ុ ទ ្ ទ េ ស ំ
ឧ ប ណ ា ប េ ន ្ ត ិ ប ិ ឧ ប ដ ្ ឋ ា ប េ ន ្ ត ិ ប ិ ស ម ្ ភ ុ ញ ្ ជ ន ្ ត ិ ប ិ ស ហ ា ប ិ
ស េ យ ្ យ ំ ក ប ្ ប េ ន ្ ត ិ ។ យ េ ត េ ភ ិ ក ្ ខ ូ អ ប ្ ប ិ ច ្ ឆ ា ។ ប េ ។
ត េ ឧ ជ ្ ឈ ា យ ន ្ ត ិ ទ ី យ ន ្ ត ិ វ ិ ច ា ច េ ន ្ ត ិ ក ច ំ ហ ិ ជ ា ម
ឆ ព ្ ភ ិ យ ា ភ ិ ក ្ ខ ូ ជ ា ន ំ ត ថ ា ជ ា ស ិ ត ំ ក ណ ្ ហ ក ំ ស ម-
ណ ុ ទ ្ ទ េ ស ំ ឧ ប ណ ា ប េ ស ្ ស ន ្ ត ិ ប ិ ឧ ប ដ ្ ឋ ា ប េ ស ្ ស ន ្ ត ិ ប ិ ស ម ្ ភ ុ-
ញ ្ ជ ិ ស ្ ស ន ្ ត ិ ប ិ ស ហ ា ប ិ ស េ យ ្ យ ំ ក ប ្ ប េ ស ្ ស ន ្ ត ី ត ិ ។ ប េ ។
ស ច ្ ច ំ ភ ិ ក ្ ខ ូ ត ុ ម ្ ហ េ ភ ិ ក ្ ខ ូ ជ ា ន ំ ត ថ ា ជ ា ស ិ ត ំ ក ណ ្ ហ ក ំ
ស ម ណ ុ ទ ្ ទ េ ស ំ ឧ ប ណ ា ប េ ថ ា ប ិ ឧ ប ដ ្ ឋ ា ប េ ថ ា ប ិ ស ម ្ ភ ុ ញ ្ ជ-
ថ ា ប ិ ស ហ ា ប ិ ស េ យ ្ យ ំ ក ប ្ ប េ ថ ា ត ិ ។ ស ច ្ ច ំ ភ ត ា ត ិ ។

---

1 ប ិ អ ត ិ ប រ អ ម ា ម ក ា ត ិ វ ណ ្ ណ ន ា ។

ថ្ងៃនេះជាដើម អ្នកឯងមិនត្រូវអាងព្រះដ៏មានព្រះភាគអង្គនោះថា ជាសាស្តារបស់អ្នកឡើយ សមណុទ្ទេសទាំងឡាយដទៃ តែងបាននូវកិរិយាដេករួមឯណា អស់រាត្រីពីរនិងរាត្រីបីជាមួយនឹងភិក្ខុទាំងឡាយ កិរិយាដេកនៅរួមនោះ មិនមានដល់អ្នកទេ នៃមនុស្សក្រៅការ អ្នកឯងចូរចៀសចេញទៅ អ្នកចូរវិនាសទៅ ។ ក្នុងកាលនោះឯង សង្ឃបានឲ្យកណ្ហកសមណុទ្ទេសវិនាសហើយ ។

[២៩២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា កណ្ហកសមណុទ្ទេសសង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលខ្ញុះ ឲ្យបម្រើខ្ញុះ បរិភោគរួមខ្ញុះ សម្រេចឥរិយាបថដេករួមខ្ញុះ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀលបន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងថា កណ្ហកសមណុទ្ទេសដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ មិនគួរនឹងបញ្ចុះបញ្ចូលខ្ញុះ ឲ្យបម្រើខ្ញុះ បរិភោគរួមខ្ញុះ សម្រេចឥរិយាបថដេករួមខ្ញុះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយដឹងថា កណ្ហកសមណុទ្ទេសដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលខ្ញុះ ឲ្យបម្រើខ្ញុះ បរិភោគរួមខ្ញុះ សម្រេចឥរិយាបថដេករួមខ្ញុះ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។

វិតរហិ ពុទ្ធោ ភគវា ភិក្ខូ ហិ ជាម តុម្ហេ មោឃបុរិសា ជានំ តថាជានិតំ ភណ្ហាកំ សមណុទ្ទេសំ ឧបលាបេស្សថាបិ ឧបដ្ឋាបេស្សថាបិ សម្ភុញ្ជិស្សថាបិ សហាបិ សេយ្យំ ភណ្ឌេស្សថ នេតំ មោឃបុរិសា អប្ប្ សន្ថានំ វ បសាទាយ បសន្ថានំ វ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សមណុទ្ទេសោបិ ចេ ឯវំ វទេយ្យ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ ន ជាលំ អន្តរាយាតិ ។ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាវុសោ សមណុទ្ទេស ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ សមណុទ្ទេស អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាតិ ។ ឯវញ្ច សោ សមណុទ្ទេសោ ភិក្ខូហិ

ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំង-ឡាយដឹងថា កណ្ហកសមណុទ្ទេសដែលសង្ឆឲ្យវិនាស យ៉ាងនោះហើយ មិនគួរនឹងបញ្ចុះបញ្ចូលខ្ញុះ ឲ្យបម្រើខ្ញុះ បរិភោគខ្ញុះ សម្រេចតវិយាបជ ដេកជ្ជមខ្ញុះទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែ ជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា បើសមណុទ្ទេសពោលយ៉ាងនេះ ថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំង-ឡាយណា ដែលព្រះដ៏មានព្រះភាគ សំដែងហើយថា ជាធម៌ធ្វើសេចក្តី អន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នក សេពទេ ។ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស អ្នកឯងកុំនិយាយយ៉ាងនេះឡើយ អ្នកកុំពោល បង្ការ៉ាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្ការ៉ាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រោះព្រះដ៏មានព្រះភាគ មិនពោលយ៉ាងនេះទេ នែអាវុសោ សមណុទ្ទេស ធម៌ទាំងឡាយធ្វើសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគ សំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តី អន្តរាយដល់បុគ្គលអ្នកសេព (មែន) ។ សមណុទ្ទេសនោះកាលដែលភិក្ខុ

រុច្ចមានោ តថេវ បត្តណ្ណោយ្យ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ អជ្ជតគ្គេ តេ អាវុសោ សមណុទ្ទេស ន ចេវ សោ ភគវា សត្ថា អបទិសិតញ្ចេ យម្ជ្ជិចញ្ញ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទ្វិរត្តតិរត្តំ សហសេយ្យំ សាបិ តេ ជត្តិ ចរ បិរេ រិនស្ជាតិ ។ យោ បន ភិក្ខុ ជានំ តថាជាសិតំ សមណុទ្ទេសំ ឧបលាបេយ្យ វា ឧបដ្ឋាបេយ្យ វា សម្ភុញ្ជេយ្យ វា សហ វា សេយ្យំ កប្ប្យ្យ ចាចិត្តិយន្តិ ។

[២៩៣] សមណុទ្ទេសោ ជាម សាមណេរោ រុច្ចតិ ។ ឯវំ វេទេយ្យាតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា រុត្តា ភគវតា តេ បដិសេវតោ ជាលំ អន្ត-រាយាយាតិ ។

[២៩៤] សោ សមណុទ្ទេសោតិ យោ សោ ឯវំវាទី សមណុទ្ទេសោ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្ជន្តិ យេ សុណន្តិ តេហិ រត្តញ្ចេ មា

ទាំងឡាយពោលយ៉ាងនេះហើយ ក៏នៅតែប្រកាន់ដដែល សមណុទ្ទេស នោះកិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុ-ទ្ទេស កាលមានថ្ងៃនេះជាដើម អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះ ថា ជាសាស្ដារបស់អ្នកឡើយ សាមណេរទាំងឡាយដទៃតែងបានកិរិយា ដេករួមឯណាអស់រាត្រីពីរបី ជាមួយនឹងកិក្ខុទាំងឡាយ ការដេកនៅរួម នោះ មិនមានដល់អ្នកទេ នែមនុស្សក្រៅការ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ ។ កិក្ខុណាមួយដឹងថា សមណុទ្ទេសដែលសង្ឆឲ្យវិនាស យ៉ាងនោះហើយ បញ្ចុះបញ្ចូលក្ដី ឲ្យបម្រើក្ដី បរិភោគរួមក្ដី សម្រេច ឥរិយាបថដេករួមក្ដី កិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[២៩៣] ដែលហៅថា សមណុទ្ទេស គឺសំដៅយកសាមណេរ ។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មាន ព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគ សំដែងថា ជាធម៌ធ្វើសេចក្ដីអន្ដរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដី អន្ដរាយដល់បុគ្គលអ្នកសេពទេ ។

[២៩៤] ពាក្យថា សមណុទ្ទេសនោះ គឺសមណុទ្ទេសដែលជា អ្នកពោលយ៉ាងនេះនោះឯង ។ ពាក្យថា កិក្ខុទាំងឡាយ គឺកិក្ខុទាំងឡាយ ឯទៀត ។ កិក្ខុទាំងឡាយណាឃើញ កិក្ខុទាំងឡាយណាឮ កិក្ខុ

អាវុសោ សមណុទ្ទេស ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ សមណុទ្ទេស អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិ-សេវតោ អន្តរាយាយាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ អជ្ជតគ្គេ តេ អាវុសោ សមណុទ្ទេស ន ចេវ សោ ភគវា សត្ថា អបទិសិតព្វោ យម្បិចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទ្វិរត្ततិរត្តំ សហសេយ្យំ សាបិ តេ ន ត្ថិ ចរ បិរេ វិនស្សាតិ ។

[២៩៥] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ ជាម សាមំ វា ជានាតិ អញ្ញេ វា

ទាំងឡាយនោះត្រូវពោលនឹងសមណុទ្ទេសនោះថា នែអាវុសោសមណុ-ទ្ទេស អ្នកកុំពោលយ៉ាងនេះឡើយ កុំពោលបង្ការ៉ាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្ការ៉ាច់ព្រះដ៏មានព្រះភាគ មិនសម្រេចប្រយោជន៍ទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោសមណុទ្ទេស ធម៌ទាំងឡាយ ដែលធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេព (មែន) ។ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវពោលអស់វារៈពីរដងផង ត្រូវពោលអស់វារៈបីដងផង ។ បើសមណុទ្ទេសនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ សម-ណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយយ៉ាងនេះថា នែអាវុសោសម-ណុទ្ទេស កាលមានថ្ងៃនេះជាដើម អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះថា ជាសាស្តារបស់អ្នកឡើយ សមណុទ្ទេសទាំងឡាយដទៃតែងបានការដេកនៅរួមឯណា អស់រាត្រីពីរនិងរាត្រីបីជាមួយនឹងភិក្ខុទាំងឡាយ ការដេកនៅរួមនោះមិនមានដល់អ្នកទេ នែមនុស្សឥតគេរាប់ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ ។

[២៩ថ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខា-បទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី

តស្ស អាហេចេន្តិ សោ វ អាហេចេតិ ។ តថាជាសិតន្តិ ឯវំ ជាសិតំ ។ សមណុទ្ទេសោ ជាម សាមណេរោ រុច្ចតិ ។ ឧបលាបេយ្យ វាតិ តស្ស បត្តំ វ ចីវរំ វ ឧទ្ទេសំ វ បរិបុច្ឆំ វ ឧស្សាមីតិ ឧបលាបេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបដ្ឋាបេយ្យ វាតិ តស្ស ចុណ្ណំ វ មត្តិកំ វ ឧទ្ធកដ្ឋំ វ មុខោទកំ វ សាដិយតិ អាបត្តិ ចាចិត្តិយស្ស ។ សម្ភុញ្ជេយ្យ វាតិ សម្ភោគោ ជាម ទ្វេ សម្ភោគា អាមិសសម្ភោគោ ច ធម្មសម្ភោគោ ច ។ អាមិស-សម្ភោគោ ជាម អាមិសំ ឧតិ វ បដិក្ខណ្ហាតិ វ អាបត្តិ ចាចិត្តិយស្ស ។ ធម្មសម្ភោគោ ជាម ឧទ្ទិសតិ វ ឧទ្ទិសាបេតិ វ ។ បឧេន ឧទ្ទិសតិ វ ឧទ្ទិសាបេតិ វ បឧ បឧ អាបត្តិ ចាចិត្តិយស្ស ។ អក្ខរាយ ឧទ្ទិ-សតិ វ ឧទ្ទិសាបេតិ វ អក្ខរក្ខរាយ អាបត្តិ ចាចិត្តិ-យស្ស ។ សហ វ សេយ្យំ កប្បេយ្យាតិ ឯកច្ឆន្នេ ជាសិតកេ សមណុទ្ទេសេ ជិបន្ទ ភិក្ខុ ជិបជ្ជតិ

ភិក្ខុទាំងឡាយដទៃប្រាប់ភិក្ខុនោះក្តី ឬសមណុទ្ទេសនោះប្រាប់ក្តី ។ ពាក្យ
ថា ដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ គឺសង្ឃឲ្យខូចយ៉ាងនេះហើយ ។
ដែលហៅថា សមណុទ្ទេស គឺសំដៅយកសាមណេរ ។ ពាក្យថា បញ្ចុះ
បញ្ចូលក្តី គឺភិក្ខុបញ្ចុះបញ្ចូលដោយគិតថា អញនឹងឲ្យបាត្រក្តី ចីវរក្តី
បាលីក្តី អដ្ឋកថាក្តី ដល់សមណុទ្ទេសនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា
ឲ្យបម្រើក្តី គឺភិក្ខុត្រេកអរនឹងគ្រឿងលំអិតក្តី ដីស្អិតក្តី ឈើស្ងួតក្តី ទឹក
ខ្ចីរមាត់ក្តី របស់សមណុទ្ទេសនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា
បរិភោគរួមក្តី គឺបរិភោគរួមមានពីរយ៉ាង បានដល់បរិភោគរួមដោយ
អាមិសៈ ១ បរិភោគរួមដោយធម៌ ១ ហៅថា បរិភោគរួម ។ ដែលហៅថា
បរិភោគរួមដោយអាមិសៈ គឺភិក្ខុឲ្យអាមិសៈក្តី ទទួលក្តី ត្រូវអាបត្តិបាចិត្តិយ ។
ដែលហៅថា បរិភោគរួមដោយធម៌ គឺភិក្ខុសំដែងធម៌ដល់សមណុទ្ទេស
នោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ។ ភិក្ខុសំដែងធម៌ដល់
សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ដោយបទ
ត្រូវអាបត្តិបាចិត្តិយ រាល់ ១ បទ ។ ភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី
ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយ
រាល់ ១ អក្ខរៈ ។ ពាក្យថា សម្រេចកិរិយាដេកនៅរួមក្តី គឺកាលបើសម-
ណុទ្ទេសដែលសង្ឃឲ្យវិនាសនោះបានដេកហើយ ភិក្ខុក៏ដេកក្នុងទីបិទបាំង

អាបត្តិ ចាចិត្តិយស្ស ។ ភិក្ខុ ជិបន្ធេ ជាសិតកោ សមណុាខ្ជេសោ ជិបជ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ ឧភោ ១ ជិបជ្ជន្តិ អាបត្តិ ចាចិត្តិយស្ស ។ ឧជ្ជហិត្វា បុនប្ប្ជុំ ជិបជ្ជតិ អាបត្តិ ចាចិត្តិយស្ស ។

[២៩៦] ជាសិតកេ ជាសិតកសញ្ញី ឧបលាបេតិ ១ ឧបដ្ឋាបេតិ ១ សម្ភុញ្ជតិ ១ សហ ១ សេយ្យំ កប្ប្ជតិ អាបត្តិ ចាចិត្តិយស្ស ។ ជាសិតកេ វេមតិកោ ឧបលាបេតិ ១ ឧបដ្ឋាបេតិ ១ សម្ភុញ្ជតិ ១ សហ ១ សេយ្យំ កប្ប្ជតិ អាបត្តិ ទុក្ក្ជដស្ស ។ ជាសិតកេ អជាសិតកសញ្ញី ឧបលាបេតិ ១ ឧបដ្ឋាបេតិ ១ សម្ភុញ្ជតិ ១ សហ ១ សេយ្យំ កប្ប្ជតិ អជាបត្តិ ។ អជាសិតកេ ជាសិតកសញ្ញី អាបត្តិ ទុក្ក្ជដស្ស ។ អជាសិតកេ វេមតិកោ អាបត្តិ ទុក្ក្ជដស្ស ។ អជា-សិតកេ អជាសិតកសញ្ញី អជាបត្តិ ។

ជាមួយ ត្រូវអាបត្តិបាចិត្តិយ ។ កាលបើកិក្ខុដេកហើយ សមណុទ្ទេស ដែលសង្ឆ ឲ្យវិនាសក៏ដេកនៅ (ដែរ) កិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ឬដេកទាំងពីរនាក់ កិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុក្រោកឡើងហើយ ដេកញ្ជ ។ ត្រូវអាបត្តិបាចិត្តិយ ។

[២៩៦] សមណុទ្ទេសដែលសង្ឆ ឲ្យវិនាសហើយ កិក្ខុសំគាល់ថា សង្ឆ ឲ្យវិនាសហើយ ។ បញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី ត្រូវអាបត្តិបាចិត្តិយ ។ សមណុទ្ទេសដែលសង្ឆ ឲ្យវិនាសហើយ កិក្ខុមានសេចក្តីសង្ស័យ ហើយបញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី ត្រូវអាបត្តិទុក្កដ ។ សមណុទ្ទេស ដែលសង្ឆ ឲ្យវិនាសហើយ កិក្ខុសំគាល់ថា សង្ឆ មិនបានឲ្យវិនាស ទៅវិញហើយ ។ បញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយា ដេករួមក្តី មិនត្រូវអាបត្តិ ។ សមណុទ្ទេសដែលសង្ឆ មិនឲ្យវិនាស កិក្ខុ សំគាល់ថា សង្ឆ ឲ្យវិនាស ត្រូវអាបត្តិទុក្កដ ។ សមណុទ្ទេសដែលសង្ឆ មិន ឲ្យវិនាស កិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សមណុទ្ទេសដែល សង្ឆ មិនឲ្យវិនាស កិក្ខុសំគាល់ថា សង្ឆ មិនឲ្យវិនាស មិនត្រូវអាបត្តិ ។

បាចិត្តិយកណ្ឌ សប្បាណកវគ្គស្ស ទសមសិក្ខាបទស្ស អនាបត្តិវារោ

[២៩៧] អនាបត្តិ អនាសិតកោតិ ជានាតិ តំ ជិដ្ឋឹ បដិនិស្សជ្ជោតិ ជានាតិ ឧម្មត្តកស្ស អាទិកម្មិ-កស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

សប្បាណកវគ្គោ សត្តមោ ។

តស្សុទ្ទានំ

សញ្ចិច្ចវធសប្បាណំ ឧក្កោដុជ្ជុលូធាធនំ
ឆនវីសតិ សត្តញ្ច សំវិធានអវិដ្ឋកំ
ឧក្ខិត្តកណ្ហកញ្ចេវ ឧស សិក្ខាបធា ឥមេតិ ។

[*២៩៧*] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺកិក្ខុដឹងថា សមណុទ្ទេសនោះសង្ឆមិនបានឲ្យវិនាស ១ កិក្ខុដឹងថា សម-ណុទ្ទេសនោះលះបង់ទិដ្ឋិនោះហើយ ១ កិក្ខុធ្លត ១ កិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ១០ ចប់ ។

សប្បាណកវគ្គទី ៧ ចប់ ។

ឧទ្ទានៃសប្បាណកវគ្គនោះ

មាន ១០ សិក្ខាបទនេះគឺ

សញ្ចិច្ចវធសិក្ខាបទ ១ *សប្បាណសិក្ខាបទ ១*

ឧក្កោសិក្ខាបទ ១ *ទុដ្ឋុល្លទានសិក្ខាបទ ១*

ឱនវីសតិសិក្ខាបទ ១ *សត្ថសិក្ខាបទ ១*

សំវិធានសិក្ខាបទ ១ *អរិដ្ឋកសិក្ខាបទ ១*

ឧក្ខិត្តសិក្ខាបទ ១ *កណ្ហកសិក្ខាបទ ១ ។*

សហធម្មិកវគ្គស្ស បឋមសិក្ខាបទំ

[២៩៨] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អជ្ឌាចារំ អាចរតិ ។ ភិក្ខូ ឯវមាហំសុ មា អាវុសោ ឆន្ន ឯវរូបំ អកាសិ ឧត្តំ ភាសតីតិ ។ សោ ឯវំ វទេតិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ឧញ្ញ ភិក្ខុំ ញត្តុំ វិនយធរំ បរិបុច្ឆ-មីតិ ។ យេ តេ ភិក្ខូ អប្ឌិច្ឆា ។ បេ ។ តេ ឧជ្ឌាយន្តិ ខីយន្តិ វិបាចេន្តិ ឥមំ ហិ នាម អាយស្មា ឆន្នោ ភិក្ខូហិ សហធម្មិកំ រុចូមានោ ឯវំ វក្ខតិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ឧញ្ញ ភិក្ខុំ ញត្តុំ វិនយធរំ បរិបុច្ឆាមីតិ ។ បេ ។ សចេ ភិវ ត្ថ ឆន្ន ភិក្ខូហិ សហធម្មិកំ រុចូមានោ ឯវំ វទេសិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ឧញ្ញ ភិក្ខុំ ញត្តុំ វិនយធរំ បរិបុច្ឆាមីតិ ។

សហាធម្មិកវគ្គ សិក្ខាបទទី ១

[២៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ ឃោសិតារាម ទៀបក្រុងកោសម្ពី ។ សម័យនោះឯង ឆន្ន:ដ៏មានអាយុ តែងប្រព្រឹត្តអនាចារ ។ ភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា នែ អាវុសោឆន្ន: អ្នកកុំធ្វើកម្មមានសភាពយ៉ាងនេះ កម្មដែលអ្នកធ្វើនេះ មិនគួរទេ ។ ឆន្នភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែល ឈ្វាស ដែលទ្រទ្រង់វិន័យ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នា តិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ ថា ឆន្ន:ដ៏មានអាយុ កាលបើភិក្ខុទាំងឡាយពោលពាក្យប្រកបដោយ ធម៌ មិនគួរនឹងពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់ សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែល ឈ្វាស ដែលទ្រទ្រង់វិន័យនៅឡើយ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់ សួរថា នែឆន្ន: ឮថា អ្នកឯងកាលបើភិក្ខុទាំងឡាយពោលពាក្យ ប្រកបដោយធម៌ និយាយ (នឹងភិក្ខុទាំងឡាយ) យ៉ាងនេះវិញថា នែអាវុ-សោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បាន សាកសួរភិក្ខុដទៃ ដែលឈ្វាស ដែលទ្រទ្រង់វិន័យនៅឡើយ ពិតមែនឬ ។

សចេ ភតវាតិ ។ ឯតរហិ ពុទ្ធោ ភតវា ភេជ្ជ ហិ ជាម ត្ថ មោឃបុរិស ភិក្ខូហិ សហធម្មិកំ រុចមានោ ឯវំ វក្ខសិ ន តាវាហំ អាវុសោ ឯតស្មឺ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន ញ្ញ ភិក្ខុ ព្យត្ត វិនយធរ បរិបុច្ឆាមីតិ ន ត មោឃបុរិស អប្ប សន្ថ ១ ១ ១

ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា នែមោឃបុរស កាលបើភិក្ខុទាំងឡាយនិយាយពាក្យប្រកបដោយធម៌ អ្នកឯងមិនគួរនឹងពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្វាស ដែលទ្រទ្រង់វិន័យនៅឡើយ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាលភិក្ខុទាំងឡាយ ពោលពាក្យប្រកបដោយធម៌ ហើយពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែលឈ្វាស ដែលទ្រទ្រង់វិន័យដរាបណា ខ្ញុំនឹងមិនសិក្សាសិក្ខាបទនេះដរាបនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសិក្សាគួរដឹងច្បាស់ គួរសាកសួរ គួរពិចារណា ។ នេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

[២៩៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ ។ ដែលហៅថា ពាក្យប្រកបដោយធម៌ គឺសិក្ខាបទណា ដែលព្រះដ៏មានព្រះភាគបញ្ញត្តហើយ សិក្ខាបទនោះហៅថា ពាក្យប្រកបដោយធម៌ ។

តេន រុច្ចមានោ ឯវំ វទេតិ ន តាវាហំ អាវុសោ ឯតស្មឿ សិក្ខាបទេ សិក្ខិស្សামិ យាវ ជញ្ញ ភិក្ខុ ព្យត្តំ វិនយ-ធរំ បណ្ឌិតំ មេធាវឿ ពហុស្សុតំ ធម្មកថិកំ បរិបុច្ឆាមីតិ ភណាតិ អាបត្តិ ចាចិត្តិយស្ស ។

[៣០០] ឧបសម្ប្ជ្ជ ឧបសម្ប្ជ្ជសញ្ញី ឯវំ វទេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ប្ជ្ជ វេមតិកោ ឯវំ វទេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ប្ជ្ជ អនុប-សម្ប្ជ្ជសញ្ញី ឯវំ វទេតិ អាបត្តិ ចាចិត្តិយស្ស ។ អប្ប្ជ្ជ្ជ

ភិក្ខុនោះ កាលភិក្ខុទាំងឡាយពោលតាមសិក្ខាបទនោះ ត្រឡប់ជាពោលយ៉ាងនេះ គឺពោលថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាក្នុងសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសជាវិន័យធរ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថិកនៅឡើយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៣០០] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្នពិតមែន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុកាលភិក្ខុទាំងឡាយ ពោលតាមពាក្យដែលមិនមែនជាវិនយ-បញ្ញត្តិ ហើយពោលយ៉ាងនេះថា ពាក្យនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីផ្ទរផង់ចាកកិលេស មិនប្រព្រឹត្តទៅដើម្បីកំចាត់បង់កិលេស មិនប្រព្រឹត្តទៅដើម្បីនាំមកនូវសេចក្តីជ្រះថ្លា មិនប្រព្រឹត្តទៅដើម្បីមិនសន្សំនូវកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាមទេ (ម្យ៉ាងទៀត) ពោលថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនោះទេ ព្រោះខ្ញុំមិនទាន់

ញត្តំ រិនយធរំ បណ្ឌិតំ មេធាវឺ ពហុស្សុតំ ធម្មកថិកំ បរិបុច្ឆាមីតិ ភណាតិ អាបត្តិ ទុក្កដស្ស ។ អនុប-សម្ផន្នេន បញ្ញត្តេន វា អប្ផញ្ញត្តេន វា រុច្ចមានោ ឥទំ ន សល្ខេ្ទាយ ន ជូតត្ថាយ ន ចាសាធិ-ភតាយ ន អបចយាយ ន រិរិយារម្ភាយ សំវត្តតីតិ ឯវំ វេទេតិ ន តាវាហំ អាវុសោ ឯតស្មឺ សិក្ខា-បទេ សិក្ខិស្ផាមិ យាវ ន ញ្ញ ភិក្ខុ ញត្តំ រិនយធរំ បណ្ឌិតំ មេធាវឺ ពហុស្សុតំ ធម្មកថិកំ បរិបុច្ឆាមីតិ ភណាតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ ឧប-សម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ អនុប-សម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

សាកសួរភិក្ខុដទៃ ដែលឈ្វាសទ្រទ្រង់វិន័យ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថិកនៅឡើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាលអនុបសម្បន្ន ពោលដោយវិនយបញ្ញត្តិក្តី ដោយពុទ្ធវចនៈដែលមិនមែនជាវិនយបញ្ញត្តិក្តី ត្រឡប់ពោលយ៉ាងនេះថា ពាក្យនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីផ្ទរផង់ចាកកិលេស មិនប្រព្រឹត្តទៅដើម្បីកំចាត់កិលេស មិនប្រព្រឹត្តទៅដើម្បីនាំមកនូវសេចក្តីជ្រះថ្លា មិនប្រព្រឹត្តទៅដើម្បីមិនសន្សំនូវកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាមទេ (ម្យ៉ាងទៀត) ពោលថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្វាសទ្រទ្រង់វិន័យ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថិកនៅឡើយ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[៣០១] សិក្ខមានេនាតិ សិក្ខិតុកាមេន ។ អញ្ញា-
តព្វន្តិ ជានិតព្វំ ។ បរិបុច្ឆិតព្វន្តិ ឥទំ ភន្តេ កថំ
ឥមស្ស ភោ អត្ថោតិ ។ បរិបញ្ហិតព្វន្តិ ចិន្តេតព្វំ តុល-
យិតព្វំ ។ អយំ តត្ត សាមីចីតិ អយំ តត្ត អនុធម្មតា ។

[៣០២] អនាបត្តិ ជានិស្សាមិ សិក្ខិស្សាមីតិ
ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

[៣០១] ត្រង់ពាក្យថា អ្នកសិក្សា គឺអ្នកមានសេចក្តីប្រាថ្នា ដើម្បីនឹងសិក្សា ។ ពាក្យថា គួរដឹងច្បាស់ គឺគួរចេះ ។ ពាក្យថា គួរសាកសួរ គឺគួរសាកសួរថា បពិត្រលោកដ៏ចម្រើន ពាក្យនេះដូចម្តេច ពាក្យនេះមានសេចក្តីដូចម្តេច ។ ពាក្យថា គួរពិចារណា គឺគួរគិតគួរថ្លឹង ។ ពាក្យថា នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺថានេះតាមទំនៀមក្នុងសិក្ខាបទនោះ ។

[៣០២] *ភារៈដែលមិនត្រូវអាបត្តិ* (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុពោលថា ខ្ញុំនឹងដឹង ខ្ញុំនឹងសិក្សា ១ ភិក្ខុធ្លត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១ ចប់ ។

ទុតិយសិក្ខាបទំ

[៣០៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ភគវា ភិក្ខូនំ អនេកបរិយា-
យេន វិនយកថំ កថេតិ វិនយស្ស វណ្ណោ ភាសតិ
វិនយបរិយត្តិយា វណ្ណោ ភាសតិ អាទិស្ស អាទិស្ស
អាយស្មតោ ឧចាលិស្ស វណ្ណោ ភាសតិ ។ ភិក្ខូ
ភគវា ខោ អនេកបរិយាយេន វិនយកថំ កថេតិ
វិនយស្ស វណ្ណោ ភាសតិ វិនយបរិយត្តិយា វណ្ណោ ភាសតិ
អាទិស្ស អាទិស្ស អាយស្មតោ ឧចាលិស្ស វណ្ណោ
ភាសតិ ហន្ទ មយំ អាវុសោ អាយស្មតោ ឧចាលិស្ស
សន្តិកេ វិនយំ បរិយាបុណាមាតិ ។ តេ ច ពហូ
ភិក្ខូ ថេរា ច នវា ច មជ្ឈិមា ច អាយស្មតោ
ឧចាលិស្ស សន្តិកេ វិនយំ បរិយាបុណន្តិ ។ អថខោ
ធញ្ញិយានំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ អាវុសោ
ពហូ ភិក្ខូ ថេរា ច នវា ច មជ្ឈិមា ច អាយស្មតោ
ឧចាលិស្ស សន្តិកេ វិនយំ បរិយាបុណន្តិ សចេ

សិក្ខាបទទី ២

[៣០៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់សំដែងវិនយកថា សំដែងគុណនៃវិន័យ ទ្រង់សំដែងគុណនៃការរៀនវិន័យ ទ្រង់កំណត់រឿយ ៗ ហើយទ្រង់សំដែងគុណរបស់ព្រះឧបាលិដ៏មានអាយុ ដល់ភិក្ខុទាំងឡាយដោយបរិយាយជាច្រើន ។ ភិក្ខុទាំងឡាយនិយាយថា ព្រះដ៏មានព្រះភាគទ្រង់សំដែងវិនយកថា ទ្រង់សំដែងគុណនៃវិន័យ ទ្រង់សំដែងគុណនៃការរៀនវិន័យ ទ្រង់កំណត់រឿយ ៗ ហើយទ្រង់សំដែងគុណរបស់ព្រះឧបាលិដ៏មានអាយុ ដោយបរិយាយជាច្រើន នៃអាវុសោទាំងឡាយ បើដូច្នោះ យើងនឹងរៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ ។ ទើបភិក្ខុទាំងឡាយនោះ ជាថេរៈខ្លះ ជាភិក្ខុថ្មីខ្លះ ជាភិក្ខុកណ្តាលខ្លះច្រើនរូប រៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ ។ លំដាប់នោះឯង ពួកឆព្វគ្គិយ-ភិក្ខុមានគំនិតដូច្នេះថា នៃអាវុសោទាំងឡាយ ឥឡូវនេះឯង ភិក្ខុច្រើនអង្គ ជាថេរៈខ្លះ ជាភិក្ខុថ្មីខ្លះ ជាភិក្ខុកណ្តាលខ្លះ រៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ បើភិក្ខុទាំងឡាយនេះ ជាអ្នកចេះស្ទាត់

ឥមេ វិនយេ បកតញ្ញូនោ ភវិស្សន្តិ អម្ហេ យថិច្ឆកំ
អាកឌ្ឍិស្សន្តិ បរិកឌ្ឍិស្សន្តិ ហន្ទ មយំ អាវុសោ
វិនយំ វិវណ្ណេមាតិ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ ភិក្ខូ
ឧបសង្កមិត្វា ឯវំ វទេន្តិ កឹ បនិមេហិ ខុទ្ទានុខុទ្ទកេហិ
សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ យាវទេវ កុក្កុច្ចាយ វិហេសាយ
វិលេខាយ សំវត្តន្តីតិ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា
។ បេ ។ តេ ញជ្ឈាយន្តិ ឲីយន្តិ វិចារេន្តិ កថំ
ហិ នាម ឆព្ពគ្គិយា ភិក្ខូ វិនយំ វិវណ្ណេស្សន្តីតិ
។ បេ ។ សចេ ការ តុម្ហេ ភិក្ខវេ វិនយំ វិវណ្ណេថាតិ ។
សចេ ភគវាតិ ។ វិការហិ ពុទ្ធោ ភគវា កថំ
ហិ នាម តុម្ហេ មោឃបុរិសា វិនយំ វិវណ្ណេស្សថ
នេតំ មោឃបុរិសា អប្ឋសន្ថានំ វា បសាទាយ ប-
សន្ថានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ
ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ
ចាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេយ្យ ឥមានិ ខ្ជ
ខ្ជ

ក្នុងវិន័យនឹងទាញមក នឹងប្រានទៅនូវយើងទាំងឡាយតាមគាប់ចិត្ត នៃអាវុសោទាំងឡាយ ណ្ហើយចុះ យើងគួរពោលបង្ហាប់វិន័យវិញ ។ ទើបពួកធម្មគ្គិយភិក្ខុ ចូលទៅជិតភិក្ខុទាំងឡាយ ហើយនិយាយយ៉ាងនេះថា ប្រយោជន៍អ្វីដោយសិក្ខាបទតូច ៗ ទាំងនេះ ដែលបុគ្គលណាមួយសំដែងឡើងហើយ សិក្ខាបទទាំងឡាយនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីក្តៅក្រហាយចិត្ត ដើម្បីសេចក្ដីលំបាកចិត្ត ដើម្បីសេចក្ដីសាំញ៉ាំចិត្ត ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកធម្មគ្គិយភិក្ខុមិនគួរនឹងពោលបង្ហាប់វិន័យសោះ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ ឮថាអ្នកទាំងឡាយពោលបង្ហាប់វិន័យ ពិតមែនឬ ។ ពួកធម្មគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងពោលបង្ហាប់វិន័យទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលបើភិក្ខុសំដែងឡើងនូវបាតិមោក្ខ ហើយពោលយ៉ាងនេះថា ប្រយោជន៍អ្វីដោយសិក្ខាបទ

ខុន្ធានុខុន្ធកេហិ សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ យាវទេវ
ការណ្ណុច្ចាយ វិហេសាយ វិលេខាយ សំវត្តន្តីតិ សិក្ខា-
បទវិវណ្ណនកេ ចាចិត្តិយន្តិ ។

[៣០៤] យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។
ចាតិមោក្ខេ ឧទ្ទិស្សមានេតិ ឧទ្ទិស្សន្តេ វា ឧទ្ទិសាបេន្តេ
វា សជ្ឈាយំ វា ការេន្តេ ។ ឯវំ វេយ្យាតិ ការ៉ ។ ១ ១ ១

តូច ។ ទាំងនេះដែលភិក្ខុណាមួយសំដែងឡើងហើយ សិក្ខាបទទាំងឡាយ នេះប្រព្រឹត្តទៅ ដើម្បីសេចក្តីក្តៅក្រហាយចិត្ត ដើម្បីសេចក្តីលំបាកចិត្ត ដើម្បីសេចក្តីរសេមរសាមចិត្តប៉ុណ្ណោះឯង ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះពោលបង្ហាប់សិក្ខាបទ ។

[៣០៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា កាលបើភិក្ខុសំដែងឡើងនូវបាតិមោក្ខ គឺកាលបើភិក្ខុសំដែងឡើងឯងក្តី ឲ្យគេសំដែងឡើងក្តី ធ្វើស្វាធ្យាយក្តី ។ ពាក្យថា ពោលយ៉ាងនេះ គឺភិក្ខុណាពោលបង្ហាប់វិន័យដល់ឧបសម្បន្នផងគ្នាថា ប្រយោជន៍អ្វីដោយសិក្ខាបទតូច ។ ទាំងនេះដែលភិក្ខុណាមួយសំដែងឡើងហើយ សិក្ខាបទទាំងនេះប្រព្រឹត្តទៅដើម្បីសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីរសេមរសាមចិត្ត ប៉ុណ្ណោះឯង ភិក្ខុណារៀនសិក្ខាបទនេះ ភិក្ខុនោះមានសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីរសេមរសាមចិត្ត ភិក្ខុណាមិនរៀនសិក្ខា-បទនេះ ភិក្ខុនោះមិនមានសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីរសេមរសាមចិត្តទេ សិក្ខាបទនេះ បើមិនមានអ្នកណា សំដែងឡើងក៏ជាការល្អ សិក្ខាបទនេះបើមិនមានអ្នកណាសិក្សាក៏ជាការល្អ សិក្ខាបទនេះ

ឥធ០ រ០ អជានិតំ ឥធ០ រ០ វិនយោ ឯ អន្តរធាយតុ ឥមេ ឯ ភិក្ខូ អបកតញ្ញូនោ ហោន្តូតិ ឧបសម្បន្នស្ស វិនយំ ១ វ្យ្ជ្ជ្ជ

បើមិនមានអ្នកណារៀនក៏ជាការល្អ សិក្ខាបទនេះ បើមិនមានអ្នកណាទ្រទ្រង់ក៏ជាការល្អ វិន័យចូរអន្តរធានទៅ ឬកិក្ខុទាំងឡាយនេះ ចូរកុំឲ្យចេះដឹងអ្វីសោះ កិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៣០៥] *ឧបសម្បន្ន កិក្ខុសំគាល់ថា ឧបសម្បន្ន ហើយពោលបង្ហាប់វិន័យ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន កិក្ខុមានសេចក្តីសង្ស័យ ហើយពោលបង្ហាប់វិន័យ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន កិក្ខុសំគាល់ថា មិនមែនឧបសម្បន្នហើយពោលបង្ហាប់វិន័យ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុពោលបង្ហាប់ធម៌ដទៃ ត្រូវអាបត្តិទុក្កដ ។ កិក្ខុពោលបង្ហាប់វិន័យក្តីធម៌ដទៃក្តី ចំពោះអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន កិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន កិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន កិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។*

[៣០៦] *ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺកិក្ខុមិនចង់ពោលបង្ហាប់ ១ កិក្ខុពោលថា ណ្ហើយចុះអ្នកចូររៀន ព្រះសូត្រទាំងឡាយក្តី គាថាទាំងឡាយក្តី អកិធម្មក្តី ជាមុនសិន ចាំរៀនវិន័យជាខាងក្រោយវិញ ១ កិក្ខុឆ្គត ១ កិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ២ ចប់ ។

ឥតិយសិក្ខាបទំ

[៣០៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ អនាចារំ អាចរិ-
ត្វា អញ្ញាណាកេន អាបន្នាតិ ជានន្ត្វតិ ចាតិមោក្ខេ
ឧទ្ទិស្យមានេ ឯវំ វទេន្តិ ឥមានេវ ខោ មយំ ជានាម
អយម្បិ ការ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អ-
ន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតីតិ ។ យេ តេ ភិក្ខូ អប្ប៊ិច្ឆា
។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ
ជាម ឆព្ភក្ខិយា ភិក្ខូ ចាតិមោក្ខេ ឧទ្ទិស្យមានេ ឯវំ
វក្ខន្តិ ឥមានេវ ខោ មយំ ជានាម អយម្បិ ការ ធម្មោ
សុត្តាគតោ សុត្តបរិយាបន្នោ អន្ត្ឌ្ឍមាសំ ឧទ្ទេសំ
អាគច្ឆតីតិ ។ បេ ។ សចេ ការ តុម្ហេ ភិក្ខវេ
ចាតិមោក្ខេ ឧទ្ទិស្យមានេ ឯវំ វទេថ ឥមានេវ ខោ
មយំ ជានាម អយម្បិ ការ ធម្មោ សុត្តាគតោ
សុត្តបរិយាបន្នោ អន្ត្ឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតីតិ ។

សិក្ខាបទទី ៣

[៣០៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង
ពួកឆព្វគ្គិយភិក្ខុនាំគ្នាប្រព្រឹត្តអនាចារហើយគិតថា ភិក្ខុទាំងឡាយចូរដឹងថា
យើងទាំងឡាយត្រូវអាបត្តិដោយសេចក្តីលួង់ កាលភិក្ខុកំពុងសំដែងបាតិ-
មោក្ខ ក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងឥឡូវនេះ
ថា ធម៌នេះមកហើយក្នុងសុត្ត: រាប់ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេស
(ការសូត្រ) រាល់កន្ទះខែ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានប្រាជ្ញាតិច
។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួក
ឆព្វគ្គិយភិក្ខុ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ម្តេចក៏នាំគ្នាពោលយ៉ាង
នេះថា យើងទាំងឡាយទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ធម៌នេះ
មកហើយក្នុងសុត្ត: រាប់ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេសរាល់កន្ទះខែ
។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា
អ្នកទាំងឡាយ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ក៏នាំគ្នាពោលយ៉ាងនេះថា
យើងទាំងឡាយទើបតែនឹងដឹងឥឡូវនេះថា ធម៌នេះមកហើយក្នុងសុត្ត:
រាប់ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេសរាល់កន្ទះខែ ពិតមែនឬ ។

សចេ ភគវតិ ។ វិតរហិ ពុទ្ធោ ភគវា ភេជ្ជ ហិ ជាម
តុម្ហេ មោឃបុរិសា ចាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វក្ខថ
ឥជានេវ ខោ មយំ ជានាម អយម្ប៎ិ ភិក្ខុ ឆម្ហោ សុត្តា-
ភតោ សុត្តបរិយាបន្នោ អនូ១ាមាសំ ឧទ្ទេសំ អាគច្ឆតីតិ
ឆេតំ មោឃបុរិសា អប្ប១ាសន្ធានំ វ បសាជាយ
បសន្ធានំ វ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន
ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ
អនូ១ាមាសំ ចាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេយ្យ
ឥជានេវ ខោ អហំ ជានាមិ អយម្ប៎ិ ភិក្ខុ ឆម្ហោ
សុត្តាភតោ សុត្តបរិយាបន្នោ អនូ១ាមាសំ ឧទ្ទេសំ
អាគច្ឆតីតិ ។ តញ្ច ភិក្ខុំ អញ្ញេ ភិក្ខូ ជានេយ្យុំ
ឆិសិន្ធបុព្វំ ឥមិនា ភិក្ខុនា ទ្ធិត្តិក្ខត្តុំ ចាតិមោក្ខេ
ឧទ្ទិស្សមានេ ១ោ បន ១ាទោ ភិយ្យោតិ ន ច
ឥស្ស ភិក្ខុនោ អញ្ញាណ១ោ ១ន មុត្តិ អត្ថិ យញ្ច
ឥត្ត អាបត្តឺ អាបន្នោ ឥញ្ច យថាឆម្ហោ ១ាវេឥ១ោ
ឧត្ត១ិញ្ចស្ស[1] មោហោ អាវេបេឥ១ោ ឥស្ស ឥ អាវុសោ

---

1 ឱ.ម. ឧត្ត១ិ ចស្ស ។

ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយកាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនគួរនឹងមកពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ធម៌នេះមកហើយក្នុងសុត្ត: រាប់ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេសរាល់កន្ទះខែ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលភិក្ខុកំពុងសំដែងបាតិមោក្ខរាល់កន្ទះខែ ហើយពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ឮថាធម៌នេះមកហើយក្នុងសុត្ត: រាប់ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេសរាល់កន្ទះខែ ។ បើភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុនោះថា ភិក្ខុនេះធ្លាប់អង្គុយស្តាប់បាតិមោក្ខ ដែលភិក្ខុសំដែងអស់វារៈពីរបីដងហើយ នឹងពោលទៅថ្វីទៀតដល់ការស្តាប់ច្រើនដង សេចក្តីរួច (ចាកអាបត្តិ) ដោយអាការដែលមិនដឹងមិនមានដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវអាបត្តិណា ក្នុងរឿងអនាចារនោះ សង្ឆគប្បីញ៉ាំងភិក្ខុនោះឲ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ម្យ៉ាងទៀត គប្បីលើកមោហារោបនកម្មដល់ភិក្ខុនោះថែមទៀតថា ម្នាល

អលាភា តស្ស តេ ពុល្ហ ! ! !

អាវុសោ (ការនេះ) មិនជាលាភរបស់អ្នកឯងទេ អ្នកឯងបាននូវរបស់អាក្រក់ ដោយហេតុថា កាលភិក្ខុកំពុងសំដែងបាតិមោក្ខ អ្នកមិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អឡើយ ។ នេះជាអាបត្តិបាចិត្តិយ ព្រោះកែងធ្វើវង្វេងនោះ (ធ្វើពើ) ។

[៣០៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខា-បទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា រាល់កន្ទះខែ គឺរាល់ថ្ងៃឧបោសថ ។ ពាក្យថា កាលភិក្ខុកំពុងសំដែងបាតិមោក្ខ សេចក្តីថា កាលភិក្ខុកំពុងសូត្របាតិមោក្ខ ។ ពាក្យថា ពោលយ៉ាងនេះ សេចក្តីថា ភិក្ខុណាប្រព្រឹត្តអនាចារហើយប្រាថ្នាថា ភិក្ខុទាំងឡាយចូរដឹងថា យើងត្រូវអាបត្តិដោយអាការមិនដឹង កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ភិក្ខុនោះពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងឥឡូវនេះថា ឦថាធម៌នេះមកហើយក្នុងសុត្ត: រាប់ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេសរាល់កន្ទះខែដូច្នេះ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[៣០៩] តញ្ចេតិ មោហេតុកាមំ ភិក្ខុំ អញ្ញ ភិក្ខូ ជានេយ្យុំ ឯសិន្ទបុត្ថំ ឥមិនា ភិក្ខុនា ទ្វិត្តិក្ខត្តុំ ចាតិមោក្ខេ ឧទ្ទិស្យមានេ ពោ បន ភាគោ ភិយ្យោតិ ន ច តស្ស ភិក្ខុនោ អញ្ញាណភោគេន មុត្តិ អត្ថិ យញ្ច តត្ថ អាបត្តី អាបន្នោ តញ្ច យថាធម្មោ ការេតព្ពោ ឧត្តរិញ្ចស្ស មោហោ អារោបេតព្ពោ ។ ឯវញ្ច បន ភិក្ខវេ អារោបេតព្ពោ ។ ញ្យត្តេន ភិក្ខុនា បដិពលេន សង្ឆោ ញ្ញាបេតព្ពោ សុណាតុ មេ ភន្តេ សង្ឆោ អយំ ឥត្ថ-ន្នាមោ ភិក្ខុ ចាតិមោក្ខេ ឧទ្ទិស្យមានេ ន សាធុកំ អដ្ឋ-កត្វា មនសិការោតិ ។ យទិ សង្ឆស្ស បត្តកល្ល សង្ឆោ ឥត្ថ្ថន្នាមស្ស ភិក្ខុនោ មោហំ អារោបេយ្យ ។ ឯសា ញ្ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ អយំ ឥត្ថ្ថន្នាមោ ភិក្ខុ ចាតិមោក្ខេ ឧទ្ទិស្យមានេ ន សាធុកំ អដ្ឋិកត្វា មនសិការោតិ ។ សង្ឆោ ឥត្ថ្ថន្នាមស្ស

[៣០៩] ពាក្យថា បើ (ភិក្ខុទាំងឡាយដទៃដឹង) នូវភិក្ខុនោះ សេចក្តីថា ភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុអ្នកប្រាជ្ញានូវសេចក្តីវង្វេងថា ភិក្ខុនេះធ្លាប់អង្គុយ (ស្តាប់) បាតិមោក្ខដែលភិក្ខុសំដែងអស់វារៈពីរបីដងហើយ នឹងពោលទៅថ្មីទៀតដល់ការស្តាប់ច្រើនដង សេចក្តីរួច (ចាកអាបត្តិ) ដោយអាការដែលមិនដឹងមិនមានដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវអាបត្តិណា ក្នុងរឿងអនាចារនោះ សង្ឆគប្បីញ៉ាំងភិក្ខុនោះ ឲ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ ម្យ៉ាងទៀត គប្បីលើកសេចក្តីវង្វេង គឺមោហារោបនកម្មដល់ភិក្ខុនោះថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ សង្ឆគប្បីលើកមោហារោបន-កម្មឡើងយ៉ាងនេះ ។ ភិក្ខុដែលជាអ្នកឈ្វាស អង់អាច គប្បីញ៉ាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អឡើយ ។ បើមោហារោបនកម្ម មានកាលដ៏សមគួរដល់សង្ឆហើយ សង្ឆគប្បីលើកមោហារោបនកម្ម ដល់ភិក្ខុឈ្មោះនេះ ។ នេះជាវាចាប្រកាសឲ្យសង្ឆដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អទេ ។ ឥឡូវនេះ សង្ឆលើកនូវ

ភិក្ខុនោ មោហំ អាវេបេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ មោហស្ស អាវេបនា សោ តុណ្ហីភាវ យស្ស ឧក្ខមតិ សោ ភាសេយ្យ ។ អាវេ-បិតោ សង្ឆេន ឥត្ថន្នាមស្ស ភិក្ខុនោ មោហោ ។ ខមតិ សង្ឆស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៣១០] អនាវេបិតេ មោហេ មោហេតិ អាបត្តិ ទុក្កដស្ស ។ អាវេបិតេ មោហេ មោហេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣១១] ឧម្មត្តកេ ឧម្មត្តកសញ្ញី មោហេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧម្មត្តកេ វេមតិកោ មោហេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧម្មត្តកេ អឧម្មត្តកសញ្ញី មោហេតិ អាបត្តិ ចាចិត្តិយស្ស ។ អឧម្មត្តកេ

មោហារោបនកម្មដល់ភិក្ខុឈ្មោះនេះ ។ ការលើកមោហារោបនកម្ម ដល់ភិក្ខុឈ្មោះនេះគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ មោហារោបនកម្ម សង្ឆបានលើកឡើងហើយដល់ភិក្ខុឈ្មោះនេះ ។ ការលើកមោហារោបនកម្មនេះ សមគួរដល់សង្ឆ ហេតុនោះសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវមោហារោបនកម្មនេះ ដោយការស្ងៀមនៅយ៉ាងនេះ ។

[៣១០] កាលមោហារោបនកម្ម សង្ឆមិនទាន់លើកឡើងទេ បើភិក្ខុក្ងែងធ្វើវង្វេង ត្រូវអាបត្តិទុក្កដ ។ កាលមោហារោបនកម្ម សង្ឆលើកឡើងហើយ ភិក្ខុនៅក្ងែងធ្វើវង្វេងទៀត ត្រូវអាបត្តិបាចិត្តិយ ។

[៣១១] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយក្ងែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្សយ ហើយក្ងែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយក្ងែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា

ឆម្ម្ហកម្ម្ហសញ្ញី អាបត្តិ ទុក្ខ្ជ ។ អ ឆ ម្ម្ហ ក ម្ម្ហ
ម ម ត ិ ។ ។ ។

កម្មប្រកបដោយធម៌ ហើយ (ក្លែងធ្វើវង្វេង) ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣១២] *ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុមិនទាន់បានស្តាប់បាតិមោក្ខដោយពិស្តារ ១ ភិក្ខុស្តាប់បាតិមោក្ខដោយពិស្តារអស់ភារៈមិនទាន់ដល់ពីរបីដង ១ ភិក្ខុមិនប៉ង់នឹងក្លែងធ្វើវង្វេង ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៣ ចប់ ។

ចតុត្ថសិក្ខាបទំ

[៣១៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ភុបិតា អនត្ត-
មនា សត្ត្រសវត្ថិយានំ ភិក្ខូនំ បហារំ ទេន្តិ ។ តេ
ភេទន្តិ ។ ភិក្ខូ ឍវមាហំសុ ភិស្ស តុម្ហេ អាវុសោ
ភេទថាតិ ។ ឥមេ អាវុសោ ឆព្ភក្ខិយា ភិក្ខូ ភុបិតា
អនត្តមនា អម្ហាកំ បហារំ ទេន្តីតិ ។ យេ តេ ភិក្ខូ
អប្ឍិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ភេ
ហិ ជាម ឆព្ភក្ខិយា ភិក្ខូ ភុបិតា អនត្តមនា ភិក្ខូនំ
បហារំ ឧស្ឍន្តីតិ ។ បេ ។ សច្ចំ ភិរ តុម្ហេ ភិក្ខូ
ភុបិតា អនត្តមនា ភិក្ខូនំ បហារំ ទេថាតិ ។ សច្ចំ
ភគវាតិ ។ វិតរហិ ពុទ្ធោ ភគវា ភេ ហិ ជាម
តុម្ហេ មោឃបុរិសា ភុបិតា អនត្តមនា ភិក្ខូនំ បហារំ
ឧស្ឍថ ទេតំ មោឃបុរិសា អប្ឍសន្ធានំ វ បសាទាយ

សិក្ខាបទទី ៤

[៣១៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង
ពួកឆព្វគ្គិយភិក្ខុក្រោធខឹង ហើយឲ្យប្រហារដល់ពួកសត្តរសវគ្គិយភិក្ខុ
(ភិក្ខុមានពួក ១៧) ។ សត្តរសវគ្គិយភិក្ខុទាំងនោះនាំគ្នាស្រែកយំ ។ ភិក្ខុ
ទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ អ្នកទាំងឡាយ ហេតុអ្វី
បានជាយំ ។ ពួកសត្តរសវគ្គិយភិក្ខុឆ្វើយថា ម្នាលអាវុសោ ពួកឆព្វគ្គិយ-
ភិក្ខុទាំងនេះ ក្រោធខឹងបានឲ្យប្រហារដល់ពួកយើង ។ ភិក្ខុទាំងឡាយណា
មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល
បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងក្រោធខឹង ហើយទៅប្រហារភិក្ខុ
ទាំងឡាយសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ
ទាំងឡាយ ឮថាអ្នកទាំងឡាយក្រោធខឹង ហើយនាំគ្នាប្រហារភិក្ខុទាំង-
ឡាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តា
ប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា
ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងក្រោធខឹង ហើយនាំគ្នា
ប្រហារភិក្ខុទាំងឡាយទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំ

បសន្នានំ វា កិយ្យោ ការាយ ។ បេ ។ ឯវញ្ហ បន
ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន
ភិក្ខុ ភិក្ខុស្ស ការ្ហ ការ្ហ ។ ការ្ហ ។ ការ្ហ ។

ឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្រោធខឹង ហើយឲ្យប្រហារដល់ភិក្ខុផងគ្នា ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ពាក្យថា ដល់ភិក្ខុផងគ្នា គឺដល់ភិក្ខុដទៃ ។ ពាក្យថា ក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តគុំគួន មានចិត្តរឹងត្អឹង ។ ពាក្យថា ឲ្យប្រហារ គឺឲ្យប្រហារដោយកាយក្តី ដោយវត្ថុជាប់នឹងកាយក្តី ដោយវត្ថុសម្រាប់ចោលក្តី ដោយហោចទៅសូម្បីតែដោយស្វឹកព្រលិត ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៥] ឧបសម្បន្ន[1] ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយក្រោធខឹងឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្រោធខឹងឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា ជាអនុបសម្បន្ន[2] ហើយក្រោធខឹងឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោធខឹង ហើយឲ្យប្រហារ ដល់អនុបសម្បន្ន

---

១ បានដល់ភិក្ខុ ។ ២ បានដល់ជនមិនមែនភិក្ខុ ។

អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ ឧបសម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ អនុបសម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣១៦] អនាបត្តិ ភេសជ្ជេ ឧ្ជ្ជ្ជ

ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិ ទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ (ហើយឲ្យប្រហារ) ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវ អាបត្តិទុក្កដ ។

[៣១៦] *វារៈដែលមិនត្រូវអាបត្តិ* (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) *គឺភិក្ខុដែលជនណាមួយបៀតបៀនហើយមានសេចក្តីប្រាថ្នា ដើម្បីនឹងឲ្យ រួចខ្លួនក៏ឲ្យប្រហារទៅវិញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៤ ចប់ ។

បញ្ចមសិក្ខាបទំ

[៣១៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ភុបិតា អនត្តមនា សត្ថុសាសនក្ខិយានំ ភិក្ខូនំ តលសត្ថិកំ ឧក្ខិវន្តិ ។ តេ បហារសមុច្ចិតា ហោន្តិ ។ ភិក្ខូ ឱវាទាយ ភិក្ខុ តុម្ហេ អាវុសោ ហោថ ។ ឥមេ អាវុសោ ឆព្ភក្ខិយា ភិក្ខូ ភុបិតា អនត្តមនា អម្ហាកំ តលសត្ថិកំ ឧក្ខ-ិវន្តីតិ ។ យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ភគ្គ ហិ ជាម ឆព្ភក្ខិយា ភិក្ខូ ភុបិតា អនត្តមនា[1] ភិក្ខូនំ តលសត្ថិកំ ឧក្ខិវិស្ស្ជន្តីតិ ។ បេ ។ សច្ចំ ភិរ តុម្ហេ ភិក្ខវេ ភុបិតា អនត្តមនា ភិក្ខូនំ តលសត្ថិកំ ឧក្ខិវថាតិ ។ សច្ចំ ភគ្ភវាតិ ។ វិតរហិ ពុទ្ធោ ភគ្ភ ភគ្ភ ហិ ជាម តុម្ហេ មោឃបុរិសា ភុបិតា អនត្តមនា ភិក្ខូនំ តលសត្ថិកំ ឧក្ខិវិស្ស្ជ

---

១ ឯត្ថន្តរេ សត្ថុសាសនក្ខិយានន្តិ ភត្ថ ចិ ហោ ត្ថ ភ ។

សិក្ខាបទទី ៥

[៣១៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកធព្ធគ្គិយភិក្ខុក្រោធខឹង ហើយងាលំពែងគឺបាតដៃឡើងសំដៅពួកសត្តរស-វគ្គិយភិក្ខុ (ធ្វើអាការបីដូចជានឹងវាយ) សត្តរសវគ្គិយភិក្ខុទាំងនោះ ទើបតែនឹងរួចអំពីប្រហារមកហើយ (មានសេចក្ដីភិតភ័យ) ក៏នាំគ្នាយំ ។ ភិក្ខុទាំង-ឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វី បានជាពួកអ្នកយំ ។ សត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ធព្ធគ្គិយភិក្ខុទាំងនេះ ក្រោធខឹង ហើយងាបាតដៃឡើងដូចជាលំពែងសំដៅពួកយើង ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកធព្ធគ្គិយភិក្ខុមិនគួរនឹងក្រោធខឹងហើយងាបាតដៃឡើង ដូចជាលំពែងសំដៅភិក្ខុផងគ្នាសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយក្រោធខឹង ហើយងាបាតដៃឡើង ដូចជាលំពែងសំដៅភិក្ខុទាំងឡាយ ពិតមែនឬ ។ ពួកធព្ធគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាជ្រាស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងក្រោធខឹង ហើយងាបាតដៃឡើង ដូចជាលំពែងសំដៅភិក្ខុទាំងឡាយទេ

ឆេតំ មោឃបុរិសា អប្ឋសន្ថានំ វា បសាទាយ
បសន្ថានំ វា កិយ្យាការាយ ។ បេ ។ ឯវញ្ហ បន
ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន
ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ ឆលសត្តិកំ
ឧក្ខិបេយ្យ ចាចិត្តិយន្តិ ។

[៣១៨] យោ បជានាតិ យោ យានិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ឋេតោ ភិក្ខូតិ ។
ភិក្ខុស្ឆាតិ អញ្ញស្ស ភិក្ខុស្ស ។ កុបិតោ អនត្តមនោតិ
អនភិរទ្ធោ អាហតចិត្តោ ទ្ទិលជាតោ ។ ឆលសត្តិកំ
ឧក្ខិបេយ្យាតិ កាយំ វា កាយប្ឋដិពទ្ធំ វា អន្ថមសោ
ឧប្ឋលបត្ថំបិ ឧច្ចារេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣១៩] ឧបសម្ឋន្ថេ ឧបសម្ឋន្ថសញ្ញី កុបិតោ
អនត្តមនោ ឆលសត្តិកំ ឧក្ខិរតិ អាបត្តិ ចាចិត្តិយស្ស ។
ឧបសម្ឋន្ថេ វេមតិកោ កុបិតោ អនត្តមនោ ឆល-
សត្តិកំ ឧក្ខិរតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ឋន្ថេ
អនុបសម្ឋន្ថសញ្ញី កុបិតោ អនត្តមនោ ឆលសត្តិកំ
ឧក្ខិរតិ អាបត្តិ ចាចិត្តិយស្ស ។ អនុបសម្ឋន្ថស្ស

ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្រោធខឹង ហើយងាឡើងនូវលំពែងគឺបាតដៃសំដៅភិក្ខុផងគ្នា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៣១៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា សំដៅភិក្ខុផងគ្នា គឺសំដៅភិក្ខុដទៃ ។ ពាក្យថា ក្រោធខឹង គឺមានចិត្តមិនត្រេកអរ មានចិត្តគុំគួន មានចិត្តរឹងត្អឹង ។ ពាក្យថា ងាឡើងនូវលំពែងគឺបាតដៃ សេចក្តីថា ភិក្ខុលើកកាយក្តី លើកវត្ថុជាប់នឹងកាយក្តី ឡើងជន្ល ដោយហោចទៅសូម្បីតែស្វឹកព្រលិត ត្រូវអាបត្តិបាចិត្តិយ ។

[៣១៩] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយក្រោធខឹងងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្រោធខឹងងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ហើយក្រោធខឹងងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោធខឹងដល់

ភិក្ខុបិតោ អនត្តមនោ តលសត្តិកំ ឧក្ខិបតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣២០] អនាបត្តិ កោនចិ វិហេឋិយមានោ មោក្ខាធិប្បាយោ តលសត្តិកំ ឧក្ខិបតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

អនុបសម្ផន្ន ហើយដាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិទុក្កដ ។ អនុបសម្ផន្ន ភិក្ខុសំគាល់ថា ឧបសម្ផន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្ផន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្ផន្ន ភិក្ខុសំគាល់ថា អនុបសម្ផន្ន ត្រូវអាបត្តិទុក្កដ ។

[៣២០] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបនេះមាន ៣ យ៉ាង) គឺ ភិក្ខុដែលជនណាមួយ បៀតបៀនហើយមានសេចក្តីប្រាថ្នាដើម្បីនឹងឲ្យ រួចខ្លួនក៏ដាលំពែងគឺបាតដៃឡើង ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៥ ចប់ ។

ឆដ្ឋសិក្ខាបទំ

[៣២១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ភិក្ខុំ អមូលកេន
សង្ឆាទិសេសេន អនុទ្ធំសេន្តិ ។ យេ តេ ភិក្ខូ អប្ឆិន្ន
។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម
ឆព្ភក្ខិយា ភិក្ខូ ភិក្ខុំ អមូលកេន សង្ឆាទិសេសេន
អនុទ្ធំសេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ
ភិក្ខុំ អមូលកេន សង្ឆាទិសេសេន អនុទ្ធំសេថាតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ
នាម តុម្ហេ មោឃបុរិសា ភិក្ខុំ អមូលកេន សង្ឆាទិ-
សេសេន អនុទ្ធំសេស្សថ នេតំ មោឃបុរិសា អប្ប-
សន្ថានំ វា បសាទាយ បសន្ថានំ វា កិយ្យោការាយ

សិក្ខាបទទី ៦

[៣២១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្ភ-គ្គិយភិក្ខុនាំគ្នាកំចាត់ (គឺចោទ) ភិក្ខុផងគ្នាដោយអាបត្តិសង្ឆាទិសេសមិនមានមូល ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំង-ឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្ភគ្គិយភិក្ខុមិនគួរនឹងចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឆាទិសេសមិនមានមូលសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ ចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឆាទិសេសមិនមានមូល ពិតមែនឬ ។ ពួកឆព្ភគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឆាទិសេសមិនមានមូលទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ

។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ អមូលកេន សង្ឆាទិសេសេន អនុទ្ធំសេយ្យ ចាចិត្តិយន្តិ ។

[៣២២] យោ បជានាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ប្រេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញ ភិក្ខុំ ។ អមូលកំ ជាម អធិដ្ឋ អសុតំ អបរិសុទ្ធិតំ ។ សង្ឆាទិសេសេជានាតិ តេរសន្ធ អញ្ញតរេន ។ អនុទ្ធំសេយ្យាតិ ចោទេតិ វា ចោជាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។

[៣២៣] ឧបសម្ប្ជេ ឧបសម្ប្ជន្ធសញ្ញី អមូលកេន សង្ឆាទិសេសេន អនុទ្ធំសេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ប្ជេ វេមតិកោ អមូលកេន សង្ឆាទិសេសេន អនុទ្ធំសេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ប្ជេ អនុ-បសម្ប្ជន្ធសញ្ញី អមូលកេន សង្ឆាទិសេសេន អនុទ្ធ-សេតិ អាបត្តិ ចាចិត្តិយស្ស ។ អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អនុទ្ធំសេតិ អាបត្តិ ទុក្កដស្ស ។

។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឆាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។

[៣២២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុដទៃ ។ ដែលហៅថា មិនមានមូល គឺអាបត្តិសង្ឆាទិសេសដែលខ្លួនមិនបានឃើញ មិនបានឮ មិនបានរង្កៀស ។ ពាក្យថា ដោយអាបត្តិសង្ឆាទិសេស គឺបណ្តាសង្ឆាទិសេសទាំង ១៣ សិក្ខាបទ សិក្ខាបទណាមួយ ។ ពាក្យថា ចោទ សេចក្តីថា ភិក្ខុចោទឯងក្តី ប្រើគេឲ្យចោទក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៣២៣] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយចោទដោយអាបត្តិសង្ឆាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយចោទដោយអាបត្តិសង្ឆាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ហើយចោទដោយអាបត្តិសង្ឆាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុចោទដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ត្រូវអាបត្តិទុក្កដ ។

អនុបសម្បន្នំ អនុទ្ទំសេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុប-សម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣២៤] អនាបត្តិ តថាសញ្ញី ចោទេតិ វា ចោទា-បេតិ វា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុចោទអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន (ហើយចោទ) ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុ-បសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[៣២៧] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុមានសេចក្តីសំគាល់ពិតមែនហើយចោទឯងក្តី ប្រើគេឲ្យចោទក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៦ ចប់ ។

សត្តមសិក្ខាបទំ

[៣២៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយានំ
ភិក្ខូនំ សញ្ជិច្ច ការ្ណ្ណុំ ឧបនហន្តិ ភគវតា អាវុសោ
សិក្ខាបទំ បញ្ញត្តំ ន ឈានីសតិវស្សា បុគ្គលោ ឧប-
សម្ផាទេតព្ពោតិ តុម្ហេ ច ឈានីសតិវស្សា ឧបសម្ផន្នា
ការ្ណ្ណ ជោ តុម្ហេ អនុបសម្ផន្នាតិ ។ តេ ពោធន្តិ ។
ភិក្ខូ ឯវមាហំសុ ការ្ណ្ណ តុម្ហេ អាវុសោ ពោធថាតិ ។
ឥមេ អាវុសោ ឆព្វគ្គិយា ភិក្ខូ អម្ហាកំ សញ្ជិច្ច ការ្ណ្ណុំ
ឧបនហន្តីតិ ។ យេ តេ ភិក្ខូ អប្ផិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ការ្ណ្ណ ហិ នាម ឆព្វគ្គិយា
ភិក្ខូ[1] ភិក្ខូនំ សញ្ជិច្ច ការ្ណ្ណុំ ឧបនហិស្សន្តីតិ ។ បេ ។
សច្ចំ ការ តុម្ហេ ភិក្ខវេ ភិក្ខូនំ សញ្ជិច្ច ការ្ណ្ណុំ

---

១ ឯត្ថន្តរេ សត្តរសវគ្គិយានន្តិបិ ការ្ណ្ណ ចិ ពោត្តកេ អត្ថិ ។

សិក្ខាបទទី ៧

[៣២៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង
ពួកឆព្វគ្គិយភិក្ខុ ក្ងែងបង្ក្រហេតុឲ្យមានសេចក្ដីរង្ការសសង្ស័យកើតដល់ពួក
សត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់
បញ្ញត្តទុកហើយថា បុគ្គលមានឆ្នាំថយពី ២០ សង្ឆមិនគប្បីឲ្យឧបសម្បទា
ឡើយ ចំណែកពួកលោកមានអាយុមិនទាន់ដល់ ២០ ឆ្នាំមកទទួលឧប-
សម្បទា ពួកលោកមិនមែនជាឧបសម្បន្នទេដឹង ។ សត្តរសវគ្គិយ-
ភិក្ខុទាំងនោះក៏នាំគ្នាយំ ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុ-
សោ ពួកលោកយំ ព្រោះអ្វី ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា អាវុសោ
ឆព្វគ្គិយភិក្ខុទាំងនេះ ក្ងែងបង្ក្រហេតុឲ្យមានសេចក្ដីរង្ការសសង្ស័យ ដល់
ពួកយើង ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុ
ទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិន
គួរនឹងបង្ក្រហេតុឲ្យមានសេចក្ដីរង្ការសសង្ស័យ ដល់ភិក្ខុទាំងឡាយផង
គ្នាសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ
ឮថា ពួកអ្នកឯងក្ងែងបង្ក្រហេតុ ឲ្យមានសេចក្ដីរង្ការសសង្ស័យដល់ភិក្ខុ

ឧបនហាថាតិ ។ សចេ ភគវាតិ ។ វិតរហិ ពុទ្ធោ ភគវា ឥមំ ហិ ជាម តុម្ហេ មោឃបុរិសា ឥត្ថិំ សញ្ចិច្ច ឥត្ថិ ឧបនហិស្សថ នេតំ មោឃបុរិសា អប្ប្ សន្ថានំ វ បសាទាយ បសន្ថានំ វ ឥត្ថ-ភាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស សញ្ចិច្ច ឥត្ថិ ឧបនហេយ្យ ឥតិស្ស មុហុត្តម្ប្ យ អជ្ជាសុ ភវិស្ស្ តីតិ ឯតនេវ បច្ចយំ ឥត្ថ្ យ អនញ្ញ ចាចិត្តិយន្តិ ។

[៣២៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្ម្ អត្ថ អធិ ប្ បេ ។ ភិក្ខូតិ ។ ភិក្ខុ ស្ សតិ អញ្ញ ភិក្ខុ ។ សញ្ចិ ច្ចាតិ ជានន្តោ សញ្ជានន្តោ ចេ ច អ ភ ិ ត ិ ត ្ យ ។ ឥត្ថ ិ ។ ឧ ន ្ ម ី ស ត ិ ។ ។ ។

ទាំងឡាយផងគ្នា ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងកើតមានបង្ក ឲ្យមានសេចក្តីរង្គៀសសង្ស័យដល់ភិក្ខុទាំងឡាយផងគ្នាទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកើតមានបង្ក ឲ្យមានសេចក្តីរង្គៀសសង្ស័យ ដល់ភិក្ខុផងគ្នាដោយគិតថា (សេចក្តីរង្គៀសសង្ស័យនេះ) កើតឡើង ការមិនសប្បាយចិត្តនឹងមានដល់ភិក្ខុនោះ ១ រំពេចមិនខាន ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើសេចក្តីរង្គៀសសង្ស័យនោះឯងជាហេតុពិត មិនមែនហេតុដទៃឡើយ ។

[៣២៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ដល់ភិក្ខុផងគ្នា គឺដល់ភិក្ខុដទៃ ។ ពាក្យថា ក្ងេង សេចក្តីថា ភិក្ខុដឹងគឺដឹងជាក់ ក្ងេងល្មើសប្រព្រឹត្តកន្ទង ។ ពាក្យថា បង្ក ឲ្យមានសេចក្តីរង្គៀសសង្ស័យ សេចក្តីថា ភិក្ខុណាបង្ក ឲ្យមានសេចក្តីរង្គៀសសង្ស័យថា លោកទំនង

ឧបសម្ផន្នោ វិកាលេ មញ្ញេ តយា ភុត្តំ មជ្ជំ មញ្ញេ តយា បីតំ មាតុក្ការមេន សន្ធ្វី រហោ មញ្ញេ តយា ជិសិន្ធន្តិ ការ្ចុំ ឧបឧហតិ អាបត្តិ ចាចិត្តិយស្ស ។ ឯតនេវ បច្ចយំ ការ្ចា អនញ្ញន្តិ ន អញ្ញោ ការ្ចិ បច្ចយោ ហោតិ ការ្ចុំ ឧបឧហិតុំ ។

[៣២៧] ឧបសម្ផន្នេ ឧបសម្ផន្នសញ្ញី សញ្ចិ ការ្ចុំ ឧបឧហតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ផន្នេ វេមតិការ សញ្ចិ ការ្ចុំ ឧបឧហតិ អាបត្តិ ចា-ចិត្តិយស្ស ។ ឧបសម្ផន្នេ អនុបសម្ផន្នសញ្ញី សញ្ចិ ការ្ចុំ ឧបឧហតិ អាបត្តិ ចាចិត្តិយស្ស ។ អនុប-សម្ផន្នស្ស សញ្ចិ ការ្ចុំ ឧបឧហតិ អាបត្តិ ទុក្ការ្ចជ្ជស្ស ។ អនុបសម្ផន្នេ ឧបសម្ផន្នសញ្ញី អាបត្តិ ទុក្ការ្ចជ្ជស្ស ។ អនុបសម្ផន្នេ វេមតិការ អាបត្តិ ទុក្ការ-ជ្ជស្ស ។ អនុបសម្ផន្នេ អនុបសម្ផន្នសញ្ញី អាបត្តិ ទុក្ការ្ចជ្ជស្ស ។

ជាមានឆ្នាំមិនទាន់គ្រប់ ២០ ហើយឧបសម្បទាទេដឹង លោកបរិភោគអាហារក្នុងវេលាវិកាលទេដឹង លោកផឹកទឹកស្រវឹងទេដឹង លោកអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមទេដឹង ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើសេចក្តីរង្គៀសសង្ស័យនោះឯងជាហេតុពិត មិនមែនហេតុដទៃទេឡើយ សេចក្តីថា ហេតុណាមួយដទៃគ្មាន ចំពោះត្រង់បង្ក ហេតុឲ្យមានសេចក្តីរង្គៀសសង្ស័យកើតឡើងប៉ុណ្ណោះឯង ។

[៣២៧] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយកៃ្វងផ្តើមសេចក្តីរង្គៀសសង្ស័យឲ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧប-សម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយកៃ្វងផ្តើមសេចក្តីរង្គៀសសង្ស័យឲ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ហើយកៃ្វងផ្តើមសេចក្តីរង្គៀសសង្ស័យឲ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុកៃ្វងផ្តើមសេចក្តីរង្គៀសសង្ស័យឲ្យកើតឡើងដល់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

បាចិត្តិយកណ្ឌ សហាធម្មិកវគ្គស្ស សត្តមសិក្ខាបទស្ស អនាបត្តិវារោ

[៣២៨] អនាបត្តិ ន ការ្ណកុ ចំ ឧបឧហិតុការ្ណោ ឧនវីសតិវស្សោ មញ្ញ តំ ឧបសម្ប ន្ធោ រ ការ្ណ លេ មញ្ញ តយ ការ្ណ តំ មជ្ជ មញ្ញ តយ ការ្ណ ត ការ្ណ ការ្ណ ការ្ណ

[៣២៨] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុមិនមានបំណង នឹងផ្តើមសេចក្តីរង្គៀសសង្ស័យឲ្យកើតឡើង តែពោល (តាមសេចក្តីយល់) ថា លោកប្រហែលមានឆ្នាំមិនទាន់ដល់ ២០ ហើយឧបសម្បទាទេដឹង លោកបរិភោគអាហារក្នុងវេលាវិកាលទេដឹង លោកផឹកទឹកស្រវឹងទេដឹង លោកអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមទេដឹង ណ្តើយចុះ លោកចូរដឹងចុះ លោកកុំរង្គៀសសង្ស័យស្តាយក្រោយឡើយ ១ ភិក្ខុឆ្គត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៧ ចប់ ។

អដ្ឋមសិក្ខាបទំ

[៣២៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ឃេសលេហិ
ភិក្ខូហិ សទ្ធឹ កណ្ហាន្តិ ។ ឃេសលា ភិក្ខូ ឍវំ វទេន្តិ
អលជ្ជិនោ ឥមេ អាវុសោ ឆព្ភក្ខិយា ភិក្ខូ ន សក្ការ
ឥមេហិ សហ ភណ្ឌិតុន្តិ ។ ឆព្ភក្ខិយា ភិក្ខូ ឍវំ វទេន្តិ
កិស្ស តុម្ហេ អាវុសោ អម្ហេ អលជ្ជិវាទេន ចោទេថាតិ ។
ភគវតោ បន តុម្ហេ អាវុសោ អស្សុត្ថាតិ ។ មយំ
អាយស្មន្តានំ ឧបស្សុតឺ តិដ្ឋាមាតិ ។ យេ តេ
ភិក្ខូ អប្ឆិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ
វិចារេន្តិ ភគវតោ ហិ ជាម ឆព្ភក្ខិយា ភិក្ខូ ភិក្ខូនំ
ភណ្ឌនជាតានំ ភគលហជាតានំ វិវាទជាតានំ ឧបស្សុតឺ
តិដ្ឋិស្សន្តីតិ ។ បេ ។ សច្ចំ ភិរ តុម្ហេ ភិក្ខវេ ភិក្ខូនំ
ភណ្ឌនជាតានំ ភគលហជាតានំ វិវាទជាតានំ ឧបស្សុតឺ
តិដ្ឋថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា

សិក្ខាបទទី ៨

[៣២៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង
ពួកឆព្វគ្គិយភិក្ខុឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ។
ពួកភិក្ខុដែលមានសីលជាទីស្រលាញ់និយាយគ្នាយ៉ាងនេះថា ម្នាលអាវុ-
សោ ឆព្វគ្គិយភិក្ខុទាំងនេះជាពួកអលជ្ជីទេ ពួកយើងមិនអាចឈ្លោះនឹងពួក
នេះទេ ។ ពួកឆព្វគ្គិយភិក្ខុ (បានឮ) ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ
ព្រោះហេតុអ្វី អ្នកទាំងឡាយញ៉ាំងពួកយើងឲ្យដល់ដោយពាក្យថា អលជ្ជី ។
ពួកភិក្ខុមានសីលជាទីស្រឡាញ់សួរថា ម្នាលអាវុសោ ចុះពួកអ្នកបានឮ
ក្នុងទីណា ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា យើងទាំងឡាយឈរអែបស្តាប់
ពួកលោកដ៏មានអាយុ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច
។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វ-
គ្គិយភិក្ខុ កាលភិក្ខុទាំងឡាយបង្ក្គហេតុ ប្រកួតប្រកាន់ ទាស់ទែងគ្នា មិនគួរ
នឹងឈរអែបស្តាប់សោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាល
ភិក្ខុទាំងឡាយ ឮថា កាលភិក្ខុទាំងឡាយបង្ក្គហេតុប្រកួតប្រកាន់ទាស់
ទែងគ្នា ពួកអ្នកឯងឈរអែបស្តាប់ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូល
ថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ

កថំ ហិ ជាម តុម្ហេ មោឃបុរិសា ភិក្ខូនំ ភណ្ឌនជាតានំ
កលហជាតានំ វិវាទជាបន្ធានំ ឧបស្សុតឺ តិដ្ឋិស្សថ
ឌេតំ មោឃបុរិសា អប្ឍសន្ធានំ វ បសាទាយ
បសន្ធានំ វ ភិយ្យោភាវាយ ។ បេ ។ ឯវញ្ហ បន
ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន
ភិក្ខុ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទ-
បន្ធានំ ឧបស្សុតឺ តិដ្ឋេយ្យ យំ ឥមេ ភណ្ឌិស្ឍន្តិ
តំ សោស្ឍាមីតិ ឯតេវ បច្ចយំ ការិត្ហា អនញ្ញ
ទាចិត្តិយន្តិ ។

[៣៣០] យោ បជានតិ យោ យាធិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឺ អត្ថ អធិប្ឍេតោ ភិក្ខូតិ ។
ភិក្ខូនន្តិ អញ្ញេសំ ភិក្ខូនំ ។ ភណ្ឌនជាតានំ កលហ-
ជាតានំ វិវាទជាបន្ធានន្តិ អធិការណជាតានំ ។ ឧបស្ឍតឺ
តិដ្ឋេយ្យាតិ ឥមេសំ សុត្ហា ចោឌេស្ឍាមិ សារេស្ឍាមិ
បដិចោឌេស្ឍាមិ បដិសារេស្ឍាមិ មញ្ជ្ជុ ការិស្ឍាមីតិ

ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ កាលបើភិក្ខុទាំងឡាយ បង្ក្គហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ពួកអ្នកឯងមិនគួរនឹងឈរអៃបស្តាប់ទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលបើភិក្ខុទាំងឡាយ បង្ក្គហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ទៅឈរអៃបស្តាប់ដោយគិតថា ភិក្ខុទាំងនេះនឹងពោលពាក្យណា អញនឹងស្តាប់ពាក្យនោះ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើកិរិយាឈរអៃបស្តាប់នោះជាហេតុពិត មិនមែនហេតុដទៃឡើយ ។

[៣៣០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា កាលបើភិក្ខុទាំងឡាយ គឺកាលបើភិក្ខុទាំងឡាយដទៃ ។ ពាក្យថា បង្ក្គហេតុប្រកួតប្រកាន់ទាស់ទែងគ្នា គឺភិក្ខុទាំងនោះមានអធិករណៈកើតឡើងហើយ ។ ពាក្យថា ឈរអៃបស្តាប់ គឺភិក្ខុដើរទៅដោយគិតថា អញស្តាប់ភិក្ខុទាំងនេះហើយនឹងចោទនឹងឲ្យរលឹក នឹងចោទចំពោះ នឹងឲ្យរលឹកចំពោះ នឹងធ្វើឲ្យអៀនខ្មាស

កច្ចតិ អាបត្តិ ទុក្កដស្ស ។ យត្ត បិតោ សុណាតិ អាបត្តិ ចាចិត្តិយស្ស ។ បច្ចតោ កច្ចន្តោ តុរិតោ កច្ចតិ សោស្សាមីតិ អាបត្តិ ទុក្កដស្ស ។ យត្ត បិតោ សុណាតិ អាបត្តិ ចាចិត្តិយស្ស ។ ឋិតោ កច្ចន្តោ ឋិហីយតិ សោស្សាមីតិ អាបត្តិ ទុក្កដស្ស ។ យត្ត បិតោ សុណាតិ អាបត្តិ ចាចិត្តិយស្ស ។ ភិក្ខុស្ស បិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាកង្ខា មន្តេន្តំ ឧក្កាសិតព្ពំ វិជានាបេតព្ពំ ។ ណោ ចេ ឧក្កាសេយ្យ វា វិជានាបេយ្យ វា អាបត្តិ ចាចិត្តិយស្ស ។ ឯតនេវ បច្ចយំ ការិត្វា អនញ្ញន្តិ ន អញ្ញោ ការ្យ បច្ចយោ ហោតិ ឧបស្សុតឹ តិដ្ឋិតុំ ។

[៣៣១] ឧបសម្ជន្ទ ឧបសម្ជន្ទសញ្ញី ឧប-ស្សុតឹ តិដ្ឋតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ជន្ទ ឧមតិការ ឧបស្សុតឹ តិដ្ឋតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្ជន្ទ អនុបសម្ជន្ទសញ្ញី ឧបស្សុតឹ តិដ្ឋតិ អាបត្តិ ចាចិត្តិយស្ស ។ អនុបសម្ជន្ទស្ស ឧបស្សុតឹ តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្ជន្ទ ឧបសម្ជន្ទសញ្ញី

ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះឈរស្តាប់ក្នុងទីណា ត្រូវអាបត្តិ
បាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុដើរទៅតាមក្រោយ បើដើរទៅដោយ
រហ័សដោយគិតថា អញនឹងស្តាប់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរស្តាប់
ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុដើរទៅមុនហើយ
ឈប់ដោយគិតថា អញនឹងស្តាប់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរស្តាប់
ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុណាមកកាន់ទី
ឈរក្តី ទីអង្គុយក្តី ទីដេកក្តី របស់ភិក្ខុផងគ្នា ភិក្ខុនោះគប្បីក្អក គប្បី
ញ៉ាំងភិក្ខុដែលកំពុងប្រឹក្សាគ្នានោះឲ្យដឹង ។ បើភិក្ខុនោះមិនក្អកគ្រហែមក្តី
មិនឲ្យគេដឹងក្តី ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើកិរិយាឈរ
អែបស្តាប់នោះជាហេតុពិត មិនមែនហេតុដទៃឡើយ សេចក្តីថា ហេតុ
ឯណានីមួយដទៃគ្មានទេ ចំពោះត្រង់ការឈរអែបស្តាប់ប៉ុណ្ណោះឯង ។

[៣៣១] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយឈរ
អែបស្តាប់ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ
ហើយឈរអែបស្តាប់ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា
អនុបសម្បន្ន ហើយឈរអែបស្តាប់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុឈរ
អែបស្តាប់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា

អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្ផន្នេ អនុបសម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣៣២] អនាបត្តិ ឥមេសំ សុត្វា ឱវមិស្សាមិ វិមិស្សាមិ រូបសមិស្សាមិ អត្ថានំ បរិមោចេស្សាមីតិ កច្ចតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នដដែល ត្រូវអាបត្តិទុក្កដ ។

[៣៣២] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដើរទៅដោយគិតថា អញនឹងស្តាប់ភិក្ខុទាំងនេះ ហើយនឹងថយចេញ នឹងវៀរនឹងរម្ងាប់ (សេចក្តីប្រកួតប្រកាន់) នឹងដោះខ្ជូន ១ ភិក្ខុធ្លុត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៨ ចប់ ។

នវមសិក្ខាបទំ

[៣៣៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ អនាចារំ
អាចរិត្វា ឯកមេកស្ស កម្មេ កយិរមានេ
បដិក្កោសន្តិ ។ តេន ខោ បន សមយេន សង្ឆោ
សន្និបតិតោ ហោតិ ភេជ្ជចិវេ ការណីយេន ។
ឆព្ភក្ខិយា ភិក្ខូ ចីវរកម្មំ ករោន្តា ឯកស្ស ឆន្ទំ
អទំសុ ។ អថខោ សង្ឆោ អយំ អាវុសោ ឆព្ភក្ខិ-
យោ ភិក្ខុ ឯកោ អាគតោ ហន្ទស្ស មយំ កម្មំ
ករោមាតិ តស្ស កម្មំ អកាសិ ។ អថខោ សោ
ភិក្ខុ យេន ឆព្ភក្ខិយា ភិក្ខូ តេនុបសង្ក្រមិ ។
ឆព្ភក្ខិយា ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ ភិ អាវុសោ
សង្ឆោ អកាសីតិ ។ សង្ឆោ មេ អាវុសោ កម្មំ
អកាសីតិ ។ ន មយំ អាវុសោ ឯតទត្ថាយ
ឆន្ទំ អទម្ហា តុយ្ហំ កម្មំ ការិស្សតីតិ សចេ មយំ
ជានេយ្យាម តុយ្ហំ កម្មំ ការិស្សតីតិ ន មយំ ឆន្ទំ

សិក្ខាបទទី ៩

[៣៣៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួក
ឆព្វគ្គិយភិក្ខុ បានប្រព្រឹត្តអនាចារ កាលសង្ឆធ្វើកម្ម (ដើម្បីដាក់ទោស)
ដល់ភិក្ខុមួយរូប ។ ក៏នាំគ្នានិយាយខ្ជាស់ ។ គ្រានោះឯង សង្ឆបាន
ប្រជុំគ្នាដោយសង្ឆកិច្ចនីមួយ ។ ទើបពួកឆព្វគ្គិយភិក្ខុ កំពុងធ្វើចីវរកម្ម
បានឲ្យឆន្ទៈ (សេចក្តីគាប់ចិត្តរបស់ខ្លួន) ដល់ភិក្ខុមួយរូប ។ គ្រានោះឯង
សង្ឆប្រឹក្សាគ្នាថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុនេះមកតែម្នាក់ឯង បើដូច្នោះ
ពួកយើងត្រូវធ្វើកម្មដល់ភិក្ខុនោះចុះ ហើយបានធ្វើកម្មដល់ភិក្ខុនោះ ។
ទើបភិក្ខុនោះ ចូលទៅរកពួកឆព្វគ្គិយភិក្ខុ ។ ពួកឆព្វគ្គិយភិក្ខុបានសួរភិក្ខុ
នោះយ៉ាងនេះថា ម្នាលអាវុសោ សង្ឆបានធ្វើអ្វី ។ ភិក្ខុនោះប្រាប់
ថា ម្នាលអាវុសោ សង្ឆបានធ្វើកម្មដល់ខ្ញុំ ។ ពួកឆព្វគ្គិយភិក្ខុបាន
និយាយថា ម្នាលអាវុសោ យើងទាំងឡាយបានឲ្យឆន្ទៈ ដើម្បីជា
ប្រយោជន៍ដល់កម្មនេះដោយគិតថា សង្ឆនឹងធ្វើកម្មដល់លោកក៏ទេ បើ
យើងទាំងឡាយដឹងថា សង្ឆនឹងធ្វើកម្មដល់លោកសោត យើងទាំងឡាយ

ឧនេយ្យាមាតិ ។ យេ តេ ភិក្ខូ អប្ជិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ឆព្ភក្តិយា ភិក្ខូ ឆម្ជិកានំ កម្មានំ ឆន្ទំ ឧត្វា បច្ឆា ខីយនធម្មំ អាបជ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឆម្ជិកានំ កម្មានំ ឆន្ទំ ឧត្វា បច្ឆា ខីយនធម្មំ អាបជ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃ-បុរិសា ឆម្ជិកានំ កម្មានំ ឆន្ទំ ឧត្វា បច្ឆា ខីយនធម្មំ អាបជ្ជិស្សថ នេតំ មោឃបុរិសា អប្ឋសន្ធានំ វា បសា-ទាយ បសន្ធានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឆម្ជិកានំ កម្មានំ ឆន្ទំ ឧត្វា បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ ចាចិត្តិយន្តិ ។

[៣៣៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ឋេតោ ភិក្ខូ-តិ ។ ឆម្ជិកំ នាម កម្មំ អបលោកនកម្មំ ញត្តិកម្មំ

មិនឲ្យធ្ន:ទេ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកធព្ធគ្គិយភិក្ខុមិនគួរនឹងឲ្យធ្ន:ដល់សង្ឆកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងរាល់គ្នាឲ្យធ្ន: ដើម្បីសង្ឆ-កម្មដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញពិតមែនឬ ។ ពួកធព្ធគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងឲ្យធ្ន:ដើម្បីសង្ឆកម្មប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ឲ្យធ្ន:ដើម្បីកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយពោលតិះដៀលជាខាងក្រោយ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៦] *ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ កម្មដែលហៅថា ប្រកបដោយធម៌នោះ*

ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ឧម្មេន វិនយេន សត្ថុ សាសនេន កតំ ឯតំ ឧម្មិកំ ជាម កម្មំ ។ ឆន្ទំ ឧត្វា ទីយតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៣៥] ឧម្មកម្មេ ឧម្មកម្មសញ្ញី ឆន្ទំ ឧត្វា ទីយតិ អាបត្តិ ចាចិត្តិយស្ស ។ ឧម្មកម្មេ វេមតិកោ ឆន្ទំ ឧត្វា ទីយតិ អាបត្តិ ទុក្កដស្ស ។ ឧម្មកម្មេ អឧម្មកម្មសញ្ញី ឆន្ទំ ឧត្វា ទីយតិ អនាបត្តិ ។ អឧម្ម-កម្មេ ឧម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អឧម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អឧម្មកម្មេ អឧម្ម-កម្មសញ្ញី អនាបត្តិ ។

[៣៣៦] អនាបត្តិ អឧម្មេន វា វត្ថេន វា ឧ-ម្មារហស្ស វា កម្មំ កតន្តិ ជានន្តោ ទីយតិ ឧម្មត្ត-កស្ស អានិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ដែលសង្ឆ ធ្វើតាមធម៌ តាមវិន័យ តាមពាក្យប្រដៅរបស់ព្រះសាស្តា កម្មនេះ ហៅថា កម្មប្រកបដោយធម៌ ។ ភិក្ខុព្រមឲ្យឆន្ទ: ហើយត្រឡប់តិះដៀល (ជាខាងក្រោយវិញ) ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៥] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យឆន្ទ:ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យឆន្ទ:ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិទុក្កដ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឆន្ទ: ត្រឡប់តិះដៀល មិនត្រូវអាបត្តិអ្វី ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ (ហើយឲ្យឆន្ទ:ត្រឡប់តិះដៀល) ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិអ្វី ។

[៣៣៦] វារ:ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដឹងថា កម្មដែលសង្ឆ ធ្វើដោយមិនជាធម៌ក្តី ដោយពួកក្តី ដល់ភិក្ខុអ្នកមិនគួរដល់កម្មក្តី ហើយតិះដៀល ១ ភិក្ខុឆ្គត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[៣៣៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សង្ឆោ សន្ថិបតិតោ ហោតិ គេនចិទេវ ការណីយេន ។ ឆព្ពគ្គិយា ភិក្ខូ ចីវរកម្មំ ការេន្តា ឯកស្ស ឆន្ទំ អទំសុ ។ អថខោ សង្ឆោ យស្ស្តាយ សន្ថិបតិតោ តំ កម្មំ ការិស្សាមាតិ ញត្តឺ ឋបេសិ ។ អថខោ សោ ភិក្ខុ ឯវមេវ ឯកមេកស្ស កម្មំ ការេន្តិ ការេ ។ ១ ។ ១ ។ ១

សិក្ខាបទទី ១០

[៣៣៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ
វត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង
សង្ឆបានប្រជុំគ្នាដោយសង្ឆកិច្ចឯណានីមួយ ។ ពួកឆព្វគ្គិយភិក្ខុកំពុង
ធ្វើចីវរហើយបានឲ្យឆន្ទៈដល់ភិក្ខុមួយរូប ។ គ្រានោះឯង សង្ឆប្រជុំគ្នាដើម្បី
ប្រយោជន៍ដល់កម្មណា ហើយតាំងញត្តិឡើងដោយប្រឹក្សាគ្នាថា យើង
ទាំងឡាយនឹងធ្វើនូវកម្មនោះ ។ ខណៈនោះ ភិក្ខុនោះបាននិយាយថា ភិក្ខុ
ទាំងនេះតែងធ្វើកម្មដល់ភិក្ខុមួយរូប ។ យ៉ាងនេះឯង (ឥឡូវ) លោកទាំង-
ឡាយនឹងធ្វើកម្មដល់អ្នកណាបាន ហើយមិនឲ្យឆន្ទៈក៏ក្រោកចាកអាសនៈ
ចៀសចេញទៅ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។
ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្ទុះបង្ហាប់ថា កាលសង្ឆកំពុង
ប្រឹក្សាវិនិច្ឆ័យ ភិក្ខុមិនបានឲ្យឆន្ទៈ មិនគួរនឹងក្រោកចាកអាសនៈចៀស
ចេញទៅសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា
កាលសង្ឆកំពុងប្រឹក្សាវិនិច្ឆ័យ (គឺសង្ឆកំពុងវិនិច្ឆ័យរឿងអ្វីមួយមិនទាន់
ហើយ) អ្នកឯងមិនបានឲ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅ
ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។

វិតរហិ ពុទ្ធោ ភគវា ភិក្ខូ ហិ ជាម ត្វំ មោឃបុរិស សង្ឆេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កាមិ ស្ស្ សិ ឌេតំ មោឃបុរិស អប្ប្ សន្ថានំ វ បសាទាយ បសន្ថានំ វ ភិយ្យោ ភាវាយ ។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ ឌ ្ ឌ ្ ឌ ្

ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស កាលសង្ឆកំពុងប្រឹក្សាវិនិច្ឆ័យ ហេតុអ្វីក៏អ្នកឯង មិនឲ្យធន្ទ:ហើយក្រោកចាកអាសន:ចៀសចេញទៅ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលពាក្យវិនិច្ឆ័យកំពុងប្រព្រឹត្តទៅក្នុងសង្ឆ មិនឲ្យធន្ទ:ហើយក្រោកចាកអាសន: ចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ រឿងដែលសង្ឆប្រាប់ហើយ តែមិនទាន់បានវិនិច្ឆ័យក្តី ញត្តិសង្ឆតាំងទុកហើយក្តី កម្មវាចាសង្ឆធ្វើមិនទាន់ហើយក្តី ឈ្មោះថា ពាក្យវិនិច្ឆ័យ (កំពុងប្រព្រឹត្តទៅ) ក្នុងសង្ឆ ។ ពាក្យថា ភិក្ខុមិនឲ្យធន្ទ:ហើយក្រោកចាកអាសន:ចៀសចេញទៅ សេចក្តីថា ភិក្ខុចេញទៅដោយគិតថា មិនដឹងជាការអ្វី កម្មនេះជាកម្មកំរើកទេ ជាពួកទេ សង្ឆមិនត្រូវធ្វើទេ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុកំពុងលះហត្ថបាសបរិ-សទ្យ ត្រូវអាបត្តិទុក្កដ ។ កាលលះហត្ថបាសហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៩] ឆម្មកម្ម ឆម្មកម្មសញ្ញី ឆន្ទំ អនត្វា ឧដ្ឋាយសនា បក្កមតិ អាបត្តិ ចាចិត្តិយស្ស ។ ឆម្មកម្ម វេមតិកោ ឆន្ទំ អនត្វា ឧដ្ឋាយសនា បក្កមតិ អាបត្តិ ទុក្កដស្ស ។ ឆម្មកម្ម អឆម្មកម្មសញ្ញី ឆន្ទំ អនត្វា ឧដ្ឋាយសនា បក្កមតិ អនាបត្តិ ។ អឆម្មកម្ម ឆម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អឆម្មកម្ម វេមតិកោ អាបត្តិ ទុក្កដស្ស ។ អឆម្មកម្ម អឆម្មកម្មសញ្ញី អនាបត្តិ ។

[៣៤០] អនាបត្តិ សង្ឆ្ស្ស ភណ្ឌំ វ កាល-ហោ វ ១ ១ ១

[៣៣៩] *កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយ ធម៌ ហើយមិនឲ្យធ្នូ:ក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយមិនឲ្យធ្នូ: ក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។ កម្មប្រកបដោយ ធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ហើយមិនឲ្យធ្នូ:ក្រោកចាក អាសនៈចៀសចេញទៅ មិនត្រូវអាបត្តិ ។ កម្មមិនប្រកបដោយធម៌ភិក្ខុសំគាល់ ថា កម្មប្រកបដោយធម៌ (ហើយមិនឲ្យធ្នូ:ក្រោកចាកអាសនៈ ចៀសចេញ ទៅ) ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកប ដោយធម៌ មិនត្រូវអាបត្តិ ។*

[៣៤០] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុទៅ ដោយគិតថា សេចក្តីបង្ក្រហេតុក្តី សេចក្តីប្រកួតប្រកាន់ក្តី សេចក្តីប្រកាន់ខុសគ្នាក្តី សេចក្តីទាស់ទែងក្តី នឹងមានដល់សង្ឆ ១ ភិក្ខុទៅដោយគិតថា ការបែកធ្លាយនៃសង្ឆក្តី ការប្រេះធ្លាយនៃសង្ឆក្តី នឹងមាន ១ ភិក្ខុទៅដោយគិតថា សង្ឆនឹងធ្វើកម្មមិនប្រកបដោយធម៌ក្តី នឹងធ្វើកម្មជាពួកក្តី នឹងធ្វើកម្មដល់ភិក្ខុដែលមិនគួរដល់កម្មក្តី ១*

កម្មំ ការិស្សតីតិ តច្ឆតិ តិលាធো តច្ឆតិ តិលានស្ស ការណាយេន តច្ឆតិ ឧច្ចារេន វា បស្សាវេន វា ឬ ជ្ឈិតោ តច្ឆតិ ន កម្មំ ការិតោ ការមោ បុន បច្ឆាតមិស្ស- មីតិ តច្ឆតិ ឧម្មត្តកស្ស អាធិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុមានជំងឺចៀសចេញទៅ ១ ភិក្ខុទៅដោយកិច្ចដែលគួរធ្វើដល់ភិក្ខុឈឺ ១ ភិក្ខុដែលឧច្ចារៈក្តី បស្សាវៈក្តីបៀតបៀនហើយទៅ ១ ភិក្ខុមិនប្រាថ្នាដើម្បីនឹងញ៉ាំងកម្មឲ្យកម្រើកហើយចេញទៅដោយគិតថា អញនឹងត្រឡប់មកវិញទៀត ១ ភិក្ខុធ្លត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

ឯកាទសមសិក្ខាបទំ

[៣៤១] តេន សមយេន ពុទ្ធោ ភគវា រាជគហេ
វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ
បន សមយេន អាយស្មា ឧញ្ញោ មលុ្យបុត្តោ សជ្ឈិស្ស
សេនាសនញ្ច បញ្ញាបេតិ ភត្តានិ ច ឧទ្ទិសតិ ។
សោ ចាយស្មា ឧុព្ភលចីវរោ ហោតិ ។ តេន ខោ
បន សមយេន សជ្ឈិស្ស ឯកំ ចីវរំ ឧប្បន្នំ ហោតិ ។
អថខោ សជ្ជោ តំ ចីវរំ អាយស្មតោ ឧញ្ញស្ស មលុ-
បុត្តស្ស អជាសិ ។ ឆព្ភក្ខិយា ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ
វិចារេន្តិ យថាសន្ថុតំ ភិក្ខូ សជ្ជិកំ លាភំ បរិណា-
មេន្តីតិ ។ យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ឆព្ភក្ខិយា
ភិក្ខូ សមត្តេន សជ្ជេន ចីវរំ ឧត្វា បច្ចា ខីយនធម្មំ
អាបជ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ
សមត្តេន សជ្ជេន ចីវរំ ឧត្វា បច្ចា ខីយនធម្មំ
អាបជ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា សមត្តេន

សិក្ខាបទទី ១១

[៣៦១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត
វេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ទព្ធ-
មល្ល្ហបុត្រដ៏មានអាយុ ចាត់ចែងសេនាសនៈ និងសំដែងកត្តដល់សង្ឆ ។
ទព្ធមល្ល្ហបុត្រដ៏មានអាយុនោះ ជាអ្នកមានចីវរទុព្ធលភាព ។ សម័យនោះឯង
ចីវរ ១ បានកើតឡើងដល់សង្ឆ ។ សង្ឆឲ្យចីវរនោះ ដល់ទព្ធមល្ល្ហបុត្រ
ដ៏មានអាយុ ។ ពួកឆព្ភគ្គិយភិក្ខុនាំគ្នា ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា
ភិក្ខុទាំងឡាយបង្ហោនលាភរបស់សង្ឆទៅតាមសេចក្តីគាប់ចិត្ត ។ ភិក្ខុទាំង-
ឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោល
ទោស តិះដៀល បន្ទុះបង្ហាប់ថា កាលបើសង្ឆព្រមព្រៀងគ្នាឲ្យចីវរ (ដល់
ភិក្ខុ) ហើយ ពួកឆព្ភគ្គិយភិក្ខុមិនគួរនឹងមកតិះដៀលជាខាងក្រោយសោះ
។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាសង្ឆ
ព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ អ្នកទាំងឡាយត្រឡប់មកតិះ-
ដៀលជាខាងក្រោយវិញ ពិតមែនឬ ។ ពួកឆព្ភគ្គិយភិក្ខុទូលថា សូមទ្រង់
មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះ-
ដៀលថា ម្នាលមោឃបុរសទាំងឡាយ (កាលបើ) សង្ឆព្រមព្រៀងគ្នា

សង្ឆេន ចីវរំ ឧត្វា បច្ឆា ទីយនឆម្ចំ អាបជ្ជិស្សថ ឆេតំ មោឃបុរិសា អប្ប្ សន្ថានំ វ បសាឆាយ បសន្ថ-ំ វ កិយ្យោ ការ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សមត្ថេ ន សង្ឆេន ចីវរំ ឧត្វា បច្ឆា ទីយនឆម្ចំ អាបជ្ជេយ្យ យថាសន្ថុតំ ភិក្ខូ សជ្ជ្ជិកំ លាភំ បរិណ ាមេ ត្ថ ិ ចាចិ ត្ត ិ យ ន្ត ិ ។

[៣៤២] យោ បជ ានាតិ យោ យ ាទ ិ ។ បេ ។ ភិ ក ្ខ ូ ត ិ ។ បេ ។ អ យ ំ ឥ ម ្ ម ឯ អ ត ្ ត អ ធ ិ ប ្ ប ោ ភ ិ ក ្ ខ ូ - ត ិ ។ ស ម ត ្ ថ ោ ជ ាម ស ង ្ ឆ ោ ស ម ា ន ស ំ ว ាសោ ស - ម ា ន ស ី ម ា យ ំ ប ិ ត ោ ។ ចី ว រ ំ ជ ាម ឆ ន ្ (ចី ว ร ก (អ ញ ្ ញ ត ร ំ ចី ว ร ំ ว ิ ก ป ្ ป ณ ุ ป ก (((

ឲ្យចីវរ (ដល់ភិក្ខុ) ហើយ មិនគួរនឹងពួកអ្នកឯង តិះដៀលជាខាងក្រោយវិញទេ ម្នាលមោឃបុរសទាំងឡាយ អំពីនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ (កាលបើ) សង្ឆព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ ក៏ដល់នូវធម៌គឺកិរិយាតិះដៀលជាខាងក្រោយវិញថា ភិក្ខុទាំងឡាយបង្ហោនលាភរបស់សង្ឆ តាមសេចក្ដីគាប់ចិត្ត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៤២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ សង្ឆមានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាស្មើគ្នា ហៅថា ព្រមព្រៀងគ្នា ។ ដែលហៅថា ចីវរ គឺបណ្ដាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្ប[1]បាន ។ ពាក្យថា ឲ្យ គឺឲ្យដោយខ្លួនឯង ។ ដែលហៅថា តាមសេចក្ដីគាប់ចិត្ត នោះ គឺតាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលធ្លាប់ស្គាល់គ្នា តាមបុគ្គលដែលធ្លាប់គប់គ្នា តាមបុគ្គលដែលមានឧបដ្ឋាយ៍ស្មើគ្នា តាមបុគ្គល

---

១ អដ្ឋកថា បានដល់សម្ពត់ខ្នាតតូច បណ្ដោយ ៨ ធ្នាប់ ទទឹង ៤ ធ្នាប់ដោយធ្នាប់ព្រះសុគតឡើងទៅ ហៅថា សម្ពត់គួរដល់ការវិកប្ប ។

ចរិយកតា ។ សជ្ជិកំ នាម សជ្ជិស្ស ជិន្នំ ហោតិ
បរិច្ចត្តំ ។ លាភោ នាម ចីវរបិណ្ឌបាតសេនាសនគិ-
លានប្បច្ចយភេសជ្ជបរិក្ខារា អន្តមសោ ចុណ្ណាបិណ្ឌោបិ
ឧន្ត្ថកដ្ឋំបិ ឧសិកសុត្តំបិ ។ បច្ចា ទីយនតម្ម អាប-
ជ្ជេយ្យាតិ ឧបសម្ផន្នស្ស សង្ឆេន សម្មតស្ស សេនា-
សនប្បញ្ញាបកស្ស វា ភត្តុទ្ទេសកស្ស វា យាគុភាជ-
កស្ស វា ផលភាជកស្ស វា ខជ្ជភាជកស្ស វា អប្ប-
មត្តកវិស្សជ្ជកស្ស វា ចីវរំ ជិន្នេ ទីយតិ អាបត្តិ
ចាចិត្តិយស្ស ។

[៣៤៣] ឆម្មកម្មេ ឆម្មកម្មសញ្ញី ចីវរំ ជិន្នេ
ទីយតិ អាបត្តិ ចាចិត្តិយស្ស ។ ឆម្មកម្មេ រេមតិកោ
ចីវរំ ជិន្នេ ទីយតិ អាបត្តិ ចាចិត្តិយស្ស ។ ឆម្មកម្មេ អ-
ឆម្មកម្មសញ្ញី ចីវរំ ជិន្នេ ទីយតិ អាបត្តិ ចាចិត្តិយស្ស ។
អញ្ញំ បរិក្ខារំ ជិន្នេ ទីយតិ អាបត្តិ ទុក្កដស្ស ។ ឧប-
សម្ផន្នស្ស សង្ឆេន អសម្មតស្ស សេនាសនប្បញ្ញាប-
កស្ស វា ភត្តុទ្ទេសកស្ស វា យាគុភាជកស្ស វា

ដែលមានអាចារ្យស្មើគ្នា ។ ដែលហៅថា របស់សង្ឆនោះ បានខាងលាក ដែលគេលះបង់ប្រគេនដល់សង្ឆ ។ ដែលហៅថា លាកនោះ បានខាងចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ដោយហោចទៅ សូម្បីតែដុំលំអិតក្តី ឈើស្ងួនក្តី អម្បោះរង់ដើងក្តី (ក៏ហៅថា លាក) ។ ពាក្យថា ដល់នូវធម៌គឺកិរិយាតិះដៀល ជាខាងក្រោយ សេចក្តីថា ភិក្ខុតិះដៀលសង្ឆដែលបានឲ្យចីវរ ដល់ឧបសម្បន្នដែលសង្ឆ សន្ទតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ជាអ្នកសំដែងនូវកត្តក្តី ជាអ្នកចែកនូវបបរក្តី ជាអ្នកចែកនូវផ្ទៃឈើក្តី ជាអ្នកចែកនូវបង្អែមក្តី ជាអ្នកចាត់-ចែងនូវវត្ថុបន្ទិចបន្ទួចក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៣៤៣] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយតិះដៀលសង្ឆដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយតិះដៀលសង្ឆដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយតិះដៀលសង្ឆដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុតិះដៀលសង្ឆដែលបានឲ្យបរិក្ខារដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុតិះដៀលសង្ឆដែលបានឲ្យចីវរឬបរិក្ខារដទៃ ដល់ឧបសម្បន្នដែលសង្ឆ មិនបានសន្ទតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ជាអ្នកសំដែងនូវកត្តក្តី ជាអ្នក

ផលភាជកស្ស វា ខជ្ជភាជកស្ស វា អប្ប្ឫមត្តក-
វិស្ជ្ជកស្ស វ ចីវរំ វ អញ្ញ វ បរិក្ខារំ ឥន្ធ ទីយតិ
អាបត្តិ ទុក្ខ្ជស្ស ។ អនុបសម្ជ្ជ្ជ

ចែកនូវបបរក្តី ជាអ្នកចែកនូវផ្ទៃឈើក្តី ជាអ្នកចែកនូវបង្អែមក្តី ជាអ្នកចាត់ចែងនូវវត្ថុបន្ទិចបន្ទួចក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុតិះដៀលសង្ឆដែលបានឲ្យចីវរ ឬបរិក្ខារដទៃ ដល់អនុបសម្បន្នដែលសង្ឆសន្ទ្ធត ឬមិនបានសន្ទ្ធតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ជាអ្នកសំដែងនូវកត្តក្តី ជាអ្នកចែកនូវបបរក្តី ជាអ្នកចែកនូវផ្ទៃឈើក្តី ជាអ្នកចែកនូវបង្អែមក្តី ជាអ្នកចាត់ចែងនូវវត្ថុបន្ទិចបន្ទួចក្តី ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣៦៧] ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុតិះដៀលសង្ឆអ្នកធ្វើ ព្រោះឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ ដោយប្រក្រតីថា ប្រយោជន៍អ្វីដោយលាភ ដែលសង្ឆឲ្យដល់ភិក្ខុនោះ ភិក្ខុនោះទុកជាបានហើយ ក៏គង់ធ្វើលាភនោះឲ្យវិនាសទៅដដែល នឹងមិនបាននាំយកទៅដោយប្រពៃទេ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

ទ្វាទសមសិក្ខាបទំ

[៣៤៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ
បន សមយេន សាវត្ថិយំ អញ្ញតរស្ស ឃរស្ស សង្ឆ្ស
សចីវរភត្តំ បដិយត្តំ ហោតិ ភោជេត្វា ចីវរេន អច្ឆាទេស្ស-
មាតិ ។ អថខោ ឆព្ភក្ខិយា ភិក្ខូ យេន សោ ឃរោ តេនុ-
បសង្ក្រមិំសុ ឧបសមង្ក្រមិត្វា តំ ឃរំ ឯតទវោចុំ ទេថាវុសោ
ឥមានិ ចីវរានិ ឥមេសំ ភិក្ខូនន្តិ ។ ន មយំ ភន្តេ
ជនឃ្ឆាម អម្ហាកំ សង្ឆ្ស អនុរុស្ស សចីវរភិក្ខា
បញ្ញត្តាតិ ។ ពហូ អាវុសោ សង្ឆ្ស ជាយកា ពហូ
សង្ឆ្ស ភត្តា ឥមេ តុម្ហេ ជិឃ្ឆាយ តុម្ហេ សម្ឃ្ស្ស ឦ
ឥជ វិហរន្តិ តុម្ហេ ចេ ឥមេសំ ន ជនឃ្ឆថ អថ ភោជ-
ឃហិ ឥមេសំ ជនឃ្ឆតិ ទេថាវុសោ ឥមានិ ចីវរានិ ឥមេសំ
ភិក្ខូនន្តិ ។ អថខោ សោ ឃរោ ឆព្ភក្ខិយេហិ ភិក្ខូហិ

សិក្ខាបទទី ១២

[៣៤៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ប្រជុំជនពួកមួយ ក្នុងក្រុងសាវត្ថីនាំគ្នាតាក់តែងចង្ហាន់ព្រមទាំងចីវរទុក ដើម្បីថ្វាយសង្ឆ ដោយគិតគ្នាថា យើងទាំងឡាយនឹងនិមន្តឲ្យលោកធាន់ហើយនឹងប្រគេន ចីវរ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅកាន់ទីប្រជុំជននោះ លុះចូល ទៅហើយ បាននិយាយពាក្យនេះនឹងប្រជុំជននោះថា ម្នាលអាវុសោ ពួកអ្នកចូរឲ្យចីវរទាំងនេះដល់ភិក្ខុទាំងឡាយនេះ ។ ពួកជនទាំងនោះបាន និយាយតបវិញថា ព្រះករុណា ពួកខ្ញុំមិនថ្វាយទេ ពួកខ្ញុំធ្លាប់តាក់តែង ចង្ហាន់ព្រមទាំងចីវរទុកដើម្បីថ្វាយសង្ឆរាល់ ១ ឆ្នាំ ។ ពួកឆព្វគ្គិយភិក្ខុ និយាយលួងលោមថា ម្នាលអាវុសោ ទាយករបស់សង្ឆមានច្រើន ភត្ត របស់សង្ឆក៏មានច្រើន ភិក្ខុអម្បាលនេះបានអាស្រ័យលើអ្នកទាំងឡាយ បានជួបប្រសព្វអ្នកទាំងឡាយទើបមកគង់នៅក្នុងទីនេះបាន បើអ្នកទាំង-ឡាយមិនប្រគេនដល់លោកទាំងនេះ ចុះអ្នកណាតើគេនឹងប្រគេនដល់ លោកទាំងនេះបាន ម្នាលអាវុសោ ចូរអ្នកទាំងឡាយឲ្យនូវចីវរទាំងឡាយ នេះដល់ភិក្ខុអម្បាលនេះចុះ ។ ប្រជុំជននោះ កាលត្រូវពួកឆព្វគ្គិយភិក្ខុ

ជិឃ្យីឍ្ឃ្យីយមានោ យថាបដិយត្តំ ចីវរំ ឆព្ភក្ខ្យានំ ភិក្ខ្ហំ ជត្វា សជ្ជ៎ំ ភត្តេន បរិវិសិ ។ យេ តេ ភិក្ខ្ហ ជានន្តិ សជ្ជ៎ស្ស សចីវរភត្តំ បដិយត្តំ ន ច ជានន្តិ ឆព្ភក្ខ្យានំ ភិក្ខ្ហំ ជិន្ធន្តិ តេ ឯវមាហំសុ ឱណោជេថ អាវុសោ សជ្ជ៎ស្ស ចីវរន្តិ ។ ជត្តិ ភន្តេ យថាបដិយត្តំ ចីវរំ អយ្យា ឆព្ភក្ខ្យា អយ្យានំ ឆព្ភក្ខ្យានំ បរិណាមេន្តីតិ ។ យេ តេ ភិក្ខ្ហ អប្ឃ្ជ្ជ ។ បេ ។ តេ ឧជ្ជ្ឈាយន្តិ ខ៎ីយន្តិ វិចារេន្តិ កថំ ហិ ជាម ឆព្ភក្ខ្យា ភិក្ខ្ហ ជានំ សជ្ជ៎ិកំ លាភំ បរិណាតំ បុក្ខ្ហលស្ស បរិណាមេស្ស្ជ្ជ៎ីតិ ។ បេ ។ សចំ ភ្ការ តុម្ហេ ភិក្ខ្ហវេ ជានំ សជ្ជ៎ិកំ លាភំ បរិណាតំ បុក្ខ្ហលស្ស បរិណាមេថាតិ ។ សចំ ភ្ការ ។ ភ្ការ ហិ ពុទ្ធ្ធ ភ្ការ ភ្ការ ហិ ជាម តុម្ហេ ម្ហោ ឃ ១ ១ ១

កិលមន្តីតិ ។ អស្សាសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិចារេន្តានំ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ភិក្ខូ ន មត្តំ ជានិត្វា ពហូ សូចិយវេ វិញ្ញាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ន មត្តំ ជានិត្វា ពហូ សូចិយវេ វិញ្ញាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ន មត្តំ ជានិត្វា ពហូ សូចិយវេ វិញ្ញាបេស្សន្តិ នេតំ ភិក្ខវេ អប្ឋសន្ថានំ វា បសាទាយ បសន្ថានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អដ្ឋិមយំ វា ទន្តមយំ វា វិសាណមយំ វា សូចិយរំ ការាបេយ្យ ភេទនកំ ចាចិត្តិយន្តិ ។

ក៏នឿយព្រួយលំបាក ។ កាលមនុស្សទាំងនោះកំពុងតែពោលទោស តិះ-ដៀល បន្ទុះបង្ហាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះ-បង្ហាប់ថា ភិក្ខុទាំងឡាយមិនគួរនឹងមិនដឹងប្រមាណ សូមបំពង់ម្ជុលច្រើន (ហួសកំណត់) ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ ឮថាភិក្ខុទាំងឡាយមិនស្គាល់ប្រមាណ សូមបំពង់ម្ជុលច្រើន ពិត-មែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះ-ពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោយ-បុរសទាំងនោះ មិនគួរនឹងមិនដឹងប្រមាណ សូមបំពង់ម្ជុលច្រើនទេ ម្នាលភិក្ខុ-ទាំងឡាយ អំពើនេះ មិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្ម-ឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ-យ៉ាងនេះថា ភិក្ខុណាមួយ ឲ្យគេធ្វើបំពង់ម្ជុលជាវិការនៃធ្នឹងក្តី ជាវិការ-នៃភ្ជុកក្តី ជាវិការនៃស្នែងក្តី ត្រូវកេទនកបាចិត្តិយ[1] ។

---

១ អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវបំបែកបំពង់ម្ជុលនោះមុនជាវិនយកម្ម ទើបសំដែងបាន បើមិនបានធ្វើវិនយកម្មទេ សំដែងមិនបានឡើយ ។

[៣៧០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អដ្ឋិ នាម យង្គ្លីញ្ចិ អដ្ឋិ ។ ឧណ្ហោ នាម ហត្ថិឧណ្ហោ រុច្ចតិ ។ វិសាណំ នាម យង្គ្លីញ្ចិ វិសាណំ ។ ការ-ភេយ្យាតិ ការោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ភិន្ទិត្វា ចាចិត្តិយំ ទេសេតព្វំ ។

[៣៧១] អត្តនា វិប្ប្ការតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អត្តនា វិប្ប្ការតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ប-ការតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ប្ការតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិ-យស្ស ។ អញ្ញស្សត្ថាយ ការោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន ការតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខា-បទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ធ្នឹង គឺធ្នឹងណាមួយ ។ ដែលហៅថា ក្ងុក សំដៅយកក្ងុកដំរីជាប្រមាណ ។ ដែលហៅថា ស្នែង គឺស្នែងណាមួយ ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ត្រូវបំបែកបំពង់ម្ជុលដែលខ្លួនបានមកនោះ ហើយសឹមសំដែងអាបត្តិបាចិត្តិយ ។

[៣៧១] ភិក្ខុញ្ចាំងបំពង់ម្ជុលដែលខ្លួនធ្វើមិនទាន់ស្រេច ឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់អ្នកដទៃ ឲ្យសម្រេចនូវបំពង់ម្ជុលដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។ បំពង់ម្ជុលដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ បំពង់ម្ជុលដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី នូវបំពង់ម្ជុលដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានបំពង់ម្ជុលដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៧២] អជ្ជាបត្តិ ឥណ្ឌ្ហិកាយ អរណ្ហិកេ រីថេ អញ្ជនិយា អញ្ជនីសលាកាយ ភសីជដេ ឧទក-បុញ្ជនិយា ឧម្មត្តកស្ស អាជិកម្ម្ហិកស្ស្ហាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

[៣៧២] *ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺកិក្ខុយកឆ្នឹងជាដើមមកធ្វើជាឡេវក្ខុំ ១ ធ្វើជារបស់សម្រាប់ពួតក្ងើង ១ ធ្វើជាក្រវិលវត្តពន្ធចង្កេះ ១ ធ្វើជាក្ងាក់សម្រាប់ដាក់ថ្នាំបន្ដក់ភ្នែក ១ ធ្វើជាចង្កឹះនៃក្ងាក់នោះ ១ ធ្វើជាមៀនកាំបិត ១ ធ្វើជារបស់សម្រាប់ជូតទឹក ១ កិក្ខុឆ្ពត ១ កិក្ខុដើមបញ្ញត្ដិ ១ ។*

សិក្ខាបទទី ៤ ចប់ ។

បញ្ចមសិក្ខាបទំ

[៣៧៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ
ឧច្ចេ មញ្ចេ សយតិ ។ អថខោ ភគវា សម្ពហុលេហិ
ភិក្ខូហិ សទ្ធឹ សេនាសនចារិកំ អាហិណ្ឌន្តោ យេន-
យស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស វិហារោ តេនុប-
សង្កមិ ។ អទ្ទសា ខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ
ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ឌិស្វាន ភគវន្តំ ឯតទវោច
អាគច្ឆតុ មេ ភន្តេ ភគវា សយនំ បស្សតូតិ ។ អថ-
ខោ ភគវា តតោ វ បដិនិវត្តិត្វា ភិក្ខូ អាមន្តេសិ
អាសយតោ ភិក្ខវេ មោឃបុរិសោ វេឌិតព្ពោតិ ។ អថខោ
ភគវា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អនេកបរិយាយេន
វិគរហិត្វា ឧត្តរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ
សិក្ខាបទំ ឧទ្ទិសេយ្យាថ ន្ត្រ បន ភិក្ខុនា មញ្ចំ វ

សិក្ខាបទទី ៥

[៣៧៣] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុសិងលើគ្រែដ៏ខ្ពស់ ។ លោនោះ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិក ជាមួយនឹងពួកភិក្ខុច្រើនរូប ហើយចូលទៅកាន់វិហារដែលព្រះឧបនន្ទសក្យបុត្តដ៏មានអាយុនៅ ។ ឯព្រះឧបនន្ទសក្យបុត្តដ៏មានអាយុបានក្រឡេកទៅឃើញព្រះដ៏មានព្រះភាគកំពុងយាងមកពីចម្ងាយ លុះបានឃើញហើយ ក៏បានក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ចូលមកទតមើលទីដេក របស់ខ្ញុំព្រះអង្គសិន ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រឡប់មកពីទីនោះវិញ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឯមោឃបុរស អ្នកទាំងឡាយគប្បីដឹងដោយទីអាស្រ័យ[1] ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសព្រះឧបនន្ទសក្យបុត្តដ៏មានអាយុដោយអនេកបរិយាយ ។ បេ ។ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឲ្យគេធ្វើគ្រែក្តី

---

1 បានដល់ទីនៅ ។

បីបំ វា ការយមានេន អដ្ឋង្គុលចាឧកំ ការេតព្វំ សុតតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អជនិយា តំ អតិក្ការមយតោ ឆេឧនកំ ចាចិត្តិយន្តិ ។

[៣៧៤] ឆវំ ជាម ការណំ ឧចាជាយ រុច្ចតិ ។ មញ្ចោ ជាម ចត្តារោ មញ្ចា មសារកោ ពុន្ធិការ្ជាពន្ធោ ការ្ជាវ្ជ្ជ្ជ

តាំងក្តីដ៏ថ្មី ត្រូវឲ្យធ្វើឲ្យមានជើង ៨ ធ្នាប់ដោយធ្នាប់ព្រះសុគត រាស់ពីត្រឹមមេគ្រែខាងក្រោមចុះទៅ (បើធ្វើ) ឲ្យកន្ទងហួសពីនោះទៅ ត្រូវឆេទនកបាចិត្តិយ[១] ។

[៣៧៤] ដែលហៅថា ថ្មី គឺសំដៅយកការធ្វើឡើងជាប្រមាណ ។ ដែលហៅថា គ្រែ គឺគ្រែមាន ៤ យ៉ាង បានដល់គ្រែដែលគេដាប់ជើងហើយបញ្ចូលមេគ្រែទៅក្នុងដំណាប់នោះ ១ គ្រែដែលគេបង្ហាំជើងគ្រែដោយមេគ្រែ ហើយធ្វើដោយសង្ហេបជាបល្ងង្ក ១ គ្រែដែលគេធ្វើជើងប្រហែលនឹងជើងសត្វសេះសត្វពពែជាដើម ១ គ្រែដែលគេបានបញ្ចុះពន្ធ្ជញ្ជាទៅក្នុងមេ ១ ។ ដែលហៅថា តាំង គឺតាំងមាន ៤ យ៉ាង តាំងដែលគេដាប់ជើងហើយបញ្ចូលមេតាំងទៅក្នុងដំណាប់នោះ ១ តាំងដែលគេបង្ហាំជើងតាំងដោយមេតាំង ហើយធ្វើដោយសង្ហេបជាបល្ងង្ក ១ តាំងដែលគេធ្វើជើងប្រហែលនឹងជើងសត្វសេះសត្វពពែជាដើម ១ តាំងដែលគេបានបញ្ចុះពន្ធ្ជញ្ជាទៅក្នុងមេ ១ ។ ពាក្យថា ឲ្យគេធ្វើគឺធ្វើឯងក្តី ឲ្យគេធ្វើក្តី ។ ពាក្យថា ឲ្យធ្វើឲ្យមានជើង ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត រៀរចាកមេគ្រែខាងក្រោម គឺរៀរមេគ្រែខាងក្រោមចុះទៅ

---

១ អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវកាត់ (ជើងគ្រែ) នោះមុនជាវិនយកម្មទើបសំដែងបាន បើមិនបានធ្វើវិនយកម្មទេ សំដែងមិនបានឡើយ ។

តំ អតិក្ការមេត្វា ករោតិ វ ការាបេតិ វ បយោគេ ទុក្កដំ បដិលាភេន ធិដ្ឋិត្វា ចាចិត្តិយំ ទេសេតព្ពំ ។

[៣៧៥] អត្តនា វិប្ប្ការតំ អត្តនា បរិយោសា-បេតិ អាបត្តិ ចាចិត្តិយស្ស ។ អត្តនា វិប្ប្ការតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ប្ការតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ប្ការតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញស្ស្ត្ថាយ ករោតិ វ ការាបេតិ វ អាបត្តិ ទុក្ក-ដស្ស ។ អញ្ញេន ការតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្ក្ដ្ស ។

[៣៧៦] អនាបត្តិ បមាណិកំ ករោតិ ឩនកំ ករោតិ អញ្ញេន ការតំ បមាណាតិក្ក្ដ្ដ្ដ

គឺវាស់ពីត្រឹមមេគ្រែខាងក្រោម ភិក្ខុធ្វើដោយខ្លួនឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្ទ្ធ ហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ត្រូវកាត់ គ្រែក្នុងខណៈដែលបានមកចេញ ហើយសឹមសំដែងអាបត្តិបាចិត្តិយ ។

[៣៧៥] គ្រែដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ គ្រែដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃ សម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ គ្រែដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុធ្វើឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ គ្រែដែលអ្នកដទៃ ធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើគ្រែដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិ ទុក្កដ ។ ភិក្ខុបានគ្រែ ឬតាំងដែលអ្នកដទៃធ្វើ (ហើយយកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៧៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុធ្វើត្រូវតាមប្រមាណ ១ ភិក្ខុធ្វើឲ្យថយចុះពីប្រមាណ ១ ភិក្ខុបានគ្រែ ឬតាំងដែលអ្នកដទៃធ្វើឲ្យហួសប្រមាណ (យកមក) កាត់ចេញហើយ ប្រើប្រាស់ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៥ ចប់ ។

ឆដ្ឋសិក្ខាបទំ

[៣៧៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ មញ្ចំបិ បីឋំបិ
តូលោនទ្ធំ ការាបេន្តិ ។ មនុស្សា វិហារចារិកំ អា-
ហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ឥមំ
ហិ នាម សមណា សក្យបុត្តិយា មញ្ចំបិ បីឋំបិ
តូលោនទ្ធំ ការាបេស្សន្តិ សេយ្យថាបិ គិហី កាមភោ-
គិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈា-
យន្តានំ ខីយន្តានំ វិចារេន្តានំ ។ យេ តេ ភិក្ខូ អប្ចិច្ឆា
។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ឥមំ ហិ នាម
ឆព្ភក្ខិយា ភិក្ខូ មញ្ចំបិ បីឋំបិ តូលោនទ្ធំ ការា-
បេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ មញ្ចំបិ
បីឋំបិ តូលោនទ្ធំ ការាបេថាតិ ។ សច្ចំ ភគវាតិ ។

សិក្ខាបទទី ៦

[៣៧៧] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកធព្ធគ្គិយភិក្ខុឲ្យគេធ្វើគ្រែខ្ទះ តាំងខ្ទះ ញាត់ដោយសំឡីគរ ឬសំឡីកប្បាស (ជាដើម) ។ ពួកមនុស្សនាំគ្នាដើរទៅកាន់វិហារចារិក បានឃើញ ហើយ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកសមណៈជាសក្យបុត្ត មិនគួរនឹងឲ្យគេធ្វើគ្រែខ្ទះ តាំងខ្ទះ ញាត់ដោយសំឡីដូចជាពួកគ្រហស្ថ អ្នកបរិភោគកាមគុណសោះ ។ កាលមនុស្សទាំងនោះ ពោលទោស តិះ-ដៀល បន្ទុះបង្ហាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកធព្ធគ្គិយភិក្ខុមិនគួរនឹងឲ្យគេធ្វើគ្រែខ្ទះ តាំងខ្ទះ ញាត់ ដោយសំឡីសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយឲ្យគេធ្វើគ្រែខ្ទះ តាំងខ្ទះ ញាត់ដោយសំឡី ពិតមែនឬ ។

រិតរហិ ពុទ្ធោ ភគវា ភិក្ខូ ហិ ជាម តុម្ហេ មោឃបុរិសា មញ្ចំ ឬ ឬ ១ តូលោនទ្ធំ ការាបេស្សថ ឥតិ មោឃ-បុរិសា អប្ប ១ ១ ១

ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងឲ្យគេធ្វើគ្រែខ្ទះ តាំងខ្ទះ ញាត់ដោយសំឡីទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យគេធ្វើគ្រែក្ដី តាំងក្ដី ញាត់ដោយសំឡី ត្រូវឧទ្ទាលនកបាចិត្តិយ[1] ។

[៣៧៨] ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ដែលហៅថា គ្រែ គឺគ្រែមាន ៤ យ៉ាង បានដល់គ្រែដែលគេដាប់ជើង ហើយបញ្ចូលមេគ្រែទៅក្នុងដំណាប់នោះ ១ គ្រែដែលគេបង្ហាំជើងគ្រែដោយមេគ្រែ ហើយធ្វើដោយសង្ហេបជាបល្ងង្ក ១ គ្រែដែលគេធ្វើជើងប្រហែលនឹងជើងសេះជើងពពែជាដើម ១ គ្រែដែលគេបានបញ្ចុះបន្ទូញទៅក្នុងមេ ១ ។ ដែលហៅថា តាំង គឺតាំងមាន ៤ យ៉ាង បានដល់តាំងដែលគេដាប់ជើង ហើយបញ្ចូលមេតាំងទៅក្នុងដំណាប់នោះ ១

---

១ អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវទំលាយ (សំឡី) នោះមុនជាវិនយកម្ម ទើបសំដែងបាន បើមិនបានធ្វើវិនយកម្មទេ សំដែងមិនបានឡើយ ។

មសារកំ ពុន្ធិកាពន្ធំ ឧកុដ្ឋិរចាឧកំ អាហច្ចចាឧកំ ។ តូលំ ជាម តីណិ តូលានិ រុក្ខតូលំ លតាតូលំ ចោត-ភីតូលំ ។ ការាបេយ្យាតិ ឧកេតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ឧគ្ហាលេត្វា ចាចិត្តិយំ ឧទ្ទេសេតព្ពំ ។

[៣៧៩] អត្តនា វិប្ផកតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អត្តនា វិប្ផកតំ បរេហិ បរិ-យោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ផកតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ផកតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញស្ស ត្តាយ ឧកេតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន ឧកតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

តាំងដែលគេបង្ហាំជើងតាំងដោយមេតាំងទាំងឡាយ ហើយធ្វើដោយ
សង្ខេបជាបណ្ដូ ១ តាំងដែលគេធ្វើជើងប្រហែលនឹងជើងសេះ ជើងពពែជា
ដើម ១ តាំងដែលគេបានបញ្ចុះជើងទៅក្នុងមេ ១ ។ ដែលហៅថា សំឡី
គឺសំឡីមាន ៣ យ៉ាង គឺសំឡីកើតពីដើមឈើ (មានដើមរកាជាដើម) ១
សំឡីកើតពីវល្ជ៏ (មានវល្ជ៏ទឹកដោះជាដើម) ១ សំឡីកើតអំពីស្មៅ ១ ។
ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើដោយខ្លួនឯងក្ដី ឲ្យគេធ្វើក្ដី ត្រូវអាបត្តិ
ទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវរើកកាយសំឡីក្នុងគ្រែក្នុងខណៈដែល
បានមក ហើយសឹមសំដែងអាបត្តិចេញ ។

[៣៧៩] គ្រែឬតាំងដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេច
ដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ គ្រែឬតាំងដែលខ្លួនធ្វើមិនទាន់
ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ គ្រែឬតាំង
ដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិ
បាចិត្តិយ ។ គ្រែឬតាំងដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃ
ទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើគ្រែឬតាំងដោយខ្លួនឯងក្ដី
អ្នកដទៃធ្វើក្ដី ដើម្បីបុគ្គលដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានគ្រែឬតាំង
ដែលអ្នកដទៃធ្វើឲ្យ (ហើយយកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

បាចិត្តិយកណ្ឌោ រតនវគ្គស្ស ឆដ្ឋសិក្ខាបទស្ស អនាបត្តិវារោ

[៣៨០] អនាបត្តិ អាយោគេ ការយពន្ធនេ អំស-ពន្ធកេ បត្តត្ថវិការយ បរិស្សាវនេ ពិម្ពោហនំ ការោតិ អញ្ញេន ការ៉ំ បដិលភិត្វា ឧទ្ធារេត្វា បរិភុញ្ជតិ ឧម្មត្ត-ការ្ស អាទិការ្ម្ម ការ្ស្ស ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

[៣៨០] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុធ្វើជាសំពត់អាយោគ ១ ធ្វើជាវត្ថពន្ធចង្កេះ ១ ធ្វើជាយោគបាត្រ ១ ធ្វើជាស្ងោកបាត្រ ១ ធ្វើជាតម្រងទឹក ១ ធ្វើជាខ្នើយ ១ ភិក្ខុបានគ្រែឬតាំងដែលអ្នកដទៃធ្វើឲ្យ (ហើយយកមក) ទម្ងាយចេញទើបប្រើប្រាស់ ១ ភិក្ខុឆ្ពត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៦ ចប់ ។

សត្តមសិក្ខាបទំ

[៣៨១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ភគវតា ភិក្ខូនំ និសីទនំ
អនុញ្ញាតំ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ភគវតា និសីទនំ
អនុញ្ញាតន្តិ អឌ្ឍមាណិកានិ និសីទនានិ ធារេន្តិ
មញ្ចេ្ចបិ បីឋេ្ចបិ ភិសេ្ចបិ ១ លេ្ហន្តិ ។
យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ ឧជ្ឌាយន្តិ
ខីយន្តិ វិចារេន្តិ ១ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ
អឌ្ឍមាណិកានិ និសីទនានិ ធារេស្សន្តីតិ ។ បេ ។
សច្ចំ កិរ ១ ១ ១

សិក្ខាបទទី ៧

[៣៨១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សំពត់និសីទន: (សំពត់សម្រាប់ទ្រាប់អង្គុយ) ព្រះដ៏មានព្រះភាគទ្រង់ បានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ ។ ឯពួកឆព្វគ្គិយភិក្ខុគិតថា សំពត់និសីទន:ព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយ ។ ក៏ប្រើ ប្រាស់សំពត់និសីទន:ទាំងឡាយមិនសមប្រមាណ ធ្វើឲ្យសំពត់និសីទន: ទាំងនោះសំយុងចុះពីខាងមុខខ្លះ ពីខាងក្រោយខ្លះ នៃគ្រែនិងតាំង ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរ នឹងប្រើប្រាស់សំពត់និសីទន:មិនសមប្រមាណសោះ ។ បេ ។ ព្រះ អង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើ ប្រាស់សំពត់និសីទន:មិនសមប្រមាណពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មាន ព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នក ទាំងឡាយ មិនគួរនឹងប្រើប្រាស់សំពត់និសីទន:មិនសមតាមប្រមាណទេ នៃមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យកាន់តែជ្រះថ្លាឡើងទេ

។ បេ ។ ឯវញ្ហ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ-
សេយ្យាថ និសីទនំ បន ភិក្ខុនា ការយមានេន
បមាណិកំ ការេតព្ពំ ។ តត្រិទំ បមាណំ ទីឃសោ
ទ្វេ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ឌិយឌ្ឍំ ។ តំ
អតិក្ក្រាមយតោ ឆេទនកំ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ
ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៨២] តេន ខោ បន សមយេន អាយស្ម
ឧបាលិ មហាការោ ហោតិ ។ សោ ភគវតោ
បុរតោ និសីទនំ បញ្ញាបេត្វា សមន្តតោ សមញ្ញមានោ
និសីទតិ ។ អថខោ ភគវា អាយស្មន្តំ ឧបាលឿ ឯតទ-
វោច កិស្ស ត្វំ ឧបាលិ និសីទនំ បញ្ញាបេត្វា សមន្តតោ
សមញ្ញសិ សេយ្យថាបិ បុរាណសិការោ ជ្ជោតិ ។ តថា
ហិ បន ភន្តេ ភគវតា ភិក្ខូនំ អតិខុទ្ទកំ និសីទនំ
អនុញ្ញាតន្តិ ។ អថខោ ភគវា ឯតស្មឿ និទានេ
ឯតស្មឿ បការណេ ធម្មឿ កថំ កត្វា ភិក្ខូ អាមន្តេសិ
អនុជានামិ ភិក្ខវេ និសីទនស្ស ទសាវិទត្ថឿ

ฯ លេ ฯ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខា-
បទនេះយ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសំពត់និសីទន: គប្បីឲ្យគេធ្វើឲ្យត្រូវប្រ-
មាណ ฯ ឯប្រមាណក្នុងសំពត់និសីទន:នោះយ៉ាងនេះ គឺបណ្តោយ ២
ចំអាម ទទឹង ១ ចំអាមកន្ទុះ ដោយចំអាមព្រះសុគត ฯ បើភិក្ខុធ្វើឲ្យកន្ទុង
ហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ฯ សិក្ខាបទនេះ ព្រះដ៏មាន
ព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ฯ

[៣៨២] សម័យនោះឯង ឧទាយិដ៏មានអាយុមានរាងកាយធំ ฯ
ឧទាយិនោះបានក្រាលសំពត់និសីទន: ចំពោះព្រះកន្ត្រៃព្រះដ៏មានព្រះភាគ
រួចទាញឲ្យយឺតដោយជុំវិញហើយអង្គុយនៅ ฯ លំដាប់នោះ ព្រះដ៏មាន
ព្រះភាគ ទ្រង់ត្រាស់នឹងឧទាយិដ៏មានអាយុយ៉ាងនេះថា នែឧទាយិអ្នកបាន
ជាក្រាលសំពត់និសីទន:ហើយទាញឲ្យយឺតដោយជុំវិញ ដូចជាជាងសៀ
ស្ងែកពីដើម ព្រោះហេតុអ្វី ฯ ឧទាយិនោះក្រាបទូលថា បពិត្រព្រះអង្គ
ដ៏ចម្រើន បានជាខ្ញុំព្រះអង្គធ្វើដូច្នោះ ព្រោះសំពត់និសីទន:ដែលព្រះដ៏មាន
ព្រះភាគទ្រង់អនុញ្ញាត ដល់ភិក្ខុទាំងឡាយតូចពេកណាស់ ฯ ព្រោះនិទាន
នេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុ
ទាំងឡាយក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យត)

ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ជិសី-ឧនំ បន ភិក្ខុនា ការយមានេន បមាណិកាកំ ការ-តព្វំ ។ តត្រិទំ បមាណំ ឌីឃសោ ទ្វេ វិឧត្តិយោ សុគតវិឧត្តិយា តិរិយំ ឧិយ្ឍ្យ ឧសាវិឧត្តិ ។ តំ អតិក្ខ្លាមយតោ ឆេឧនកំ ចាចិត្តិយន្តិ ។

[៣៨៣] ជិសីឧនំ ជាម សឧសំ រុច្ចតិ ។ ការ-យមានេជាតិ ការោន្តោ វា ការាបេន្តោ វា ។ បមាណិកាកំ ការតព្វំ ។ តត្រិទំ បមាណំ ឌីឃសោ ទ្វេ វិឧត្តិយោ សុគតវិឧត្តិយា តិរិយំ ឧិយ្ឍ្យ ឧសាវិឧត្តិ ។ តំ អតិក្ខ្លាមេត្វា ការោតិ វា ការាបេតិ វា បយោគេ ឧុក្ខ្លជ្ជ បដិលាភេន ឆិន្ទិត្វា ចាចិត្តិយំ ឆេសេតព្វំ ។

[៣៨៤] អត្តនា វិឃ្ឃកតំ អត្តនា បរិយោសា-បេតិ អាបត្តិ ចាចិត្តិយស្ស ។ អត្តនា វិឃ្ឃកតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិឃ្ឃកតំ អត្តនា បរិយោសាបេតិ អាបត្តិ

នូវជាយនៃសំពត់និសីទន: ១ ចំអាមទៀត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនឹងឲ្យគេធ្វើសំពត់និសីទន:ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់និសីទន: នោះយ៉ាងនេះ គឺបណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្ទុះ នឹងជាយ ១ ចំអាម ដោយចំអាមព្រះសុគត ។ (បើភិក្ខុធ្វើ) ឲ្យកន្ទងហួសពីនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

[៣៨៣] ដែលហៅថា សំពត់និសីទន:នោះ គឺសំដៅយកសំពត់និសីទន:ដែលមានជាយ ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី ។ ភិក្ខុត្រូវធ្វើឲ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់និសីទន: នោះយ៉ាងនេះ គឺបណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្ទុះ នឹងជាយ ១ ចំ-អាម ដោយចំអាមព្រះសុគត ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្ទងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់និសីទន:ក្នុងខណ:ដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ ។

[៣៨៤] សំពត់និសីទន:ដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់និសីទន:ដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ សំពត់និសី-ទន:ដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិ

ចាចិត្តិយស្ស ។ បវេហិ ១ ១ ១

បាចិត្តិយ ។ សំពត់និសីទនៈដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសំពត់និសីទនៈដែលបុគ្គលដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៨៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុធ្វើសំពត់និសីទនៈត្រូវតាមប្រមាណ ១ ភិក្ខុធ្វើសំពត់និសីទនៈថយចុះពីប្រមាណ ១ ភិក្ខុបានសំពត់និសីទនៈ ដែលអ្នកដទៃធ្វើឲ្យលើសហួសប្រមាណ ហើយកាត់ចេញទើបប្រើប្រាស់ ១ ភិក្ខុធ្វើសំពត់និសីទនៈឲ្យជាពិតានក្តី ឲ្យជាកម្រាលផែនដីក្តី ឲ្យជារនាំងក្តី ឲ្យជាពួកក្តី ឲ្យជាខ្នើយក្តី ១ ភិក្ខុធ្ជត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៧ ចប់ ។

អដ្ឋមសិក្ខាបទំ

[៣៨៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ភគវតា ភិក្ខូនំ កណ្ឌុប្បដិច្ឆាទិ
អនុញ្ញាតា ហោតិ ។ ឆព្ភក្ខិយា ភិក្ខូ ភគវតា
កណ្ឌុប្បដិច្ឆាទិ អនុញ្ញាតាតិ អប្បមាណិកាយោ កណ្ឌុ-
ប្បដិច្ឆាទិយោ ធារេន្តិ បុរតោបិ បច្ឆតោបិ អាកឌ្ឍន្តា
អាហិណ្ឌន្តិ ។ យេ តេ ភិក្ខូ អប្ឋិច្ឆា ។ បេ ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម
ឆព្ភក្ខិយា ភិក្ខូ អប្បមាណិកាយោ កណ្ឌុប្បដិច្ឆាទិយោ
ធារេស្សន្តីតិ ។ បេ ។ សច្ចំ किर តុម្ហេ ភិក្ខវេ អប្បមាណិ-
កាយោ កណ្ឌុប្បដិច្ឆាទិយោ ធារេថាតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម
តុម្ហេ មោឃបុរិសា អប្បមាណិកាយោ កណ្ឌុប្បដិច្ឆា-
ទិយោ ធារេស្សថ នេតំ មោឃបុរិសា អប្បសន្ថានំ វា
បសាទាយ បសន្ថានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ច

សិក្ខាបទទី ៨

[៣៨៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគបានអនុញ្ញាតសំពត់សម្រាប់គ្របកម (ជាដើម) ដល់ភិក្ខុទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា សំពត់សម្រាប់គ្របកមព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយ ។ ក៏ប្រើប្រាស់នូវសំពត់សម្រាប់គ្របកមទាំងឡាយមិនសមប្រមាណ ទាញពីមុខខ្ទះ ពីក្រោយខ្ទះ ហើយចេញដើរទៅ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងប្រើប្រាស់សំពត់សម្រាប់គ្របកមមិនសមប្រមាណសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់សម្រាប់គ្របកមទាំងឡាយមិនសមប្រមាណ ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់សំពត់សម្រាប់គ្របកម មិនសមប្រមាណទេ នែពួកមោឃបុរស អំពើនេះ មិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ កណ្ឌ-ប្បដិច្ឆាទឺ បន ភិក្ខុនា ការយមានេន បមាណិកា ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ចតស្សោ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទ្វេ វិទត្ថិយោ ។ តំ អតិក្កាមយតោ ឆេទនកំ ចាចិត្តិយន្តិ ។

[៣៨៧] កណ្ឌុប្បដិច្ឆាទិ នាម យស្ស អជោនាកិ ឧព្ភជានុមណ្ឌលំ កណ្ឌូ វ បីឌ្យកា វ អស្សារោ វ ចុលុ្លកច្ឆো វ អាពាធো តស្ស បដិច្ឆាទនត្ថាយ ។ ការយមានេនាតិ ការោន្ត្ត វ ការាបេន្ត្ត វ ។ បមាណិកា ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ចតស្សោ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទ្វេ វិទត្ថិយោ ។ តំ អតិក្កាមេត្វា ការោតិ វ ការាបេតិ វ បយោគេ ទុក្កដំ បដិលាភេន ធិទ្ធិត្វា ចាចិត្តិយំ ទេសេតព្វំ ។

[៣៨៨] អត្តនា វិប្ប្ការតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អត្តនា វិប្ប្ការតំ បរេហិ

អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសំពត់សម្រាប់គ្របកម ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់សម្រាប់គ្របកមនោះ យ៉ាងនេះ គឺបណ្តោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឲ្យកន្ទងហួសប្រ-មាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

[៣៨៧] សំពត់ដែលគេធ្វើដើម្បីបិទ ឬគ្របនូវអាពាធ គឺកម ឬរមាស់ក្តី បូសតូចក្តី ទឹកវង៉ៃក្តី បូសធំក្តី តាំងពីខាងក្រោមផ្ងិតចុះមក តាំងពីមណ្ឌលជង្គង់ឡើងទៅរបស់ភិក្ខុ ហៅថា សំពត់សម្រាប់គ្របកម ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី ។ ភិក្ខុត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់សម្រាប់គ្របកមនោះយ៉ាងនេះ គឺបណ្តោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្ទងហួសប្រមាណនោះ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់សម្រាប់គ្របកមក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ ។

[៣៨៨] សំពត់សម្រាប់គ្របកមដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់សម្រាប់គ្របកមដែល

បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ
ឱ្យកតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។
បរេហិ ឱ្យកតំ បរេហិ បរិយោសាបេតិ អាបត្តិ
ចាចិត្តិយស្ស ។ អញ្ញស្ស្ត្ថាយ ករោតិ វ ការាបេតិ វ
អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា
បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៨៥] អនាបត្តិ បមាណិកំ ករោតិ ឧនកំ
ករោតិ អញ្ញេន កតំ បមាណាតិក្កន្តំ បដិលភិត្វា
ធិក្ខិត្វា បរិភុញ្ជតិ វិតានំ វ ភុម្មត្ថរណំ វ សាណិប្បាការំ
វ ភិសឹ វ ពិម្ពោហនំ វ ករោតិ ឧម្មត្តកស្ស
អាទិកម្មិកស្ស្ត្ថាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

ខ្លួនធ្វើមិនទាន់ស្រេច កិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ សំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើមិនទាន់ស្រេច កិក្ខុ ឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើមិនទាន់ស្រេច កិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ កិក្ខុបានសំពត់សម្រាប់គ្របកម ដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៨៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺកិក្ខុធ្វើសំពត់សម្រាប់គ្របកមត្រូវតាមប្រមាណ ១ កិក្ខុធ្វើសំពត់សម្រាប់គ្របកមថយចុះពីប្រមាណ ១ កិក្ខុបានសំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើឲ្យកន្ទ្ធ១ហួសប្រមាណហើយកាត់ចេញ ទើបប្រើប្រាស់ ១ កិក្ខុធ្វើសំពត់សម្រាប់គ្របកមឲ្យជាពិតានក្តី ជាគ្រឿងកម្រាលផែនដីក្តី ជារនាំងក្តី ជាពួកក្តី ជាខ្នើយក្តី ១ កិក្ខុឆ្ពត ១ កិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

នវមសិក្ខាបទំ

[៣៩០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ភគវតា ភិក្ខូនំ វស្សិកសាដិកា
អនុញ្ញាតា ហោតិ ។ ឆព្ពគ្គិយា ភិក្ខូ ភគវតា វស្សិ-
កសាដិកា អនុញ្ញាតាតិ អឌ្ឍមាណិកាយោ វស្សិក-
សាដិកាយោ ជាវន្តិ បុរតោបិ បច្ឆតោបិ អាកឌ្ឍន្តា
អាហិណ្ឌន្តិ ។ យេ តេ ភិក្ខូ អប្ចិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ឆព្ពគ្គិយា
ភិក្ខូ អឌ្ឍមាណិកាយោ វស្សិកសាដិកាយោ
ជាវេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អឌ្ឍមា-
ណិកាយោ វស្សិកសាដិកាយោ ជាវេថាតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ
មោឃបុរិសា អឌ្ឍមាណិកាយោ វស្សិកសាដិកាយោ
ជាវេស្សថ នេតំ មោឃបុរិសា អប្ឋសន្ថានំ វា បសា-
ទាយ បសន្ថានំ វា កិយ្យោការាយ ។ បេ ។ ឯវញ្ច

សិក្ខាបទទី ៩

[៣៩០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេត-ពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សំពត់វស្សិកសាដកព្រះដ៏មានព្រះភាគបានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ ។ ឯពួកឆព្វគ្គិយភិក្ខុគិតគ្នាថា សំពត់វស្សិកសាដកព្រះដ៏មានព្រះភាគបានអនុញ្ញាតហើយ ។ ក៏ប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណ ទាញពីមុខខ្លះ ពីក្រោយខ្លះ ហើយចេញដើរទៅ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វ-គ្គិយភិក្ខុ មិនគួរនឹងប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំង-ឡាយប្រើប្រាស់សំពត់វស្សិកសាដក មិនសមប្រមាណ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់សំពត់វស្សិកសាដក មិនសមប្រមាណទេ នែពួកមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុ

បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ វស្សិកសា-ដិកំ បន ភិក្ខុនា ការយមានេន បមាណិកា ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ឆ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ អឌ្ឍតេយ្យា ។ តំ អតិក្កាម-យតោ ឆេទនកំ ចាចិត្តិយន្តិ ។

[៣៩១] វស្សិកសាដិកា នាម វស្សានស្ស ចាតុម្មាសត្ថាយ ។ ការយមានេនាតិ ការេន្តោ វា ការាបេន្តោ វា ។ បមាណិកា ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ឆ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ អឌ្ឍតេយ្យា ។ តំ អតិក្កាមេត្វា ការេតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ធិត្តិ្វា ចាចិត្តិយំ ឆេទេតព្វំ ។

[៣៩២] អត្តនា វិប្ប្ការតំ អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អត្តនា វិប្ប្ការតំ បរេហិ បរិ-យោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ប្ការតំ

ទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសំពត់វស្សិកសាដក ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ ។ ឯប្រមាណក្នុងសំពត់វស្សិកសាដកនោះយ៉ាងនេះ គឺបណ្តោយ ៦ ចំអាម ទទឹង ២ ចំអាមកន្ទុះ ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឲ្យកន្ទុងហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

[៣៩១] ដែលហៅថា សំពត់វស្សិកសាដកនោះ គឺសំពត់ដែលភិក្ខុធ្វើសម្រាប់ងូតទឹកភ្ជៀងអស់ ៤ ខែនៃវស្សានរដូវ ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី ។ ភិក្ខុត្រូវឲ្យគេធ្វើឲ្យត្រូវតាមប្រមាណ ។ ឯប្រមាណក្នុងសំពត់វស្សិកសាដកនោះយ៉ាងនេះ គឺបណ្តោយ ៦ ចំអាម ទទឹង ២ ចំអាមកន្ទុះ ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្ទុងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់វស្សិកសាដក ក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ ។

[៣៩២] សំពត់វស្សិកសាដកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់វស្សិកសាដកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ សំពត់វស្សិកសាដក ដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេច

អត្តនា បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ បរេហិ វិប្ផកតំ បរេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញស្ស ត្តាយ កភេតិ វ ការាបេតិ វ អាបត្តិ ទុក្ក-ដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្ក ដស្ស ។

[៣៩៣] អនាបត្តិ បមាណិកំ ភេតិ ឩនកំ ភេតិ អញ្ញេន កតំ បមាណាតិក្ក ន្តំ បដិលភិត្វា ធិដ្ឋិត្វា បរិភុញ្ជតិ វិតានំ វ ភុម្មត្ថរណំ វ សាណិប្ប-ការំ វ ភិសឺ វ ពិម្ពោហនំ វ ភេតិ ឧម្មត្ត ភស្ស អាទិ ភម្មិ ភស្ស ។

នវមសិក្ខាបទំ និដ្ឋិតំ ។

ដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់វស្សិកសាដកដែលអ្នកដទៃធ្វើ មិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសំពត់វស្សិកសាដកដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៩៣] *វារៈដែលមិនត្រូវអាបត្តិ* (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុធ្វើសំពត់វស្សិកសាដកត្រូវតាមប្រមាណ ១ ភិក្ខុធ្វើសំពត់វស្សិកសា-ដកថយចុះពីប្រមាណ ១ ភិក្ខុបានសំពត់វស្សិកសាដកដែលអ្នកដទៃធ្វើឲ្យ ហួសប្រមាណ ហើយ (យកមក) កាត់ចេញ ទើបប្រើប្រាស់ ១ ភិក្ខុ ធ្វើសំពត់វស្សិកសាដក (នោះ) ឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជារនាំងក្តី ជាពួកក្តី ជាខ្នើយក្តី ១ ភិក្ខុឆ្ពួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៩ ចប់ ។

ទសមសិក្ខាបទំ

[៣៩៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន អាយស្មា ឧន្ទោ ភគ-
វតោ មាតុច្ឆាបុត្តោ អភិរូចោ ហោតិ ទស្សនីយោ
ចាសាទិកោ ចតុរង្គុលោមកោ ភគវតា ។ សោ
សុកតចីវរប្ឆមាណំ ចីវរំ ជាវេតិ ។ អទ្ធសំសុ ខោ
ថេរា ភិក្ខូ អាយស្មន្តំ ឧន្ទំ ទ្ធរតោ រ អាគច្ឆន្តំ
ជិស្វាន ភគវា អាគច្ឆតីតិ អាសជ្ជ រុជ្ជហន្តិ ។ តេ
ឧបគតំ សញ្ជានិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ភគ
ហិ ជាម អាយស្មា ឧន្ទោ សុកតចីវរប្ឆមាណំ ចីវរំ
ជាវេស្ឆតីតិ ។ បេ ។ សច្ចំ ភិរ ត្វំ ឧន្ទ សុកតចីវរប្ឆ-
មាណំ ចីវរំ ជាវេសីតិ ។ សច្ចំ ភគវាតិ ។ វិតរហិ ពុទ្ធោ
ភគវា ភគ ហិ ជាម ត្វំ ឧន្ទ សុកតចីវរប្ឆ-
មាណំ ចីវរំ ជាវេស្ឆសិ ឧនតំ ឧន្ទ អប្ឆសន្ធានំ ភ

សិក្ខាបទទី ១០

[៣៩៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេត-ពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះនន្ទដ៏មានអាយុ ជាបុត្តនៃព្រះមាតុច្ឆានៃព្រះដ៏មានព្រះភាគ មានរូបល្អគួរនឹងរមិលមើល នាំឲ្យជ្រះថ្លា មានកំពស់ទាបជាងព្រះដ៏មានព្រះភាគ ៤ ធ្នាប់ ។ ព្រះនន្ទនោះទ្រង់ចីវរប៉ុនគ្នានឹងចីវរព្រះសុគត ។ ពួកភិក្ខុជាថេរៈបានឃើញព្រះនន្ទដ៏មានអាយុ ដើរមកអំពីចម្ងាយ លុះឃើញហើយក៏នាំគ្នាក្រោកឡើងអំពីអាសនៈ ដោយគិតថា ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរមក ។ លុះព្រះនន្ទចូលមកជិតហើយ ភិក្ខុទាំងនោះ ក៏ស្គាល់ច្បាស់ ទើបពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ព្រះនន្ទដ៏មានអាយុមិនគួរនឹងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគតសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែនន្ទ ឮថាអ្នកឯងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគត ពិតមែនឬ ។ ព្រះនន្ទនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែនន្ទ អ្នកឯងមិនគួរនឹងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគតទេ នែនន្ទ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា

បសាទាយ បសន្នានំ វា ភិយ្យោភावាយ ។ បេ ។ ឯវញ្ហេ បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សុគតចីវរប្ប្រមាណំ ចីវរំ ការាបេយ្យ អតិរេកំ វា ឆេទនកំ ចាចិត្តិយំ ។ តត្រិទំ សុគតស្ស សុគតចីវរប្ប្រមាណំ ទីឃសោ ទ្វេ វិទត្ថិយោ សុគ-តវិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ។ ឥទំ សុគតស្ស សុគតចីវរប្ប្រមាណន្តិ ។

[៣៩៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ប្រេតោ ភិក្ខូតិ ។ សុគតចីវរប្ប្រមាណំ នាម ទីឃសោ ទ្វេ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ។ ការាបេយ្យាតិ ការេតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ធិដ្ឋិតា ចាចិត្តិយំ ទេសេតព្ពំ ។

[៣៩៦] អត្តនា ១ ១ ១

ឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យគេធ្វើចីវរប៉ុនចីវរព្រះសុគតឬធំជាង ត្រូវធ្លាក់ទោសបាចិត្តិយ ។ ឯប្រមាណសុគតចីវររបស់ព្រះសុគតនោះយ៉ាងនេះ គឺបណ្ដោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។ នេះជាប្រមាណសុគតចីវររបស់ព្រះសុគត ។

[៣៩ថ] ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ប្រមាណសុគតចីវរ គឺបណ្ដោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើឯងក្ដី ឲ្យគេធ្វើក្ដី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់ចីវរក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ ។

[៣៩៦] ចីវរដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។

បវេហិ វិប្ផកតំ បវេហិ បរិយោសាបេតិ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ការេតិ វ ការ-បេតិ វ អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៩៧] អនាបត្តិ ឧនកំ ការេតិ អញ្ញេន កតំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ វិតានំ វ ភុម្មត្ថរណំ វ សាណិប្ផាការំ វ ភិសឺ វ ពិម្ពោហនំ វ ការេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

រតនវគ្គោ នវមោ ។

តស្សុទ្ទានំ

រញ្ញោ ច រតនំ សង្ខំ សូចិ មញ្ចញ្ច តូលិកំ
ជិសីឧនញ្ច ការ្ណាញ្ច រស្ជិការ សុតតេន ចាតិ ។

ចីវរដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៩៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះ មាន ៥ យ៉ាង) គឺភិក្ខុធ្វើចីវរបយចុះពីប្រមាណ ១ ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយ (យកមក) កាត់ចេញ ទើបប្រើប្រាស់ ១ ភិក្ខុធ្វើចីវរនោះ ឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជារនាំងក្តី ជាពួកក្តី ជាខ្នើយក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

រតនវគ្គទី ៩ ចប់ ។

ឧទ្ទានៃរតនវគ្គនោះ (មាន ១០ សិក្ខាបទ) គឺ

ពាជសិក្ខាបទ ១	រតនសិក្ខាបទ ១
សន្ថតសិក្ខាបទ ១	សូចិសិក្ខាបទ ១
មញ្ចសិក្ខាបទ ១	តូលិកសិក្ខាបទ ១
និសីទនសិក្ខាបទ ១	កណ្ឌុសិក្ខាបទ ១
វស្សិកសិក្ខាបទ ១	សុគតសិក្ខាបទ ១ ។

បាចិត្តិយកណ្ឌេ រតនវគ្គស្ស ទសមសិក្ខាបទស្ស ឧទ្ទេសោវសានំ

[៣៩៨] ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ទ្វេនវុតិ ចាចិត្តិយា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ កচ្চិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កচ្চិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ কচ্চিত্থ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។ ឯवमेतं ធារយាមីតិ ។

បាចិត្តិយកណ្ឌំ និដ្ឋិតំ ។

[៣៩៨] *បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាចិត្តិយទាំង ៩២ ខ្ញុំបានសំដែងរួចហើយ ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈជាគម្រប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈជាគម្រប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធហើយ ក្នុងអាបត្តិទាំងនេះ ព្រោះហេតុនោះ បានជាអស់លោកស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីបរិសុទ្ធិនេះ ដោយការស្ងៀមនៅយ៉ាងនេះឯង ។*

បាដិទេសនីយកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ ចត្តារោ ចាដិទេសនីយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

បឋមសិក្ខាបទំ

[៣៩៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី សាវត្ថិយំ បិណ្ឌាយ ចរិត្វា បដិក្កមនកាលេ អញ្ញតរំ ភិក្ខុំ បស្សិត្វា ឯតទវោច ហន្ទយ្យ ភិក្ខុ បដិក្តណ្ហាតិ ។ សុដ្ឋុ ភគិនីតិ សព្ពេ វ អក្តហោសិ ។ សា ឧបកដ្ឋេ កាលេ ជាសក្ខិ បិណ្ឌាយ ចរិតុំ ធិន្ធកត្តា អហោសិ ។ អថខោ សា ភិក្ខុនី ទុតិយម្ឫ ជិវសំ ។ បេ ។ តតិយម្ឫ ជិវសំ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បដិក្កម- នកាលេ តំ ភិក្ខុំ បស្សិត្វា ឯតទវោច ហន្ទយ្យ

បាដិទេសនីយកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាដិទេសនីយ: ទាំង ៤ នេះ តែងមកកាន់ខ្ញុំ ។

សិក្ខាបទទី ១

[៣៩៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ឯង មានភិក្ខុនី ១ រូបទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី កាលដែលត្រឡប់មកវិញ បានឃើញភិក្ខុ ១ រូប ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលចង្ហាន់សិន ។ ភិក្ខុនោះតបថា នែនាង ប្រពៃហើយ ។ ក៏ទទួលចង្ហាន់ទាំងអស់ ។ កាលបើវេលាជិត (ថ្ងៃត្រង់ហើយ) ភិក្ខុនីនោះ ក៏មិនអាចនឹងដើរទៅបិណ្ឌបាតបានឡើយ ក៏ដាច់ចង្ហាន់ ។ លុះគ្រាខាងក្រោយមក ភិក្ខុនីនោះទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី អស់ថ្ងៃជាគម្រប់ពីរដងផង ។ បេ ។ អស់ថ្ងៃជាគម្រប់បីដងផង ក្នុងវេលាដែលត្រឡប់មកវិញ ក៏បានឃើញភិក្ខុនោះទៀត ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់

ភិក្ខុំ បដិក្ខណ្ហាតិ ។ សុដ្ឋុ ភតិនីតិ សព្ពេ រ អក្ខហេសិ ។ សា ឧបកដ្ឋេ កាលេ ជាសក្ខិ បិណ្ឌាយ ចរិតុំ ធិន្ធកត្តា អហោសិ ។ អថខោ សា ភិក្ខុនី ចតុត្តេ ជិវសេ រថិយាយ បវេជ្ជ្ជ្

ទទួលយកចង្ហាន់សិន ។ ភិក្ខុនោះតបថា នែនាង ប្រពៃហើយ ។ ក៏ទទួលយកចង្ហាន់ទាំងអស់ ។ កាលបើវេលាជិត (ថ្ងៃត្រង់ហើយ) ភិក្ខុនីនោះ ក៏មិនអាចនឹងដើរទៅបិណ្ឌបាតបានឡើយ ក៏ដាច់ចង្ហាន់ ។ លំដាប់នោះ លុះដល់ថ្ងៃទី ៤ ភិក្ខុនីនោះ ក៏ធេងធោងដើរទៅតាមច្រក ។ មានសេដ្ឋីគហបតីម្នាក់ កាលបររថមកដល់ផ្លូវប្រសព្វគ្នា ក៏បាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ លោកចូរចៀសចេញ ។ ភិក្ខុនីនោះ កាលចៀសចេញទៅក៏ដួលជិតកន្ទែងនោះឯង ។ សេដ្ឋីគហ-បតី ក៏បានញ៉ាំងភិក្ខុនីនោះឲ្យអត់ទោសថា បពិត្រលោកម្ចាស់ សូមលោកមេត្តាអត់ទោស (ដ្បិត) លោកម្ចាស់ខ្ញុំបានធ្វើឲ្យដួលហើយ ។ ភិក្ខុនីនោះតបថា នែគហបតី ខ្ជូនអាត្មា អ្នកឯងនឹងបានធ្វើឲ្យដួលក៏ទេ ខ្ជូនអាត្មាជាស្ត្រីមានកំលាំងអន់ស្រាប់ទេតើ ។ សេដ្ឋីគហបតីសួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី បានជាលោកមានកំលាំងអន់ថយ ។ ខណៈនោះ ភិក្ខុនីនោះ ក៏បានប្រាប់សេចក្ដីនុ៎ះដល់សេដ្ឋីគហបតី (ដោយសព្វគ្រប់) ។ សេដ្ឋីគហបតីក៏បាននាំយកភិក្ខុនីនោះ ទៅឯផ្ទះឲ្យធាន់ចង្ហាន់រួចហើយ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា លោកម្ចាស់ទាំងឡាយ មិនគួរនឹងទទួលអាមិសៈអំពីដៃភិក្ខុនីសោះ ដ្បិតមាតុគ្រាមតែងបានលាភ

កិច្ចលាភោ មាតុគ្គាមោតិ ។ អស្សាសុំ ខោ ភិក្ខូ
សេដ្ឋិស្ស គហបតិស្ស ឧជ្ឌាយន្តស្ស ទីយន្តស្ស
វិចាចេន្តស្ស ។ យេ តេ ភិក្ខូ អប្ឆិច្ឆា ។ បេ ។
តេ ឧជ្ឌាយន្តិ ទីយន្តិ វិចាចេន្តិ ឥមំ ហិ នាម
ភិក្ខុ ភិក្ខុនិយា ហត្ថតោ អាមិសំ បដិគ្គហេស្សតីតិ
។ បេ ។ សច្ចំ ឥមិ ត្វំ ភិក្ខុ ភិក្ខុនិយា ហត្ថតោ
អាមិសំ បដិគ្គហេសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា
តេ ភិក្ខុ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។
អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ
បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា ឥមំ
ហិ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា
ហត្ថតោ អាមិសំ បដិគ្គហេស្សសិ នេតំ មោឃបុរិស
អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភា-
វាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុ-
និយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា
ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទেយ្យ វា

ដោយកម្រ ។ កាលដែលសេដ្ឋីគហបតី ពោលទោស តិះដៀល
បន្ទុះបង្ហាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ពួកភិក្ខុណាមានសេចក្តីប្រាថ្នា
តិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ភិក្ខុមិនគួរ
នឹងទទួលយកអាមិស:អំពីដៃភិក្ខុនីសោះ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់
ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងទទួលយកអាមិស:អំពីដៃភិក្ខុនី ពិតមែន
ឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មាន
ព្រះភាគទ្រង់ត្រាស់សួរថា នែភិក្ខុ ភិក្ខុនីនោះត្រូវជាញាតិរបស់អ្នកដែរ
ឬមិនត្រូវជាញាតិទេ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនី
នោះមិនត្រូវជាញាតិទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែមោឃបុ-
រស បុគ្គលដែលមិនមែនជាញាតិ តែងមិនដឹងនូវអំពើសមគួរ ឬមិនសមគួរ
អំពើល្អិតល្អ ឬមិនល្អិតល្អរបស់ស្ត្រីដែលមិនមែនជាញាតិឡើយ នែមោឃ-
បុរសអ្នកឯងមិនគួរនឹងទទួលយកអាមិស:អំពីដៃភិក្ខុនីដែលមិនមែនជាញាតិ
ទេ នែមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះ-
ថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ
យ៉ាងនេះថា ភិក្ខុណាមួយទទួលយកខាទនីយ: ឬភោជនីយ: ដោយដៃរបស់
ខ្លួន អំពីដៃភិក្ខុនីដែលមិនមែនជាញាតិ ដែលចូលទៅកាន់ចន្ទោះផ្ទះ

ភុញ្ជេយ្យ វា បដិគ្គណ្ហេយ្យ តេន ភិក្ខុនា តាវយ្ជ អាវុសោ ឆមំ អាបជ្ជិ អសប្ជាយំ ចាដិគ្គសនីយំ តំ បដិគ្គណ្ហាមីតិ ។

[៤០០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្ប្ជេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុតា អសម្ពន្ធា ។ ភិក្ខុនី នាម ឧភតោសង្ឆ្ជ ឧបសម្ប្ជន្នា ។ អន្ត្ជយរំ នាម ១ថ្ជ(១) ព្ជ្ជហំ សិង្ខ្ជាដកំ ឃរំ ។ ខាទនីយំ នាម បញ្ជ ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ១ថ្ជ អ្ជសេសំ ខាទ-នីយំ នាម ។ ភោជនីយំ នាម បញ្ជ ភោជនានិ ១ិទនោ ១ុម្ជាសោ ១ត្ត ១ច្ជ ១ំ ។ ១ាទិ១ាមិ ១ុ១ិ១ាមីតិ ១ដិ១ណ្ហាតិ ១ាបត្តិ ១ុ១ាជ ។ ១ាជ្ជ១ាវ ១ាជ្ជ១ាវ ១ាបត្តិ ១ាដិ១ណ្ហ ។ ១ាញ្ញ១ាយ ១ាញ្ញ១ាតិ១ ១ាញ្ជ ១ាជ្ជ១ាវ ១ាវ ១ាជ ១ាត្ត១ ១ាទនីយ ១ា ១ាជ ១ា ១ាហ ១ដិ១ណ្ហ ១ា

---

១ ១ថ្ជ១ាតិ ១ា ១ាហ ។

ហើយទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនោះត្រូវសំដែងអាបត្តិបាដិទេសនីយ:ថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិបាដិទេសនីយ: ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀលហើយមិនជាទីសប្បាយ ឥឡូវខ្ញុំសូមសំដែងអាបត្តិនោះចេញ ។

[៨០០] ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា ក្នុងសិក្ខាបទទី ១ នៃបាវាជិកកណ្ឌ ។ ភិក្ខុនីដែលមិនបានជាប់ទាក់ទងគ្នា អំពីចំណែកខាងមាតាឬបិតាដរាបតាំងពីគូនៃជីដូនជីតាទី ៧ ហៅថា មិនមែនជាញាតិ ។ ស្ត្រីដែលបានឧបសម្បទាក្នុងសំណាក់សង្ឆទាំងពីរពួក ហៅថា ភិក្ខុនី ។ ច្រកវហ្ជ (ក្តី) ច្រកទាល់ (ក្តី) ទីប្រជុំផ្លូវមានជ្រុង ៤ ឬមានជ្រុង ៣ (ក្តី) ផ្ទះរបស់ត្រកូល (ក្តី) ហៅថា ចន្ទោះផ្ទះ ។ ដែលហៅថា ខាទនីយ: គឺលើកលែងភោជនទាំង ៥ និងរបស់ដែលជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ក្រៅពីនោះហៅថា ខាទនីយ:ទាំងអស់ ។ ដែលហៅថា ភោជនីយ:នោះ គឺភោជនមាន ៥ យ៉ាង បានដល់បាយ ១ នំកុម្មាស ១ សម្ជូរ ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលយកខាទនីយ: ឬភោជនីយ: ដោយបំណងថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយ: គ្រប់ ១ ១ រ:ដែលលេបចូលទៅ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយទទួលយកខាទនីយ: ឬ ភោជនីយ:ដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្ទោះផ្ទះ យកមកទំពាស៊ីក្តី

ភុញ្ជតិ វា អាបត្តិ ចាជិនេសនីយស្ស ។ អញ្ញាតិ-
ការយ រេមតិកោ អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ
វា ភោជនីយំ វា សហត្ថា បដិក្ខិបិត្វា ខាទតិ
វា ភុញ្ជតិ វា អាបត្តិ ចាជិនេសនីយស្ស ។ អញ្ញាតិ-
ការយ ញាតិការសញ្ញី អន្តរឃរំ បវិដ្ឋាយ ហត្ថតោ
ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិក្ខិបិត្វា
ខាទតិ វា ភុញ្ជតិ វា អាបត្តិ ចាជិនេសនីយស្ស ។ យាម-
ការលិកំ សត្តាហការលិកំ យាវជីវិកំ អាហារត្ថាយ
បដិក្ខិត្តាតិ អាបត្តិ ទុក្ខដស្ស ។ អជ្ឌោហារេ អជ្ឌោ-
ហារេ អាបត្តិ ទុក្ខដស្ស ។ ឯកតោ ឧបសម្ប្ជ្ជាយ
ហត្ថតោ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិក្ខិត្តាតិ
អាបត្តិ ទុក្ខដស្ស ។ អជ្ឌោហារេ អជ្ឌោហារេ អាបត្តិ
ទុក្ខដស្ស ។ ញាតិការយ អញ្ញាតិការសញ្ញី អាបត្តិ
ទុក្ខដស្ស ។ ញាតិការយ រេមតិកោ អាបត្តិ ទុក្ខដស្ស ។
ញាតិការយ ញាតិការសញ្ញី អនាបត្តិ ។

បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយ: ។ ភិក្ខុមានសេចក្តីសង្ស័យនឹង ភិក្ខុនីដែលមិនមែនជាញាតិ ហើយទទួលយកខាទនីយ: ឬភោជនីយ:ដោយ ដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្ទោះផ្ទះ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយ: ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ ថា ជាញាតិ ហើយទទួលយកខាទនីយ: ឬភោជនីយ: ដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្ទោះផ្ទះ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយ: ។ ភិក្ខុទទួលយករបស់ដែលជាយាមកាលិក សត្តាហកាលិក នឹងរបស់ដែលជាយាវជីវិក ដើម្បីជាអាហារ ត្រូវ អាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ ៗ វារៈដែលលេបចូលទៅ ។ ភិក្ខុទទួលយកខាទនីយ: ឬភោជនីយ:អំពីដៃភិក្ខុនី ដែលបានឧបសម្បទា ក្នុងសំណាក់សង្ឆតែម្នាង ដោយបំណងថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ ៗ វារៈដែល លេបចូលទៅ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ត្រូវ អាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិឡើយ ។

បាដិទេសនីយកណ្ឌ បឋមសិក្ខាបទស្ស អនាបត្តិវារោ

[៤០១] អជានតិ ញាតិកាយ ជានេតិ ន ទេតិ ឧបនិក្ខិបិត្វា ទេតិ អន្តរារាមេ ភិក្ខុនូបស្សយេ តិត្ថិយសេយ្យាយ បដិក្ខមនេ តាមតោ ធីហរិត្វា ទេតិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ទេតិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

បាដិទេសនីយកណ្ឌ សិក្ខាបទទី ១ វារៈដែលមិនត្រូវអាបត្តិ

[*៨០១*] *វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១១ យ៉ាង) គឺកិក្ខុនីជាញាតិ ១ កិក្ខុនីមិនមែនជាញាតិ ឲ្យគេឲ្យនូវខាទនីយៈនិងភោជនីយៈ មិនបានឲ្យដោយខ្លួនឯង ១ កិក្ខុនីមិនមែនជាញាតិ បានដាក់ចុះនូវខាទនីយៈ និងភោជនីយៈហើយឲ្យ ១ កិក្ខុនីមិនមែនជាញាតិ បានឲ្យនូវខាទនីយៈនិង ភោជនីយៈក្នុងលំនៅរបស់កិក្ខុនីខាងក្នុងអារាម ១ កិក្ខុនីមិនមែនជាញាតិ បានឲ្យនូវខាទនីយៈ និងភោជនីយៈក្នុងដំណេករបស់តិរ្ថិយ ១ កិក្ខុនីមិនមែន ជាញាតិ បាននាំយកខាទនីយៈ និងភោជនីយៈអំពីស្រុក ហើយឲ្យក្នុង វេលាដែលត្រឡប់មកវិញ ១ កិក្ខុនីបាននាំយករបស់ដែលជាយាមកាលិក សត្តាហកាលិក និងរបស់ដែលជាយាវជីវិក ឲ្យដោយពាក្យថា កាលបើ ហេតុមាន សូមលោកម្ចាស់និមន្តធាន់ចុះ ១ កិក្ខុទទួលយកខាទនីយៈ និង ភោជនីយៈអំពីដៃរបស់សិក្ខមានា ១ កិក្ខុទទួលយកខាទនីយៈនិងភោជ-នីយៈអំពីដៃសាមណេរី ១ កិក្ខុធ្លត ១ កិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ១ ចប់ ។

ទុតិយសិក្ខាបទំ

[៤០២] តេន សមយេន ពុទ្ធោ ភគវា ភាគ្គវោ
វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន
សមយេន ភិក្ខូ ការណេសុ និមន្តិតា ភុញ្ជន្តិ ។ ឆព្ព-
ក្តិយា ភិក្ខុនិយោ ឆព្ពក្តិយានំ ភិក្ខូនំ ភោសាសន្តិយោ
បិតា ហោន្តិ ឥធ ស្ងមំ ឌេថ ឥធ ឱនមំ ឌេថាតិ ។
ឆព្ពក្តិយា ភិក្ខូ យាវទត្ថំ ភុញ្ជន្តិ ។ អញ្ញេ ភិក្ខូ ន
ចិត្តរូបំ ភុញ្ជន្តិ ។ យេ តេ ភិក្ខូ អប្ឆិន្ន ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ១ កថំ ហិ នាម ឆព្ពក្តិយា
ភិក្ខូ ភិក្ខុនិយោ ភោសាសន្តិយោ ន និវាសេស្ស្ដ្ដីតិ
។ បេ ។ សច្ចំ ១ ១ ១

សិក្ខាបទទី ២

[៤០២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេ-ឡុវនជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង មានពួកភិក្ខុដែលគេបាននិមន្តមកធាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុនីទៅឈរបង្គាប់គេថា អ្នកទាំងឡាយចូរប្រគេនសម្ងមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះដូច្នេះ ចំពោះឆព្វគ្គិយភិក្ខុទាំងឡាយ ។ ឯពួកឆព្វគ្គិយភិក្ខុក៏បានធាន់ដរាបទាល់តែឆ្អែត ។ ពួកភិក្ខុឯទៀតក៏ធាន់ចង្ហាន់មិនបានបរិបូណ៌ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងមិនឃាត់ពួកភិក្ខុនីដែលជាអ្នកបង្គាប់គេសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមិនបានឃាត់ពួកភិក្ខុនីដែលកំពុងបង្គាប់គេ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងមិនឃាត់ពួកភិក្ខុនីដែលកំពុងបង្គាប់គេទេ ម្នាលមោឃបុរសទាំងឡាយ អំពីនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឧជ្ជិសេយ្យាថ ភិក្ខូ បណ្ដេ ការុលេសុ ជិមន្ដិតា ភុញ្ជន្ដិ ។ តត្រ ចេ[1] ភិក្ខុនី ភោសាសមាឧ្យចា ឋិតា ហោតិ ឥជ សូបំ ឧេជ ឥជ ឋិជនំ ឧេជាតិ ។ តេហិ ភិក្ខូហិ សា ភិក្ខុនី អបសាឧេតព្ជា អបសក្ក តាវ ភតិជ យាវ ភិក្ខូ ភុញ្ជន្ដីតិ ។ ឯកស្ស្ជ ចេ[2] ភិក្ខុជោ ជប្ជជ-ភាសេយ្ យ តំ ភិក្ខុនី អបសាឧេតុំ អបសក្ក តាវ ភតិជ យាវ ភិក្ខូ ភុញ្ជន្ដីតិ ឋជ ឧេសេតព្ជ ។ តេហិ ភិក្ខូហិ ការយ្ជ អាវុសោ ជ ម្ជ អាបជ្ជ ម្ហា អសប្ជាយ ចាជ ឧេ-សនីយ តំ ឋជ ឧេសេមាតិ ។

[៤០៣] ភិក្ខូ ឋជ ការុលេសុ ជិមន្ដិតា ភុញ្ជន្ដីតិ ការុ ជ ជាម ចត្ដារ ការុ ជ ខត្ដ្ជ ការុ ជ ព្រាហ្ម ណ-ការុ ជ ជ ការុ ជ ជ ។ ជិមន្ដិតា ភុញ្ជន្ដីតិ ឋ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ។ ភិក្ខុនី ជាម ឧ ជ ជ ជ ។

---

1 ចេ ជ ជ ជ ។ 2 ឧ. ម. ជ ជ ។

អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុទាំងឡាយ ដែលជនបាននិមន្តហើយ ធាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ ។ បើមានភិក្ខុនីមកឈរបង្ហាប់គេជិតទីនោះថា អ្នកទាំងឡាយចូរប្រគេនសម្ងមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះ ។ ភិក្ខុទាំងនោះត្រូវបណ្ដេញភិក្ខុនីនោះថា នែនាង ។ ចូរថយចេញទៅសិន ទម្រាំតែពួកភិក្ខុធាន់រួចសព្វគ្រប់ ។ ភិក្ខុសូម្បី ១ រូប បើមិនបានពោលបណ្ដេញភិក្ខុនីនោះដោយពាក្យថា នែនាង ។ ចូរថយចេញទៅ ទម្រាំតែពួកភិក្ខុធាន់រួចសព្វគ្រប់ ដូច្នេះសិនទេ ភិក្ខុទាំងនោះត្រូវសំដែងដោយពាក្យថា ម្នាលអាវុសោ យើងត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយ: ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល មិនជាទីសប្បាយចិត្ត ឥឡូវយើងសូមសំដែងអាបត្តិនោះចេញ ។

[៤០៣] ពាក្យថា ភិក្ខុទាំងឡាយដែលជនបាននិមន្តធាន់ក្នុងសំ-ណាក់របស់ត្រកូលទាំងឡាយ សេចក្ដីថា ដែលហៅថា ត្រកូល បានដល់ត្រកូល ៤ ពួក គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលឈ្មួញ ១ ត្រកូលអ្នកគ្រួ ១ ។ ពាក្យថា ដែលគេនិមន្តធាន់ គឺភិក្ខុដែលពួកជនបាននិមន្តធាន់ដោយភោជនទាំង ៥ ភោជនណាមួយ ។ ដែលហៅថា ភិក្ខុនី គឺស្ត្រីដែលបានឧបសម្បទា ក្នុងសំណាក់សង្ឆទាំងពីរពួក ។

ហេសាសន្តី ជាម យថាមិត្តតា យថាសន្ធិដ្ឋតា យថា-
សម្ភត្តតា យថាសមានុបជ្ឌាយកតា យថាសមានា-
ចរិយកតា ឥធ សូបំ ទេថ ឥធ ឱទនំ ទេថាតិ
អយំ ហេសាសន្តី ជាម ។ តេហិ ភិក្ខូហីតិ ភុញ្ជមា-
នេហិ ភិក្ខូហិ ។ សា ភិក្ខុនីតិ យា សា ហេសាសន្តី
ភិក្ខុនី ។ តេហិ ភិក្ខូហិ សា ភិក្ខុនី អបសាទេតព្ពា
អបសក្ក តាវ ភគិនិ យាវ ភិក្ខូ ភុញ្ជន្តីតិ ។ ឯកស្ស្ចបិ
ចេ ភិក្ខុនោ អនបសាទិតេ[1] ខាទិស្សាមិ ភុញ្ជិស្សាមីតិ
បដិក្ខណ្ណាតិ អាបត្តិ ទុក្ខ្ជស្ស ។ អជ្ឌ្ណាហារេ អជ្ឌ្ណា-
ហារេ អាបត្តិ ចាជិទេសនីយស្ស ។

[៤០៤] ឧបសម្ឪ្ជាយ ឧបសម្ឪ្ជសញ្ញ្ជ ហេសា-
សន្ធិយា ន ជិវ្ជតិ អាបត្តិ ចាជិទេសនីយស្ស ។
ឧបសម្ឪ្ជាយ វេមតិកោ ហេសាសន្ធិយា ន ជិវ្ជតិ
អាបត្តិ ចាជិទេសនីយស្ស ។ ឧបសម្ឪ្ជាយ អនុប-
សម្ឪ្ជសញ្ញ្ជ ហេសាសន្ធិយា ន ជិវ្ជតិ អាបត្តិ

---

១ អនបសាទិតោតិ កត្ថចិ ឧបាត្ថកេ ទិស្សតិ ។ អនបសាទតោ អនបសាទនតោ វាតិ
អម្ហាកម្ឧបន ខន្តិ ។

ដែលហៅថា បង្ហាប់ គឺកិក្ខុនីណាពោលថា អ្នកទាំងឡាយចូរប្រគេនសម្ងមក ក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះ តាមសមគួរដល់ភិក្ខុ ដែលជាមិត្ត ភិក្ខុដែលធ្លាប់ស្គាល់ ភិក្ខុដែលធ្លាប់ស្និទ្ធស្នាល ភិក្ខុដែល មានឧបជ្ឈាយ៍ស្មើគ្នា ភិក្ខុដែលមានអាចារ្យស្មើគ្នា ភិក្ខុនីនេះហៅថា ជាអ្នក បង្ហាប់ ។ ពាក្យថា ភិក្ខុទាំងនោះ គឺពួកភិក្ខុដែលកំពុងធាន់ (នោះឯង) ។ ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលកំពុងបង្ហាប់នោះឯង ។ ភិក្ខុទាំងនោះ ត្រូវបណ្ដេញភិក្ខុនីនោះដោយពាក្យថា នែនាង ។ ចូរថយចេញទៅសិន ទម្រាំតែពួកភិក្ខុធាន់រួចសព្វគ្រប់ ។ ភិក្ខុសូម្បី ១ រូប បើមិនបានបណ្ដេញ ភិក្ខុនីទេ ហើយទទួលយកដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ។ ១ ១ ១

ចាដិទេសនីយស្ស ។ ឯកតោ ឧបសម្ផន្នាយ ភេសា-
សន្តិយា ន និវារេតិ អាបត្តិ ទុក្កដស្ស ។ អនុប-
សម្ផន្នាយ ឧបសម្ផន្នសញ្ញី អាបត្តិ ទុក្កដស្ស ។
អនុបសម្ផន្នាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុ-
បសម្ផន្នាយ អនុបសម្ផន្នសញ្ញី អនាបត្តិ ។

[៤០៥] អនាបត្តិ អត្តនោ ភត្តំ ជានេតិ ន ទេតិ
អញ្ញេសំ[១] ភត្តំ ទេតិ ន ជានេតិ យំ ន ជិន្នំ តំ
ជានេតិ យត្ត ន ជិន្នំ តត្ត ជានេតិ សព្វេសំ សមកំ
ជានេតិ សិក្ខមានា ភេសាសតិ សាមណេរី ភេសាសតិ
បញ្ចេ ភោជនានិ បវេត្វា សេសានំ អនាបត្តិ ឧម្មត្តកស្ស
អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

---

១ អញ្ញស្សាតិបិ បាឬ ។

បាដិទេសនីយ: ។ ស្រីដែលបានឧបសម្បទាក្នុងសំណាក់ភិក្ខុនីសង្ឆតែម្ខាងកំពុងពោលបង្ហាប់ ភិក្ខុមិនបានពោលហាម ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុសំគាល់ថា ឧបសម្បន្នាទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុសំគាល់ថា អនុបសម្បន្នាមែន មិនត្រូវអាបត្តិឡើយ ។

[៨០៥] ភារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុនីបង្ហាប់ទាយកឲ្យប្រគេនកត្តរបស់ខ្លួន មិនប្រគេនដោយខ្លួនឯង ១ ភិក្ខុនីប្រគេនកត្តរបស់ពួកជនដទៃ មិនបានប្រើអ្នកដទៃឲ្យប្រគេន ១ វត្ថុណាដែលទាយកមិនទាន់ប្រគេន ភិក្ខុនីក៏បង្ហាប់គេឲ្យប្រគេនវត្ថុនោះ ១ ទាយកមិនទាន់ប្រគេនក្នុងទីណា ភិក្ខុនីបង្ហាប់គេឲ្យប្រគេនក្នុងទីនោះ ១ ភិក្ខុនីបង្ហាប់គេឲ្យប្រគេនកត្តដ៏ស្មើគ្នាដល់ពួកភិក្ខុទាំងពួង ១ សិក្ខមានាពោលបង្ហាប់ ១ សាមណេរីពោលបង្ហាប់ ១ អាបត្តិមិនមានដល់ភិក្ខុព្រោះភោជនទាំងពួង រៀរលែងតែភោជន ៥ យ៉ាងចេញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ២ ចប់ ។

ततियसिक្ខាបទំ

[៤០៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ
បន សមយេន សាវត្ថិយំ អញ្ញតរំ កុលំ ឧភតោ បសន្នំ
ហោតិ សទ្ធាយ វឌ្ឍតិ ភោគេន ហាយតិ ។ យំ តស្មឹ
កុលេ ឧប្បជ្ជតិ បុរេភត្តំ ខាទនីយំ វា ភោជនីយំ វា
តំ សពុ្ធ ភិក្ខូនំ វិស្សជ្ជេត្វា អប្បេកចា អនសិតា
អច្ឆន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ ១ កថំ
ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា
បដិគ្គហេស្សន្តិ ឥមេ ឥមេសំ ១ ទត្វា អប្បេកចា អន-
សិតា អច្ឆន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ
ឧជ្ឈាយន្តានំ ខីយន្តានំ វិចារេន្តានំ ។ អថ ខោ តេ
ភិក្ខូ ភគវតោ ឯតមត្តំ អារោចេសុំ ។ អថ ខោ ភគវា
ឯតស្មឹ និទានេ ឯតស្មឹ បការណេ ១ ១ ១

សិក្ខាបទទី ៣

